សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# អភ័យឯកសិទ្ធិរដ្ឋសភានៅកម្ពុជា (ករណីសិក្សាប្រៀបធៀបប្រទេសជប៉ុន)

ស្រាវជ្រាវ ពីថ្ងៃទី០១ ខែមេសា ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦

ស្រាវជ្រាវដោយៈ
និស្សិតឈ្មោះ **ក. ធូ អេនេច**
**ខ័រ ជារិទ្ធ**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឈុន ណារ៉ែត**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ
ជំនាន់ទី២១ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ**ធូ វេនេច** និង ខ្ញុំបាទឈ្មោះ**វ៉ រ ដារិទ្ធ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តឆ្នាំទី៤ ជំនាន់ទី២១(អាហារូបករណ៍) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា២០១២-២០១៦។

យើងខ្ញុំទាំងពីរបានសម្រេចនូវសមិទ្ធផលស្នាដៃ នៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំ ក្រោមប្រធានបទ **"អភ័យឯកសិទ្ធិរដ្ឋសភានៅកម្ពុជា"** (ករណីសិក្សាប្រៀបធៀបប្រទេសជប៉ុន) ប្រកបដោយភាពជោគជ័យ និងប្រសិទ្ធិភាព ។ ភាពជោគជ័យនៃសមិទ្ធផលនេះអាស្រ័យទៅលើបុព្វហេតុជាច្រើន ដែលជម្រុញឱ្យយើងខ្ញុំបានខិតខំប្រឹងប្រែងក្នុងការបង្កើតស្នាដៃមួយនេះលេចចេញជារូបរាងឡើង។

ជាដំបូង យើងខ្ញុំទាំងពីរនាក់ សូមក្រាបប្រណិប័ត និងសូមសម្តែងនូវសេចក្តីដឹងគុណ យ៉ាងជ្រាលជ្រៅជូនចំពោះលោកអ្នកមានគុណទាំងពីរ ដែលលោកបានខិតខំចិញ្ចឹមបីបាច់ ថែរក្សារូបកូនតាំងពីកំណើតកើតជា រហូតបានធំពេញវ័យ ព្រមទាំងបានអប់រំប្រៀនប្រដៅកូនប្រកប ដោយព្រហ្មវិហារធម៌ មិនតែប៉ុណ្ណោះបានបញ្ជូនកូនឱ្យទៅសាលាក្រេបជញ្ជក់ចំណេះដឹង ព្រមទាំង បានឧបត្ថម្ភទាំងផ្នែកស្មារតី និងសម្ភារៈសព្វបែបយ៉ាងរហូតកូនបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនាពេលនេះ។

ទន្ទឹមនឹងនេះ យើងខ្ញុំក៏សូមធ្វើការគោរពដឹងគុណ និង ថ្លែងអំណរគុណជាអនេកជូនចំពោះឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្រ្តាចារ្យទាំងអស់នៃសាកលវិទ្យាល័យដែលពួកលោកបានគ្រប់គ្រង ដឹកនាំសាកលវិទ្យាល័យ និងបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ប្រៀនប្រដៅ និងបង្ហាត់បង្រៀនយើងខ្ញុំយ៉ាងយកចិត្តទុកដាក់ និងជួយសម្រួលសព្វបែបយ៉ាងដល់ការសរសេរសារណារបស់យើងខ្ញុំ។

យើងខ្ញុំ សូមធ្វើការថ្លែងអំណរគុណជាពិសេសជូនចំពោះ៖

- លោកសាស្រ្តាចារ្យបណ្ឌិត **ឈុន ណារ៉េត**ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃខិតខំផ្ទេរ រាល់ចំណេះដឹង និងគំនិតល្អៗ ក្នុងការកែលម្អរាល់ចំនុចខ្វះខាតដើម្បីដឹកនាំការសរសេរសារណារបស់យើងខ្ញុំរហូតលេចចេញជារូបរាងឡើងប្រកបដោយភាពជោគជ័យ។
- សាស្រ្តាចារ្យនៃមជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវស្តីពីច្បាប់ជប៉ុន(CJL) ដែលបានខិតខំបង្ហាត់បង្រៀនទាំងភាសា និងច្បាប់ជប៉ុន និងជួយទាំងស្មារតី និងសម្ភារៈទាក់ទងនឹងប្រធានបទ ផ្នែកប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន។

ជាចុងក្រោយ យើងខ្ញុំសូមជូនស្នាដៃនេះជាគុណប្រយោជន៍ជូនចំពោះអ្នកមានគុណដែលបានរៀបរាប់ខាងលើ និងសូមសន្យាថានឹងប្រើប្រាស់ស្នាដៃនេះជាគុណប្រយោជន៍ចូលរួមចំណែកបម្រើ និងអភិវឌ្ឍសង្គមជាតិដើម្បីជាតម្លៃតបស្នង។ យើងខ្ញុំសូមប្រសិទ្ធពរជ័យជូនចំពោះពួកលោកឱ្យបានប្រកបទៅដោយអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំមក យើងខ្ញុំបានក្រេបជញ្ជក់យកចំនេះដឹង និងបទពិសោធន៍ល្អៗជាច្រើន ព្រមទាំងមានគំនិតរីកដុះដាលកាន់តែទូលំទូលាយឡើង។

ប្រធានបទស្តីអំពី **"អភ័យឯកសិទ្ធិរដ្ឋសភានៅកម្ពុជា"** (ករណីសិក្សាប្រៀបធៀបប្រទេសជប៉ុន) នេះ ត្រូវបានតាក់តែងឡើងនៅក្នុងគោលបំណងចូលរួមចំណែកលើកស្ទួយវិស័យច្បាប់ ជាពិសេស ដើម្បីជាកិច្ចសម្រួលទៅដល់សិស្ស និស្សិត សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ដែលមានបំណង ចង់ធ្វើការស្វែងយល់ពីប្រព័ន្ធសភានិយមនៅកម្ពុជា ពិសេសទាក់ទងនឹងអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រនៃសភាជាន់ទាប ដែលជាស្ថាប័នមានអំណាចកំពូល ក្នុងការកំណត់ជោគវាសនារបស់ជាតិ ដោយអាចប្រៀបធៀបការអនុវត្តរវាងប្រទេសជាតិយើងជាមួយនឹងជាតិដទៃ។

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដែលបានធ្វើការតាក់តែងនូវស្នាដៃនេះឡើងដោយយើងខ្ញុំបានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយ កំលាំងចិត្ត សម្រិតសម្រាំងទៅលើខ្លឹមសារនៃប្រធានបទ ដើម្បីឱ្យខ្លឹមសារនៃប្រធានបទរបស់យើងខ្ញុំមានភាពច្បាស់លាស់ គ្រោះក្បាយគ្រប់ជ្រុងជ្រោយដើម្បីជាគុណប្រយោជន៍ពិតប្រាកដ។ យើងខ្ញុំជឿជាក់ថាស្នាដៃមួយនេះពិតជាផ្តល់អត្ថប្រយោជន៍ និងជាទុនក្នុងការពង្រីកពុទ្ធិ គំនិត និងចំណេះដឹងក្នុងការស្រាវជ្រាវពីគ្រប់បណ្តាមជ្ឈដ្ឋានអ្នកអានទាំងអស់។

ថ្វីត្បិតថា យើងខ្ញុំបានខិតខំប្រឹងប្រែងក្នុងការសម្រិតសម្រាំងស្នាដៃនេះឱ្យមានលក្ខណៈល្អប្រសើរ និងទទួលបានជោគជ័យយ៉ាងណាក៏ដោយ តែយើងខ្ញុំជឿជាក់ថា ស្នាដៃមួយនេះពិតជាមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយនោះឡើយ គឺជៀសមិនផុតពីការមានកំហុសដោយអចេតនាជាប្រការណាមួយទាំងទៅលើខ្លឹមសារ អក្ខរាវិរុទ្ធជាដើម និងមិនមានលក្ខណៈ ពិស្តារ លម្អិតទៅតាមការចង់ចេះចង់ដឹងគ្មានព្រំដែនរបស់មិត្តអ្នកអាននោះឡើយ។ យើងខ្ញុំសូមធ្វើការអភ័យទោសរាល់កំហុសអចេតនាទាំងអស់ និងរង់ចាំស្វាគមន៍ដោយក្តីរីករាយរាល់មតិរិះគន់កែលម្អរក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋានអ្នកអានគ្រប់ពេលវេលា ដើម្បីជាទុន ក្នុងការកែលម្អរស្នាដៃមួយនេះឱ្យកាន់តែបានល្អ សុក្រឹត្យត្រឹមត្រូវ និងយុត្តិធម៌បន្ថែមទៀត ដើម្បីជាគុណប្រយោជន៍ទៅថ្ងៃខាងមុខទៀតដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ។

# មាតិកា

**សេចក្តីថ្លែងអំណរគុណ**
**អារម្ភកថា**
**សេចក្តីផ្តើម** .......... ១
**ជំពូកទី១ អំពីសញ្ញាណទូទៅ និងកំណត់កំណើតនៃរដ្ឋសភា** .......... ៦
**ផ្នែកទី១ ប្រវត្តិនៃការកកើតរដ្ឋសភានៅលើពិភពលោក** .......... ៧
**ផ្នែកទី២ សារតានៃការកកើតរដ្ឋសភានៅកម្ពុជា** .......... ៧
**កថាខណ្ឌទី១ ប្រវត្តិនៃការកកើត** .......... ៨
១. រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាទី១ ( ១៩៤៦-១៩៧០ ) .......... ៨
២. រដ្ឋសភានៃសាធារណរដ្ឋខ្មែរ ( ១៩៧០-១៩៧៥ ) .......... ៨
៣. រដ្ឋសភានៃកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់ ១៩៧៩) .......... ៩
៤. រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា (១៩៧៩-១៩៩៣) .......... ១០
៥. រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាទី២( ១៩៩៣-បច្ចុប្បន្ន ) .......... ១០
**កថាខណ្ឌទី២ ការបង្កើតរដ្ឋសភាកម្ពុជានាពេលបច្ចុប្បន្ន** .......... ១១
១. ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ .......... ១១
២. ការរៀបចំដំណើរការនៃរដ្ឋសភា .......... ១២
៣. អាណត្តិរដ្ឋសភា .......... ១៣
៤. សមាជិករដ្ឋសភា .......... ១៣
ក. លក្ខន្តិកៈ .......... ១៤
ក.១ លក្ខខណ្ឌនៃការឈរឈ្មោះ .......... ១៤
ក.២ លក្ខខណ្ឌមិនអាចឈរឈ្មោះ .......... ១៤
ខ. ពិធីបើកសម័យប្រជុំដំបូង .......... ១៥
ខ.១ ករណីធម្មតា .......... ១៥
ខ.២ ករណីពិសេស .......... ១៦
**កថាខណ្ឌទី ៣ ការបង្កើតរដ្ឋសភាកម្ពុជានីតិកាលទី៥** .......... ១៦
១. ស្ថានភាពទូទៅបន្ទាប់ពីការបោះឆ្នោត .......... ១៧
២ ការបង្កើតរដ្ឋសភានីតិកាលទី៥ .......... ១៨
ក. ការកោះអញ្ជើញប្រជុំរបស់អង្គព្រះមហាក្សត្រដល់គណបក្សជាប់ឆ្នោត .......... ១៨
ខ. ការបើកកិច្ចប្រជុំលើកដំបូងរបស់រដ្ឋសភានីតិកាលទី ៥ .......... ១៩
គ. សមាជិករដ្ឋសភានីតិកាលទី៥ .......... ២០
**ផ្នែកទី៣ សារតានៃការកកើតរដ្ឋសភានៅជប៉ុន** .......... ២១
**កថាខណ្ឌទី១ ប្រវត្តិនៃការកកើត** .......... ២១
១. សារតានៃការបង្កើតរដ្ឋសភា(សភាអាណាចក្រ)នៅសម័យម៉េជិ .......... ២២
២. សារតានៃការបង្កើតរដ្ឋសភានៅសម័យបច្ចុប្បន្ន .......... ២៣
**កថាខណ្ឌទី២ ការបង្កើតរដ្ឋសភាជប៉ុននាពេលបច្ចុប្បន្ន** .......... ២៦

១. ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ..... ២៦
២. ការរៀបចំដំណើរការនៃរដ្ឋសភា ..... ២៧
៣. អាណត្តិរដ្ឋសភា ..... ២៨
៤. សមាជិករដ្ឋសភា ..... ២៨
៥. ការកោះហៅមកជុំគ្នា និងពិធីបើកនីតិកាល ..... ២៨
**ជំពូកទី ២ អភ័យឯកសិទ្ធិសមាជិករដ្ឋសភាប្រទេសកម្ពុជា និងប្រទេសជប៉ុន** ..... ២៩
**ផ្នែកទី១ អភ័យឯកសិទ្ធិសមាជិករដ្ឋសភាកម្ពុជា** ..... ២៩
**កថាខណ្ឌទី១ ប្រវត្តិនៃការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញ** ..... ៣០
១. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាទី១ ..... ៣០
២. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ..... ៣០
៣. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ..... ៣០
៤. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា ..... ៣០
៥. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញរដ្ឋកម្ពុជា ..... ៣១
៦. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាទី២ ..... ៣១
**កថាខណ្ឌទី២ ការអនុវត្តជាក់ស្តែងនៃសិទ្ធិមានអភ័យឯកសិទ្ធិ** ..... ៣២
១. អត្ថន័យ និងការចាប់ផ្តើមមានអភ័យឯកសិទ្ធិ ..... ៣២
ក. អត្ថន័យ ..... ៣២
ខ. ការចាប់ផ្តើមមានអភ័យឯកសិទ្ធិរដ្ឋសភា ..... ៣៣
២. មូលហេតុ និងលក្ខខណ្ឌនៃការដកអភ័យឯកសិទ្ធិ និងការបាត់បង់អភ័យឯកសិទ្ធិ ..... ៣៤
៣. នីតិវិធីនៃការដកអភ័យឯកសិទ្ធិ ..... ៣៥
៤. ការផ្តល់អភ័យឯកសិទ្ធិឡើងវិញ ..... ៣៦
**ផ្នែកទី២ អភ័យឯកសិទ្ធិសមាជិករដ្ឋសភាជប៉ុន** ..... ៣៧
**កថាខណ្ឌទី១ អំពីប្រវត្តិនៃការផ្តល់អភ័យឯកសិទ្ធិក្នុងរដ្ឋធម្មនុញ្ញ** ..... ៣៧
១. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញនៅសម័យម៉េជិ ..... ៣៨
២. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញនៅសម័យបច្ចុប្បន្ន ..... ៣៨
**កថាខណ្ឌទី២ ការអនុវត្តជាក់ស្តែងនៃសិទ្ធិមានអភ័យឯកសិទ្ធិ** ..... ៣៨
១. អំពីអភ័យឯកសិទ្ធិមិនអាចត្រូវបានចាប់ខ្លួន ..... ៣៩
ក. អត្ថន័យនៃពាក្យ ចាប់ខ្លួន ..... ៣៩
ខ. អញ្ញត្រកម្មនៃអភ័យឯកសិទ្ធិមិនត្រូវបានចាប់ខ្លួន ..... ៤១
គ. លក្ខខណ្ឌក្នុងការចាប់ខ្លួន ..... ៤២
ឃ. ការចាប់ខ្លួនក្រៅសភា ..... ៤៣
ង. ការចាប់ខ្លួនក្នុងសភា ..... ៤៣
ច.នីតិវិធីក្នុងការទាមទារឱ្យមានការចាប់ខ្លួន ..... ៤៣
ឆ.ការធ្វើការទទួលស្គាល់នូវសមាជិកសភាដែលត្រូវបានធ្វើការចាប់ខ្លួនមុនអាណត្តិ ..... ៤៤
ជ.ការស្នើរសុំទាមទារឱ្យមានការដោះលែង ..... ៤៤
២. អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ..... ៤៤
ក. អត្ថន័យនៃការថ្លែងសុន្ទរកថា ការបញ្ចេញយោបល់ និងការបោះឆ្នោតបញ្ចេញមតិ ..... ៤៥

ខ. សមាសភាគនៃអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ..................................................... ៤៦
គ. ទំហំនៃអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់....................................................................... ៤៧
ឃ. សកម្មភាពនៅក្នុងសភា ................................................................................................................... ៤៨
ង. ប្រសិទ្ធិភាពនៃអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់.............................................................. ៤៨
ច. ទស្សនៈវិស័យក្នុងការផ្តល់អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ............................................. ៤៩
ឆ. ព្រំដែននៃអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ....................................................................... ៥០
ជ. ភាពចាំបាច់ ឬមិនចាំបាច់នៃការចេញដីការឱ្យចាប់ខ្លួន ឬដាក់ឱ្យសមាជិកសភាជាប់ពិរុទ្ធ ........................ ៥១

**ផ្នែកទី៣ ការសិក្សាប្រៀបធៀបអភ័យឯកសិទ្ធិរដ្ឋសភានៅប្រទេសកម្ពុជា និង ប្រទេស ជប៉ុន..................................................................................................... ៥៣**

**កថាខណ្ឌទី១ ចំនុចស្របគ្នានៃការផ្តល់អភ័យឯកសិទ្ធិ........................................................ ៥៣**
១. គោលបំណងនៃការផ្តល់អភ័យឯកសិទ្ធិ ........................................................................................... ៥៤
២. លក្ខណៈនៃអភ័យឯកសិទ្ធិ .............................................................................................................. ៥៥

**កថាខណ្ឌទី២ ចំនុចខុសគ្នានៃការផ្តល់អភ័យឯកសិទ្ធិ........................................................ ៥៦**
១. ទាក់ទិនទៅនឹងអភ័យឯកសិទ្ធិក្នុងការមិនត្រូវបានចាប់ខ្លួន ................................................................ ៥៦
ក. ករណីក្នុងការមានការចាប់ខ្លួនសមាជិករដ្ឋសភាមុនអាណត្តិ.................................................................. ៥៧
ខ. លក្ខខណ្ឌក្នុងការចាប់ខ្លួនដោយបទល្មើសព្រហ្មទណ្ឌជាក់ស្តែង........................................................... ៥៧
គ. នីតិវិធីនៃកាស្នើរសុំលើកអភ័យឯកសិទ្ធិដើម្បីចាប់ខ្លួនសមាជិករដ្ឋសភា............................................... ៥៨
ឃ. ការស្នើរសុំទាមទារឱ្យមានការដោះលែងសមាជិករដ្ឋសភា..................................................................... ៥៩
២. ទាក់ទិនទៅនឹងអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់ .................................................................. ៥៩
ក. ការកំនត់ទៅលើនិយមន័យនៃការបញ្ចេញមតិយោបល់.......................................................................... ៥៩
ខ. ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរបស់រដ្ឋ......................................................................................... ៦០
គ. សមាសភាគនៃអភ័យឯកសិទ្ធិ ........................................................................................................... ៦១
ឃ. ទំហំនៃការផ្តល់អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ..................................................................... ៦១

**ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយទាក់ទងបញ្ហាក្នុងការអនុវត្តសិទ្ធិនៃអភ័យឯកសិទ្ធិរបស់ប្រទេសកម្ពុជា និងប្រទេសជប៉ុន....... ៦៣**

**ផ្នែកទី១ បញ្ហាប្រឈម.......................................................................................................... ៦៣**

**កថាខណ្ឌទី១ បញ្ហាប្រឈមនៅកម្ពុជា....................................................................................... ៦៣**
១. ការបកស្រាយផ្សេងគ្នាទៅលើអត្ថិភាពនៃការមានអភ័យឯកសិទ្ធិ.......................................................... ៦៤
២. ការកំណត់មិនច្បាស់លាស់អំពីវិសាលភាពនៃការផ្តល់អភ័យឯកសិទ្ធិ ........................................................ ៦៥
៣. វប្បធម៌និទណ្ឌភាពចំពោះការបំពានទៅលើតំណាងរាស្ត្រ........................................................................ ៦៨
៤. ការបកស្រាយផ្ទុយគ្នាចំពោះការលើកអភ័យឯកសិទ្ធិសភាដោយបទល្មើសព្រហ្មទណ្ឌ ............................. ៦៩
៥. ការចោទប្រកាន់តាមមាត្រា៥៣៨នៃក្រមព្រហ្មទណ្ឌ ............................................................................... ៧១
៦. ការបកស្រាយផ្សេងគ្នាទាក់ទិននឹងការកោះហៅសមាជិករដ្ឋសភាចូលខ្លួនក្នុងតុលាការ .............................. ៧២
៧. ការបកស្រាយផ្សេងគ្នាទៅលើមាត្រា៨០នៃរដ្ឋធម្មនុញ្ញ .......................................................................... ៧៤
៨. បញ្ហាចោទទៅលើអត្ថន័យនៃការញុះញង់ និង ការបញ្ចេញមតិ............................................................... ៧៦

**កថាខណ្ឌទី២ បញ្ហាប្រឈមនៅជប៉ុន........................................................................................ ៧៧**
១. លក្ខខណ្ឌ និងរយៈពេលនៃការចាប់ខ្លួន............................................................................................ ៧៧
២. ករណីមានការបរិហាកេរ្តិ៍ពីសំណាក់សមាជិកសភា.............................................................................. ៨០

**ផ្នែកទី២ ដំណោះស្រាយ** ........ ៨១
**កថាខណ្ឌទី១ ដំណោះស្រាយនៅកម្ពុជា** ........ ៨១
១. បណ្តាទស្សនៈទូទៅទាក់ទិននឹងមាត្រា៨០នៃរដ្ឋធម្មនុញ្ញ និង ការបញ្ចេញមតិរបស់តំណាងរាស្ត្រ ........ ៨១
២. មតិយោបល់របស់អ្នកវិភាគឯករាជ្យ បណ្តាអង្គការសង្គមស៊ីវិល និង អង្គការក្រៅរដ្ឋាភិបាលនានា ........ ៨៤
ក. ទាក់ទិននឹងករណីការបកស្រាយផ្សេងគ្នាលើរដ្ឋធម្មនុញ្ញមាត្រា៨០........ ៨៤
ខ. ទាក់ទងករណីតំណាងរាស្ត្រមិនចូលខ្លួនតាមការកោះហៅរបស់តុលាការ........ ៨៥
គ. ទាក់ទិនចំពោះការបកស្រាយផ្ទុយគ្នាចំពោះនីតិវិធីដកហូតអភ័យឯកសិទ្ធិរដ្ឋសភា ដោយបទល្មើសព្រហ្មទណ្ឌ ........ ៨៦
ឃ. ទាក់ទិននឹងការចេញដីការកោះហៅតំណាងរាស្ត្រ ........ ៨៨
**កថាខណ្ឌទី២ ដំណោះស្រាយនៅជប៉ុន** ........ ៨៩
១. ដំណោះស្រាយទៅលើបញ្ហាការកំណត់លក្ខខណ្ឌ និងរយៈពេលចាប់ខ្លួន ........ ៨៩
២. ដំណោះស្រាយទៅលើករណីបរិហាកេរ្តិ៍របស់សមាជិករដ្ឋសភា ........ ៩២
**សេចក្តីសន្និដ្ឋាន** ........ ៩៥
**អនុសាសន៍** ........ ៩៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**
- **ឧបសម្ព័ន្ធ១** មាត្រានៃរដ្ឋធម្មនុញ្ញបច្ចុប្បន្នទាក់ទងនឹងរដ្ឋសភាកម្ពុជា
- **ឧបសម្ព័ន្ធ២** បញ្ជីរាយនាមតំណាងរាស្ត្រនីតិកាលទី៥នៃរដ្ឋសភាកម្ពុជា
- **ឧបសម្ព័ន្ធ៣** សេចក្តីថ្លែងការណ៍របស់ក្រុមសមាជិកសភាគណបក្សសង្គ្រោះជាតិ
- **ឧបសម្ព័ន្ធ៤** សេចក្តីថ្លែងការណ៍របស់ក្រសួងយុត្តិធម៌
- **ឧបសម្ព័ន្ធ៥** សំណើសុំលើកអភ័យឯកសិទ្ធិសភា
- **ឧបសម្ព័ន្ធ៦** សេចក្តីថ្លែងការណ៍របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
- **ឧបសម្ព័ន្ធ៧** ដីការកោះហៅតំណាងរាស្ត្រ
- **ឧបសម្ព័ន្ធ៨** សេចក្តីថ្លែងហេតុរបស់ក្រសួងយុត្តិធម៌
- **ឧបសម្ព័ន្ធ៩** ការឆ្លើយតបរបស់រដ្ឋសភាតាមសំណើក្រសួងយុត្តិធម៌
- **ឧបសម្ព័ន្ធ១០** បទអន្តរាគមន៍របស់ឯកឧត្តម អង្គវង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សម្រាប់កិច្ចប្រជុំឆ្លើយបំភ្លឺផ្ទាល់មាត់នៅវិមានរដ្ឋសភា

- **ឧបសម្ព័ន្ធ១១** មាត្រានៃរដ្ឋធម្មនុញ្ញសម័យម៉េជិទាក់ទងនឹងរដ្ឋសភាជប៉ុន
- **ឧបសម្ព័ន្ធ១២** មាត្រានៃរដ្ឋធម្មនុញ្ញបច្ចុប្បន្នទាក់ទងនឹងរដ្ឋសភាជប៉ុន
- **ឧបសម្ព័ន្ធ១៣** បញ្ជីរាយនាមសមាជិករដ្ឋសភាជប៉ុនឆ្នាំ២០១៤

# សេចក្តីផ្តើម

លទ្ធិប្រជាធិបតេយ្យបានរីកលូតលាស់យ៉ាងឆាប់រហ័ស គឺដោយសារតែប្រទេសជាច្រើនលើសលប់នៅលើពិភពលោក បាននឹងកំពុងតែដឹកនាំគ្រប់គ្រងប្រទេស តាមបែបប្រជាធិបតេយ្យ ដែលជាលទ្ធិមួយអាចនាំឱ្យប្រទេសជាតិមានការអភិវឌ្ឍ មានសុខសន្តិភាព និងស្ថេរភាពក្នុងសង្គម ព្រមទាំងឈានទៅរកប្រទេសនីតិរដ្ឋ។ ប្រទេសកម្ពុជា និង ប្រទេសជប៉ុនបានឆ្លងកាត់នូវសង្គ្រាមជាច្រើន និងបានឆ្លងកាត់នូវការផ្លាស់ប្តូររបបគ្រប់គ្រងប្រទេស ពីសម័យកាលមួយទៅសម័យកាលមួយទៀតជាច្រើនលើកច្រើនសារ រហូតទើបបានឈានដល់របត់ក្នុងការធ្វើការគ្រប់គ្រងប្រទេស តាមបែបលទ្ធិប្រជាធិបតេយ្យដូចប្រទេសនានានៅលើពិភពលោកផងដែរ ដោយធ្វើការបោះឆ្នោត ជ្រើសរើសតំណាងរាស្ត្រ និងអ្នកដឹកនាំប្រទេសតាមរបបសភានិយម។

តាមរយៈប្រវត្តិសាស្ត្រ របបសភានិយមបានកើតឡើងដំបូងនៅប្រទេសអង់គ្លេសដែលនៅពេលនោះបន្ទាប់ពីមានការតបតរប្រឆាំងទៅនឹងការប្រើប្រាស់អំណាចរបស់ព្រះមហាក្សត្រ រហូតទទួលបានជ័យជំនះដោយគ្មានការប្រើប្រាស់អំពើហិង្សាណាមួយនោះ នៅទីបំផុត អំណាចដ៏ខ្លាំងក្លារបស់ព្រះមហាក្សត្រត្រូវបានកម្រិតដោយរដ្ឋធម្មនុញ្ញនៅបន្ទាប់ពីប្រទេសអង់គ្លេស បានប្រកាន់យកនូវរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ និងបង្កើតឱ្យមានសភាឡើងក្នុងប្រទេស ហើយផ្តល់អំណាចយ៉ាងខ្លាំងក្លាទៅដល់សភា។ ក្រោយមកទៀត ទើបប្រទេសនីមួយៗនៅលើពិភពលោកបានបង្កើតឱ្យមានសភានៅក្នុងប្រទេសរបស់ខ្លួនដែរ ដោយយកគំរូតាមប្រទេសអង់គ្លេស ហើយប្រព័ន្ធដែល តម្រូវឱ្យមានការផ្តល់អំណាចដ៏ខ្លាំងក្លាមួយដល់សភានេះដែរ បានទទួលការចាប់អារម្មណ៍ជាខ្លាំង ថែមទាំងបានរីកសាយភាយចម្រុងចំរើនដល់កំពូល ដែលប្រទេសខ្លះ អនុវត្តរបបទ្វិកសភា និងមួយចំនួនទៀតជ្រើសយកឯកសភា ។ ស្ថាប័ននីតិបញ្ញត្តិមានព្រឹទ្ធសភាជាសភាជាន់ខ្ពស់ និងរដ្ឋសភាជាសភាជាន់ទាប ប៉ុន្តែបណ្តាប្រទេសភាគច្រើន រួមទាំងប្រទេសកម្ពុជា និងប្រទេសជប៉ុនផងដែរនោះសុទ្ធតែបានផ្តល់អំណាចយ៉ាងខ្លាំងទៅដល់រដ្ឋសភាដែលជាសភាជាន់ទាប ដោយប្រគល់សិទ្ធិសម្រេចទៅលើបញ្ហាសំខាន់ៗលើសព្រឹទ្ធសភា។ ហេតុដូចនេះហើយ យើងអាចកត់សម្គាល់បានថា តំណាងរាស្ត្រក្នុងនាមជាសមាជិករបស់រដ្ឋសភាពិតជាដើរតួនាទីយ៉ាងសំខាន់ណាស់ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួនតំណាងឱ្យប្រជាពលរដ្ឋទូទាំងប្រទេស ដើម្បីសម្រេចអនាគតរបស់ប្រទេសជាតិ។

គួររំលឹកផងដែរថាជំលោះរវាងពួកកងទ័ព និងសភាដែលបានកើតឡើងនៅសម័យព្រះមហាក្សត្រឆាលីសទី១របស់អង់គ្លេស គឺមានការអនុញ្ញាតឱ្យធ្វើការចាប់ខ្លួនសមាជិកសភាដែលធ្វើការរិះគន់ទៅដល់ព្រះមហាក្សត្រ ហើយអំណាចព្រះមហាក្សត្រអាចធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយ

សមាជិកសភា ជាពិសេសគឺអាចចូលទៅក្នុងសាលប្រជុំរបស់សភា។ ដើម្បីធ្វើការការពារទៅដល់សភាពីការរំលោភបំពានសិទ្ធិ និងការចូលជ្រៀតជ្រែកពីសំណាក់អំណាចរបស់ព្រះមហាក្សត្រ និងដើម្បីការពារទៅដល់សេរីភាព ក្នុងការធ្វើសកម្មភាពក្នុងការបំពេញភារកិច្ចរបស់សមាជិកសភានីមួយៗ នៅពេលនោះមានការទាមទារឱ្យមានការផ្តល់អភ័យឯកសិទ្ធិទៅដល់សមាជិកសភាដូចជាអភ័យឯកសិទ្ធិមិនត្រូវបានចាប់ខ្លួន និងអភ័យឯកសិទ្ធិក្នុងការបញ្ចេញយោបល់ជាដើម។ ក្រោយមកទៀត ទើបការផ្តល់អភ័យឯកសិទ្ធិនេះ ទទួលបានការចាប់អារម្មណ៍ ហើយប្រទេសនីមួយៗដែលប្រកាន់យកប្រព័ន្ធសភានេះ ក៏បានទទួលយកនូវគំនិតនៃការការពារអភ័យឯកសិទ្ធិនេះ ទៅដល់សមាជិកសភាផងដែរ។

តំណាងរាស្ត្រនៅក្នុងការអនុវត្តតួនាទីរបស់ខ្លួន ជាអ្នកឃ្លាំមើលដ៏មានប្រសិទ្ធិភាពរបស់រដ្ឋាភិបាលជូនកាលអ្នកតំណាង ធ្វើសេចក្តីថ្លែងការណ៍ដែលគ្មានភស្តុតាងចោទប្រកាន់មន្ត្រីរដ្ឋាភិបាលអំពីការប្រព្រឹត្តិខុស ឬដោយគ្មានភាពអំណត់ និង ដោយមិនមានការគួរសមក្នុងការស្នើរសុំការពន្យល់បកស្រាយពីរដ្ឋាភិបាល។ នៅក្នុងស្ថានភាពជាក់ស្តែង គេអាចគិតថាសេចក្តីថ្លែងការណ៍នោះជាការបរិហារកេរ្តិ៍ ដែលនេះជាបទល្មើសទាំងផ្នែករដ្ឋប្បវេណីទាំងព្រហ្មទណ្ឌ។ បើគ្មានការលើកលែងពីការដាក់ទណ្ឌកម្មទេ អ្នកតំណាងតែងតែប្រឈមមុខនឹងគ្រោះថ្នាក់នៃការចោទប្រកាន់ អំពីបទបរិហារកេរ្តិ៍ ក្នុងនីតិវិធីព្រហ្មទណ្ឌមានចែងកំណត់ពីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង និង អាចជ្រើសរើសយកការមិននិយាយជាជាងការភ័យខ្លាចដោយសារតុលាការដាក់ទោស។ ដើម្បីចៀសវាងការភ័យខ្លាចដូចខាងលើ មានតែអភ័យឯកសិទ្ធិសភាទើបការពារអ្នកតំណាងឱ្យរួចផុតពីការចោទប្រកាន់ ក៏ដូចជាការលើកទឹកចិត្តពួកគេក្នុងការនិយាយស្តីដោយសេរី និង គ្មានការភ័យខ្លាច។ ធ្វើដូចនេះ វាធានាឱ្យមានការពិភាក្សាមួយដ៏រស់រវើក និង ការអនុវត្តន៍មួយដែលមានប្រសិទ្ធិភាពនៅក្នុងមុខងារត្រួតពិនិត្យរបស់រដ្ឋសភា។

ប៉ុន្តែដោយឡែក បើក្រលេកទៅមើលការតាក់តែងនៅក្នុងប្រព័ន្ធច្បាប់រួមទាំងការអនុវត្តទៅលើការផ្តល់អភ័យឯកសិទ្ធិនេះវិញ មិនថាតែនៅលើបណ្តាប្រទេសមួយចំនួនជួបប្រទះបញ្ហានេះទេ នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាប្រទេសជប៉ុនក៏មានបញ្ហាមួយចំនួនកើតឡើងផងដែរ។

ចំពោះនៅក្នុងប្រទេសកម្ពុជា បញ្ហាទាក់ទិននឹងអភ័យឯកសិទ្ធិរដ្ឋសភានេះអាចជាចំនុចតូចមួយដោយសារតែអភ័យឯកសិទ្ធិ គឺមានចែងតែក្នុងមួយមាត្រាតែប៉ុណ្ណោះនៅក្នុងរដ្ឋធម្មនុញ្ញ និងបទបញ្ញត្តិមួយចំនួនទៀតនៅក្នុងលក្ខន្តិកៈស្តីពីតំណាងរាស្ត្រ។ ប៉ុន្តែការជួបប្រទះនូវបញ្ហាទាំង ផ្នែកទ្រឹស្តី និងការអនុវត្តហាក់ដូចជាមានច្រើន ដោយសារការចែងមិនបានទូលំទូលាយពាក់ព័ន្ធនឹងបញ្ហាខ្លឹមសារ និងគោលការណ៍ក្នុងការអនុវត្តនានានៅក្នុងច្បាប់ដោយឡែកមួយទាក់ទងនឹងបញ្ហា

នេះគឺមិនទាន់មាននៅឡើយ ហេតុនេះហើយទើបធ្វើឱ្យចំណេះដឹង និង ការវិភាគទៅលើបញ្ហាអភ័យឯកសិទ្ធិនេះហាក់នៅមានលក្ខណៈចង្អៀត ជាពិសេសនាពេលបច្ចុប្បន្ននេះ បញ្ហាទាក់ទងនឹងអភ័យឯកសិទ្ធិរដ្ឋសភាចាប់ផ្ដើមលេចចេញនូវរូបរាងឡើងគួរឱ្យកត់សម្គាល់ បន្ទាប់ពីការបោះឆ្នោតអាណត្តិទី៥បានបញ្ចប់ទៅ កើតមានបញ្ហារការកូសប្រឈមមុខដាក់គ្នា រវាងគណបក្សឈ្នះឆ្នោតចំនួនពីរដែលមានអាសនៈនៅក្នុងសភា ប៉ុន្តែគណបក្សមានសម្លេងភាគតិចមិនបានចូល រួមក្នុងពិធីចាប់ផ្ដើមនីតិកាលថ្មីតាមការកំណត់ និង តាមការកោះអញ្ជើញពីព្រះមហាក្សត្រនោះឡើយដោយអះអាងថាលទ្ធផលឆ្នោតមិនមានភាពសុក្រឹត្យត្រឹមត្រូវ នាពេលនោះហើយដែល បញ្ហាចាប់ខ្លួនអ្នកតំណាងរាស្ត្រ និង ការតវ៉ាជជែកគ្នាអំពីអភ័យឯកសិទ្ធិសភាបានលេចរូបរាងឡើង រហូតបន្ទាប់ពីមានការសម្របសម្រួលចរចារ និង ជំនួបពិភាក្សាគ្នារវាងគណបក្សទាំងពីរទើបក្រោយមកគណបក្សមានសំលេងភាគតិចក្នុងសភា ព្រមចូលក្នុងសភាក្លាយជាតំណាងរាស្ត្រពេញសិទ្ធិ ប៉ុន្តែទោះបីជាយ៉ាងណាក៏ជំលោះនយោបាយក៏ដូចជាការជជែកវែកញែកទាក់ទិននឹងអភ័យឯកសិទ្ធិ នៅតែមិនបញ្ចប់ ហើយនៅបន្តកំដៅរហូតមកទល់សព្វថ្ងៃ និង កំពុងក្លាយជាបញ្ហាដ៏ក្ដៅគគុកនៅក្នុងសង្គមខ្មែរ ដោយមានការចាប់អារម្មណ៍ពីសំណាក់មហាជនទូទៅ មិនត្រឹមតែក្នុងជាតិតែប៉ុណ្ណោះទេក៏មានការអន្តរាគមន៍លូកដៃចូលទៅក្នុងបញ្ហានេះពីសំណាក់អន្តរជាតិផងដែរ គឺដោយសារបញ្ហាទាក់ទងនឹងការចាប់ខ្លួន ការកោះហៅអ្នកតំណាងរាស្ត្រដែលមានអភ័យឯកសិទ្ធិនេះបានបង្កទៅជាជំលោះ និង មានមតិប្រឆាំងទៅនឹងវិធានការនានារបស់អាជ្ញាធរមានសមត្ថកិច្ច បង្កភាពរាំងស្ទះធ្វើឱ្យស្ថានភាពនយោបាយកាន់តែអាក្រក់ទៅៗ ដោយសារការប្រឈមមុខដាក់គ្នារវាងគណបក្សកាន់អំណាច និង គណបក្សប្រឆាំងតែនៅតែមិនទាន់មានដំណោះស្រាយណាមួយល្អប្រសើរនៅឡើយទេ។ ទាក់ទិននឹងបញ្ហាបទបញ្ញត្តិនៃច្បាប់ទាក់ទិននឹងករណីអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រនេះ គឺកំពុងត្រូវបានបកស្រាយដោយមតិផ្ទុយផ្សេងពីគ្នា ដោយសារការចែងមិនច្បាស់លាស់ មិនមានការបកស្រាយឱ្យបានទូលំទូលាយ និងតឹងរឹងខាងផ្នែកច្បាប់ពាក់ព័ន្ធនឹងបញ្ហានេះ ទើបយើងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទមួយនេះឡើងមកធ្វើការស្រាវជ្រាវ ព្រមទាំងសិក្សាប្រៀបធៀបជាមួយប្រព័ន្ធច្បាប់នៃការផ្ដល់អភ័យឯកសិទ្ធិនៅក្នុងប្រទេសជប៉ុន ដែលយើងអាចកត់សម្គាល់បានពីដំណើរការនៃការអនុវត្តច្បាប់ និង លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសជប៉ុនហាក់មានលក្ខណៈល្អប្រសើរច្រើនបើប្រៀបធៀបទៅនឹងបណ្ដាប្រទេសក្នុងតំបន់អាស៊ី។

ប្រធានបទនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការយល់ដឹងបន្ថែមទៀតពីចំនុចដ៏រសើបទាក់ទងនឹងបញ្ហាជុំវិញប្រធានបទ ជាពិសេសបញ្ហាទ្រឹស្ដីខ្លឹមសារ និងការអនុវត្តជាក់ស្ដែងថាតើមូលហេតុណាមួយ ដែលជម្រុញឱ្យមានការបកស្រាយផ្ទុយគ្នា ចំនុចណាមួយជាចំនុចបញ្ហា

ប្រឈមខ្លាំង ដើម្បីស្វែងរកនូវដំណោះស្រាយដ៏សមស្របមួយ ដោយហេតុថាបញ្ហាទាក់ទងនឹងប្រធានបទនេះកំពុងតែក្តៅគគុក និងទទួលបានចំណាប់អារម្មណ៍ខ្លាំងមានន័យថាមានបញ្ហាជំលោះប៉ុន្តែនៅតែមិនទាន់មានដំណោះស្រាយ ដែលនេះជាប្រធានបទដ៏ថ្មីស្រឡាងមួយគឺចាំបាច់ណាស់ត្រូវតែយកមកធ្វើការសិក្សា និងត្រូវតែធ្វើការស្រាវជ្រាវដោយសារទាក់ទងទៅនឹងបញ្ហាស្ថានភាពនយោបាយដែលអាចហៅថាជាចរន្តឈាមនៃអាយុជីវិតរបស់ប្រទេសជាតិ ដោយយើងធ្វើការសិក្សាប្រៀបធៀបស្វែងយល់ និងពន្លេចនូវទិដ្ឋភាពទូទៅ ព្រមទាំងវិភាគ ប្រមូលផ្តុំគំនិត ទ្រឹស្តី បញ្ហា និងដំណោះស្រាយរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន ក្នុងគោលបំណងសិក្សាប្រៀបធៀបពីគុណសម្បត្តិ និង គុណវិបត្តនៃប្រព័ន្ធនៃការផ្តល់អភ័យឯកសិទ្ធិរបស់ប្រទេសទាំងពីរ ដើម្បីស្វែងរកនូវដំណោះស្រាយដ៏ល្អប្រសើរមួយទៅលើបញ្ហានេះ ។

ដើម្បីឈានទៅដល់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើ យើងខ្ញុំសូមលើកយកនូវចំណោទបញ្ហាធំៗចំនួន៥ដូចខាងក្រោម៖

- តើប្រវត្តិនៃការកកើតរដ្ឋសភានៅលើពិភពលោកមានលក្ខណៈយ៉ាងដូចម្តេច? តើការកកើតរដ្ឋសភា នៅក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុនមានប្រវត្តិយ៉ាងណាខ្លះ?
- តើការបង្កើត និង ការរៀបចំដំណើរការនៃរដ្ឋសភានៃប្រទេសកម្ពុជា និង ប្រទេសជប៉ុនដំណើរការទៅយ៉ាងដូចម្តេច?
- តើការផ្តល់អភ័យឯកសិទ្ធិសភាមានប្រវត្តិយ៉ាងដូចម្តេច? និងការអនុវត្តជាក់ស្តែងនៃសិទ្ធិមានអភ័យឯកសិទ្ធិនេះមានដំណើរការប្រព្រឹត្តិទៅយ៉ាងដូចម្តេច?
- តើប្រព័ន្ធនៃការផ្តល់អភ័យឯកសិទ្ធិរដ្ឋសភារវាងប្រទេសទាំងពីរមានលក្ខណៈស្របគ្នា និងខុសគ្នាត្រង់ចំនុចណាខ្លះ?
- តើនៅក្នុងការអនុវត្តជាក់ស្តែង ប្រទេសទាំងពីរបានជួបប្រទះនូវបញ្ហាអ្វីខ្លះ និងមានដំណោះស្រាយ ទៅលើបញ្ហាទាំងនោះយ៉ាងដូចម្តេចដែរ?

នៅក្នុងការកំណត់ដែនទំហំនៃការស្រាវជ្រាវនេះផងដែរ នៅក្នុងសារណានេះយើងនឹងលើកយកទាំងប្រវត្តិនៃការកកើតរដ្ឋសភាដំបូងនៅលើពិភពលោក និងប្រវត្តិនៃការកកើតរដ្ឋសភា និងដំណើរការនៃការបង្កើតរដ្ឋសភានៅក្នុងប្រទេសកម្ពុជា និង ជប៉ុនរួមទាំងបកស្រាយអំពីសមាជិករដ្ឋសភាដែលជាតំណាងរាស្ត្រផងដែរ ប៉ុន្តែអ្វីដែលយើងធ្វើការផ្តោតសំខាន់ និងចង់បានបំផុតនោះគឺទាក់ទិនទៅនឹងបញ្ហាអភ័យឯកសិទ្ធិរដ្ឋសភា ជាពិសេសបញ្ហាដែលកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជាចាប់តាំងកើតមានភាពរកាំរកូសក្នុងរង្វង់បញ្ហា ក្រោយពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី

៥នេះមក។ ការសិក្សាស្រាវជ្រាវទៅលើបញ្ហាទាំងនេះមិនត្រឹមតែពន្លេចឱ្យឃើញពីចំនុចឬសគល់នៃបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្វែងរកឱ្យឃើញនូវដំណោះស្រាយសមស្រមដ៏ល្អប្រសើរមួយសម្រាប់ប្រទេសជាតិផងដែរ ដោយធ្វើការប្រៀបធៀបជាមួយនឹងប្រព័ន្ធនៃប្រទេសជប៉ុន។

នៅក្នុងការស្រាវជ្រាវនេះទៀតសោត យើងខ្ញុំបានខិតខំប្រមូលទិន្នន័យតាមពីររបៀបគឺទាញទិន្នន័យពីឯកសារនានាដែលមានទិន្នន័យអាចប្រើប្រាស់បាននៅក្នុងការស្រាវជ្រាវ និងបានចម្រាញ់ចេញពីផ្នែកទ្រឹស្តីនានាទាក់ទិននឹងប្រធានបទ ដោយទិន្នន័យទាំងនោះមានប្រភព២។ ប្រភពទីមួយគឺបានពីប្រព័ន្ធអ៊ីនធឺណែត ដោយយើងស្រាវជ្រាវរកទិន្នន័យជាក់ស្តែងនៅក្នុងគេហទំព័ររបស់ក្រសួង និងស្ថាប័ននានា ជាពិសេសគេហទំព័រសារពត៌មាននានា រួមទាំងការបង្ហោះ នៅក្នុងប្រព័ន្ធFacebook ក៏ដូចជាការផ្សព្វផ្សាយតាមវិទ្យុ។ ប្រភពមួយទៀតគឺបានមកពីឯកសារច្បាប់លិខិតបទដ្ឋានគតិយុត្តនានារួមមានរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីលក្ខន្តិកៈអ្នកតំណាងរាស្រ្តជាដើម។ល។ និងបណ្តាសៀវភៅរបស់សាស្រ្តាចារ្យមួយចំនួនទាំងទិន្នន័យរបស់ខ្មែរ និងជប៉ុន។

ដើម្បីជាការឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើ យើងធ្វើការសិក្សាអំពី៣ជំពូកធំៗដូចតទៅៈ

ជំពូកទី១ អំពីសញ្ញាណទូទៅ និងកំណកំណើតនៃរដ្ឋសភា

ជំពូកទី២ អំពីអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភានៅប្រទេសកម្ពុជា និង ប្រទេសជប៉ុន

ជំពូកទី៣ អំពីបញ្ហាប្រឈម និងដំណោះស្រាយទាក់ទងបញ្ហាក្នុងការអនុវត្តសិទ្ធិមានអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភានៃប្រទេសកម្ពុជា និង ប្រទេសជប៉ុន

# ជំពូកទី១
# អំពីសញ្ញាណទូទៅ និងកំណត់កំណើតនៃរដ្ឋសភា

នៅក្នុងជំពូកទី១នេះចែកចេញជា៣ផ្នែក ដោយយើងនឹងធ្វើការសិក្សាអំពីប្រវត្តិនៃការកកើតរដ្ឋសភានៅលើពិភពលោក(ផ្នែកទី១) សាវតានៃការកកើតរដ្ឋសភានៅប្រទេសកម្ពុជា(ផ្នែកទី២) និងសាវតានៃការកកើតរដ្ឋសភានៅប្រទេសជប៉ុន (ផ្នែកទី៣)។

## ផ្នែកទី១ ប្រវត្តិនៃការកកើតរដ្ឋសភានៅលើពិភពលោក

របបសភានិយមមានច្រើន មិនមែនមានតែមួយនោះទេ ពីព្រោះវាត្រូវកសាងឡើងតាមលក្ខណៈប្រទេសជាតិនីមួយៗ។ ប៉ុន្តែជារួមវាមានយន្តការរបៀបដូចគ្នា។ តាមប្រវត្តិសាស្ត្រ របបសភានិយមបានកកើតឡើងនៅតាមប្រទេសអង់គ្លេសនាពាក់កណ្តាលស.វទី១៨ និង ប្រទេសបារាំងនាដើម ស.វទី ១៩ ហើយជាបន្តបន្ទាប់មកនៅក្នុងប្រទេសផ្សេងៗទៀតនៅលើពិភពលោកយើងនេះក៏បានចាប់ផ្តើម គ្រប់គ្រងប្រទេសដោយប្រកាន់យករបបសភានិយមនេះឡើង[1]។

គេបានសង្កេតឃើញថា របបសភានិយមផុសឡើងនៅសម័យអំណាចស្តេចកំពុងចាប់ចុះអន់ថយ ហើយត្រូវតែសម្របសម្រួលជាមួយអង្គការតំណាង អ្នកមាន និងអ្នកចេះដឹងដែលកំពុងរីកសាយភាយពេញទាំងផ្ទៃប្រទេសនោះ។ ហេតុដូចនេះហើយបានជារបបសភានិយមត្រូវបានគេចាត់ទុកថាជារបបសេរីដែលបានរំលត់របបផ្តាច់ការ។ ប៉ុន្តែដើមដំបូង របបនេះជារបបសំរាប់អ្នកមានលុយ ពីព្រោះ អ្នកមានលុយទើបមានសិទ្ធិបោះឆ្នោតដែលគេមានធនធានល្មមជាប់ពន្ធ។ អ្នកក្រដែលច្បាប់មិនតម្រូវឱ្យបង់ពន្ធគឺមិនមានសិទ្ធិបោះឆ្នោតទេ។ ក្រោយៗមករបបសភានិយមក៏ចេះតែវិវត្តន៍បន្តិចម្តងៗតាមកាលវេលារហូតមកដល់សព្វថ្ងៃ។

ថ្វីបើទ្រឹស្តីនៃការបែងចែកអំណាចនេះ ដើរតួនាទីសំខាន់ក្នុងរបបនេះដោយហេតុថាវាជាលក្ខខណ្ឌដំបូង និងចាំបាច់នៃការបែងចែករវាងអង្គការនីតិបញ្ញត្តិ និង អង្គការនីតិប្រតិបត្តិ របបសភានេះហាក់ ដូចជាកើតឡើងដោយចៃដន្យពុំមែនដោយចលនាគំនិតនយោបាយអ្វីដែលមានពីមុនមកនោះទេ។ សភាពការណ៍នេះគេអាចកត់សម្គាល់បាននៅប្រទេសអង់គ្លេស ដែលជាប្រទេសផ្តួចផ្តើមមុនគេ ក្នុងការបង្កើតឱ្យមានរបបសភានិយមនេះឡើង។ ប៉ុន្តែប្រទេសដទៃទៀតដែលចម្លងតាមរបបអង់គ្លេស ហាក់ដូចជាមិនមែនជាភាពចៃដន្យទេ ព្រោះគេបានគិតគូរពិចារណាទុកជាស្រេចមុននឹងសម្រេចយក ប្រព័ន្ធសភានិយមនេះតាមគំរូរបស់ប្រទេសអង់គ្លេស។ យ៉ាងណាមិញ ប្រវត្តិនៃ

[1] ម៉ុក ដារ៉ា 「នីតិរដ្ឋធម្មនុញ្ញ」, សៀវភៅសិក្សាឆ្នាំទី២, ទំព័រ៧៩

ការបោះឆ្នោតនៅលើពិភពលោក និង ការឈរឈ្មោះឱ្យគេបោះឆ្នោតបានកំណត់មនុស្សមួយចំនួន ដែលមិនត្រូវ បានរាប់បញ្ចូលក្នុងការបោះឆ្នោតដូចជា ជនជាតិភាគតិច បព្វជិត ឬស្រ្តីភេទ ។

តាមប្រវត្តិសាស្រ្តពិភពលោកដូចជា នៅអាមេរិក រដ្ឋធម្មនុញ្ញឆ្នាំ ១៧៨៧ អ្នកមានសិទ្ធិបោះឆ្នោត និង ឈរឈ្មោះ ឱ្យគេបោះឆ្នោត ជាបុរស ស្បែកស និងជាម្ចាស់ដីធ្លី ។ មកដល់ដើមស.វ ទី ១៩ ការកម្រិតសិទ្ធិបោះឆ្នោតដែលយោងទៅលើកម្មសិទ្ធិ ត្រូវបំបាត់ចោល ហើយស្រ្តីដណ្តើមបានសិទ្ធិបោះឆ្នោតនៅឆ្នាំ ១៩២០ ។

នៅឆ្នាំ ១៩៦០ ជនជាតិស្បែកខ្មៅនៅអាមេរិកភាគខាងត្បូង ទាមទារបានសិទ្ធិបោះឆ្នោត ហើយទទួលបានសិទ្ធិពេញលេញនៅឆ្នាំ ១៩៧១ ។ យុវជនក្មេងៗ នៅសហរដ្ឋអាមេរិកទទួលបានសិទ្ធិបោះឆ្នោតនៅពេលច្បាប់បានចារឹកបន្ថយអាយុពី ២១ ឆ្នាំ មកត្រឹម ១៨ ឆ្នាំ ។

នៅប្រទេសបារាំង បុរសមានសិទ្ធិបោះឆ្នោតពិតប្រាកដចាប់ពីឆ្នាំ១៨៤៨ ឯស្រ្តីចាប់ពីឆ្នាំ ១៩៤៤ ។ ការប្រកាន់យកលទ្ធិប្រជាធិបតេយ្យជាបំណងប្រាថ្នារបស់ប្រជារាស្រ្តទូទៅ ដែលស្រលាញ់យុត្តិធម៌ សមធម៌ តម្លាភាពក្នុងការជ្រើសរើសតំណាងរបស់ខ្លួនតាមរយៈការបោះឆ្នោត ដើម្បីឱ្យបានមេដឹកនាំ ដែលតំណាងឱ្យឆន្ទៈរាស្រ្តក្នុងការបម្រើប្រយោជន៍ទូទៅ ។

## ផ្នែកទី២ សាវតានៃការកកើតរដ្ឋសភានៅកម្ពុជា

តាមប្រវត្តិសាស្រ្ត ប្រទេសកម្ពុជារបបរាជានិយមផ្តាច់ការ គឺបានរៀបចំឱ្យមានស្ថាប័នតំណាងមួយមានឈ្មោះថា ស្ថាប័នពិគ្រោះយោបល់នៃប្រជាជនដើម ដែលចេញដោយព្រះរាជប្បញ្ញត្តិចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩១៣[2]។

ក្រោយមក ក្រោមការដឹកនាំរបស់ព្រះបាទសម្តេចនរោត្តម សីហនុ ព្រះអង្គបានផ្លាស់ប្តូរពីស្ថាប័នពិគ្រោះយោបល់ មកជា សភាតំណាងនៃប្រជាជនកម្ពុជាវិញ។ ការប្រកាន់យកលទ្ធិប្រជាធិបតេយ្យ គឺជាបំណងប្រាថ្នា របស់អ្នកស្នេហាជាតិ អ្នកស្រលាញ់យុត្តិធម៌ ហើយក៏ជាបំណងប្រាថ្នាចំបងរបស់ប្រជារាស្រ្តទូទៅផងដែរ ទើបបានព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហនុ ព្រះអង្គបាន ធ្វើការកែប្រែរបបនយោបាយគ្រប់គ្រងរដ្ឋ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៤៦ ដោយការផ្លាស់ប្តូរ ពីរបបរាជានិយមផ្តាច់ការ ទៅជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញវិញ។ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៤៦ ព្រះអង្គបានរៀបចំការបោះឆ្នោតជាសកលមួយ ដោយធ្វើការជ្រើសរើសសភាធម្មនុញ្ញ ក្នុងការអនុម័តព្រាងទី១ នៃរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ហើយក៏ដើម្បីបង្កើតឱ្យមានសភាជាតិផងដែរចាប់តាំងពីពេលនោះមក។

---

[2] ដុំ អុឹម [ស្ថាប័ននយោបាយព្រះរាជាណាចក្រកម្ពុជា], បោះពុម្ពលើកទី១, ឆ្នាំ២០១២, ទំព័រ ៩៤

## កថាខណ្ឌទី១ ប្រវត្តិនៃការកកើត

### ១. រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាទី១ ( ១៩៤៦-១៩៧០ )

រដ្ឋសភារបស់ប្រទេសកម្ពុជាបានកើតឡើងជាលើកដំបូងថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៤៦ ដែលគេហៅថា "រដ្ឋសភាបណ្ដោះអាសន្ន" ។ "រដ្ឋសភាបណ្ដោះអាសន្ន" នេះ មានតួនាទីតាក់តែងរដ្ឋធម្មនុញ្ញជាលើកដំបូងរបស់ប្រទេសកម្ពុជា ដែលរដ្ឋធម្មនុញ្ញទី១ នោះត្រូវបាន ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជា ប្រកាសឱ្យប្រើនូវថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៤៧ ។

រដ្ឋសភាលើកដំបូង ឬរដ្ឋសភាអាណត្តិទី១មានសមាជិកសរុប ៦៧ រូប ដែលមាន ឯកឧត្ដម អៀវ កើស មកពីគណបក្សប្រជាធិបតេយ្យជាប្រធានរដ្ឋសភា ហើយបានបើកសម័យប្រជុំលើកដំបូងនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៤៦ ។

រដ្ឋសភាអាណត្តិទី២ បង្កើតឡើងនៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៥១ រដ្ឋសភាអាណត្តិទី៣ បង្កើតឡើងនៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៥៥ រដ្ឋសភាអាណត្តិទី៤ បង្កើតឡើងនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៥៨ រដ្ឋសភាអាណត្តិទី ៥ បង្កើតឡើងនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៦២ និងរដ្ឋសភាអាណត្តិទី ៦ បង្កើតឡើង នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៦៦ ។

រដ្ឋសភាទី១របស់ប្រទេសកម្ពុជានីតិកាលមានរយៈពេល ៤ ឆ្នាំ ហើយដែលកើតចេញពីការបោះឆ្នោតជាសកល និង ដោយចំពោះពីប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសដែលមានសិទ្ធិបោះឆ្នោតដែលច្បាប់បានកំណត់ឱ្យមានអាយុពី ២០ ទៅ ទើបមានសិទ្ធិបោះឆ្នោត ។ ប៉ុន្តែទាហាន និងបុព្វជិតមិនមានសិទ្ធិបោះឆ្នោតទេ ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រត្រូវមានអាយុយ៉ាងតិចចាប់ពី ២៥ ឆ្នាំឡើងទៅ ។ សភានៃប្រទេសកម្ពុជាមានពីរថ្នាក់គឺ រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រ ( ព្រឹទ្ធសភា )[3] ។

### ២. រដ្ឋសភានៃសាធារណរដ្ឋខ្មែរ ( ១៩៧០-១៩៧៥ )

នៅក្នុងរដ្ឋធម្មនុញ្ញ ( ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧២ ) នៃរបបសាធាណរដ្ឋខ្មែរ បាន ចារឹកលក្ខណៈទ្វិកសភានិយម។ សភាមានសមាជិកចំនួន៨០នាក់យ៉ាងតិច។ អ្នកមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺពលរដ្ឋមានសិទ្ធិបោះឆ្នោតទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២០ឆ្នាំគត់មកទល់ថ្ងៃបោះឆ្នោត ។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយចំពោះ ជាសម្ងាត់ និង ដោយសន្លឹកឆ្នោតមួយមាននាមតែមួយ សម្រាប់អាណត្តិ៤ឆ្នាំ ។ តំណាងរាស្ត្រអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាថ្មីបាន ។

---

[3] កៅ មុយថុង [រដ្ឋធម្មនុញ្ញកម្ពុជា], បោះពុម្ពលើកទី១, ដោយបណ្ណាគារអង្គរ, ឆ្នាំ២០០៦, ទំព័រ១២

នៅក្នុងពេលមានសង្គ្រាម ឬ មានអសន្តិសុខខ្លាំង សមាជិកសហសភា[4] ត្រូវជ្រើសតាំងដោយការបោះឆ្នោត ជាសកល ដោយចំពោះ ជាសម្ងាត់ និងដោយសន្លឹកបញ្ជី។ ក្នុងករណីដែលការបោះឆ្នោតមិនអាចប្រព្រឹត្តិទៅកើត ប្រធានាធិបតីនៃសាធារណៈរដ្ឋ អាចពន្យាអាណត្តិសមាជិកសហ.សភាបានមួយឆ្នាំម្តង ។

អាណត្តិសមាជិករបស់សហសភាមានវិសមិតភាព និង ការបំពេញមុខងារសាធារណៈជាសកម្ម។ សមាជិកសហសភាម្នាក់ៗ មិនអាចបំពេញមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតរបស់សាធារណរដ្ឋដែលចែងក្នុងរដ្ឋធម្មនុញ្ញ វៀរលែងតែមុខងារ សមាជិកតុលាការជាន់ខ្ពស់ចេញ [5]។

**៣. រដ្ឋសភានៃកម្ពុជាប្រជាធិបតេយ្យ ( ឆ្នាំ ១៩៧៥ ដល់ ១៩៧៩ )**

នៅក្នុងរដ្ឋធម្មនុញ្ញ ( ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ ) នៃរបបកម្ពុជាប្រជាធិបតេយ្យ បានចែងសង្កត់ធ្ងន់ផ្តល់តួនាទីយ៉ាងសំខាន់ទៅឱ្យប្រជាពលរដ្ឋ កម្មករ កសិករក្រ កសិករកណ្តាល ថ្នាក់ក្រោម និងស្រទាប់ពលករផ្សេងទៀត ។ ក្រៅពីនេះគឺ កងកម្លាំងប្រដាប់អាវុធ ឬកងទ័ពប្រជាជនបដិវត្តកម្ពុជា ។

ការងារអ្វីៗទាំងអស់ គឺធ្វើឡើងក្នុងគោលបំណង និងប្រយោជន៍ប្រជាពលរដ្ឋទាំងអស់ សមដូចបាវចនា " កម្ពុជាប្រជាធិបតេយ្យ " ។ មធ្យោបាយផលិតកម្មសំខាន់ជាទូទៅនៃសេដ្ឋកិច្ចជាកម្មសិទ្ធិ របស់ប្រជាជន និង របស់សមូហភាព ហើយអ្វីជាសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃជារបស់ឯកជន។ ម្យ៉ាងទៀត ដើម្បីជាការលើកតម្កើងពលរដ្ឋជាធំ អំណាចធ្វើច្បាប់ក៏សម្តែងចេញតាមរយៈពលរដ្ឋជាធំដែរ ។

អំណាចធ្វើច្បាប់ ជាអំណាចរបស់សភាតំណាងប្រជាជន កម្មករ កសិករ ពលករ កម្ពុជាផ្សេងទៀត ។ សភានេះមានឈ្មោះជាផ្លូវការថា " សភាតំណាងប្រជាជនកម្ពុជា " សភាតំណាងប្រជាជនកម្ពុជាមានសមាជិកទាំងអស់ ២៥០ រូប ក្នុងនោះគឺ ៖

- តំណាងកសិករ : ១៥០ នាក់
- តំណាងកម្មករ និងពលករផ្សេងទៀត : ៥០ នាក់
- តំណាងកងទ័ពបដិវត្ត : ៥០ នាក់

សមាជិកសភាតំណាងប្រជាជន ត្រូវបានប្រជាជនជ្រើសតាំងឡើង ដោយការបោះឆ្នោតទូទាំងប្រទេស ដោយផ្ទាល់ និងដោយសម្ងាត់ក្នុងរយៈពេល ៥ ឆ្នាំម្តង [6]។ ទោះបីការសម្តែងឡើងកំណត់អាណត្តិជាក់លាក់ និងកើតចេញពីការបោះឆ្នោតក៏ដោយ ប៉ុន្តែមិនបានសម្តែងឱ្យច្បាស់ថា

---

[4] សភា និងព្រឹទ្ធសភា

[5] មាត្រា៥០នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឆ្នាំ១៩៧២

ពលរដ្ឋមានសិទ្ធិបោះឆ្នោត មានអាយុប៉ុន្មាន ហើយអ្នកដែលមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតក៏មិនបានកំណត់ច្បាស់ថាចាប់ពីអាយុប៉ុន្មាននោះដែរ ។ សមត្ថកិច្ចសភាតំណាងប្រជាជនមានភារកិច្ចសម្រេចច្បាប់ និងកំណត់មាគ៌ានយោបាយផ្សេងៗក្នុងប្រទេស និង ក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ ។

### ៤. រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា ( ១៩៧៩-១៩៩៣ )

យោងតាមរដ្ឋធម្មនុញ្ញ ( ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨១ ) នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានសម្តែងថា រដ្ឋសភាជាអង្គការកំពូលនៃរដ្ឋអំណាច និង ជាអង្គការតំណាងជាន់ខ្ពស់របស់ប្រជាជននៃ(សាធារណរដ្ឋប្រជាមានិតកម្ពុជា)[7] និង(រដ្ឋកម្ពុជា)[8]។ រដ្ឋសភាមានតំណាងប្រជាជន ដែលត្រូវបានជ្រើសរើស តាមគោលការណ៍បោះឆ្នោតជាសាកល ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសជាសម្ងាត់ [9] ។ ចំនួនតំណាងប្រជាជននៅរដ្ឋសភា និងបែបបទនៃការជ្រើសតាំងត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

ដោយសាររបបសាធាណរដ្ឋប្រជាមានិតកម្ពុជាអនុវត្តនយោបាយកុំម្មុយនីសឯកបក្ស ទើបមិនឃើញពីការកំណត់ក្នុងរដ្ឋធម្មនុញ្ញ អំពីសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងរបស់ប្រជាពលរដ្ឋឱ្យច្បាស់លាស់ថា តើពលរដ្ឋមានអាយុប៉ុន្មានមានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាង ឬ ឈរឈ្មោះឱ្យគេបោះឆ្នោត ហើយតំណាងប្រជាជនចំនួនប៉ុន្មានរូបនោះដែរ ។

ក្រុមប្រឹក្សារដ្ឋមានភារកិច្ចក្នុងការរៀបចំការបោះឆ្នោត ៣ ខែ មុនផុតកំណត់នីតិកាលរដ្ឋសភាចាស់ ។ ក្នុងពេលប្រទេសមានអសន្តិសុខ មិនអាចធ្វើការបោះឆ្នោតជ្រើសរើសសភាប្រជាជនថ្មីបាន រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនបាន [10] ។ នៅក្នុងកាលៈទេសៈពិសេសដូចនេះ បានបង្ហាញខាងលើ រដ្ឋសភាប្រកាសបន្តនីតិកាលរបស់ខ្លួនដោយមិនបានបញ្ជាក់ឆ្នាំឱ្យច្បាស់លាស់ឡើយ ។

### ៥. រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាទី២( ១៩៩៣-បច្ចុប្បន្ន)

រដ្ឋសភាជាអង្គការកំពូលតំណាងជាន់ខ្ពស់របស់ប្រជាពលរដ្ឋ និងជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ។ តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

---

[6] មាត្រា៦នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦

[7] មាត្រា៩៥នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១

[8] មាត្រា៩៥នៃរដ្ឋធម្មនុញ្ញរដ្ឋកម្ពុជាឆ្នាំ១៩៨៩

[9] មាត្រា៩៦វាក្យខណ្ឌ១ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា

[10] មាត្រា៩៧នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី២ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ បានបញ្ជាក់ថា សមាជិកសភាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប[11]តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកលដោយសេរីដោយចំពោះនិងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។ តំណាងរាស្ត្រអាចឈរឈ្មោះឱ្យគេបោះឆ្នោតជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះ គឺពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច២៥ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត ។

តំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាងប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនប៉ុណ្ណោះទេ ។ អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ ។

**កថាខណ្ឌទី២ ការបង្កើតរដ្ឋសភាកម្ពុជានាពេលបច្ចុប្បន្ន**

**១ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ**

ការបោះឆ្នោត និងសមាសភាពនៃរដ្ឋសភា គឺមានកំណត់នៅក្នុងមាត្រារដ្ឋធម្មនុញ្ញមាត្រា ៧៦ ដែលបានចែងថា:

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោត ជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសារជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត ។

អង្គការរៀបចំការបោះឆ្នោត បែបបទ និង ការប្រព្រឹត្តិទៅនៃការបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់ស្តីពីការបោះឆ្នោត ។

ចំពោះបែបបទនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ( មាត្រា ៧៦ វាក្យខណ្ឌ២ ) គឺធ្វើឡើងតាម របៀបជាសេរី សកល ដោយស្មើភាព ដោយផ្ទាល់ សម្ងាត់ សម្រាប់គ្រប់ប្រជាពលរដ្ឋខ្មែរដែលមាន សិទ្ធិបោះឆ្នោត ដូចដែល មានចែងក្នុងមាត្រា ៣៤ នៃរដ្ឋធម្មនុញ្ញ ។ ចំណុចត្រង់នេះមិនទាមទារឱ្យមានការអធិប្បាយលម្អិតអ្វីនោះទេ ខុសពីលក្ខខណ្ឌដែលអាចឈរឈ្មោះបោះឆ្នោតបានត្រូវមានការបញ្ជាក់ខ្លះ ។ ជាដំបូង គឺលក្ខខណ្ឌអាយុ ដែលទាមទារទៅលើ បេក្ខជន ( ២៥ ឆ្នាំ ជាអាយុដែលធ្លាប់មានចែងដោយរដ្ឋធម្មនុញ្ញឆ្នាំ ១៩៧២ ក្នុងមាត្រា៤៧ វាក្យខណ្ឌ៣ ) ព្រមទាំងលក្ខខណ្ឌសញ្ជាតិខ្មែរ "ពីកំណើត" ( មាត្រា ៧៦វាក្យខណ្ឌ៤ ) ។ ចំណុចបង្ហាញឱ្យឃើញពីគំនិត

[11] មាត្រា៧៦នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាទី២ ១៩៩៣

បែបជាតិនិយម ដូចបានចែងនៅក្នុងបញ្ញត្តិទាក់ទិនទៅនឹងការទទួលស្គាល់សេរីភាពសាធារណៈ។ លក្ខខណ្ឌទាំងនេះមានលក្ខណៈតឹងរឹងគួរឱ្យកត់សម្គាល់ ដោយបញ្ជាក់អំពីឆន្ទៈប្រមូលផ្តុំនៅក្នុងការអនុវត្តអំណាច នៅក្នុងក្របខណ្ឌជាលក្ខណៈជាតិនិយម "សុទ្ធសាធ" ។

ម្យ៉ាងទៀត គេមិនធ្លាប់ឃើញមានការបែងចែកលក្ខខណ្ឌបែបនេះក្នុងរដ្ឋធម្មនុញ្ញពីមុននោះទេ[12] ។ ចំពោះបែបបទផ្សេងទៀតនៃការជ្រើសរើស និងជាពិសេសវិធីបោះឆ្នោត រដ្ឋធម្មនុញ្ញតម្រូវឱ្យបញ្ជាក់នៅក្នុងច្បាប់បោះឆ្នោតក្រោយមួយ[13] ( មាត្រា ៧៦. វាក្យខណ្ឌ ៥ ) ។

### ២ ការរៀបចំដំណើរការនៃរដ្ឋសភា

យ៉ាងយូររយៈពេល៦០ថ្ងៃក្រោយការបោះឆ្នោត រដ្ឋសភាត្រូវបើកសម័យប្រជុំរបស់ខ្លួនជាលើកដំបូងតាមរយៈការកោះប្រជុំពីព្រះមហាក្សត្រ[14] ។ ម្យ៉ាងទៀត ក្នុងរយៈពេល ៦០ថ្ងៃនេះ ក៏ជាលទ្ធផលនៃការបោះឆ្នោតជ្រើសរើសរដ្ឋសភាថ្មី ត្រូវបានប្រកាសឱ្យបានមុនការកំណត់រយៈពេលឱ្យកោះប្រជុំរដ្ឋសភាថ្មីជាលើកដំបូងដែរ ។ រយៈពេល៦០ ថ្ងៃក្រោយការបោះឆ្នោត រដ្ឋសភាថ្មីត្រូវចូលកាន់មុខតំណែងរបស់ខ្លួនជាលើកដំបូងក្រោមអធិបតីភាពនៃព្រះមហាក្សត្រ និង ព្រះមហេសី ។

សម័យប្រជុំលើកដំបូងនេះ ចាប់ផ្តើមដំណើរការ ដោយសម្រេចឱ្យបាននូវកិច្ចការ ៤ បែប ដែលចែងឡើងដោយ មាត្រា ៨២ ៖

- ការសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ : ជាអំណាចសំខាន់របស់សភា ដែលអាចមានការប៉ះទង្គិចទៅនឹងអំណាចដែលផ្តល់ឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការ " ត្រួតពិនិត្យ និងដោះស្រាយរាល់បញ្ហាតវ៉ា ទាមទារ ទាក់ទិនទៅនឹងការបោះឆ្នោត ( មាត្រា ១៣៦ វាក្យខណ្ឌទី ២ ) " ។ យើងអាចមានការព្រួយបារម្ភថា បើមានលក្ខណៈផ្ទុយគ្នារវាងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទៅនឹងសេចក្តីសម្រេចអង្គសភា ទាក់ទិនទៅនឹងសុពលភាពសមាជិកសភាណាមួយនោះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញអាចនឹងត្រូវបានទុកចោលដោយឡែក ។ ដូច្នេះចំនុចនេះបង្ហាញអំពីនីតិវិធីពីរយ៉ាងទាក់ទិនទៅនឹងកម្មវត្ថុរួមតែមួយ ដែលអាចផ្តល់នូវផលវិបាកគួរឱ្យកត់សម្គាល់ ។
- ការធ្វើសច្ចាប្រណិធានរបស់សមាជិកសភា ។

[12] លើលក្ខខណ្ឌនៃការឈរឈ្មោះនេះ. មើល ឈន សុភាព. ដ.ឯ.ម ទំព័រ ១៨៥ និងបន្តបន្ទាប់ ។

[13] ច្បាប់បោះឆ្នោតចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៧. កម្រងអត្ថបទច្បាប់ឆ្នាំ ១៩៩៧ ទំព័រ ២៤០ និងបន្ត. ដែលកែប្រែដោយច្បាប់ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ។

[14] មាត្រា ៨២ វាក្យខណ្ឌទី ១ " រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ " ។

- ការបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។
- ការអនុម័តនូវបទបញ្ជាផ្ទៃក្នុង ដែលកំណត់អំពីការរៀបចំ និង ដំណើរប្រព្រឹត្តិទៅនៃរដ្ឋសភា[15] ។

### ៣. អាណត្តិរដ្ឋសភា

មាត្រា ៧៨ វាក្យខណ្ឌ១នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានកំណត់ថា "នីតិកាលរបស់រដ្ឋសភាកំណត់ត្រឹម៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង" រយៈពេល៥ឆ្នាំសម្រាប់នីតិកាលរបស់សភា គឺមានលក្ខណៈសមរម្យ ព្រោះថា ជារយៈពេលសមល្មមសម្រាប់ឱ្យមានការអនុម័ត និង សម្រេចឱ្យបាននូវគោលនយោបាយសំខាន់ៗ ហើយចៀសវាងនូវរយៈពេលវែងហួសហេតុដែលប្រាសចាកពីលក្ខណៈនៃរបបប្រជាធិបតេយ្យ ។

ក្នុងករណីមានការរំលាយសភាមុនអាណត្តិ ការបោះឆ្នោតថ្មីមួយត្រូវបានរៀបចំធ្វើឡើងក្នុងរយៈពេល ៦០ ថ្ងៃ ហើយក្នុងរយៈពេលនេះ រដ្ឋាភិបាលបន្តការគ្រប់គ្រង និងចាត់ចែងលើកិច្ចការប្រចាំថ្ងៃ [16] ។ ចំណុចចុងក្រោយនេះផងដែរ គួរមានការពិចារណាបន្តិចថា រដ្ឋាភិបាលដែលបន្តគ្រប់គ្រងកិច្ចការប្រចាំថ្ងៃនេះ គឺបានផ្តួលរលំរួចហើយមុននឹងមានការរំលាយសភា។ រដ្ឋាភិបាលនឹងត្រូវបញ្ចប់តួនាទី ពេលមានសភាថ្មីដែលនឹងមានការបង្កើតរដ្ឋាភិបាលថ្មី។ ការរៀបចំការបោះឆ្នោតជាថ្មីនេះ គឺជាតួនាទីម្យ៉ាងនៅក្នុងកិច្ចការប្រចាំថ្ងៃ ។ ការរក្សាមុខតំណែង ក្នុងរដ្ឋាភិបាលដើម្បីរៀបចំការបោះឆ្នោត អាចនឹងជាឥទ្ធិពលម្យ៉ាង ឬជាទម្ងន់ម្យ៉ាងទៅលើការបោះឆ្នោត និងលទ្ធផលនៃការបោះឆ្នោត ពោលគឺទៅលើម្ចាស់ឆ្នោតដែលជាប្រជាពលរដ្ឋសាមញ្ញ ។ ប៉ុន្តែលក្ខណៈបែបនេះ គឺមិនមែនពិសេសសម្រាប់តែកម្ពុជានោះទេ ព្រោះយើងសង្កេតឃើញមានការអនុវត្តជាទូទៅរួចហើយនៅក្នុងរបបប្រជាធិបតេយ្យសេរីភាគច្រើននោះ ។

### ៤. សមាជិករដ្ឋសភា

សមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងអាណត្តិទី១ នៅឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៨ មានចំនួនសមាជិកទាំងអស់ ១២០ រូប អាណត្តិទី ២ មានសមាជិកចំនួន ១២២ រូប អាណត្តិទី៣ អាណត្តិទី ៤ និងអាណត្តិទី៥ មានសមាជិករដ្ឋសភាចំនួន ១២៣ រូប ។

[15] មាត្រា៩៤នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[16] មាត្រា៧៨វាក្យខណ្ឌ៤នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

តំណាងរាស្ត្រនៅក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនប៉ុណ្ណោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវចាត់ទុកជាមោឃៈ[17] ។

សមាជិករដ្ឋសភា គឺជាតំណាងរាស្ត្រដែលត្រូវបានប្រជាពលរដ្ឋខ្មែរបោះឆ្នោតជាសាកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងដោយសម្ងាត់ មកពីមណ្ឌលផ្សេងៗគ្នា នៅទូទាំងប្រទេស ដើម្បីធ្វើជាតំណាងរបស់ខ្លួននៅក្នុងរដ្ឋសភា ដើម្បីធ្វើច្បាប់ អនុម័តច្បាប់ និងតាមដានការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល[18] ។

**ក. លក្ខន្តិកៈ**

**ក.១ លក្ខខណ្ឌនៃការឈរឈ្មោះ**

តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រចែងថា ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិទៅបោះឆ្នោត និងមានបំណងឈរឈ្មោះជាបេក្ខជនដែលត្រូវបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត គឺសំដៅជាជនជាតិខ្មែរ និងសញ្ជាតិខ្មែរ ។
- អាយុ ២៥ ឆ្នាំ ឡើងទៅគិតដល់ថ្ងៃបោះឆ្នោត ។
- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។
- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- មានការតែងតាំងពីគណបក្សនយោបាយណាមួយ ដែលបានចុះបញ្ជីក្នុងការឈរឈ្មោះបោះឆ្នោតហើយ[19] ។

**ក.២ លក្ខខណ្ឌមិនអាចឈរឈ្មោះ**

តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានចែងហាមមិនឱ្យឈរឈ្មោះចំពោះបុគ្គលដូចខាងក្រោម :

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ ឬកងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបុព្វជិតសាសនា ឬ
- ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ពីបទល្មើសព្រហ្មទណ្ឌមាន ( បទឧក្រិដ្ឋ ឬបទមជ្ឈិម ) ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

[17] មាត្រា ៧៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[18] មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[19] មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ប្រកាសឲ្យប្រើថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧

- ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬ
- ជនវិកលចរិក ឬ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលដែលមានលិខិតស្នាម បញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ
- ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុប ឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬ
- សមាជិកគណៈកម្មាធិការជាតិ និង គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើស តំណាងរាស្ត្រ ឬ
- សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ
- សមាជិកព្រឹទ្ធសភា
- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ[20] ។

**ខ. ពិធីបើកសម័យប្រជុំដំបូង**

បន្ទាប់ពីប្រជាពលរដ្ឋបានបោះឆ្នោតគាំទ្រ បេក្ខជនជាប់ឆ្នោតទាំងអស់នៅពេលបើកសម័យ ប្រជុំលើកទីមួយនៃនីតិកាលនីមួយៗរដ្ឋសភាត្រូវចាប់ដំណើរការ ក្រោមអធិបតីភាពនៃប្រធាន បណ្តោះអាសន្នមួយរូប ដែលជាបេក្ខជនជាប់ឆ្នោតមានអាយុច្រើនជាងគេ ហើយដែលឥតមានគេ ប្តឹងតវ៉ា ហើយមានសមាជិកប្រាំរូបដែលជាបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រដែលមានអាយុតិច ជាងគេ ហើយដែលឥតមានគេប្តឹងតវ៉ាដើម្បីឱ្យធ្វើជាលេខាធិការដើម្បីជួយប្រធានក្នុងការងារ ។

ការបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ ក្នុងរយៈពេល៦០ថ្ងៃយ៉ាងយូរ ក្រោយពេល បោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។

ប្រធានរដ្ឋសភានៃនីតិកាលចាស់ ជាអ្នកលើកសំណើថ្វាយព្រះមហាក្សត្រដើម្បីទ្រង់ប្រទាន ការកោះប្រជុំសម័យប្រជុំដំបូងរបស់រដ្ឋសភានៃនីតិកាលថ្មី ។

សម័យប្រជុំដំបូងនៃនីតិកាលនីមួយៗរបស់រដ្ឋសភាត្រូវចាប់ដំណើរការ :

**ខ.១ ករណីធម្មតា**

ក្រោមអធិបតីភាព និង ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិកនៃរដ្ឋសភា ដែលជាប្រធាន ការិយាល័យបណ្តោះអាសន្ន ។ ប្រសិនបើមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភា ទាំងមូល ត្រូវធ្វើតាមរបៀបវារៈដូចតទៅ :

[20] មាត្រា ៣៣ ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ប្រកាសឲ្យប្រើថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧

- ប្រកាសឈ្មោះសមាជិករដ្ឋសភាពេញសិទ្ធិ
- ប្រកាសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ
- បោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា រវាងប្រធាន និងអនុប្រធានទាំងពីររបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាត ( ៥០%+១ ) នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ សមាជិករដ្ឋសភាទាំងអស់មិនអាចជជែកពិភាក្សាអ្វីឡើយ នៅក្រោមអធិបតីភាពព្រឹទ្ធសមាជិក ។

តំណាងរាស្ត្រទាំងអស់ ត្រូវតែធ្វើសច្ចាប្រណិធានមុនពេលចូលកាន់មុខតំណែង ក្រោមការដឹកនាំរបស់ប្រធាន និងអនុប្រធានទាំងពីរនៃរដ្ឋសភា ដូចដែលមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣[21] ។

**ខ.២ ករណីពិសេស**

ករណីដែលស្ថានភាពនយោបាយតម្រូវឱ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែម ដែលសំដៅធានាដល់ដំណើរការប្រព្រឹត្តិទៅជាប្រក្រតីនៃស្ថាប័នជាតិ ។

ក្រោមអធិបតីភាព និង ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិកនៃរដ្ឋសភា ដែលជាប្រធានការិយាល័យបណ្តោះអាសន្ន ។ ប្រសិនបើមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូលត្រូវធ្វើតាមរបៀបវារៈដូចតទៅ:

- ប្រកាសឈ្មោះសមាជិករដ្ឋសភាពេញសិទ្ធិ
- ប្រកាសសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ
- បោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានទាំងពីរនៃរដ្ឋសភា និងប្រធាន អនុប្រធាន គណៈកម្មការជំនាញទាំងអស់របស់រដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលនៅដើមនីតិកាលនីមួយៗ ដោយវិធីលើកដៃ ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិករដ្ឋសភាមិនអាចជជែក ឬពិភាក្សាអ្វីឡើយ នៅក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិក ។ តំណាងរាស្ត្រទាំងអស់ត្រូវតែធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែង ក្រោមការដឹកនាំរបស់ប្រធាន និងអនុប្រធានទាំងពីរនៃរដ្ឋសភាដូចមានខ្លឹមសារដែលចែងក្នុងឧបសម្ព័ន្ធទី៥នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣[22] ។

## កថាខណ្ឌទី ៣ ការបង្កើតរដ្ឋសភាកម្ពុជានីតិកាលទី៥

[21] ឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ។

[22] ប្រការពីរថ្មី បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ ។

**១. ស្ថានភាពទូទៅបន្ទាប់ពីការបោះឆ្នោត**

ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៥ បានប្រព្រឹត្តិទៅនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ដោយមានការចូលរួមពីគណបក្សចំនួន៨។ ជាលទ្ធផលក្រោយការបោះឆ្នោតបានបញ្ចប់ ទៅមានគណបក្សតែពីរប៉ុណ្ណោះដែលទទួលបានអាសនៈក្នុងសភា ដោយយោងតាមការប្រកាសលទ្ធផលនៃការបោះឆ្នោតរបស់គណៈកម្មាធិការរៀបចំការបោះឆ្នោត គណបក្សប្រជាជនទទួលបាន ៦៨អាសនៈ គណបក្សសង្គ្រោះជាតិទទួលបាន៥៥អាសនៈ។ ទោះបីជាយ៉ាងនេះក្តី គេសង្កេតឃើញថាស្ថានភាពទាំង មុនពេលបោះឆ្នោត និងក្រោយបោះឆ្នោតគឺមានសភាពតានតឹង ដោយមានការប្រឈមមុខដាក់គ្នារវាង គណបក្សទទួលបានអាសនៈទាំងពីរនេះ។ គណបក្សសង្គ្រោះជាតិបានប្រកាសក្នុងសន្និសីទកាសែតមួយ កាលពីព្រឹកថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៣ នៅទីស្នាក់ការគណបក្សរបស់ខ្លួន ដោយច្រានចោលនូវលទ្ធផលបោះឆ្នោតនោះ ។ លទ្ធផលបឋមដែលទទួលបាន គឺគណបក្សប្រជាជនកម្ពុជាទទួលបាន ៦៨ អាសនៈ និងគណបក្សសង្គ្រោះជាតិទទួលបាន ៥៥ អាសនៈ ក្នុងអាសនៈសរុបចំនួន ១២៣ នៅក្នុងរដ្ឋសភានីតិកាលទី៥ ។

បន្ទាប់ពីមានការប្រកាសលទ្ធផលជាបឋមនៃការបោះឆ្នោត កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣ លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិបានប្រកាសមិនទទួលស្គាល់លទ្ធផលបោះឆ្នោតបឋមនេះឡើយ ដោយលោកយល់ថា មានភាពមិនប្រក្រតីច្រើនជុំវិញការបោះឆ្នោត ។ លោក សម រង្ស៊ី បានអះអាងបន្ថែមទៀតថា មានឈ្មោះប្រមាណជាង១លាន២សែនឈ្មោះ គឺត្រូវបានគេលុបចោលក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងមានឈ្មោះស្ទួនប្រមាណជាង២សែននាក់ ។ ជាងនេះទៅទៀត លោកបានបន្ថែមថា នៅមានភាពមិនប្រក្រតីផ្សេងទៀត ដោយលោកបានពន្យល់ថា ការតវ៉ានេះមិនមែនជាហេតុផលចង់បានអំណាចនៅក្នុងជួររដ្ឋាភិបាលនោះទេ ។

ទាក់ទងទៅនឹងការមិនទទួលស្គាល់លទ្ធផល ប្រធានគណបក្សរូបនេះ បានផ្ញើលិខិតមួយនៅក្នុងថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៣ ជូនទៅរដ្ឋាភិបាលដើម្បីស្នើរសុំឱ្យមានការពិនិត្យឡើងវិញតាមចំណុចមួយចំនួន ។ ដោយក្នុងនោះ លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ បានអះអាងថា ជាការមិនទទួលស្គាល់តែមានផ្តល់ជាដំណោះស្រាយដោយចង់ឱ្យមានបង្កើត គណៈកម្មាធិការចម្រុះដែលមានដូចជា គណៈកម្មាធិការជាតិ អន្តរជាតិ និងភាគីទាំងពីរ ព្រមទាំង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហៅកាត់ថា គ.ជ.ប។

ទន្ទឹមនឹងការមិនទទួលស្គាល់ លទ្ធផលជាបឋមខាងលើនេះ គណបក្សសង្គ្រោះជាតិក៏បានប្រកាសថានឹងមិនបោះបង់ចោលនូវអាសនៈក្នុងរដ្ឋសភាដែលគណបក្សខ្លួនទទួលបានឡើយ ។

ជាថ្មីម្តងទៀត នៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៣ ប្រធានគណបក្សសង្គ្រោះជាតិបាន ប្រកាសថា តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិនឹងមិនចូលរួមប្រជុំសភានៅថ្ងៃដំបូងជាដាច់ខាត ប្រសិនបើពុំមានដំណោះស្រាយណាមួយឱ្យបានសមស្រប ទាក់ទងនឹងការលួចបន្លំសន្លឹកឆ្នោត នៅក្នុងការបោះឆ្នោតនីតិកាលទី៥ ។ ប្រធានគណបក្សប្រឆាំងរូបនេះ បានបញ្ជាក់យ៉ាងដូច្នេះ នៅក្នុងបណ្តាញសង្គមហ្វេសប៊ុករបស់ខ្លួន ។ លោក សម រង្ស៊ី បានបញ្ជាក់ទៀតថា យើងនឹងរួមគ្នាក្រោកឡើងទាមទារឱ្យមានការផ្លាស់ប្តូរជាដាច់ខាតនៅក្នុងឆ្នាំ ២០១៣ នេះ ។

ថ្លែងទៅកាន់ពលរដ្ឋដែលមានទំនាស់ដីធ្លីនៅបឹងកក់ នៅថ្ងៃដដែលនោះលោក សម រង្ស៊ី នៅតែទាត់ចោលលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន ហើយអំពាវនាវឱ្យអង្គការអន្តរជាតិចូលអន្តរាគមន៍ធ្វើជាអាជ្ញាកណ្តាលសម្រាប់ការដោះស្រាយភាពមិនប្រក្រតី ដែលបក្សប្រឆាំងចោទថាបានបង្កឡើងដោយគណបក្សកាន់អំណាច និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប៉ុន្តែការគំរាមមិនចូលប្រជុំសភារបស់គណបក្សប្រឆាំង មិនបានធ្វើឱ្យគណបក្សកាន់អំណាចព្រួយបារម្ភនោះទេ ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់យ៉ាងច្បាស់លាស់ថា បើទោះបីជាគណបក្សប្រឆាំងមិនចូលរួមក៏ដោយ ក៏គណបក្សប្រជាជនកម្ពុជានៅតែអាចដំណើរការរដ្ឋសភាសម្រាប់នីតិកាលថ្មីបានដដែល ។ សម្រាប់គណបក្សកាន់អំណាច ការមិនចូលរួមរបស់គណបក្សប្រឆាំង មានន័យស្មើនឹងការបោះបង់អាសនៈសភាចោល ហើយពេលនោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងធ្វើការបែងចែកអាសនៈទាំងនោះឱ្យទៅគណបក្សនយោបាយផ្សេងៗទៀត[23] ។

### ២ ការបង្កើតរដ្ឋសភានីតិកាលទី ៥

#### ក. ការកោះអញ្ជើញប្រជុំរបស់អង្គព្រះមហាក្សត្រដល់គណបក្សជាប់ឆ្នោត

ក្រោយការប្រកាសលទ្ធផលផ្លូវការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលស្ថាប័ននេះ បានចេញសេចក្តីសម្រេចលេខ ៩១៤/១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ដែលប្រព្រឹត្តិទៅនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣ រួចមក បើទោះបីជាមានការជំទាស់ និងតវ៉ាប្រឆាំងពីសំណាក់គណបក្សប្រឆាំងដែលមានសម្លេងតិចក្នុងសភាក្តី ព្រះមហាក្សត្រកោះហៅអ្នកតំណាងរាស្ត្រទាំងអស់ស្របតាមមាត្រា៨២ថ្មី កថាខណ្ឌ១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណា

[23] ដកស្រង់ចេញពីវិទ្យុបារាំងអន្តរជាតិ(RFI): គណបក្សសង្គ្រោះជាតិមិនទទួលស្គាល់លទ្ធផល តែមិនបោះបង់អាសនៈក្នុងសភាទេ ចេញផ្សាយថ្ងៃទី ២៩/០៧/២០១៣ ដោយ ជា ប៊ុនធឿន ។

ចក្រកម្ពុជាដែលចែងថា រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមរយៈការអញ្ជើញរបស់ព្រះមហាក្សត្រ ។

នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៣ នៅព្រះបរមរាជវាំង ព្រះមហាក្សត្របានប្រគល់ជូន ព្រះរាជសារកោះប្រជុំដល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ចំនួន៦៨ និង ចំពោះ ឯកឧត្តម សម រង្ស៊ី ចំនួន ៥៥ ដើម្បីប្រគល់ឱ្យអ្នកតំណាងរាស្ត្រជាប់ឆ្នោតនៃគណបក្សរៀងៗខ្លួន ចូលរួមសម័យប្រជុំលើកដំបូងនៃរដ្ឋសភានីតិកាលទី៥ នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣ ។

គួរគូសបញ្ជាក់ថា ការប្រគល់នូវព្រះរាជលិខិតកោះប្រជុំនេះ គឺធ្វើឡើងនៅកាលបរិច្ឆេទតែមួយនៃវេលាដែលតំណាងគណបក្សជាប់ឆ្នោតទាំងពីរ ត្រូវបានព្រះមហាក្សត្រកោះប្រជុំដើម្បីដោះស្រាយបញ្ហាជាតិតែម្តង ។

**ខ. ការបើកកិច្ចប្រជុំលើកដំបូងរបស់រដ្ឋសភានីតិកាលទី៥**

នៅព្រឹកថ្ងៃច័ន្ទ ទី២៣ ខែកញ្ញា ឆ្នាំ២០១៣ សម័យប្រជុំនៃរដ្ឋសភាជាលើកដំបូងបានចាប់ផ្តើមតាមការគ្រោងទុក ដោយមានតំណាងរាស្ត្រទាំង ៦៨ រូប មកពីគណបក្សកាន់អំណាចចូលរួម តែមិនមានវត្តមានរបស់តំណាងរាស្ត្រគណបក្សប្រឆាំងនោះទេ។ ព្រះមហាក្សត្រ ព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនីទ្រង់បានយាងមកដល់រដ្ឋសភានៅវេលាម៉ោង៨នឹង២០នាទីព្រឹក ដើម្បីគង់ជាព្រះរាជាធិបតី ក្នុងសម័យប្រជុំជាប្រវត្តិសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងពិធីនោះ ក្រៅពីវត្តមានឥស្សរនយោបាយជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជាក៏មានការរួមពីមន្ត្រីឯកអគ្គរាជទូត និងឯកអគ្គរដ្ឋទូតប្រចាំកម្ពុជា មួយចំនួនដែលក្នុងនោះមានដូចជា ទូតអាមេរិក បារាំង អង់គ្លេស សហភាពអ៊ឺរ៉ុប និងចិន ព្រមទាំងតំណាងរាស្ត្រក្រៅរដ្ឋាភិបាលមួយចំនួនក៏ចូលរួមធ្វើជាភ្ញៀវកិត្តិយសក្នុងពិធីដ៏ឱឡារិកនេះដែរ។ ក្នុងឱកាសបើកសម័យប្រជុំសភាលើកដំបូងនេះ ព្រះមហាក្សត្រព្រះបាទសម្តេចនរោត្តម ព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់មានព្រះរាជបន្ទូលបញ្ជាក់ទៅកាន់តំណាងរាស្ត្រដែលចូលរួមទាំងអស់ថា សម័យប្រជុំដំបូងនៃរដ្ឋសភានីតិកាលទី៥នេះ ជាឱកាសថ្មីនៃប្រវត្តិសាស្ត្ររបស់ស្ថាប័ននីតិបញ្ញត្តិ។

ព្រះអង្គមានព្រះបន្ទូលថា ដើម្បីភារៈកិច្ចដ៏ឧត្តុងឧត្តមនេះ ប្រជាជាតិកម្ពុជាត្រូវមានឯកភាព និងមហាសាមគ្គីជាតិខ្ពស់បំផុត ដោយឈរលើមូលដ្ឋាននៃការអនុវត្តន៍គោលការណ៍លទ្ធិប្រជាធិបតេយ្យ និង នីតិរដ្ឋដែលបានអនុវត្តតាំងពីឆ្នាំ១៩៩៣មក។ ជាពិសេស ត្រូវសាងឱ្យមានយុត្តិធម៌សង្គមឱ្យកាន់តែមានកម្រិតកាន់តែខ្ពស់ជាលំដាប់។ ព្រះអង្គមានបន្ទូលបន្ថែម ដោយទ្រង់សង្ឃឹមថា

តំណាងរាស្រ្តទាំងអស់មានការប្រឹងប្រែង អស់ពីកម្លាំងចិត្តកាយ ប្រមូលផ្តុំរបស់ខ្លួន ក្រោមការដឹកនាំប្រជុំរបស់លោកហេង សំរិន។

នៅក្នុងសម័យប្រជុំនេះហើយ ដែលលោកហេង សំរិន ព្រឹទ្ធសមាជិករដ្ឋសភា បានប្រកាសនូវបញ្ជីរាយនាមបេក្ខជនជាប់ឆ្នោតជាតំណាងរាស្រ្តនីតិកាលទី៥ តាមលំដាប់ពីអាយុខ្ពស់មកទាបទាំង១២៣រូប ខណៈដែលមិនមានវត្តមានតំណាងរាស្រ្តជាប់ឆ្នោតទាំង៥៥រូប របស់គណបក្សសង្រ្គោះជាតិចូលរួម ។

ក្រោយការប្រកាសឈ្មោះអ្នកតំណាងរាស្រ្តជាប់ឆ្នោតទាំងអស់ លោក ហេង សំរិន បានស្នើរអង្គប្រជុំដែលមានតែតំណាងរាស្រ្តគណបក្សប្រជាជន អនុម័តបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ក្រោយពីការប្រកាសសម្រេចផ្តល់សុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។

ដោយឡែក ស្របពេលនឹងតំណាងរាស្រ្តទាំង៦៨រូបរបស់គណបក្សប្រជាជនបានកំពុងចូលរួមក្នុងពីធីបើកសម័យប្រជុំដំបូងនៅភ្នំពេញ តំណាងរាស្រ្តគណបក្សសង្រ្គោះជាតិទាំងអស់ បានកំពុងស្នាក់នៅឯខេត្តសៀមរាប និងមានគម្រោងវិលត្រឡប់មករាជធានីភ្នំពេញ ក្រោយការប្រជុំសភាដំបូង។ បើតាម លោក យឹម សុវណ្ណ បើទោះបីជាតំណាងរាស្រ្តបក្សសង្រ្គោះជាតិទាំងអស់បានធ្វើពិធីសច្ចាប្រណិធាន នៅមុខប្រាសាទអង្គរវត្តរួចហើយក៏ដោយ ក៏សមាជិកតំណាងរាស្រ្តទាំងអស់នោះ នៅបន្តជួបប្រជុំគ្នានៅទីរួមខេត្តសៀមរាបដដែល ដើម្បីពិភាក្សាការងារកំណែទម្រង់ជាតិសំខាន់ៗ។ លោក យឹម សុវណ្ណ បញ្ជាក់ថា តំណាងរាស្រ្តគណបក្សសង្រ្គោះជាតិទាំងអស់មិនផ្លាស់ប្តូរជំហាររបស់ខ្លួន ក្នុងការមិនចូលរួមប្រជុំសភាលើកដំបូងនោះទេ ។

តែបន្ទាប់ពីពួកគេធ្វើពិធីសច្ចាប្រណិធាន នៅមួយឆ្នាំក្រោយមកពោល គឺនៅចុងឆ្នាំ២០១៤ តំណាងរាស្រ្តគណបក្សសង្រ្គោះជាតិ ដឹកនាំ ដោយ សម រង្ស៊ី និង លោក កឹម សុខា បាននាំគ្នាចូលទៅកាន់ដំបូលរដ្ឋសភា កាន់តួនាទីរៀងៗខ្លួន ដោយមិនមានការសាកសួរមតិម្ចាស់ឆ្នោត ហើយក៏មិននឹកដល់បារមី និង វត្ថុស័ក្តិសិទ្ធនៅតំបន់ប្រាសាទអង្គរដែលពួកគេបានសន្យា និង សច្ចាប្រណិធានជាមួយនោះឡើយ[24]។

**គ. សមាជិករដ្ឋសភានីតិកាលទី ៥**

[24] ដកស្រង់ចេញពីគេហទំព័រ http://www.freshnewsasia.com/index.php/en/26901-2016-06-18-15-05-45.html [ការបូងសួងរបស់ CNRP មិនស័ក្តិសិទ្ធឡើយ] ចេញផ្សាយថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦

រដ្ឋសភានីតិកាលទី៥ កើតចេញពីការបោះឆ្នោតសកល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ តាមប្រព័ន្ធសមាមាត្រ មាន២៤មណ្ឌល រាជធានី-ខេត្ត មានគណបក្សនយោបាយចំនួន៨ចូលរួម។ ប្រជាពលរដ្ឋបានចុះឈ្មោះបោះឆ្នោតចំនួន ៩.៦៧៥.៤៥៣នាក់ ប្រជាជនបានទៅបោះឆ្នោតចំនួន ៦.៧៣៥.២៤៤នាក់ ស្មើនឹង ៦៩,៦១%។

អាសនៈដែលទទួលបានៈ គណបក្សប្រជាជនកម្ពុជា ៦៨ អាសនៈ ស្មើនឹង៥៥,២៨% គណបក្សសង្គ្រោះជាតិ ៥៥ អាសនៈ ស្មើនឹង៤៤,៧១% ។ តំណាងរាស្ត្រសរុបចំនួន១២៣រូប ក្នុងនោះ តំណាងរាស្ត្រស្ត្រី ២៥ រូប ស្មើនឹង ២០,៣២% តំណាងរាស្ត្រជនជាតិភាគតិចចំនួន២រូប ក្រុមស្ត្រីសមាជិករដ្ឋសភាត្រូវបានបង្កើត។

រដ្ឋសភាបានប្រជុំក្រោមអធិបតីភាព សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ព្រឹទ្ធសមាជិករដ្ឋសភា ដើម្បីបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញ និងផ្តល់សេចក្តីទុកចិត្តរាជរដ្ឋាភិបាល នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣[25]។

## ផ្នែកទី៣ សាវតានៃការកកើតរដ្ឋសភានៅជប៉ុន

### កថាខណ្ឌទី១ ប្រវត្តិនៃការកកើត

ប្រទេសជប៉ុន ស្ថិតនៅចុងបូព៌ាតាមឆ្នេរសមុទ្រនៃទ្វីបអាស៊ី ហើយមាន កោះធំតូចជាងមួយពាន់។ ក្នុងចំនោមនោះមានកោះធំៗបួន ដូចជា កោះហុកកៃដូ ហុងស៊ូ ស៊ីកូគូ និង គ្យូស៊ូ។

មិនខុសពីប្រទេសកម្ពុជាទេ ប្រទេសជប៉ុនក៏មានការផ្លាស់ប្តូរនូវរបបនៃការកាន់កាប់អំណាចពីសម័យកាលមួយទៅសម័យកាលមួយទៀតដែរ។ យោងទៅតាមប្រវត្តិសាស្ត្ររបស់ប្រទេសនេះ មានការបែងចែកប្រទេសជាសម័យកាល ដែលមានសម័យបុរាណ ចុងសម័យបុរាណ យុគសម័យកណ្តាលដែលរួមមាន សម័យកាម៉ាគុរ៉ា សម័យមុរ៉ូម៉ាឈិ ឬសម័យសង្គ្រាមក្នុងប្រទេស រហូតឈានដល់សម័យទំនើបហៅថាសម័យ អេដុ ហើយក៏ឈានដល់សម័យបច្ចុប្បន្ន ដែលរួមមានសម័យម៉េជិ និងសម័យថៃស្យូ ស្យូវ៉ា។

នៅសម័យបុរាណ អំណាចគ្រប់គ្រងរដ្ឋ គឺប្រមូលក្នុងកណ្តាប់ដៃព្រះចៅអធិរាជដែលនៅពេលនោះប្រទេសជប៉ុនបានធ្វើការដឹកនាំប្រទេសតាមរបៀបអធិរាជចិន ប៉ុន្តែនៅចុងសម័យបុរាណ របបអធិរាជត្រូវបានផ្តួលរលំដោយអ្នកចម្បាំងសាមុរ៉ៃ ដែលដឹកនាំដោយពួកមេទ័ពប្រឆាំងគ្នាឥតឈប់ឈរ រហូតមកដល់យុគសម័យកណ្តាល ដែលនៅពេលនោះហើយដែលរបបសក្តិភូមិបានកើត

[25] www.national-assembly.org.kh , ចូលមើលលើកចុងក្រោយៈ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៦ សូមមើលឧបសម្ព័ន្ធជាភាសាខ្មែរ ឧបសម្ព័ន្ធ២ បញ្ជីរាយនាមតំណាងរាស្ត្រនីតិកាលទី៥

ឡើង ហើយប្រទេសជប៉ុនត្រូវបានគ្រប់គ្រងដោយប្រព័ន្ធសក្តិភូមិរហូតឈានដល់សម័យម៉េជិ ទើបរបបមួយនេះត្រូវបានលុបបំបាត់ចោល ហើយក៏បានប្រកាន់យករបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនៅឆ្នាំ១៨៨៩ ហើយនៅក្នុងឆ្នាំ១៨៩០ ការបោះឆ្នោតជាលើកដំបូងបានចាប់ផ្តើម ពេលនោះហើយដែលសភាអាណាចក្រ បានបង្កើតឡើងជាលើកដំបូង ក្នុងរបត់ប្រវត្តិសាស្ត្រថ្មីរបស់ជប៉ុន។

## ១. សាវតានៃការបង្កើតរដ្ឋសភា(សភាអាណាចក្រ)នៅសម័យម៉េជិ

បន្ទាប់ពីរដ្ឋាភិបាលសម័យអេដុបានដួលរលំ ជប៉ុនបានរៀបចំប្រទេសឡើងវិញដែលមានឈ្មោះថាសករាជពន្លឺ ឬសម័យម៉េជិ ហើយនៅឆ្នាំ១៨៦៨រដ្ឋាភិបាលថ្មីមួយ គឺរដ្ឋាភិបាលម៉េជិត្រូវបានបង្កើតឡើងដោយយកអធិរាជជាធំវិញ ក្នុងរាជ្យព្រះចៅមូជីហ៊ីតុ។ រដ្ឋាភិបាលថ្មីនេះ បានតាំងទីនៅទីក្រុងតូក្យូហើយចាប់ផ្តើមកសាងរដ្ឋទំនើបឡើង។ តាមកំណែទម្រង់ថ្មី រដ្ឋាភិបាលម៉េជិ បានបដិសេធចោលប្រព័ន្ធសក្តិភូមិនៃសម័យអេដុ ហើយដាក់គោលដៅគ្រប់គ្រងជាតិដោយប្រកាន់អំណាចកណ្តាល[26]។ ជាងនេះទៅទៀតបានធ្វើការលុបបំបាត់ចោលនូវការបែងចែកវណ្ណៈ ហើយក៏បានអនុវត្តន៍ពាក្យស្លោកនៃដើមសម័យម៉េជិ សំដៅលុបបំបាត់ចោលនូវវណ្ណៈទាំងបួនក្នុងសម័យអេដុដែលមានដូចជា វណ្ណៈអ្នកចំបាំង កសិករ កម្មករ និង អ្នកជំនួញ។ ពលរដ្ឋទូទៅត្រូវមានកាតព្វកិច្ចបំរើយោធា ហើយបំពេញកាតព្វកិច្ចដូចគ្នាទាំងអស់ ។ ជាងនេះទៀតបានកែលំអរនូវសន្ធិសញ្ញាដែលគ្មានសមភាពរវាងបណ្តាប្រទេសផ្សេងៗ នៅអ៊ឺរ៉ុប និង អាមេរិក ហើយថែមទាំងបានធ្វើការប្រឆាំងតបតទៅនឹងបណ្តាប្រទេសនៅអ៊ឺរ៉ុបទាំងនោះ។ ការធ្វើវិសោធនកម្មសន្ធិសញ្ញានេះគឺក្នុងគោលបំណងបង្កើនធនធានក្នុងប្រទេស បង្កើតកំលាំងយោធា និងការធ្វើឱ្យអំណាចរបស់ប្រទេសកាន់តែរឹងមាំ ព្រមទាំងបើកចំហ អរិយធម៌ និងអភិវឌ្ឍសង្គម ទទួលវប្បធម៌អ៊ឺរ៉ុប ទំនើបភាវូបនីយកម្មពាណិជ្ជកម្មតាមបែបបញ្ចិមប្រទេស។ រដ្ឋាភិបាលម៉េជិ បានបង្កើតរដ្ឋាភិបាលបក្ខសម្ព័ន្ធឡើង ព្រមទាំងបានបង្កើតរដ្ឋធម្មនុញ្ញដំបូង និងសភាឡើង។ នៅពេលនោះដែរ មានចលនាបះបោរមួយបានកើតឡើងរីករាលដាលទូទាំងប្រទេស ដែលចលនានេះជាចលនាទាមទារសិទ្ធិសេរីភាពពលរដ្ឋប្រឆាំងនឹងរដ្ឋាភិបាលបក្សសម្ព័ន្ធ។ ប្រជាជនជប៉ុនបាននាំគ្នាធ្វើការទាមទារឱ្យមានសភាដែលកើតចេញពីការបោះឆ្នោតរបស់ប្រជាជន។ រដ្ឋាភិបាលបានយល់ព្រមទទួលស្គាល់ការបង្កើតរដ្ឋធម្មនុញ្ញ

[26]名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（２０１１年２月）、４７－４８頁。
មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រវត្តិសាស្ត្រ និង ពលរដ្ឋវិទ្យាដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ) (ខែកុម្ភៈ ឆ្នាំ ២០១១)ទំព័រ៤៧ ដល់ ៤៨

ព្រមទាំងបានបង្កើតសភា និងគណបក្សនយោបាយ ហើយក៏បានធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញឡើង។ នាពេលនោះដែរ ជប៉ុនបានប្រកាន់យករបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដោយនៅឆ្នាំ១៨៨៩ រដ្ឋធម្មនុញ្ញមហាអាណាចក្រជប៉ុន[27] ឬមហាចក្រពត្តិជប៉ុន ត្រូវបានប្រកាសឱ្យប្រើ។ រដ្ឋធម្មនុញ្ញនេះ បង្កើតឡើងដោយទទួលឥទ្ធិពលពីទ្រឹស្តីរដ្ឋធម្មនុញ្ញរបស់ប្រទេសអាឡឺម៉ង់ ដែលបានចែងផ្តល់អំណាចយ៉ាងខ្លាំងដល់ព្រះចៅអធិរាជ និងរដ្ឋាភិបាល ។ តាមរយៈការប្រកាន់យករបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនេះ គឺព្រះមហាក្សត្រត្រូវបានរដ្ឋធម្មនុញ្ញកំណត់ពីសិទ្ធិរបស់ទ្រង់ ឯអ្នកមានអំណាចពិតប្រាកដគឺសភា។

នៅឆ្នាំ១៨៨៩នេះដែរ ទន្ទឹមនឹងរដ្ឋធម្មនុញ្ញបានបង្កើតឡើង ក៏មានការអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ក៏ប៉ុន្តែមានតែ មនុស្សប្រុសដែលមានអាយុចាប់ពី២៥ឆ្នាំ និងអ្នកដែលមានលទ្ធភាពបង់ពន្ធខ្ពស់តែ ប៉ុណ្ណោះទើបអាចចូលរួមក្នុងការបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត។ ទីបំផុតនៅក្នុងឆ្នាំ១៨៩០ ការបោះឆ្នោតជាលើកដំបូងបានចាប់ផ្តើម ពេលនោះហើយដែលសភាអាណាចក្របានបង្កើតឡើងជាលើកដំបូង។

### ២. សាវតានៃការបង្កើតរដ្ឋសភានៅសម័យបច្ចុប្បន្ន

ចាប់ពីឆ្នាំ១៨៦៨ក្នុងសម័យម៉េជិ ឬ សករាជពន្លឺមក ប្រទេសនេះបានខិតខំកសាងឧស្សាហកម្មមូលដ្ឋាន និង ទទួលការវិនិយោគពីបរទេស ។ បន្តរហូតមកដល់ឆ្នាំ១៩១៤ នៅអ៊ឺរ៉ុបមានការកកើតឡើងនូវសង្គ្រាមលោកលើកទីមួយ រហូតដល់ឆ្នាំ១៩១៨ ទើបបញ្ចប់[28]។ ដើម្បីធ្វើការប្រមូលផ្តុំអំណាចរបស់ប្រទេសក្នុង សម័យសង្គ្រាមលោកលើកទី១ នៅអ៊ឺរ៉ុបមានការកេណ្ឌកម្លាំងទ័ព និងប្រើប្រាស់រាល់អ្វីៗដែលមាន នៅក្នុងប្រទេសទាំងស្រុង ដោយសារតែហេតុនេះហើយ ទើបធ្វើឱ្យពួកបណ្តាប្រទេសនានា នៅអ៊ឺរ៉ុបបានចាប់ផ្តើមយល់ដឹងអំពីលទ្ធិប្រជាធិបតេយ្យ ហើយការធ្វើការទាមទារឱ្យមានលទ្ធិមួយនេះគឺមានកាន់តែច្រើនឡើងៗ។ ដោយសារតែឥទ្ធិពលនេះ នៅប្រទេសជប៉ុនឯណោះវិញ ក៏មានសកម្មភាពទាមទារឱ្យមានការបោះឆ្នោតដោយសេរី និងបញ្ឈប់ឱ្យមានការបែងចែកវណ្ណៈឬទ្រព្យសម្បត្តិ។ ជាលទ្ធផលនៅឆ្នាំ១៩២៥ ជប៉ុនបានបង្កើតច្បាប់បោះឆ្នោតជាសកលដោយឱ្យបុរសដែលមានអាយុចាប់ពី២៥ឆ្នាំឡើងទៅទើបមានសិទ្ធិបោះឆ្នោត។ ទ្រឹស្តី និងចលនាសង្គមនាពេលនោះ ត្រូវបានគេឱ្យឈ្មោះថា ជាលទ្ធិប្រជាធិបតេយ្យថៃស្យូ ជាគោលគំនិត ឬចលនា

[27] 日本帝国憲法

[28] 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（２０１１年２月）、６０－６１頁。
មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា『ប្រវត្តិសាស្ត្រ និង ពលរដ្ឋវិទ្យាដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ) (ខែកុម្ភៈ ឆ្នាំ ២០១១), ទំព័រ៦០ ដល់ ៦១

បែបលទ្ធិប្រជាធិបតេយ្យនិយម និងសេរីនិយមដែលមានប្រជាប្រិយក្នុងសម័យនោះ។ ប៉ុន្តែការបោះឆ្នោតដោយសេរីនេះ បានជះឥទ្ធិពលដល់ចលនា សង្គមនិយម ទន្ទឹមនឹងច្បាប់ស្តីពីការថែរក្សាសន្តិសុខ ជាច្បាប់ដែលមានគោលដៅប្រឆាំង ប្រព័ន្ធកម្មសិទ្ធិឯកជន និងការផ្លាស់ប្តូរគោលនយោបាយជាតិក៏បានអនុម័តនៅពេលព្រមគ្នានោះផងដែរ។

នៅឆ្នាំ១៨៩៤ សង្គ្រាមរវាងចិន និងជប៉ុនបានកើតឡើង[29]។ ជប៉ុនបានយកជ័យជំនះ លើចិន ហើយបានត្រួតត្រាកោះតៃវ៉ាន់ដោយដាក់កោះតៃវ៉ាន់ជាអាណានិគមរបស់ខ្លួនថែមទៀតផង។ ជាងនេះទៅទៀត ប្រទេសរុស្ស៊ីបានសំលឹងដាក់គោលដៅចេញពីអាស៊ីខាងកើត ហើយធ្វើការកាន់កាប់តំបន់ឥសានប្រទេសចិន ( តំបន់ម៉ាន់ចូវ ) ដែលទាំងជប៉ុន និង រុស្ស៊ីបានដណ្តើមកាន់កាប់ប្រទេសកូរ៉េ និង ម៉ាន់ចូវ ទើបធ្វើឱ្យសង្គ្រាមរវាងប្រទេសទាំងពីរផ្ទុះឡើងនៅឆ្នាំ១៩០៤។ ជប៉ុនបាន យកជ័យជំនះលើរុស្ស៊ី ហើយនៅឆ្នាំ១៩១០បានដាក់អាណានិគមលើប្រទេសកូរ៉េ។ រុស្ស៊ីបានប្រគល់តំបន់ម៉ាន់ចូវទៅឱ្យជប៉ុន ដែលនេះជាចំនុចចាប់ផ្តើមក្នុងការតម្រង់ទិសទៅ លើតំបន់ម៉ាន់ចូវ។ នៅពេលនោះ ប្រទេសជប៉ុនចាប់ផ្តើមអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសក៏ពិតមែន ប៉ុន្តែនៅក្រៅប្រទេសវិញ ជប៉ុនបានក្លាយជាប្រទេសចក្រពត្តិនិយម ដែលជាគោលនយោបាយនៃការបង្កើតប្រទេសមហាអំណាច ដោយការយកការច្បាំង ដណ្តើមគ្រប់គ្រងប្រទេសដ៏ទៃខាងផ្នែកយោធា និងសេដ្ឋកិច្ច។ ដើម្បីទ្រទ្រង់នូវចលនាថ្មីរបស់ពិភពលោក វិធានការណ៍វ៉ាស៊ីនតោនដែលបានផ្តួចផ្តើមបង្កើតឡើងដោយអាមេរិក ជាវិធានការណ៍អន្តរជាតិរបស់អាស៊ី និងតំបន់ប៉ាស៊ីហ្វិក ដែលមានគោលដៅទប់ស្កាត់សង្គ្រាម និងសហប្រតិបត្តិការចក្រពត្តិនិយម ហើយប្រទេសជប៉ុនក៏បានចូលរួមក្នុងវិធានការណ៍នេះដែរ ។ បន្ទាប់មក ជប៉ុនក៏ចាប់ផ្តើមធ្វើកិច្ចសហប្រតិបត្តិការជាមួយអាមេរិក និងបណ្តាប្រទេសផ្សេងៗទៀតនៅអ៊ឺរ៉ុប តាមរយៈទំនាក់ទំនងការទូត។ តែផ្ទុយទៅវិញនៅឆ្នាំ១៩២៩ វិបត្តសេដ្ឋកិច្ចពិភពលោកបានផ្ទុះឡើង ហើយសេដ្ឋកិច្ចរបស់ប្រទេសជប៉ុនក៏ទទួលរងនូវផលប៉ះពាល់ដែរ ហើយធ្លាក់ទៅក្នុងស្ថានភាពធ្ងន់ធ្ងរ ទើបធ្វើឱ្យទំនាក់ទំនងការទូតបានបរាជ័យទៅវិញ ហើយកងទ័ពជើងគោកនៅ ម៉ាន់ចូវបានចាប់ផ្តើមបញ្ចេញសកម្មភាពយោធា។ នៅឆ្នាំ១៩៣១បានកើតឡើងនូវវិបត្តិនៅ ម៉ាន់ចូវ ទើបសង្គ្រាមរវាងចិន និង ជប៉ុនបានផ្ទុះឡើងទៀត ដែលជាសង្គ្រាមអូសបន្លាយទើបធ្វើឱ្យធនធានហិរញ្ញវត្ថុរបស់រដ្ឋធ្លាក់ចូលក្នុងស្ថានភាពអាក្រក់។ នៅឆ្នាំ១៩៣៨ រដ្ឋ

[29] 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（２０１１年２月）、６０－６１頁。
មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រវត្តិសាស្ត្រ និង ពលរដ្ឋវិទ្យា ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ) (ខែកុម្ភៈ ឆ្នាំ ២០១១)ទំព័រ៦០ ដល់ ៦១

បានបង្កើតច្បាប់ ដែលផ្តល់ឱ្យរដ្ឋមានសិទ្ធិអំណាចកេណ្ឌមនុស្ស និងទ្រព្យសម្បត្តិទាំងអស់របស់ប្រទេសមក ធ្វើសង្គ្រាម តែត្រូវបាននិរាករណ៍នៅឆ្នាំ១៩៤៦។

នៅឆ្នាំ១៩៣៩ សង្គ្រាមលោកលើកទី២បានផ្ទុះឡើង ។ នៅពេលនោះជប៉ុនជាដៃគូបក្សសម្ព័ន្ធរបស់អាដុលហ៊ីត្លែ។ ជាលទ្ធផល ដោយសារមានការប្រឆាំងពីសហរដ្ឋអាមេរិក នៅឆ្នាំ១៩៤១ សង្គ្រាមប៉ាស៊ីហ្វិកបានផ្ទុះឡើង។

បន្ទាប់ពីសង្គ្រាមផ្ទុះឡើងអស់រយៈពេល៤ឆ្នាំ មានសេចក្តីថ្លែងការណ៍ផតដាំដែលជាសេចក្តីថ្លែងការណ៍មួយស្នើរបង្គាប់ឱ្យជប៉ុនចុះចាញ់សង្គ្រាមដោយគ្មានលក្ខខណ្ឌ ដែលធ្វើឡើងដោយសហ.រដ្ឋអាមេរិក ចក្រភពអង់គ្លេស ប្រទេសចិននៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៤៥[30]។ ជប៉ុនបានធ្វើការចុះចាញ់ហើយធ្វើកំណែទម្រង់ការគ្រប់គ្រងផ្នែកនយោបាយ សេដ្ឋកិច្ច ការអប់រំក្រោមការគ្រប់គ្រងរបស់អាមេរិក(១៩៤៥ ដល់ ១៩៥២)។ កំណែទម្រង់ក្រោយសង្គ្រាមជាកំណែទម្រង់ធ្វើឱ្យមានប្រជាធិបតេយ្យ និង សេរីភាព ដែលត្រូវបានធ្វើឡើងដោយសភា និងរដ្ឋាភិបាលជប៉ុនក្រោមការគាបសង្កត់ពីទីបញ្ជាការដ្ឋានកណ្តាលរបស់ក្រុមប្រទេសសម្ព័ន្ធមិត្ត ហៅកាត់ថា GHQដែលពីមុនមានទីតាំងនៅតូក្យូ ប៉ុន្តែក្រោយមកក៏លែងមានទៅវិញទន្ទឹមគ្នានឹងសន្ធិសញ្ញាសន្តិភាពទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ។ អាមេរិកបានធ្វើការកែប្រែសង្គមជប៉ុនដោយការលុបបំបាត់កងទ័ព ធ្វើប្រជាធិបតេយ្យនីយកម្មជាដើមដូចជា ការរុះរើអ្នកមានប្រាក់ និងមានអំណាចគឺធ្វើ វិមជ្ឈការក្រុមសហគ្រាសខ្នាតធំ កំណែទម្រង់ដីកសិកម្ម ប្រជាធិបតេយ្យនីយកម្មការងារ និងធ្វើសេរីកម្មប្រព័ន្ធអប់រំ។ ជាមួយការបរាជ័យនៃសង្គ្រាមលោកលើកទី២ក្នុងឆ្នាំ១៩៤៥មក យើងឃើញថាប្រទេសជប៉ុនត្រូវស្ថិតក្រោមការកាន់កាប់របស់អាមេរិចហើយធ្លាក់ខ្លួនក្រ និង មានអតិផរណាទៀតផង។ ចំពោះបញ្ហានេះ ជប៉ុនសុខចិត្តទទួលយករបបគ្រប់គ្រងតាមបែបសភានិយម និង ការប្រមូលផ្តុំសេដ្ឋកិច្ច។ នៅពេលនោះសហ.រដ្ឋអាមេរិចបានអនុវត្តកំណែទម្រង់មួយចំនួនមានដូចជា កាត់ទោសឧក្រិដ្ឋជនសង្គ្រាម ប្រកាសប្រើរដ្ឋធម្មនុញ្ញមួយថ្មី រួមមានគោលការណ៍ស្តីពីសិទ្ធិមនុស្ស តាមបែបលទ្ធិប្រជាធិបតេយ្យ។

រដ្ឋធម្មនុញ្ញថ្មីមួយតាមបែបអាមេរិចត្រូវបានប្រកាសឡើងនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៤៦ ហើយអនុម័តនៅឆ្នាំ១៩៤៧ យោងទៅតាមរដ្ឋធម្មនុញ្ញថ្មី[31]នេះ ប្រទេសជប៉ុនជារដ្ឋប្រជាធិបតេយ្យអាស្រ័យសភា ឯព្រះចៅអធិរាជគ្រាន់តែជានិមិត្តរូបរបស់រដ្ឋ និងឯកភាពជាតិ ហើយប្រទេសជប៉ុន

[30]名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（２０１１年２月）、６０－６１頁。
មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រវត្តិសាស្ត្រ និង ពលរដ្ឋវិទ្យាដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ) (ខែកុម្ភៈ ឆ្នាំ ២០១១)ទំព័រ៦០ ដល់ ៦១

[31] 日本国憲法

បានក្លាយជាប្រទេសអធិបតេយ្យភាពប្រជាជន សន្តិភាពនិយម និងមានការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន។

គួរបញ្ជាក់ផងដែរថា នៅឆ្នាំ១៩៤៥ ជប៉ុនបានធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដែលមិនមែនមានតែបុរសទេដែលអាចមានសិទ្ធិចូលរួមបោះឆ្នោត និង ឈរឈ្មោះឱ្យគេបោះឆ្នោត តែបានអនុញ្ញាតឱ្យទាំងស្ត្រី និងបុរស ប៉ុន្តែមានការកម្រិតអាយុដោយអោយពលរដ្ឋទាំងប្រុសទាំងស្ត្រីដែលមានអាយុចាប់ពី២០ឆ្នាំឡើងទៅ អាចមានសិទ្ធិចូល រួមបោះឆ្នោត និងពលរដ្ឋដែលមានអាយុចាប់ពី២៥ឆ្នាំឡើងទៅអាចឈរឈ្មោះឱ្យគេបោះឆ្នោតបាន។ នៅពេលនោះហើយ ដែលការបោះឆ្នោតជាសកលដោយមានការចូលរួមទាំងបុរស និងស្ត្រីជាលើកដំបូងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៤៦។ ស្ត្រីបានចូលរួមបោះឆ្នោតជាលើកដំបូងក្នុងការជ្រើសរើសសមាជិកសភាលើកទី២២ ដែលជាលទ្ធផលនៅពេលនោះស្ត្រីដែលបានជាប់ជាតំណាងរាស្ត្រមានចំនួន៣៩នាក់។

ស្ថាប័នដែលមានអំណាចគ្រប់គ្រងកំពូល ជាតួនាទីរបស់រដ្ឋសភា ដែលត្រូវបានកំនត់ដោយមាត្រា៤១នៃរដ្ឋធម្មនុញ្ញជប៉ុនបច្ចុប្បន្ន។ សភារបស់ជប៉ុនរួមមានរដ្ឋសភាដែលជាសភាជាន់ទាប និងព្រឹទ្ធសភាជាសភាជាន់ខ្ពស់ ហើយទាំងសមាជិករដ្ឋសភា និងព្រឹទ្ធសភាគឺកើតចេញពីការបោះឆ្នោតដោយផ្ទាល់ ដែលជាប្រព័ន្ធបោះឆ្នោតមួយដែលអ្នកបោះឆ្នោតមានសិទ្ធិជ្រើសរើសដោយផ្ទាល់នូវសមាជិក ឬ មន្ត្រីរាជការជាដើម។

**កថាខណ្ឌទី២ ការបង្កើតរដ្ឋសភាជប៉ុននាពេលបច្ចុប្បន្ន**

រដ្ឋសភាឬសភាតំណាងរាស្ត្រគឺជាសភាជាន់ទាប និងជាស្ថាប័នកំពូលរបស់រដ្ឋ[32]។ រដ្ឋសភាត្រូវបានបង្កើតឡើងដោយសមាជិកសភាដែលតំណាងឱ្យប្រជាជនទូទាំងប្រទេស ហើយត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោត។ ចំនួនអាសនៈនៃសមាជិករដ្ឋសភាត្រូវកំណត់ដោយច្បាប់។[33]

**១. ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ**

ដើម្បីធ្វើការដឹកនាំនយោបាយក្នុងប្រទេសឱ្យបានត្រឹមត្រូវ ពិតប្រាកដណាស់ត្រូវតែធ្វើការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឱ្យបានត្រឹមត្រូវដែលអ្នកតំណាងរាស្ត្រនោះ ត្រូវកើតចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋតាមរយៈការបោះឆ្នោត[34]។ ប្រទេសជប៉ុននាពេលបច្ចុប្បន្ននេះ អនុវត្តនូវរបបបោះឆ្នោតដោយផ្ទាល់គឺទាំងការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។ សម័យ

[32] រដ្ឋធម្មនុញ្ញជប៉ុនមាត្រា៤១ ឆ្នាំ១៩៤៧

[33] រដ្ឋធម្មនុញ្ញជប៉ុនមាត្រា៤៣ ឆ្នាំ១៩៤៧

[34] 田中嘉彦『シリーズ憲法の論点⑥』「二院制」国立国会図書館調査及び立法考査局、２００５年、１６頁。
តាណាកាយ៉ូស៊ីហ៊ីកុ 『បញ្ហានៅក្នុងសេរីរដ្ឋធម្មនុញ្ញ⑥』「សភាពីរជាន់」ស្ថាប័នត្រួតពិនិត្យអង្គការនីតិបញ្ញត្តិ និងស្រាវជ្រាវបណ្ណាល័យសភាជាតិ, ឆ្នាំ២០០៥, ទំព័រ១៦

កាលក្រោយសង្គ្រាម ប្រព័ន្ធនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅជប៉ុនគឺត្រូវបានប្រព្រឹត្តិឡើង ដោយយោងទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅសម័យស្សូវ៉ាឆ្នាំទី២០ គឺបានធ្វើការកែប្រែប្រព័ន្ធបោះឆ្នោតដែលមានតំណាងរាស្ត្រពី៣ទៅ៥នាក់ ឈរឈ្មោះក្នុងមួយស្រុក ទៅជាប្រព័ន្ធបោះឆ្នោតដែលអនុញ្ញាតឱ្យមានតំណាងរាស្ត្រច្រើនក្នុងមួយស្រុក។

ប្រព័ន្ធដែលត្រូវបានផ្លាស់ប្តូរនេះ គឺត្រូវបានអនុវត្តតែមួយដងគត់នៅពេលមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅសម័យស្សូវ៉ាឆ្នាំទី២១ ដល់ឆ្នាំទី២២មានការទទូចទាមទារឱ្យធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសអ្នកតំណាងរាស្ត្រ ដោយជ្រើសយកការអនុវត្តប្រព័ន្ធបោះឆ្នោតដែលមានតំណាងរាស្ត្រពី៣ទៅ៥នាក់ឈរឈ្មោះក្នុងមួយស្រុកវិញ។ នៅទីបំផុតនៅឆ្នាំទី២៥ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងនៅតំណាលគ្នានោះដែរច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសមន្ត្រីសាធារណៈមួយទៀតត្រូវបានអនុម័តឡើង។ ក៏ប៉ុន្តែ ការជ្រើសរើសយកប្រព័ន្ធបែបនេះបានបង្កឱ្យមានជំលោះ រវាងបេក្ខជនឈរឈ្មោះបោះឆ្នោតនៅក្នុងគណបក្សដែលអាចនាំមកនូវការគិតគូរតែប្រយោជន៍ផ្ទាល់ខ្លួនជាងសកម្មភាពគោលនយោបាយ ទើបមានការស្នើរសុំឱ្យយកប្រព័ន្ធបោះឆ្នោតដែលយកគណបក្សនយោបាយជាធំ។ បន្ទាប់មក នៅឆ្នាំ១៩៩៤ ដោយយោងទៅតាមច្បាប់ស្តីពីការកែទម្រង់នយោបាយ បានធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសមន្ត្រីសាធារណៈ ហើយបានអនុវត្តនូវប្រព័ន្ធបោះឆ្នោតឯកកត្តនាម និងប្រព័ន្ធបោះឆ្នោតតាមសមាមាត្រ រហូតមកដល់បច្ចុប្បន្ននេះ។

ពលរដ្ឋដែលមានអាយុចាប់ពី២០ឆ្នាំឡើងទៅ អាចមានសិទ្ធិចូល រួមបោះឆ្នោត និង ពលរដ្ឋដែលមានអាយុចាប់ពី២៥ឆ្នាំឡើងទៅអាចឈរឈ្មោះឱ្យគេបោះឆ្នោតបាន។

### ២. ការរៀបចំដំណើរការនៃរដ្ឋសភា

បន្ទាប់ពីការជួបជុំគ្នានៅសភាក្រោយពេលបោះឆ្នោត សភាក្លាយជាអង្គការនីតិបញ្ញត្តិមួយដែលត្រូវបំពេញតួនាទី និង សកម្មភាពយ៉ាងសំខាន់ទៅតាមលំដាប់លំដោយដូចជានៅក្នុងករណីសមាជិករដ្ឋសភាវិញដែលស្ថិតនៅក្នុងសភាពិសេស បន្ទាប់ពីការបោះឆ្នោតបញ្ចប់ទៅ ជាដំបូងគឺត្រូវបោះឆ្នោតរើសប្រធាន និង អនុប្រធាន ហើយបន្ទាប់ពីឆ្លងកាត់ការជួបពិភាក្សាគ្នារួចមក ត្រូវកំណត់តែងតាំងអាសនៈក្នុងសភាធ្វើការសំរេចអំពីសម័យប្រជុំ និង ការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការអចិន្ត្រៃយ៍ និងការសម្រេចអំពីការបង្កើតគណៈកម្មាធិការពិសេសជាដើម[35]។

[35]高橋和之『立憲主義と日本国憲法』第２版（有斐閣、2010 年）３３０頁。
តាកាហាស៊ីកាស៊ឹយឹគី『គោលការណ៍អាស្រ័យរដ្ឋធម្មនុញ្ញ និង រដ្ឋធម្មនុញ្ញប្រទេសជប៉ុន』បោះពុម្ពលើកទី២, រោងពុម្ពយឹហិកាកុ, ឆ្នាំ២០១០, ទំព័រ៣៣០

ចំពោះការតែងតាំងគណៈរដ្ឋមន្ត្រីវិញ បើយោងទៅតាមទំលាប់ពីមុនមក ដើម្បីឱ្យដំណើរការប្រព្រឹត្តិទៅបាន គឺត្រូវធ្វើការជ្រើសរើសចេញពីប្រធានគណៈកម្មាការច្បាប់ និងរដ្ឋបាលនៃគណៈកម្មាធិការអចិន្ត្រៃយ៍។ លើសពីនេះទៅទៀត សមាជិកនៃគណៈកម្មការអចិន្ត្រៃយ៍ និងគណៈកម្មាធិការពិសេសវិញគឺត្រូវជួបពិភាក្សាគ្នា ដើម្បីធ្វើការបែងចែកជាសមាមាត្រក្នុងការកំនត់ចំនួនសមាជិកនីមួយៗ បន្ទាប់ពីផ្តល់សេចក្តីយល់ព្រមរួចទើបធ្វើការអនុម័ត។

នាពេលបច្ចុប្បន្ន ការពិភាក្សារវាងសភានីមួយៗ គឺដំណើរការឡើង ដោយយកគណៈកម្មាធិការជាគោល ហើយដើម្បីរឹតបណ្តឹងសិទ្ធិអំណាចក្នុងការដឹកនាំការធ្វើសេចក្តីសម្រេច និង ការពិភាក្សា នៅពេលទទួលបានការស្នើរពីប្រធានគណៈកម្មាធិការ ក្នុងពេលជាមួយគ្នានោះដែររាល់ការសម្រេចនានាត្រូវបានធ្វើឡើងដោយគោរពទៅតាមមតិភាគច្រើន។

ជាងនេះទៅទៀត ប្រភេទនៃគណៈកម្មាធិការនីមួយៗវិញគឺមានកំណត់នៅក្នុងច្បាប់ស្តីពីសភាក៏ប៉ុន្តែការកំណត់អំពីចំនួន និងបញ្ហាអំណាចយុត្តាធិការវិញគឺមានចែងនៅក្នុងមាត្រា៩២នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។

**៣. អាណត្តិរដ្ឋសភា**

រដ្ឋសភាមានអាណត្តិ៤ឆ្នាំ ហើយរដ្ឋសភានឹងត្រូវបញ្ចប់មុនអាណត្តិ ប្រសិនបើមានការរំលាយសភា[36]។

**៤. សមាជិករដ្ឋសភា**

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រជាកំណត់៤៨០នាក់។ តំណាងរាស្ត្រដែលកើតចេញពីការបោះឆ្នោតតាមមណ្ឌលនីមួយៗមានចំនួន៣០០នាក់។ រីឯតំណាងរាស្ត្រកើតចេញពីការបោះឆ្នោតសមាមាត្រមានចំនួន១៨០នាក់។

**៥. ការកោះហៅមកជុំគ្នា និងពិធីបើកនីតិកាល**

លិខិតក្នុងការធ្វើការកោះអញ្ជើញឱ្យចូលមកជួបប្រជុំគ្នានៅសភា ត្រូវបានកំណត់កាលបរិច្ឆេទច្បាស់លាស់ហើយ និង ការប្រារព្ធការបើកពិធីជាសាធារណៈ[37]។

លិខិតធ្វើការកោះអញ្ជើញឱ្យមកចូលបង្ហាញខ្លួននោះដែរយ៉ាងហោចណាស់ត្រូវ ធ្វើឱ្យបានមុន១០ថ្ងៃ មុននឹងធ្វើការបើកពិធីជាសាធារណៈ[38]។

[36] រដ្ឋធម្មនុញ្ញជប៉ុនមាត្រា៤៥ ឆ្នាំ១៩៤៧

[37] ច្បាប់ស្តីពីសភារបស់ប្រទេសជប៉ុនមាត្រា១កថាខណ្ឌ១ ឆ្នាំ១៩៤៧

[38] ច្បាប់ស្តីពីសភារបស់ប្រទេសជប៉ុនមាត្រា១កថាខណ្ឌ២ ឆ្នាំ១៩៤៧

# ជំពូកទី ២
# អភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភានៅប្រទេសកម្ពុជា និងប្រទេសជប៉ុន

នៅក្នុងជំពូកទី២នេះ ចែកចេញជាបីផ្នែក ដោយយើងនឹងធ្វើការសិក្សាទៅលើ អភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភាកម្ពុជា(ផ្នែកទី១) អភ័យឯកសិទ្ធិសមាជិករដ្ឋសភាជប៉ុន(ផ្នែកទី២) និងការសិក្សាប្រៀបធៀបអភ័យឯកសិទ្ធិសមាជិករដ្ឋសភារវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន( ផ្នែកទី៣)។

## ផ្នែកទី១ អភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភាកម្ពុជា

គោលការណ៍អភ័យឯកសិទ្ធិការពារ ការប្រព្រឹត្តិទៅ និង មុខងាររបស់រដ្ឋសភា និង ធានាលទ្ធភាពឱ្យមានការពិភាក្សាដោយចំហរ និងដោយសេរីនៅក្នុងសភា។ នៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យដ៏ឧត្តុងឧត្តម ការប្រជុំពិភាក្សាដោយផ្ទាល់ក្នុងចំណោមតំណាងរាស្ត្រ គឺមានសារៈសំខាន់ខ្លាំងណាស់។ ការប្រជុំ និងការពិភាក្សាអាចនាំមកនូវភាពទ្រឹងមួយកន្លែងបាន បើអ្នកធ្វើច្បាប់ត្រូវសុំអភ័យទោសបន្ទាប់ពីរាល់ពេលដែលបាននិយាយវាយប្រហារនោះ ពួកគេចាប់ផ្តើម ឬតែងតែភ័យខ្លាចអំពីផលវិបាកតាមផ្លូវច្បាប់ មុនពេលដែលពួកគេផ្តល់យោបល់អ្វីមួយ[39]។ ជំនួសការដាក់ទណ្ឌកម្មព្រហ្មទណ្ឌនៅមានទោសផ្សេងទៀត សម្រាប់ផ្ទន្ទាលើការប្រើពាក្យសំដីបំពានអាចជាសំណូមពររបស់ប្រធានរដ្ឋសភា ដើម្បីរក្សាសណ្តាប់ធ្នាប់របស់រដ្ឋសភា(ប្រការ៦២បទបញ្ជាផ្ទៃក្នុង)។ យ៉ាងណាមិញ ប្រទេសកម្ពុជាក៏បានអនុវត្តនូវរបបសភានិយម ដោយមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលតំណាងឱ្យប្រជាពលរដ្ឋទូទាំងប្រទេស ចាប់តាំងពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសរួចមក ។ របបសភានិយម បានចាប់កំណើតក្នុងប្រទេសកម្ពុជាដោយសភាធម្មនុញ្ញនាឆ្នាំ១៩៤៦ និង បានក្លាយទៅជាសភាជាតិនាឆ្នាំ១៩៤៧។ ការផ្តល់អភ័យឯកសិទ្ធិសភាជូនទៅដល់ តំណាងរាស្ត្រគឺជារឿងចាំបាច់មិនអាចខ្វះបានមួយនៅក្នុងរបបសភានិយមនេះ។ ហេតុនេះហើយ យើងទើបយើងឃើញថា ចាប់តាំងពីរបបសភានិយមត្រូវបានកកើត និងមានការបោះឆ្នោតជ្រើស រើសតំណាងរាស្ត្រតាំងពីឆ្នាំ១៩៤៧មករហូតមកដល់បច្ចុប្បន្ន ឃើញថារដ្ឋធម្មនុញ្ញនៃរបបនីមួយៗគឺសុទ្ធតែផ្តល់អភ័យឯកសិទ្ធិសភាទៅដល់តំណាងរាស្ត្រ លើកលែងតែរដ្ឋធម្មនុញ្ញសម័យប្រជាធិបតេយ្យកម្ពុជា គឺមិនមានផ្តល់អភ័យឯកសិទ្ធិអ្វីនោះឡើយ។

នៅក្នុងផ្នែកនេះ យើងនឹងធ្វើការសិក្សាអំពីប្រវត្តិនៃការផ្តល់អភ័យឯកសិទ្ធិ តាមរយៈរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាចាប់តាំងពីកកើតរដ្ឋធម្មនុញ្ញដំបូងរហូតមកដល់បច្ចុប្បន្ន(កថាខណ្ឌទី១) និងការអនុវត្តជាក់ស្តែងនៃសិទ្ធិមានអភ័យឯកសិទ្ធិ(កថាខណ្ឌទី២)។

[39] នីតិកម្ម សៀវភៅសិក្សាផ្នែកទី២ បោះពុម្ពផ្សាយដោយវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ឆ្នាំ២០០៤ ទំព័រ៣៣-៣៤

## កថាខណ្ឌទី១ អំពីប្រវត្តិនៃការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញ

**១. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាទី១ (១៩៤៧-១៩៧០)**

តាមរយៈមាត្រា ៥៥ ( មាត្រា ៥៤ចាស់ )នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាទី១បានចែង អំពីអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រថា អ្នកតំណាងរាស្ត្រ មិនអាចត្រូវគេចោទប្រកាន់រកខ្លួន ចាប់ខ្លួនឃុំឃាំង ឬ ជំនុំជំរះដោយហេតុថា អ្នកតំណាងរាស្ត្រនោះ បានសម្តែងយោបល់ ឬ បញ្ចេញមតិថាដូច្នេះ ដូច្នោះ ក្នុងក្រសួងរបស់ខ្លួនឡើយ ។

សេចក្តីខាងលើនេះ ជាអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភា ។

**២. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ ( ១៩៧០ - ១៩៧៥ )**

តាមរយៈមាត្រា ៥៤ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរបានចែងអំពីអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រថា សមាជិកសហសភាណាក៏ដោយ មិនអាចត្រូវគេចោទប្រកាន់ តាមរកខ្លួនចាប់ចងឃុំឃាំង ឬ កាត់ទោសដោយហេតុថា បានសម្តែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួន ។ សមាជិកសហសភាណាក៏ដោយ នឹងអាចត្រូវគេចោទប្រកាន់ ឬ ចាប់ចងអំពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមបាន លុះណាតែមានការអនុញ្ញាតពីសភា ដែលខ្លួនជាសមាជិក វៀរលែងតែក្នុងករណី បានប្រព្រឹត្តិបទល្មើសជាក់ស្តែងចេញ ។

ក្នុងករណីទាំងអស់ ការឃុំឃាំង ឬ ការចោទប្រកាន់សមាជិកសហសភាណាមួយ ត្រូវផ្អាក បើសិនជាមានសមាជិកបីភាគបួន "៣/៤" នៃសភាដែលខ្លួនជាសមាជិកបានបញ្ចេញមតិសុំអោយផ្អាក ។

**៣. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ( ១៩៧៥-១៩៧៩ )**

នៅក្នុងរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ ( ១៩៧៥-១៩៧៩ ) ពុំមានមាត្រាណាមួយបញ្ជាក់អំពីអភ័យឯកសិទ្ធិនៃសមាជិករដ្ឋសភានោះឡើយ ។

**៤.ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ( ១៩៧៩-១៩៨១ )**

តាមរយៈមាត្រា៥៦នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា បានចែងអំពីអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រថាៈ

សមាជិករដ្ឋសភា មានអភ័យឯកសិទ្ធិ ។

សមាជិករដ្ឋសភារូបណាក៏ដោយ មិនអាចត្រូវចោទប្រកាន់ ឬ ចាប់ចង ឬ ឃុំឃាំង ដោយហេតុពីបានសម្តែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ឬ ការចាប់ចង ឬ ការឃុំឃាំងសមាជិករដ្ឋសភាណាមួយ និងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ ពីក្រុមប្រឹក្សារដ្ឋ ក្នុងចន្លោះសម័យប្រជុំរដ្ឋសភា វៀរ

លែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោមនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនក្រុមប្រឹក្សារដ្ឋជាបន្ទាន់ ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋ ត្រូវដាក់ជូនរដ្ឋសភាអនុម័តនៅសម័យប្រជុំរដ្ឋសភាខាងមុខ។

**៥. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ( ១៩៨១-១៩៩៣ )**

តាមរយៈមាត្រា ៥៨នៃរដ្ឋធម្មនុញ្ញរដ្ឋកម្ពុជាបានចែងអំពីអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រថា:

សមាជិករដ្ឋសភាមានអភ័យឯកសិទ្ធិ ។

សមាជិករដ្ឋសភារូបណាក៏ដោយ មិនអាចត្រូវចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ដោយហេតុពីបានសម្តែងយោបល់បញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួន សមាជិករដ្ឋសភាណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ ពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនរដ្ឋសភាអនុម័តនៅសម័យប្រជុំរដ្ឋសភាខាងមុខ ។

**៦.ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី២(១៩៩៣-បច្ចុប្បន្ន)**

តាមរយៈមាត្រា នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាទី២ឆ្នាំ១៩៩៣ និង បន្តរហូតមកដល់បច្ចុប្បន្ននេះបានចែងអំពីអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រថា:

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសម្តែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភា និងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោមនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃរបស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាក តាមមតិភាគច្រើនបីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

## កថាខណ្ឌទី២ ការអនុវត្តជាក់ស្តែងនៃសិទ្ធិមានអភ័យឯកសិទ្ធិ

### ១. អត្ថន័យ និងការចាប់ផ្តើមមានអភ័យឯកសិទ្ធិ

#### ក. អត្ថន័យ

អភ័យឯកសិទ្ធិសមាជិករដ្ឋសភាត្រូវបានការពារ ឬ ធានាដោយច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជាដែលហៅថា “ រដ្ឋធម្មនុញ្ញ ” ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ត្រង់មាត្រា ៨០ បានបញ្ជាក់ អំពីអត្ថន័យទូទៅនៃពាក្យអភ័យឯកសិទ្ធិ ស្របទៅនឹងអត្ថន័យនៃនីតិរដ្ឋធម្មនុញ្ញ ។

ពាក្យអភ័យឯកសិទ្ធិនេះ មានសញ្ញាណ២ តាមន័យរដ្ឋធម្មនុញ្ញ[40] :

សិទ្ធិពិសេសមួយសំដៅធានាការពារអ្នកតំណាងរាស្ត្រ ឱ្យរួចផុតពីការចោទប្រកាន់ចាប់ខ្លួន និងការដាក់ទោស ។

បុព្វសិទ្ធិរបស់រដ្ឋសភា គឺការពារអ្នកតំណាងរាស្ត្រពីការចោទប្រកាន់ ការឃុំខ្លួន ការឃាត់ខ្លួន និង ការចាប់ខ្លួន ។

ដោយសារតែអភ័យឯកសិទ្ធិនេះហើយ ទើបអ្នកតំណាងរាស្ត្រមុននឹងទទួលការចោទប្រកាន់តាមផ្លូវតុលាការ ក៏ដូចជាមុននឹងត្រូវចាប់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច ឬក៏ទទួលខុសត្រូវចំពោះមុខច្បាប់ព្រហ្មទណ្ឌ លុះត្រារដ្ឋសភាបានដកហូតអភ័យឯកសិទ្ធិគាត់ជាមុនសិន ។

អភ័យឯកសិទ្ធិនេះមានគោលបំណងការពារ សមាជិករដ្ឋសភា ប្រឆាំងនឹងការគំរាមកំហែង ឬវិធានការបំភិតបំភ័យ ធ្វើដោយតតិយជន អ្នកនយោបាយ ឬឯកជន។ អភ័យឯកសិទ្ធិនេះ ធានាឯករាជ្យភាពរបស់តំណាងរាស្ត្រ ដើម្បីអោយគាត់អនុវត្តអាណត្តិរបស់ខ្លួន ដោយពុំមាន ការបំភិតបំភ័យ ការចាប់ខ្លួនដោយរំលោភបំពាន ឬអំពីការប៉ុនប៉ងប្រព្រឹត្តិអំពើពុករលួយ។ អភ័យឯកសិទ្ធិនេះ គ្របដណ្តប់លើទិដ្ឋភាពពីរ ដែលស្ថិតក្រោមរបបមួយផ្សេងពីគ្នា[41]៖

**ករណីទីមួយ** (ភាពមិនទទួលខុសត្រូវ)៖ អភ័យឯកសិទ្ធិក្នុងករណីនេះមានលក្ខណៈដាច់ខាត ហើយតំណាងរាស្ត្រ “មិនអាចត្រូវបាន ចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុ ពីបាន

---

[40] សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ សំរាប់ថ្នាក់មូលដ្ឋាន បណ្ឌិត ឈុន ណារ៉េត រោងពុម្ព ដារ៉ា ឆ្នាំ ២០១២

[41] ដកស្រង់ចេញពីសៀវភៅវប្បធម៌សភា ដែលរៀបចំដោយនាយកដ្ឋានគណៈកម្មការ

សម្តែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខរបស់ខ្លួនឡើយ»[42]។ ភាពមិនទទួលខុសត្រូវ មិនមែនការពារតំណាងរាស្ត្រក្នុងនាមបុគ្គលទេ ប៉ុន្តែការពារមុខងារតំណាងរាស្ត្រ ។ ភាពមិនទទួលខុសត្រូវ គ្របដណ្តប់លើការបោះឆ្នោត ការបញ្ចេញមតិ សំណើ និងរបាយការណ៍របស់តំណាងរាស្ត្រក្នុងក្របខ័ណ្ឌការប្រជុំពេញអង្គ ឬក្នុងគណៈកម្មការ។

**ករណីទីពីរ** (ភាពមិនអាចរំលោភបំពានបាន)៖ ករណីនេះ មិនមានលក្ខណៈ ដាច់ខាតទេក្នុងន័យថា អភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រអាចនឹងត្រូវដកហូតដោយសមាជិកដទៃទៀត។ ភាពមិនអាចរំលោភបំពានបាន ការពារបុគ្គលច្រើនជាងមុខងារ ដើម្បីចៀសវាង កុំអោយចាត់ទុកតំណាងរាស្ត្រ ដូចជាបុគ្គលឯកជនធម្មតា ដែលអាចជាកម្មវត្ថុនៃការបំភិតបំភ័យ និងការឃាត់ខ្លួនដោយគ្មានហេតុផល។ យោងតាមមាត្រា៨០ វាក្យខ័ណ្ឌទី៣ បានចែង ថា«ការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំខ្លួនតំណាងរាស្ត្រ ណាម្នាក់អាច ធ្វើបាន លុះណា តែមានការព្រមព្រៀងពីរដ្ឋសភា ឬ ពីគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងចន្លោះនៃសម័យប្រជុំរបស់ រដ្ឋសភា»។ វិធាននេះមានន័យថា តំណាងរាស្ត្រអាចត្រូវបានចោទប្រកាន់ទៅតុលាការ ចំពោះទំនួលខុសត្រូវរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ប៉ុន្តែត្រូវមានការយល់ព្រមអំពីតំណាងរាស្ត្រដទៃទៀត។ ការដកអភ័យឯកសិទ្ធិសភា តម្រូវអោយមានមតិភាគច្រើន ២/៣ ដែលបច្ចុប្បន្ន ៥០បូក១ នៃចំនួន សមាជិករដ្ឋសភា ទោះបីមាត្រា ៨០ ពុំមានចែងអោយច្បាស់លាស់អំពីរឿងនេះក្តី។ ផ្ទុយទៅវិញពុំចាំបាច់មានការយល់ព្រមពីរដ្ឋសភាទេសំរាប់ការចាប់ខ្លួន បើសិនជាតំណាងរាស្ត្របានប្រព្រឹត្តិនូវបទល្មើសជាក់ស្តែង (មាត្រា៨០វាក្យខ័ណ្ឌទី ៣)។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ច ត្រូវធ្វើរបាយការណ៍ជូនរដ្ឋសភានូវកាលៈទេសៈនៃការចាប់ខ្លួននេះ។ សមាជិករដ្ឋសភាអាច សម្រេចផ្អាកការចោទប្រកាន់ ក្នុងករណីបទល្មើសជាក់ស្តែង ឬក្នុងករណីបន្ទាប់ពីមានការយល់ព្រមអោយចោទប្រកាន់ ប៉ុន្តែសេចក្តីសម្រេចនេះត្រូវអនុម័ត ដោយសម្លេង ៣/៤ នៃសមាជិករដ្ឋសភាទាំងមូល។ ទោះបីជាយ៉ាងណាក៏ដោយទោះបី រដ្ឋធម្មនុញ្ញពុំបានបញ្ជាក់ក៏ដោយភាពមិនអាចរំលោភបំពានបាននេះ មានអនុភាពត្រឹមតែពន្យាអនុភាពនៃការចោទប្រកាន់ ឬការចាប់ខ្លួនប៉ុណ្ណោះ ដោយទុកឱ្យតំណាងរាស្ត្រ ស្ថិតក្នុងកិច្ចការពារពីសភារបស់ខ្លួន ក្នុងរយៈពេលនៃអាណត្តិរបស់ខ្លួន ។ បន្ទាប់ពីអាណត្តិត្រូវបញ្ចប់ការចោទប្រកាន់អាចធ្វើបាន ឬចាប់ផ្តើមធ្វើជាថ្មី។

### ខ. ការចាប់ផ្តើមមានអភ័យឯកសិទ្ធិរដ្ឋសភា

តំណាងរាស្ត្រដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ក្រោយពីបានប្រកាសសុពលភាព និងស្បថចូលកាន់តំណែងរួចហើយ គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែន

[42]មាត្រា៨០ វាក្យខ័ណ្ឌ២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

គ្រាន់តែជាតំណាងរបស់ប្រជាពលរដ្ឋនៅក្នុងមណ្ឌលរបស់ខ្លួននោះទេ [43] ។ នៅក្នុងករណីខាងលើនេះ អភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រនីមួយៗ ក៏ត្រូវបានកើតឡើងផងដែរបន្ទាប់ពីការប្រកាសសុពលភាពនៃអ្នកតំណាងរាស្ត្រហើយនោះ ព្រមទាំងត្រូវបានស្បថចូលកាន់តំណែងរួចហើយ ។

**២. មូលហេតុ និងលក្ខខណ្ឌនៃការដកអភ័យឯកសិទ្ធិ និងការបាត់បង់អភ័យឯក សិទ្ធិ**

មូលហេតុនៃការដកអភ័យឯកសិទ្ធិរដ្ឋសភារបស់សមាជិករដ្ឋសភាបាន គឺយោងតាមមាត្រា ៨០នៃរដ្ឋធម្មនុញ្ញគឺលុះត្រាតែសមាជិករូបនោះបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។

ប៉ុន្តែមានលក្ខខណ្ឌដោយយោងតាមមាត្រា ៧ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ បានចែងថា“តំណាងរាស្ត្រណាបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ នឹងអាចអនុញ្ញាតបើកឱ្យធ្វើការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន” ។ ក្នុងករណីនេះ មានន័យថា ប្រសិនបើសមាជិករដ្ឋសភាមិនបានប្រព្រឹត្តិបទល្មើសជាក់ស្តែងទេនោះ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនអាចប្រព្រឹត្តិទៅបានលុះត្រាមាន ការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាជាមុនសិនដោយការលើកអភ័យឯកសិទ្ធិរបស់សមាជិករូបនោះមុននឹងអនុវត្តន៍ ទៅតាមនីតិវិធីរបស់តុលាការ។ ប៉ុន្តែ ប្រសិនបើជាបទល្មើសជាក់ស្តែង នោះមិនចាំបាច់សុំការយល់ព្រមជាមុនពីសំណាក់រដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាដើម្បីធ្វើការប្រជុំសម្រេចដកអភ័យឯកសិទ្ធិនោះទេ គឺអាចចាប់ខ្លួនហើយចាំរាយការណ៍ជូនជាបន្ទាន់ជាក្រោយ បើយោងទៅតាមវាក្យខណ្ឌ ៣នៃមាត្រា៨០នៃរដ្ឋធម្មនុញ្ញ និងមាត្រា១២[44]នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ។

ជាងនេះទៅទៀត ចំពោះការបាត់បង់អភ័យឯកសិទ្ធិវិញ នៅក្នុងករណីដែលសមាជិករដ្ឋសភាណាម្នាក់បានទទួលមរណភាព ឬសុំលាលែងពីសមាជិកភាពជាតំណាងរាស្ត្រ ឬប្រាសចាកសមាជិកភាពរដ្ឋសភា ដោយមូលហេតុផ្សេងៗ ដូចករណីដែលសមាជិករបស់គណបក្សនយោបាយមួយបានសុំលាលែងចេញពីគណបក្សនោះ សាមីខ្លួនដែលបានសុំនោះ ត្រូវបាត់បង់សមាជិកភាពជាតំណាងរាស្ត្រដោយស្វ័យប្រវត្តិ ដែលកើតឡើងប្រាំមួយ ( ៦ ) ខែយ៉ាងតិច មុនចប់នីតិកាល។ សាមីគណបក្សនយោបាយនោះ អាចស្នើរសុំជ្រើសតាំងសមាជិកថ្មីជំនួស ដោយជ្រើសរើសក្នុង

[43] មាត្រា ២ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឆ្នាំ២០០៦

[44] ក្នុងករណីតំណាងរាស្ត្រណាបានប្រព្រឹត្តិបទល្មើសជាក់ស្តែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនបានហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នៅចន្លោះសម័យប្រជុំរដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច។

ចំណោមបេក្ខជន ដែលមានឈ្មោះតាមលេខរៀងនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលរបស់សាមីខ្លួននោះ មកជំនួសវិញដោយមិនចាំបាច់ធ្វើការបោះឆ្នោតឡើងវិញទេ[45] ។

**៣. នីតិវិធីនៃការដកអភ័យឯកសិទ្ធិ**

យោងតាមស្មារតីនៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា ៨០ វាក្យខណ្ឌទី២ នីតិវិធីនៃការដកអភ័យឯកសិទ្ធិសភា តម្រូវឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាធ្វើសំណើរដាក់ទៅសម័យប្រជុំពេញអង្គនៃរដ្ឋសភាអនុម័ត ហើយការអនុម័តយកតាមសម្លេងភាគច្រើន បីភាគបួន ( ៣/៤ ) សំដៅបញ្ឈប់ការទាមទារធ្វើការចោទប្រកាន់ និងទទួលខុសត្រូវចំពោះមុខតុលាការ ព្រមទាំងការចាប់ខ្លួនផ្សេងទៀត (មាត្រា ៨០ វាក្យខណ្ឌទី៥ នៃរដ្ឋធម្មនុញ្ញ) ។ ជាងនេះទៀតសោត រាល់ទង្វើរបស់គាត់ធ្វើឡើងក្នុងអំឡុងពេលនៃអាណត្តិជាអ្នកតំណាងរាស្ត្រមិនអនុញ្ញាតឱ្យលើកយកមកដើម្បីធ្វើការចោទប្រកាន់ពេលក្រោយដែលគាត់ផុតពីអាណត្តិនោះទេ ។

សមាជិករដ្ឋសភារូបណាដែលបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌនឹងអាច បើកឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួនទៅតាមច្បាប់ និងនីតិវិធីច្បាប់បានលុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភា ចំពោះសមាជិករដ្ឋសភារូបនោះជាមុនសិន ។ សេចក្តីស្នើរសុំ ដើម្បីលើកអភ័យឯកសិទ្ធិសភា របស់សមាជិករដ្ឋសភារូបណាមួយត្រូវតែធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលមានភ្ជាប់មកជាមួយនូវសេក្តីថ្លែងហេតុ ដើម្បីផ្ញើមកប្រធានរដ្ឋសភា[46] ។

ការលើកអភ័យឯកសិទ្ធិសភា ត្រូវធ្វើនៅក្នុងសម័យចន្លោះ ប្រជុំរដ្ឋសភាដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវធ្វើការពិនិត្យ និងពិចារណាដោយផ្អែកទៅលើបទល្មើស និងភស្តុតាងផ្សេងៗ និងសេចក្តីថ្លែងហេតុរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយត្រូវបានធ្វើការប្រជុំ និងអនុម័តសម្រេចឱ្យសមស្របទៅនឹងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវដាក់នៅចន្លោះសម័យប្រជុំពេញអង្គរបស់រដ្ឋសភា ដើម្បីដកអភ័យឯកសិទ្ធិសភាសមាជិករដ្ឋសភារូបណាមួយ ត្រូវបានអនុម័តដោយមតិភាគច្រើន ពីរភាគបី ( ២/៣ ) នៃចំនួនសមាជិករដ្ឋសភាទាំងមូល[47] ។

ការលើកអភ័យឯកសិទ្ធិសភា របស់សមាជិករដ្ឋសភា នៅក្នុងសម័យប្រជុំ ត្រូវតែអនុវត្តទៅតាមនីតិវិធីដូចតទៅ:

---

[45] មាត្រា ១២០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកតំណាងរាស្ត្រ ថ្ងៃ២៦ ខែធ្នូ ឆ្នាំ១៩៩៧

[46] មាត្រា ៨ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឆ្នាំ២០០៦

[47] មាត្រា ១១ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឆ្នាំ២០០៦

រដ្ឋសភាអាចកោះប្រជុំជាសម្ងាត់ ដោយមានការស្នើរសុំពីប្រធានរដ្ឋសភា ឬពីសមាជិករដ្ឋសភា ដែលមានចំនួនមួយភាគដប់ ( ១ ភាគ ១០ ) យ៉ាងតិច ពីនាយករដ្ឋមន្ត្រី ។ កូរ៉ុមនៃការប្រជុំត្រូវមានចំនួនសមាជិករដ្ឋសភាលើសពីពីរភាគបី ( ២ ភាគ ៣ ) នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការអនុម័តដោយយកសម្លេងភាគច្រើនពីរភាគបី ( ២ ភាគ ៣ ) នៃចំនួនសមាជិករដ្ឋសភាទាំងមូល[48] ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិករដ្ឋសភាណាមួយ ដែលអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា វៀរលែងតែក្នុងករណី ដែលសមាជិករដ្ឋសភារូបនោះបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌជាក់ស្តែងតែប៉ុណ្ណោះ ។

នៅក្នុងករណីនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីធ្វើការសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភានាពេលខាងមុខ ដើម្បីធ្វើការអនុម័តដោយមតិភាគច្រើន ពីរភាគបី ( ២ ភាគ ៣ ) នៃសមាជិករដ្ឋសភាទាំងមូល[49] ។

ក្នុងករណីទាំងអស់ខាងលើ រាល់ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាកតាមការអនុម័តដោយមតិភាគច្រើនបីភាគបួន ( ៣/៤ ) នៃសមាជិករដ្ឋសភាទាំងមូល[50] ។

### ៤. ការផ្តល់អភ័យឯកសិទ្ធិឡើងវិញ

ទាក់ទងទៅនឹងការផ្តល់អភ័យឯកសិទ្ធិរដ្ឋសភាដល់អ្នកតំណាងរាស្ត្រ ដែលបានបាត់បង់នូវសិទ្ធិពិសេសរបស់ខ្លួនសម្រាប់ការពារ ក៏ដូចជាធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ការឃុំខ្លួន ឬក៏ការឃាត់ខ្លួននោះ គឺរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ពុំបានធ្វើការចែងបញ្ជាក់ឱ្យបានច្បាស់លាស់នោះទេ ។ ក៏ប៉ុន្តែវាត្រូវបានលើកយកមកបញ្ជាក់បន្ថែម នៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រឆ្នាំ២០០៦ ។ ច្បាប់នេះ បានចង្អុលបង្ហាញថា អ្នកតំណាងរាស្ត្រអាចនឹងទទួលបានអភ័យឯកសិទ្ធិសភាមកវិញ ដោយការលើកលែងទោសពីព្រះមហាក្សត្រ "តំណាងរាស្ត្រ

[48] មាត្រា ៩ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឆ្នា២០០៦

[49] មាត្រា ៨០ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[50] មាត្រា ១៣ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឆ្នាំ២០០៦

រូបណាមួយជាទណ្ឌិត ហើយត្រូវបានព្រះមហាក្សត្រលើកលែងទោស តំណាងរាស្ត្ររូបនោះនឹងបានទទួលសុពលភាព អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិឡើងវិញ[51]» ។

បន្ថែមពីនេះទៅទៀត តំណាងរាស្ត្ររូបណាមួយ ដែលសាលក្រមជាស្ថាពរ ឬសាលដីកាជាស្ថាពរ បានសម្រេចថា ជាជនគ្មានទោស តំណាងរាស្ត្រនោះត្រូវបានទទួលជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិពេញលេញឡើងវិញ[52] ។

ក្នុងន័យនេះ គឺចង់ធ្វើការបញ្ជាក់ថា នៅពេលដែលរដ្ឋសភាត្រូវបានសម្រេចដកអភ័យឯកសិទ្ធិសភារបស់សមាជិកសភាណាម្នាក់ ដើម្បីផ្តល់សមត្ថកិច្ចឱ្យតុលាការធ្វើនីតិវិធីតាមផ្លូវច្បាប់ ក្នុងការស្វែងរកភាពយុត្តិធម៌ជូនគូរភាគី ។ ប្រសិនបើតុលាការ ធ្វើការដោះស្រាយទៅលើអ្នកតំណាងរាស្ត្ររូបនោះហើយ នៅតែរកពុំឃើញនូវភស្តុតាងបញ្ជាក់ថា គាត់បានប្រព្រឹត្តិបទល្មើសទេនោះ ក្នុងករណីនេះ តុលាការនឹងចេញសេចក្តីសម្រេចរបស់ខ្លួនទោះបីដោយសាលក្រម ឬដោយសាលដីកាក្តី ដោយធ្វើការបញ្ជាក់ថា តំណាងរាស្ត្ររូបនោះរួចផុតពីការចោទប្រកាន់របស់តំណាងអយ្យការ។ ពេលនោះគឺ គាត់នឹងទទួលបានអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិរដ្ឋសភាវិញ យ៉ាងពេញលេញដោយស្វ័យប្រវត្តិ ។

## ផ្នែកទី២ អភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភាជប៉ុន

នៅក្នុងផ្នែកនេះ យើងនឹងធ្វើការសិក្សាអំពីប្រវិត្តនៃការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញនៅសម័យម៉េជិរហូតមកដល់បច្ចុប្បន្នរបស់ប្រទេសជប៉ុន(កថាខណ្ឌទី១) និង ការអនុវត្តជាក់ស្តែងនៃសិទ្ធិមានអភ័យឯកសិទ្ធិ(កថាខណ្ឌទី២)។

### កថាខណ្ឌទី១ អំពីប្រវត្តិនៃការផ្តល់អភ័យឯកសិទ្ធិក្នុងរដ្ឋធម្មនុញ្ញ

បន្ទាប់ពីមានការរើបម្រះចេញពីការគាបសង្កត់ពីអំណាចរបស់ព្រះមហាក្សត្រ ដែលមានអំណាចអាចចាប់ខ្លួន និងធ្វើសកម្មភាពបណ្តឹងទៅលើសមាជិកសភាបានដែលនាំឱ្យមានការគំរាមកំហែងទៅដល់ឯករាជ្យភាពរបស់សភាក៏ដូចជាសេរីភាពក្នុងការប្រព្រឹត្តិទៅនានាក្នុងសភា[53]។ ការទាមទារឱ្យមាននូវអភ័យឯកសិទ្ធិក្នុងការមិនត្រូវបានចាប់ខ្លួន និងអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់ គឺជាយុទ្ធសាស្ត្រនៅក្នុងការការពារសមាជិកសភាក្នុងការបំពេញសកម្មភាពដោយសេរីរបស់ខ្លួន ហើយប្រព័ន្ធបែបសភានិយមនេះក៏បានអភិវឌ្ឍន៍ទៅមុខ និងចាប់ផ្តើមមានការទទួលស្គាល់ពីបណ្តាប្រទេសជាច្រើនយកប្រព័ន្ធបែបនេះទៅអនុវត្តន៍ដែរ។

---

[51] មាត្រា ១៥ នៃច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រ ឆ្នាំ២០០៦

[52] មាត្រា ១៦ នៃច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រ ឆ្នាំ២០០៦

[53]渋谷秀樹・赤坂正浩『憲法２統治』、（第４版、２０１０年、８４頁。）
ស៊ិប៊ឺតានិហ៊ីដេគិ・អាក:សាក:ម៉ាសាហ៊ិរុ『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤, ឆ្នាំ២០១០, ទំព័រ៨៤

អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ បើទោះបីជានៅក្នុងសម័យម៉េជិប្រកាន់យករបបប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ រីឯសម័យបច្ចុប្បន្ននេះប្រកាន់យករបបប្រជាធិបតេយ្យអាស្រ័យសភាក៏ដោយចុះ ប៉ុន្តែតាំងពីសម័យម៉េជិរហូតមកដល់បច្ចុប្បន្ន គឺសុទ្ធតែមានរដ្ឋធម្មនុញ្ញជាច្បាប់កំពូលដូចគ្នា មានសភាពីរជាន់ដូចគ្នា ហើយតំណាងរាស្ត្រសុទ្ធតែជ្រើសចេញពីការបោះឆ្នោត។ អ្វីដែលពិសេសនោះគឺ នៅក្នុងរដ្ឋធម្មនុញ្ញទាំងពីរសុទ្ធតែបានចែងអំពី សិទ្ធិដ៏ចម្បងសំខាន់ចាំបាច់បំផុតសម្រាប់តំណាងរាស្ត្រក្នុងការបំពេញតួនាទីរបស់ខ្លួននោះគឺ អភ័យឯកសិទ្ធិ។

**១. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញនៅសម័យម៉េជិ**

នៅសម័យមេជិ រដ្ឋធម្មនុញ្ញមហាអាណាចក្រជប៉ុន ឬមហាចក្រពត្តិជប៉ុន ត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ១៨៨៩នោះក៏បានចែងអំពីស្ថាប័ននីតិបញ្ញត្តិដែលមានសភាពីរជាន់ គឺរដ្ឋសភាជាសភាជាន់ទាប និង ព្រឹទ្ធសភាជាសភាជាន់ខ្ពស់។ ដោយឡែកនៅក្នុងការផ្តល់អភ័យឯកសិទ្ធិដល់តំណាងរាស្ត្រវិញ នៅក្នុងរដ្ឋធម្មនុញ្ញគឺមានចែងតែពីរមាត្រាតែប៉ុណ្ណោះក្នុងមាត្រា៥២ និង មាត្រា៥៣[54]។

**២. ការផ្តល់អភ័យឯកសិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញនៅសម័យបច្ចុប្បន្ន**

យោងទៅតាមមាត្រា៥០នៃរដ្ឋធម្មនុញ្ញជប៉ុននាពេលបច្ចុប្បន្ន បានចែងអំពីសិទ្ធិមិនអាចចាប់ខ្លួនសមាជិកសភា។ មាត្រានេះបានចែងថា លើកលែងតែមានច្បាប់ដទៃទៀតបានចែង សមាជិកសភាមិនអាចត្រូវបានចាប់ខ្លួននៅក្នុងអាណត្តិរបស់ខ្លួនឡើយ។ បើទោះបីជាមានសមាជិកណាមួយត្រូវបានចាប់ខ្លួនមុនអាណត្តិក៏ដោយ ប៉ុន្តែប្រសិនបើសភាមានតម្រូវការចាំបាច់ណាមួយកើតឡើងចំពោះសមាជិករូបនោះត្រូវតែធ្វើការដោះលែងភ្លាម។

មាត្រា៥១បានចែងអំពីសិទ្ធក្នុងការបញ្ចេញយោបល់ និង ការបោះឆ្នោតបញ្ចេញមតិរបស់សមាជិកសភា។ មាត្រានេះបានចែងបញ្ជាក់ថាការថ្លែងសុន្ទរកថា ការជជែកវែកញែកពិភាក្សា និងការបោះឆ្នោតបញ្ចេញមតិរបស់សមាជិកសភាទាំងពីរនៅក្នុងសភា គឺនឹងមិនទទួលខុសត្រូវនៅខាងសភាឡើយ។

**កថាខណ្ឌទី២ ការអនុវត្តជាក់ស្តែងនៃសិទ្ធិមានអភ័យឯកសិទ្ធិ**

ថ្វីត្បិតតែរដ្ឋធម្មនុញ្ញរបស់ប្រទេសជប៉ុន បានចែងតែពីរមាត្រាទាក់ទងទៅនឹងអភ័យឯកសិទ្ធិនេះក៏ដោយ ក៏ប៉ុន្តែមានបណ្តាសៀវភៅរបស់អ្នកជំនាញខាងផ្នែករដ្ឋធម្មនុញ្ញ និងបណ្តាយុត្តិសាស្ត្រជាច្រើនបាន ធ្វើការបកស្រាយពន្យល់យ៉ាងក្បោះក្បាយបន្ថែមទៀតទៅលើទ្រឹស្តី អត្ថន័យ គោលបំណង និងវិសាលភាពនៃការការពារអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រនេះ ដែលអាចយកមកធ្វើការបកស្រាយពន្យល់ និង យកមកដោះស្រាយយ៉ាងមានប្រសិទ្ធិភាពក្នុងករណីមានជំលោះរវាង

[54] សូមមើលឧបសម្ព័ន្ធ១១

អ្នកនយោបាយ ពិសេសពាក់ព័ន្ធនឹងតំណាងរាស្ត្រ។ យោងទៅតាមមាត្រា៥០ និង មាត្រា៥១នៃរដ្ឋធម្មនុញ្ញ សមាជិកសភាត្រូវបានការពារដោយ អភ័យឯកសិទ្ធិក្នុងការមិនត្រូវបានចាប់ខ្លួន និង អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ដែលប្រជាពលរដ្ឋធម្មតាទូទៅមិនមែនជាសមាជិកសភា គឺមិនអាចទទួលបានអភ័យឯកសិទ្ធិទាំងនេះឡើយ។

**១. អំពីអភ័យឯកសិទ្ធិមិនអាចត្រូវបានចាប់ខ្លួន**

ទន្ទឹមនឹងការរីកចំរើន និងការរីករាលដាលការអនុវត្តនូវប្រព័ន្ធសភានិយមនៅក្នុងរដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសនីមួយៗបានចែងពីអភ័យឯកសិទ្ធិមិនត្រូវបានចាប់ខ្លួននេះ ។ នៅប្រទេសអង់គ្លេសពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌ គឺមិនស្ថិតក្នុងទស្សនៈវិស័យនៃអភ័យឯកសិទ្ធិមិនត្រូវបានចាប់ខ្លួននោះទេ តែផ្ទុយទៅវិញប្រទេសបារាំង ក៏ដូចជាប្រទេសអាឡឺម៉ង់ជាដើម រាល់ការសម្រេចឱ្យចាប់ ឬមិនសម្រេចឱ្យធ្វើការចាប់ខ្លួននោះគឺទាមទារឱ្យមានគំនិតស្របគ្នាជាមុនសិនពីសភា[55]។

បើទោះបីជាឋានៈរបស់សភា ឬ ក៏ឯករាជ្យភាពរបស់អំណាចតុលាការត្រូវបានបង្កើតឱ្យមានក៏ដោយ ប៉ុន្តែការកើតមាននូវភាពទាស់ទែងគ្នាក្នុងរូបភាពនយោបាយ អាចនាំឱ្យមានការចាប់ខ្លួនមិនត្រឹមត្រូវ ជាពិសេសការចាប់ខ្លួនសមាជិកសភាគណបក្សប្រឆាំងដែលមានសំលេងតិច នៅក្នុងសភា។ និយមន័យនៃអភ័យឯកសិទ្ធិមិនត្រូវបានចាប់ខ្លួននោះគឺមិនទាន់ដូលរលំនោះទេ ប៉ុន្តែក្នុងករណីមានបណ្តឹងឱ្យធ្វើការស៊ើបអង្កេត ដោយសង្ស័យថាសមាជិកសភាណាម្នាក់បានប្រព្រឹត្តិអំពើពុករលួយជាដើមនោះ ក្នុងករណីនេះអាចមានការលូកដៃចូលពីសំណាក់រដ្ឋាភិបាល ឬគណបក្សកាន់អំណាចដែលឆ្លៀតឱកាសយកចំនេញពីករណីនេះ ហើយធ្វើការចាប់ខ្លួនដោយមិនត្រឹមត្រូវទៅលើសមាជិកសភាគណបក្សប្រឆាំង។ ហេតុដូចនេះហើយ ការផ្តល់អភ័យឯកសិទ្ធិមួយនេះទៅដល់សមាជិកសភាគឺជារឿងសំខាន់ចាំបាច់ណាស់។

**ក. អត្ថន័យនៃពាក្យ "ចាប់ខ្លួន"**

រដ្ឋធម្មនុញ្ញមាត្រា៥០ក៏បានចែងទាក់ទងទៅនឹងសិទ្ធិមិនអាចត្រូវបានចាប់ខ្លួនសមាជិកសភាផងដែរ។ ការចែងថា"សមាជិកសភាមិនអាចត្រូវបានចាប់ខ្លួនក្នុងអាណត្តិនោះ"ជាការផ្តល់អភ័យឯកសិទ្ធិដល់សមាជិកសភា[56]។

ការចែងបែបនេះ គឺក្នុងគោលបំណងដើម្បីធ្វើការការពារដល់សេរីភាពផ្ទាល់ខ្លួនចៀសវាងការរំលោភបំពានពីសំណាក់អំណាចនីតិប្រតិបត្តិ ដែលអាចធ្វើការរាំងដល់ការបំពេញភារកិច្ចរបស់

---

[55]渋谷秀樹・赤坂正浩『憲法２統治』、（第４版、２０１０年、８４頁。）
ស៊ិបឺតានិហ៊ីដេគិ・អាកៈសាកៈម៉ាសាហ៊ិរុ『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤, ឆ្នាំ២០១០, ទំព័រ៨៤
[56]渋谷秀樹・赤坂正浩『憲法２統治』、（第４版、２０１０年、８５頁。）
ស៊ិបឺតានិហ៊ីដេគិ・អាកៈសាកៈម៉ាសាហ៊ិរុ『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤, ឆ្នាំ២០១០, ទំព័រ៨៥

សមាជិកសភា និង គោលបំណងមួយទៀតនោះគឺដើម្បីការពារសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយផ្ទាល់របស់សមាជិកសភា ។ មិនតែប៉ុណ្ណោះ ទន្ទឹមនឹងការដែលសមាជិកសភាគ្រប់រូបទទួលបាននូវអភ័យឯកសិទ្ធិនៅអំឡុងពេលកាន់តំណែងក្នុងអាណត្តិ ក៏ប៉ុន្តែ មុននឹងចូលកាន់តំណែងសមាជិករូបនោះត្រូវបានចាប់ឃុំឃាំងរូបកាយទុកពីសំណាក់ស្ថាប័ននីតិប្រតិបត្តិ ធ្វើឱ្យសភាហាក់ដូចជាមិនអាចដំណើរការទៅបាន ហើយមានការចាំបាច់ក្នុងការតម្រូវឱ្យសមាជិករូបនោះត្រូវចូលកាន់តំណែងក្នុងសភា ក្នុងករណីនេះបើទោះបីជាសមាជិករូបនោះត្រូវបានចាប់ខ្លួនមុនអាណត្តិក៏ដោយក៏ត្រូវតែធ្វើការដោះលែងវិញដែរ។ ការកំណត់បែបនេះគឺដើម្បីការពារទុកជាមុនពីការឃុំឃាំងរូបកាយសមាជិកសភាដោយមិនត្រឹមត្រូវ ឬអាចមានករណីទទួលប្រយោជន៍ពីការចាប់ខ្លួន ក៏ដូចជាការរត់គេចជាដើម ហេតុនោះហើយដើម្បីបញ្ចៀសករណីទាំងនេះគួរតែឱ្យសមាជិកសភាអាចចូលរួមប្រជុំដើម្បីអាចធ្វើសេចក្តីសម្រេចផ្សេងៗបាននៅក្នុងសភា ទើបជារឿងសំខាន់ចាំបាច់ជាជាងដោយសារការចាប់ខ្លួនមិនត្រឹមត្រូវធ្វើឱ្យសមាជិករូបនោះ រត់គេចខ្លួនអាចនាំឱ្យប៉ះពាល់ដល់កិច្ចដំណើរការរបស់សភា[57]។

ពាក្យថា«ចាប់ខ្លួន»នៅក្នុងមាត្រាខាងលើ បើធ្វើការពិចារណាឱ្យបានល្អិតល្អន់ទៅលើគោលបំណងនៃការផ្តល់អភ័យឯកសិទ្ធិមិនត្រូវបានចាប់ខ្លួននេះ គឺមិនចាំបាច់គិតគូរទៅដល់ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួនដោយយោងទៅតាមនីតិវិធីព្រហ្មទណ្ឌនោះទេ។ រាល់បណ្តឹងដែលមិនជាប់ទាក់ទងទៅនឹងការឃុំឃាំងរូបកាយ ក៏ដូចជាអនុវត្តនូវការលើកលែងទោស និងដោះលែងឱ្យនៅក្រៅឃុំបន្ទាប់ពីមានសេចក្តីសម្រេចដ៏ជាក់លាក់មួយពីតុលាការទៅហើយក៏ដោយ ក៏មិនប្រាកដថានេះជាការរំលោភបំពានអភ័យឯកសិទ្ធិនោះឡើយ។ លើកលែងក្នុងករណីដែលត្រូវអនុវត្តតាមសេចក្តីសម្រេចជាក់លាក់ណាមួយ នោះផ្ទុយទៅវិញវារាប់បញ្ចូលទាំងរឿងស្ថិតក្រោមរដ្ឋបាល ដូចជាការប្រើប្រាស់បុព្វសិទ្ធិអំណាចសាធារណៈដើម្បីធ្វើការចាប់ខ្លួនជាដើម។ ប៉ុន្តែ ករណីក្នុងការដាក់បណ្តឹងចាប់ខ្លួនបែបនេះមិនទាក់ទងដល់ការចាប់ខ្លួនតាមអត្ថន័យខាងលើទេ តែនេះជាអភ័យឯកសិទ្ធិដែលមិនអាចធ្វើការប្តឹងផ្តល់បាន។ ការថែងការពារអភ័យឯកសិទ្ធិនេះនៅក្នុងមាត្រាខាងលើ គឺមិនរាប់បញ្ចូលទាំងអភ័យឯកសិទ្ធិក្នុងការធ្វើសកម្មភាពមិនស្របច្បាប់នោះឡើយ។

ខុសប្លែកអំពីសម័យដែលព្រះមហាក្សត្រទ្រង់មានអំណាចយ៉ាងខ្លាំងក្លានោះ នៅក្នុងដំណើរការអភិវឌ្ឍកសាងសង្គមនាសម័យកាលបច្ចុប្បន្ននេះ អធិបតេយ្យភាពប្រជាជនត្រូវបានបង្កើតឡើង ហើយទទួលយកការអនុវត្តប្រព័ន្ធបែងចែកអំណាចរវាងអង្គនីតិបញ្ញត្តិ និងអង្គនីតិប្រតិបត្តិ ហើយជា

[57]渋谷秀樹・赤坂正浩『憲法２統治』、（第４版、２０１０年、８５頁。）
ស៊ិប៊ីតានិហ៊ីដេគិ・អាក:សាក:ម៉ាសាហ៊ិរុ 『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤, ឆ្នាំ២០១០, ទំព័រ៨៥

ប្រព័ន្ធមួយដែលសភាជាអ្នកទទួលស្គាល់រដ្ឋាភិបាល ប៉ុន្តែការគ្រប់គ្រងស្ថិតនៅលើរដ្ឋាភិបាល។ ទោះបីជាមានមតិសង្ស័យ ទៅលើគោលបំណងនៃការជ្រើសរើសយកប្រព័ន្ធមួយនេះក៏ដោយ ក៏ត្រូវបានគេចាត់ទុកថាការជ្រើសរើសយកប្រព័ន្ធបែបនេះគឺក្នុងគោលបំណងដើម្បីការពារការត្រួតពិនិត្យទៅលើមតិភាគច្រើនរបស់សភា និងមតិភាគតិចរបស់រដ្ឋាភិបាល។

**ខ. អញ្ញត្រកម្មនៃអភ័យឯកសិទ្ធិមិនត្រូវបានចាប់ខ្លួន**

«លើកលែងតែមានច្បាប់ដទៃទៀតបានចែង» ដែលជាអញ្ញត្រកម្មនៅក្នុងមាត្រា៥០ខាងលើនេះ គឺចង់សំដៅទៅលើការចែងនៅក្នុងច្បាប់ស្តីពីសភាមាត្រា៣៣ ដែលបានកំណត់ចែងអំពី ករណីលើកលែងនៃអភ័យឯកសិទ្ធិក្នុងការមិនត្រូវបានចាប់ខ្លួនដែលមានពីរករណី គឺករណីដែលមានការប្រព្រឹត្តិបទល្មើសជាក់ស្តែងនៅក្រៅសភា និង ក្នុងករណីប្រសិនបើសមាជិកណាមួយទទួលបានការអនុញ្ញាតឱ្យធ្វើការចាប់ខ្លួនពីសភា[58]។ ការចាប់ខ្លួននេះគឺអាចប្រព្រឹត្តិទៅបានប្រសិនបើនៅក្នុងករណីមានការប្រព្រឹត្តិបទល្មើសជាក់ស្តែងហើយប្រសិនបើការពិតនៃបទល្មើសនេះ បានបង្ហាញស្តែងឡើងយ៉ាងជាក់ច្បាស់ ហើយការទទួលការអនុញ្ញាតឱ្យមានការចាប់ខ្លួនពីសភាមានភាពត្រឹមត្រូវតែប៉ុណ្ណោះដែលនេះជាការទាមទារមួយ ដើម្បីកុំឱ្យសមាជិករដ្ឋសភាមានការភ័យខ្លាច ពីការចាប់ខ្លួនមិនត្រឹមត្រូវ។ ភាពចាំបាច់ក្នុងការអនុញ្ញាតឱ្យចាប់ខ្លួននេះដែរ មុននឹងចេញដីការសុំធ្វើការចាប់ខ្លួនតុលាការដែលមានសមត្ថកិច្ចចាំបាច់ត្រូវឆ្លងកាត់សុំទៅគណៈរដ្ឋមន្ត្រីជាមុនសិន។ ក្នុងការប្រព្រឹត្តិសកម្មភាពល្មើសនៅក្នុងសភាត្រូវបានលើកលែងនោះ វាជារឿងទូទៅមួយដោយសារតែមានការប្រគល់បន្ទុកមួយនេះទៅឱ្យសភាខ្លួនឯងជាអ្នកធ្វើការសម្រេចសេចក្តីទៅលើបញ្ហាមួយនេះ ដូចជាក្នុងករណីប្រសិនបើសមាជិកសភាណាម្នាក់បានប្រព្រឹត្តិបទល្មើសជាក់ស្តែងនៅក្នុងសភានោះ ប្រសិនបើប្រធានសភាបានអនុញ្ញាតបញ្ជាឱ្យចាប់ខ្លួន អាជ្ញាធរមានសមត្ថកិច្ចក្នុងសភាអាចធ្វើការចាប់ខ្លួនបាន[59]។ ជាងនេះទៅទៀត ទោះបីជា មានគំនិតមួយចំនួនយល់ឃើញថា ការផ្តល់អភ័យឯកសិទ្ធិបែបនេះ គឺជាការទាមទារមួយដើម្បីអាចជួយការពារទៅដល់ការសម្រេចសេចក្តីរបស់សភាក៏ពិតមែន ប៉ុន្តែ វាគ្មានភាពចាំបាច់ទេក្នុងការលើកលែងការចាប់ខ្លួនសមាជិកសភាដែលប្រព្រឹត្តិបទល្មើសជាក់ស្តែង។

ការប្រព្រឹត្តិបទល្មើសជាក់ស្តែងដែលជាអញ្ញត្រកម្មនៃការផ្តល់អភ័យឯកសិទ្ធិ មិនត្រូវបានចាប់ខ្លួននេះគឺដោយសារតែគិតថា ប្រសិនបើមន្ទិលសង្ស័យក្នុងការប្រព្រឹត្តិបទល្មើសនេះបានបង្ហាញ

[58]渋谷秀樹・赤坂正浩『憲法２統治』（第４版）（２０１０年）（８５頁。）
ស៊ិបឹតានិហ៊ីដេគិ・អាកៈសាកៈម៉ាសាហ៊ិរុ 『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤, ឆ្នាំ២០១០, ទំព័រ៨៥

[59] ច្បាប់ស្តីពីសភានៃប្រទេសជប៉ុន មាត្រា១១៤ ឆ្នាំ១៩៤៧

យ៉ាងជាក់ច្បាស់នូវចំនុចសង្ស័យទាំងនោះហើយ នាំឱ្យលទ្ធភាពដែលថាអាចនឹងចាប់ខ្លួនដោយមិនមានភាពត្រឹមត្រូវនោះក៏មានកម្រិតតិចតួចដែរ។

ប៉ុន្តែ និយមន័យនៃការទទួលបានអភ័យឯកសិទ្ធិក្នុងការមិនចាប់ខ្លួននេះ គឺសំដៅដល់ការការពារ និង ការត្រួតពិនិត្យទៅលើការចាប់ខ្លួនមិនត្រឹមត្រូវពីសំណាក់រដ្ឋាភិបាល ជាពិសេសពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងការការពារនូវការបំពេញសកម្មភាពឱ្យបានគ្រប់គ្រាន់ដល់សមាជិកសភា។ ដូច្នេះហើយ គឺមានតែការទទួលបានការអនុញ្ញាតយល់ព្រមពីសភាតែប៉ុណ្ណោះទើបការចាប់ខ្លួននោះគឺជារឿងត្រឹមត្រូវ។

**គ. លក្ខខណ្ឌក្នុងការចាប់ខ្លួន**

ការទាមទារឱ្យមានការអនុញ្ញាតឱ្យធ្វើការចាប់ខ្លួន គឺគណៈរដ្ឋមន្ត្រីត្រូវដាក់សេចក្តីស្នើរទៅកាន់សភាបន្ទាប់ពីទទួលបានលិខិតស្នើរសុំឱ្យចាប់ខ្លួនពីតុលាការ។

ប៉ុន្តែ តើយោងទៅលើករណីបែបណាទើបអាចអនុញ្ញាតឱ្យធ្វើការចាប់ខ្លួនបាន និង ដើម្បីចៀសវាងការសំអាងលេសមិនត្រឹមត្រូវពីសំណាក់រដ្ឋាភិបាលដើម្បីធ្វើការចាប់ខ្លួន ហេតុនេះហើយត្រូវតែបញ្ជាក់ឱ្យបានច្បាស់ពីភាពចាំបាច់ ថាតើវាពិតជាចាំបាច់ខ្លាំងកម្រិតណាដែលតម្រូវឱ្យត្រូវតែធ្វើការចាប់ខ្លួន។ មួយវិញទៀត ត្រូវធ្វើការពិចារណាទៅដល់ចំនុចដែលថា តើការចាប់ខ្លួននោះ ជាការចាប់ខ្លួនដ៏ត្រឹមត្រូវ ឬមិនត្រឹមត្រូវ[60]។

ជាងនេះទៅទៀត ចំនុចដែលត្រូវតែធ្វើការពិចារណាផងដែរនោះ គឺសមាជិកសភារូបនោះចាំបាច់ក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅក្នុងសភា ឬយ៉ាងណា ដែលចំនុចទាំងអស់នេះជាចំនុចដែលត្រូវលើកយកមកពិចារណា និងជាលក្ខខណ្ឌដើម្បីសម្រេចសេចក្តី និងអនុញ្ញាតឱ្យធ្វើការចាប់ខ្លួន។

ប្រសិនបើក្នុងករណីមានការអនុញ្ញាតឱ្យចាប់ខ្លួនសមាជិកសភារូបនោះ ថាតើអាចកំណត់នូវលក្ខខណ្ឌ និងរយៈពេលបានដែរឬយ៉ាងណានោះ បានក្លាយទៅជាបញ្ហា។

មានន័យថា គោលបំណងនៃមាត្រា៥០ខាងលើគឺទោះបីជាស្ថិតក្នុងករណីមានការសង្ស័យថាសមាជិកសភារូបណាមួយបានប្រព្រឹត្តិបទល្មើសក៏ដោយ ទោះជាយ៉ាងនេះក្តីក៏ត្រូវតែពិនិត្យឱ្យច្បាស់លាស់ថាតើអ្នកដែលមានអំណាចក្នុងការស៊ើបអង្កេតទៅលើបទល្មើសនោះ មានបង្កកំហុសក្នុងការអនុវត្តអំណាចតុលាការរបស់ខ្លួនឬយ៉ាងណា ឬមួយក៏ទទួលរងការរំលោភបំពាន ដោយការជ្រៀតជ្រែកចូលក្នុងអំណាចរបស់តុលាការ ដើម្បីជម្រុញឱ្យមានការចាប់ខ្លួនមិនត្រឹមត្រូវដែរឬយ៉ាងណា។

---

60 小林孝輔・芹沢『憲法』第５版、２００６年、２８５頁。
កុប៉ាយ៉ាស៊ី・សេរីសាវ៉ា 『រដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៥, ឆ្នាំ២០០៦, ទំព័រ២៨៥

យ៉ាងណាមិញ សមាជិកសភាមានតួនាទីក្នុងការធ្វើសេចក្តីសម្រេចឱ្យស្របទៅតាមការកំណត់របស់ច្បាប់ និងស្របតាមភាពចាំបាច់ ដូចនេះហើយ ក្នុងនាមជាសមាជិកសភាមួយរូបមិនគួរត្រូវបានចាប់ខ្លួនដូចជាការចាប់ខ្លួនជនសង្ស័យថាបានប្រព្រឹត្តិបទល្មើស ដូចជាប្រជាពលរដ្ឋទូទៅដែរនោះទេ ប៉ុន្តែដែលសំខាន់នោះគឺត្រូវឆ្លងកាត់ការពិចារណាពីស្ថានភាពនយោបាយក្នុងប្រទេស និងភាពចាំបាច់ឱ្យបានច្បាស់លាស់ជាមុនសិនថាតើវាមានភាពចាំបាច់កម្រិតណាក្នុងការចាប់ខ្លួន ឬមិនគួរធ្វើការចាប់ខ្លួនទេ។

បើទោះជាយ៉ាងនេះក្តី ការបញ្ជាក់ខាងលើនេះដែលទាមទារនូវភាពស្របច្បាប់ត្រឹមត្រូវ និងភាពចាំបាច់ក្នុងការចាប់ខ្លួននេះគឺមិនមានកំណត់នៅក្នុងមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ ឬបទបញ្ញត្តិណាមួយនោះឡើយ ហេតុនោះទើបតម្រូវឱ្យមានការយល់ព្រមអនុញ្ញាតជាមុនសិនជារឿងចាំបាច់។

មានការទាមទារថា តើបើត្រូវចាប់ខ្លួន តើអាចចាប់ខ្លួនក្នុងករណីបែបណាទើបមានការទាមទារឱ្យមានការបញ្ជាក់ឱ្យច្បាស់លាស់ពីវិសាលភាពដោយចែងក្នុងច្បាប់មួយជាក់លាក់។

**ឃ. ការចាប់ខ្លួនក្រៅសភា**

ការចាប់ខ្លួនក្រៅសភានេះ គឺសំដៅទៅដល់ការចាប់ខ្លួនសមាជិកសភាដែលបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌជាក់ស្តែងនៅខាងក្រៅសភា។ ប្រសិនបើចាប់ខ្លួនដោយបទល្មើសខាងក្រៅជាក់ស្តែងដែលមើលឃើញផ្ទាល់នឹងភ្នែក ដូចនេះភាពមន្ទិលសង្ស័យដែលថាការចាប់ខ្លួននោះជាការចាប់ខ្លួនមិនត្រឹមត្រូវដូចជាពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ ការកេងចំនេញខាងនយោបាយជាដើមនោះក៏មានកម្រិតតិចតួចដែរ[61]។

**ង. ការចាប់ខ្លួនក្នុងសភា**

មិនត្រឹមតែមានការចាប់ខ្លួនក្រៅសភា ក្នុងករណីដែលសមាជិកសភាដែលបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌជាក់ស្តែងនៅខាងក្រៅសភានោះទេ ប៉ុន្តែក្នុងករណីមានការប្រព្រឹត្តិបទល្មើសជាក់ស្តែងនៅក្នុងសភាវិញ ក្នុងករណីនេះ គឺផ្តល់សិទ្ធិពិសេសទៅឱ្យប្រធានសភាជាអ្នកធ្វើសេចក្តីសម្រេចដោយផ្ទាល់ថាឱ្យចាប់ខ្លួន ឬមិនឱ្យចាប់ខ្លួន។ លុះត្រាមានការអនុញ្ញាតពីប្រធានសភាជាមុនសិន ទើបអាជ្ញាធរមានសមត្ថកិច្ចក្នុងសភាមានសិទ្ធិចាប់ខ្លួនសមាជិកសភារូបនោះបាន។

**ច. នីតិវិធីក្នុងការទាមទារឲ្យមានការចាប់ខ្លួន**

មាត្រា៣៤នៃច្បាប់ស្តីពីសភាបានចែងថា ការចាប់ខ្លួនសមាជិកសភាអាចធ្វើទៅបាន ដោយត្រូវទាមទារឱ្យមានការយល់ព្រមពីសំណាក់សភាហើយនោះ មុននឹងតុលាការមានសមត្ថកិច្ច ឬក៏

[61]小林孝輔・芹沢『憲法』第５版、２００６年、２８５頁。
កុប៉ាយ៉ាស៊ី・សេរីសាវ៉ា 『រដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៥, ឆ្នាំ២០០៦, ទំព័រ២៨៥

ថៅក្រមចេញដីការបង្គាប់ឱ្យចាប់ខ្លួន ត្រូវដាក់នូវលិខិតចាំបាច់ក្នុងការទាមទារឱ្យមានការចាប់ខ្លួនទៅគណៈរដ្ឋមន្រ្តី។ បន្ទាប់ពីគណៈរដ្ឋមន្រ្តីទទួលស្គាល់នូវលិខិតចាំបាច់ក្នុងការទាមទារឱ្យមានការចាប់ខ្លួនដែលតុលាការមានសមត្ថកិច្ចបានដាក់ជូនភ្លាម គឺត្រូវទាមទារឱ្យគណៈរដ្ឋមន្រ្តីធ្វើការរៀបចំនូវលិខិតចំលងពីលិខិតចាំបាច់ក្នុងការទាមទារ ឱ្យមានការចាប់ខ្លួននោះ និងធ្វើការប្រកាសទទួលស្គាល់ពីការចាប់ខ្លួននោះបន្ទាប់ពីដាក់លិខិតស្នើរទៅសភា ហើយសភាបានយល់ព្រមអនុញ្ញាតឱ្យធ្វើការចាប់ខ្លួន។

**ឆ. ការធ្វើការទទួលស្គាល់នូវសមាជិកសភាដែលត្រូវបានធ្វើការចាប់ខ្លួនមុនអាណត្តិ**

នៅពេលមានសមាជិកសភារូបណាម្នាក់ត្រូវបានចាប់ខ្លួននៅមុនពេលអាណត្តិ នៅពេលអាណត្តិចាប់ផ្តើមបើកភ្លាម គណៈរដ្ឋមន្រ្តីត្រូវរៀបចំលិខិតចំលងពីលិខិតចាំបាច់ក្នុងការទាមទារឱ្យមានការចាប់ខ្លួននោះដាក់ជូនប្រធានសភាឱ្យបានទទួលដឹង និង ទទួលស្គាល់នូវសមាជិកសភាដែលត្រូវបានធ្វើការចាប់ខ្លួននោះ[62]។

អំពីសមាជិកសភារូបណាម្នាក់ត្រូវបានចាប់ខ្លួននៅមុនពេលអាណត្តិនេះដែរ ប្រសិនបើមានសេចក្តីសម្រេចឱ្យធ្វើការពន្យាពេលនៅក្នុងការឃុំខ្លួនសមាជិកសភារូបនោះនៅក្នុងអាណត្តិ គណៈរដ្ឋមន្រ្តីត្រូវជូនដំណឹងទៅដល់ប្រធានសភាពីគោលបំណងនៃការពន្យាពេលក្នុងការឃុំខ្លួននេះ[63]។

**ជ. ការស្នើរសុំទាមទារឱ្យមានការដោះលែង**

នៅក្នុងការស្នើរទាមទារឱ្យមានការដោះលែងសមាជិកសភា ដែលត្រូវបានធ្វើការចាប់ខ្លួនមុនអាណត្តិ លុះត្រាមានការព្រមព្រៀងដោយចុះហត្ថលេខាព្រមព្រៀងពីសមាជិកសភាចំនួន២០រូបឡើងទៅ ដោយភ្ជាប់ជាមួយលិខិតចាំបាច់ក្នុងការទាមទារឱ្យមានការដោះលែងនោះដាក់ស្នើរទៅប្រធានសភា[64]។

## ២. អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់

នៅក្នុងរដ្ឋធម្មនុញ្ញមាត្រា៥១បានចែងអំពីសិទ្ធក្នុងការបញ្ចេញមតិយោបល់ របស់សមាជិកសភា។ អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិ យោបល់របស់សមាជិកសភានេះដែរ គឺបានរីកដុះដាលកកើតឡើងនៅប្រទេសអង់គ្លេស ទើបក្រោយមក ប្រទេសនីមួយៗនៅលើពិភពលោកបានចាប់ផ្តើមទទួលយកប្រព័ន្ធនៃការការពារសមាជិកសភា តាមរយៈការបញ្ចេញមតិដោយសេរីក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងនាមជាតំណាងរាស្រ្តជៀសផុតពីការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាល។ នៅ

---

[62] ច្បាប់ស្តីពីសភារបស់ជប៉ុនមាត្រា៣៤កថាខណ្ឌ២វាក្យខណ្ឌ១ ឆ្នាំ១៩៤៧

[63] ច្បាប់ស្តីពីសភារបស់ជប៉ុនមាត្រា៣៤កថាខណ្ឌ២វាក្យខណ្ឌ២ ឆ្នាំ១៩៤៧

[64] ច្បាប់ស្តីពីសភារបស់ជប៉ុនមាត្រា៣៤កថាខណ្ឌ៣ ឆ្នាំ១៩៤៧

ក្នុងការបំពេញកិច្ចការរបស់សមាជិកសភា ដោយមិនគិតពីសកម្មភាពរដ្ឋប្បវេណី ឬមួយក៏ព្រហ្មទណ្ឌឡើយ ព្រមទាំងមិនកំណត់ពីអំឡុងពេលអាណត្តិក្នុងសភាឡើយ ទោះបីនៅក្រៅសភាក៏ដោយ ក៏មានបញ្ញត្តិចែងផងដែរអំពីអភ័យឯកសិទ្ធិជាអចិន្ត្រៃយ៍មួយ ហើយបើផ្តោតការគិតទៅលើករណីដែលតម្រូវឱ្យមានការទទួលខុសត្រូវទៅលើសកម្មភាព ដែលមិនទាក់ទងទៅនឹងការបំពេញភារកិច្ច។ ត្រង់ចំនុចនេះ គួរតែធ្វើការការពារទៅលើសេរីភាពនៃការធ្វើសកម្មភាពដែលស្ថិតនៅក្នុងពេលកំពុងកាន់តំណែងក្នុងអាណត្តិសភា ដែលមានលក្ខណៈខុសគ្នាពីគោលបំណងនៃអភ័យឯកសិទ្ធិក្នុងការមិនត្រូវបានចាប់ខ្លួនរបស់សមាជិកសភា[65]។

អភ័យឯកសិទ្ធិមិនអាចត្រូវបានចាប់ខ្លួន គឺសំដៅទៅលើសេរីភាពនៃការមិនត្រូវបានចាប់ខ្លួនដោយមិនត្រឹមត្រូវ ប៉ុន្តែអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់នៅក្នុងមាត្រា៥១នេះវិញ គឺសំដៅដល់ការការពារសិទ្ធិសេរីភាព ក្នុងការនិយាយសំដែងមតិយោបល់នានារបស់សមាជិកសភានៅក្នុងសភា ដែលនេះជាការការពារទៅដល់ការបំពេញភារកិច្ច និង ការបញ្ចេញសកម្មភាពនានារបស់សមាជិកសភា ក្នុងនាមជាតំណាងរបស់ប្រជាពលរដ្ឋទូទាំងប្រទេស។ អភ័យឯកសិទ្ធិនេះ មិនមែនមានន័យថា ជាការលើកលែងទៅដល់តំណាងរាស្ត្រមិនឱ្យទទួលខុសត្រូវខាងផ្នែកនយោបាយទេ។ ក្នុងន័យនេះដែរ ប្រសិនបើសមាជិកសភារូបណាម្នាក់ បាននិយាយមិនត្រឹមត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិឯកជន និង កេរ្តិ៍ឈ្មោះរបស់ប្រជាពលរដ្ឋណាម្នាក់នោះតើគួរតែធ្វើការការពារសមាជិកសភាដោយអភ័យឯកសិទ្ធទៀត ឬក៏យ៉ាងណា?

**ក. អត្ថន័យនៃការថ្លែងសុន្ទរកថា ការបញ្ចេញយោបល់ និងការបោះឆ្នោតបញ្ចេញមតិ**

ដូចគ្នាទៅនឹងការបញ្ចេញសកម្មភាពក្នុងការបំពេញភារកិច្ចរបស់តំណាងរាស្ត្រគឺមានន័យថានៅរាល់ក្នុងសកម្មភាពរបស់តំណាងរាស្ត្រ ជាពិសេសសកម្មភាពដែលលេចធ្លោគួរឱ្យកត់សម្គាល់ដែលអាចយកមកបង្ហាញជាឧទាហរណ៍ឱ្យឃើញជាក់ស្តែង។

អត្ថន័យនៃការថ្លែងសុន្ទរកថា ការបញ្ចេញយោបល់ និងការបោះឆ្នោតបញ្ចេញមតិនៅក្នុងមាត្រា៥១នេះ បើធ្វើការសង្ខេប បង្រួមអត្ថន័យទៅ មានន័យថា ការផ្តល់វិសាលភាពនូវន័យទាំងនេះឱ្យបានទូលំទូលាយ គឺជារឿងមួយដ៏សមគួរ ថាតើការថ្លែងសុន្ទរកថាជាអ្វី ហើយការបញ្ចេញយោបល់ មានន័យយ៉ាងដូចម្តេច ហើយការបោះឆ្នោតបញ្ចេញមតិផ្តោតទៅលើអ្វីនោះ[66]។

[65]長谷部恭男『憲法』（第５版）２０１１年、３３６頁。
ហាសេបិយ៉ាសឹអុ 『រដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៥ , ឆ្នាំ២០១១, ទំព័រ៣៣៦

[66]長谷部恭男『憲法』（第５版）２０１１年、３３６頁。
ហាសេបិយ៉ាសឹអុ 『រដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៥ , ឆ្នាំ២០១១, ទំព័រ៣៣៦

ការពិភាក្សាយោបល់គឺជាការសំដែងឡើងដោយផ្ទាល់មាត់នូវមតិប្រឆាំង ឬស្របទៅលើកម្មវត្ថុនៃការប្រជុំ ចំណែកឯសុន្ទរកថាវិញ គឺជាការសំដែងចេញនូវយោបល់ដោយផ្ទាល់មាត់ដូចគ្នាតែមិនមែនជាការពិភាក្សាមានមតិស្រប មតិផ្ទុយអ្វីនោះទេ ការថ្លែងបែបនេះ ជាពិសេសគឺធ្វើឡើងនៅពេលដែលចង់ចង្អុលបង្ហាញទៅលើចំងល់ណាមួយ ទៅលើសេចក្តីព្រាងរបស់អ្នកដាក់ពាក្យស្នើរសុំ។ ចំពោះការបញ្ចេញមតិយោបល់ គឺសំដៅដល់ការសំដែងបង្ហាញនូវមតិស្រប ឬ មតិប្រឆាំងទៅលើកម្មវត្ថុនៃប្រធានបទដែលលើកឡើង នៅពេលឈរឈ្មោះ ឬ នៅពេលមានធ្វើការបោះឆ្នោតបញ្ចេញមតិណាមួយ។

ប្រសិនបើតំណាងរាស្ត្ររូបណាម្នាក់បានធ្វើសកម្មភាពណាមួយ ដែលមិនសមស្របទៅនឹងការបំពេញភារកិច្ចក្នុងមុខងាររបស់ខ្លួនតែបែរជានិយាយដើមជនដទៃ ឬ មួលបង្កាច់ និយាយបង្ខូចកេរ្តិ៍ជនដទៃតាមអំពើចិត្តនោះ ដោយអាងខ្លួនជាតំណាងរាស្ត្រមានសិទ្ធិក្នុងការបញ្ចេញមតិយោបល់នោះ គឺមិនស្ថិតក្នុងគោលដៅនៃការការពារដោយអភ័យឯកសិទ្ធិនេះទេ។

**ខ. សមាសភាគនៃអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់**

មាត្រា៦៣នៃរដ្ឋធម្មនុញ្ញជប៉ុនបានចែងថា ទោះបីជាពេលណាក៏ដោយ រាល់ពាក្យសម្តី ដែលបាននិយាយ ឬការបញ្ចេញយោបល់នានាលើសេចក្តីព្រាងច្បាប់ គឺត្រូវមានវត្តមាននៅក្នុងសភា ហេតុនេះ ទើបស្របពេលជាមួយគ្នានឹងពាក្យសម្តី ដែលបាននិយាយ ឬការបញ្ចេញយោបល់នានារបស់ខ្លួននោះ សមាជិកសភាម្នាក់ៗក៏ទាមទារឱ្យមានការការពារសិទ្ធិនោះដល់ខ្លួនផងដែរ[67]។

បើក្រលេកមើលទៅលើគោលបំណងក្នុងការផ្តល់អភ័យឯកសិទ្ធិតាមប្រទេសអង់គ្លេសក៏ដូចជាប្រទេសអាមេរិកវិញ បើគិតទៅដល់ការការពារសេរីភាពនៅក្នុងការសម្រេចសេចក្តីនៅក្នុងសភាដ៏ធំទូលាយនេះ វិសាលភាពនៃអភ័យឯកសិទ្ធិនេះ មិនកំណត់មានតែចំពោះសមាជិកសភា តែប៉ុណ្ណោះទេ ប៉ុន្តែក៏បានធ្វើការផ្តល់អភ័យឯកសិទ្ធិនេះទៅដល់សមាជិករដ្ឋាភិបាល ដែលកំពុងកាន់តួនាទីក្នុងតំណែងផងដែរ។ ប៉ុន្តែនៅប្រទេសជប៉ុនវិញ គឺដូចគ្នាទៅនឹងប្រទេសបារាំង និង អាឡឺម៉ង់ដែរ គឺការជ្រើសរើសយកប្រព័ន្ធនៃការផ្តល់អភ័យឯកសិទ្ធិនេះ គឺក្នុងគោលបំណងដើម្បីផ្តល់ការការពារឯករាជ្យមួយទៅដល់សមាជិកសភា។ នៅប្រទេសជប៉ុន រដ្ឋមន្ត្រីក្រសួងការពារជាតិ ដែលបានធ្វើការបញ្ចេញមតិយោបល់ក្នុងនាមជារដ្ឋមន្ត្រី គឺមិនទទួលបានអភ័យឯកសិទ្ធិទេ។

នៅក្នុងរដ្ឋធម្មនុញ្ញបានចែងបញ្ជាក់យ៉ាងច្បាស់ហើយថា អ្នកដែលអាចទទួលបាននូវអភ័យឯកសិទ្ធិនេះគឺសមាជិកសភា។ សមាជិកសភាដែលបានក្លាយទៅជានាយករដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី

[67]渋谷秀樹・赤坂正浩『憲法２統治』（第４版）（２０１０年）（８６頁。）
ស៊ិបឹតានិហ៊ីដេគិ・អាកៈសាកៈម៉ាសាហ៊ិរ៉ុ 『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤, ឆ្នាំ២០១០, ទំព័រ៨៦

ឧបនាយករដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័ននីតិប្រតិបត្តិ បើទោះបីជាធ្វើការសំដែងមតិយោបល់នៅក្នុងសភាក៏ដោយ ក៏មិនត្រូវបានការពារដោយអភ័យឯកសិទ្ធិនេះដែរ។ មានន័យថា អភ័យឯកសិទ្ធិមួយនេះ គឺមានអនុភាពអនុវត្តបានតែចំពោះសមាជិកសភាតែប៉ុណ្ណោះ ចំពោះប្រជាពលរដ្ឋ ប្រជាជនធម្មតា ឬនរណាក៏ដោយក៏គ្មានការការពារដោយអភ័យឯកសិទ្ធិនេះដែរ។

**គ. ទំហំនៃអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់**

ពាក្យថា«ក្នុងសភា» និង «ក្រៅសភា» មិនមែនសំដៅទៅលើក្នុង និង ក្រៅសំណង់អគាររបស់សភានោះទេ។ ការចូលរួមបញ្ចេញសកម្មភាព ក្រោមការបំពេញតួនាទីភារកិច្ចរបស់ខ្លួនក្នុងនាមជាសមាជិកសភា នៅក្នុងការប្រជុំពេញអង្គ គណៈកម្មាធិការ ការជួបប្រជុំរវាងសភាទាំងពីរ វេទិការសាកសួរផ្លាស់ប្តូរយោបល់ជាសាធារណៈជាដើមនោះ រាល់ការថ្លែងសុន្ទរកថា ការពិភាក្សា និងការបញ្ចេញមតិយោបល់ទាំងនោះគឺត្រូវទទួលបានការការពារ[68]។ ការពិភាក្សាគឺជាការសំដែងឡើងដោយផ្ទាល់មាត់នូវមតិប្រឆាំង ឬស្របទៅលើកម្មវត្ថុនៃការប្រជុំ ចំណែកឯសុន្ទរកថាវិញ គឺជាការសំដែងចេញនូវយោបល់ដោយផ្ទាល់មាត់ដូចគ្នា តែមិនមែនជាការពិភាក្សាមានមតិស្របមតិផ្ទុយអ្វីនោះទេ ការថ្លែងបែបនេះ ជាពិសេសគឺធ្វើឡើងនៅពេលដែលចង់ចង្អុលបង្ហាញទៅលើចំងល់ណាមួយទៅលើសេចក្តីព្រាងរបស់អ្នកដាក់ពាក្យស្នើរសុំ។ ចំពោះការបញ្ចេញមតិយោបល់ គឺសំដៅដល់ការសំដែងបង្ហាញនូវមតិស្របឬមតិប្រឆាំងទៅលើកម្មវត្ថុនៃប្រធានបទដែលលើកឡើង នៅពេលឈរឈ្មោះ ឬនៅពេលមានធ្វើការបោះឆ្នោតបញ្ចេញមតិណាមួយ។

ការនិយាយដើមជាសំងាត់ ឬការនិយាយចំអកចំអន់បញ្ចើចបញ្ចើដោយមានការប្រើប្រាស់សកម្មភាពហិង្សាណាមួយនោះ ទោះបីនេះជាការសំដែងយោបល់ក្នុងនាមជាសមាជិកសភាក៏ដោយ គឺមិនរាប់បញ្ចូលជាគោលដៅ ដែលស្ថិតក្នុងការផ្តល់អភ័យឯកសិទ្ធិមួយនេះ ទៅលើសកម្មភាពបែបនោះឡើយ។ ផ្ទុយទៅវិញការផ្តល់អភ័យសិទ្ធិក្នុងន័យនេះ មិនកំណត់តែទៅលើការថ្លែងសុន្ទរកថា ការពិភាក្សា ការបញ្ចេញមតិយោបល់តែប៉ុណ្ណោះទេ តែអាចរាប់បញ្ចូលទាំងសកម្មភាពមួយចំនួនដែលយើងមិនអាចធ្វើការបែងចែកឱ្យដាច់ថាតើសកម្មភាពនោះ មានទំនាក់ទំនងទៅនឹងការថ្លែងសុន្ទរកថា ឬជាការពិភាក្សា ឬជាការបញ្ចេញមតិយោបល់គឺមិនអាចធ្វើការវែកញែកបានឡើយថាចូលទៅក្នុងសកម្មភាពណាមួយនៃសកម្មភាពទាំងនេះ ប៉ុន្តែវាជាប់ទាក់ទងទៅនឹងគោលបំណងនៃសកម្មភាពដែលអាចទទួលបាន ការការពារដោយអភ័យឯកសិទ្ធិផងដែរ។

[68]渋谷秀樹・赤坂正浩『憲法２統治』（第４版）（２０１０年）（８６頁。）
ស៊ិបឺតានិហ៊ីដេគិ・អាកៈសាកៈម៉ាសាហ៊ិរ៉ុ 『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤, ឆ្នាំ២០១០, ទំព័រ៨៦

**ឃ. សកម្មភាពនៅក្នុងសភា**

«សកម្មភាព» ដែលបានចែងក្នុងមាត្រានេះ គឺរាល់សកម្មភាពដែលសមាជិកសភាបានបំពេញក្នុងតួនាទីភារកិច្ចក្នុងនាមជាសមាជិករបស់សភាមួយរូប។ ក្នុងសកម្មភាពនេះគឺ មិនទាក់ទងដល់ ការចូលរួមប្រជុំពេញអង្គ ឬ ការប្រជុំរបស់គណៈកម្មាធិការទេ ឧទាហរណ៍ដូចជាមានការបើកវេទិការសាកសួរ និងផ្លាស់ប្តូរយោបល់ជាសាធារណៈជាដើមនៅខាងក្រៅសភា[៦៩]។

មួយវិញទៀត ការបំពេញសកម្មភាពក្នុងនាមជាសមាជិកសភា ទោះបីជាស្ថិតក្នុងពេលបញ្ចប់អាណត្តិក៏ដោយ ឧទាហរណ៍ដូចជាការបំពេញសកម្មភាពនៅក្នុងពិធីបិទបញ្ចប់អាណត្តិជាដើម។

ប្រសិនបើតំណាងរាស្ត្រ បានធ្វើការផ្សព្វផ្សាយរាល់ការបញ្ចេញមតិរបស់ខ្លួននៅក្នុងសភាទៅដល់សាធារណៈជនខាងក្រៅវិញ តើទៅជាយ៉ាងណា?

បើនៅក្នុងរដ្ឋធម្មនុញ្ញសម័យម៉េជិវិញ គឺបើក្នុងករណីសមាជិកសភាណាម្នាក់ប្រព្រឹត្តិបែបនេះ គឺមិនទទួលបានការការពារតាមរយៈអភ័យឯកសិទ្ធិនេះទេ(មាត្រា៥២)។ ការផ្សព្វផ្សាយរាល់ពាក្យសំដី ឬមតិដែលខ្លួននិយាយនៅក្នុងសភាទៅដល់សាធារណៈជនខាងក្រៅនោះគឺមិនមែន"ជាសកម្មភាពនៅក្នុងសភា"ទេ។ ក៏ប៉ុន្តែ ប្រសិនបើមានការបើកពិធីប្រជុំជាសាធារណៈរបស់សភាដើម្បីផ្សព្វផ្សាយទៅដល់ពលរដ្ឋតាមមាត្រា៥៧រដ្ឋធម្មនុញ្ញវាក្យខណ្ឌ១ និង ២ បើទោះបីជាបានបញ្ចេញមតិផ្ទាល់ខ្លួនជាសាធារណៈបន្តិចបន្តួចយ៉ាងណាក្តី មួយវិញទៀតទោះបីជាមិនស្ថិតក្នុងពេលកំពុងតែប្រារព្ធពិធីនោះក៏ដោយ ក៏មិនត្រូវមានការផ្លាស់ប្តូរនូវអត្ថន័យដែលបញ្ចេញមតិនៅក្នុងសភាឡើយទើបទទួលបានការពារដោយអភ័យឯកសិទ្ធិនេះ។

**ង. ប្រសិទ្ធិភាពនៃអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់**

នៅក្នុងមាត្រា៥១ត្រង់ឃ្លាដែលបញ្ជាក់ថា« មិនទទួលខុសត្រូវនៅក្រៅសភា»នោះគឺសំដៅទៅដល់ការមិនទទួលខុសត្រូវតាមផ្លូវច្បាប់ទៅលើករណីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។ ប្រជាពលរដ្ឋទូទៅដែលមិនមែនជាសមាជិកសភា ក្នុងករណីបានប្រព្រឹត្តិបទល្មើសនាំឱ្យមានទោសណាមួយ ដូចជាទោសនៃការប្រព្រឹត្តិបទបរិហារកេរ្តិ៍ ឬបទហែកកេរ្តិ៍ធ្វើឱ្យខូចកេរ្តិ៍ឈ្មោះបុគ្គលណាម្នាក់ ប្រជាពលរដ្ឋរូបនោះនឹងត្រូវតែទទួលខុសត្រូវទៅលើការសងសំណងជំងឺចិត្តទៅដល់ជនរងគ្រោះ ដោយសារតែបានធ្វើឱ្យបានប៉ះពាល់ដល់ជីវិតឯកជន និងកេរ្តិ៍ឈ្មោះរបស់ជនដទៃទោះបីនេះជាការបញ្ចេញយោបល់ទៅតាមគំនិតយល់ឃើញ ឬក៏បានដឹងច្បាស់ថានោះជាការពិតក៏ដោយក៏ការបរិហារកេរ្តិ៍ជនដទៃដោយចាត់ទុកថា នេះក៏ជាសិទ្ធិក្នុងការបញ្ចេញយោបល់ដែរនោះ គឺមិនត្រូវបានអនុញ្ញាត

[69]渋谷秀樹・赤坂正浩『憲法２統治』（第４版）（２０１０年）（８６頁。）
ស៊ិបឹតានិហ៊ីដេគិ・អាកៈសាកៈម៉ាសាហ៊ិរ៉ុ 『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤, ឆ្នាំ២០១០, ទំព័រ៨៦

ឡើយ [70] ។ ផ្ទុយទៅវិញ ក្នុងករណីសមាជិកសភាក្នុងនាមជាអ្នកតំណាងរាស្ត្រដែលបានបញ្ចេញសកម្មភាពទទួលបន្ទុកបំពេញភារកិច្ចសំខាន់នានារបស់សភា គឺមិនទទួលខុសត្រូវទៅលើករណីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីដូចក្នុងករណីខាងលើ ដែលតម្រូវឱ្យប្រជាពលរដ្ឋធម្មតាទូទៅត្រូវទទួលខុសត្រូវនោះឡើយ។ ជាការពិតណាស់ ការជំរុញឱ្យមានការទទួលខុសត្រូវឱ្យមានភាពសមហេតុសមផលក្នុងន័យនយោបាយ គឺជាចំនុចបញ្ហាមួយដោយឡែក។ កាលពីមុន អភ័យឯកសិទ្ធិតាមផ្លូវច្បាប់ គឺជាអភ័យឯកសិទ្ធិដែលមានលក្ខណៈដាច់ខាតដែលពុំអាចជំទាស់បាន និង មិនអាចដកហូតបាន។ ប៉ុន្តែនៅពេលបច្ចុប្បន្នវិញ ដោយសារការយល់ឃើញថា វាជារឿងមិនសមហេតុផលទេ ដែលត្រូវផ្តល់ការការពារតាមផ្លូវច្បាប់ទៅដល់សមាជិកសភាដែល បានធ្វើការបញ្ចេញមតិយោបល់របស់ខ្លួនដោយការធ្វេសប្រហែស និងបង្កប់ទៅដោយគំនិតមិនល្អដែលនាំឱ្យប៉ះពាល់ទៅដល់ជីវិតឯកឯន និងកេរ្តិ៍ឈ្មោះរបស់ប្រជាពលរដ្ឋទូទៅនោះ ក្នុងករណីនេះ ការការពារដោយអភ័យឯកសិទ្ធិតាមច្បាប់គឺជារឿងមួយមិនសមហេតុផល។

### ច. ទស្សនៈវិស័យក្នុងការផ្តល់អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់

សកម្មភាពដែលត្រូវបានការពារដោយអភ័យឯកសិទ្ធិ គឺជាសកម្មភាពដែលបានប្រព្រឹត្តិនៅក្នុងសភា មានន័យថា គឺជាសកម្មភាពដែលសមាជិកសភាបានប្រព្រឹត្តិក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ នៅក្នុងការប្រជុំពេញអង្គ ក្រៅពីសកម្មភាពនៅក្នុងគណៈកម្មាធិការ ដោយយោងទៅតាមការមើលទៅលើសកម្មភាពរបស់សមាជិកសភា ដែលមិនត្រឹមតែជាសកម្មភាពនៅក្នុងសភាទេ ទោះបីជាសកម្មភាពដែលបានប្រព្រឹត្តិឡើងនៅក្រៅសភា ដូចជានៅក្នុងវេទិកាសាកសួរផ្លាស់ប្តូរយោបល់ជាសាធារណៈដែលប្រព្រឹត្តិឡើង នៅក្រៅសភាក៏ដោយក៏រាប់បញ្ចូលជាសកម្មភាពដែលត្រូវទទួលបានការការពារដោយអភ័យឯកសិទ្ធិផងដែរ [71] ។ ប្រសិនបើជាការបញ្ចេញសកម្មភាពនៅក្នុងការបំពេញតួនាទីរបស់សមាជិកសភា តាមន័យចង្អៀត ទោះបីជាមិនមែនស្ថិតនៅក្នុងពេលថ្លែងសុន្ទរកថា ពិភាក្សា និងបញ្ចេញមតិយោបល់ក៏ដោយ ក៏ការបញ្ចេញសកម្មភាពនោះ គឺស្ថិតក្នុងទស្សនៈវិស័យនៃការផ្តល់អភ័យឯកសិទ្ធិផងដែរ លើកលែងតែធ្វើសកម្មភាពហិង្សាគឺមិនផ្តល់ការការពារឱ្យឡើយ។

សិទ្ធិក្នុងការទទួលស្គាល់អំពីទស្សនៈវិស័យដែល ថាតើស្ថានភាពបែបណាមួយគួរតែស្ថិតក្នុងការការការពារពីអភ័យឯកសិទ្ធិ ឬស្ថានភាពណាមិនគួរទទួលបានការការពារនោះ គឺជាសិទ្ធិ

[70]渋谷秀樹・赤坂正浩『憲法２統治』（第４版）（２０１０年）（８６頁。）
ស៊ិប៊ឺតានិហ៊ីដេគិ・អាកៈសាកៈម៉ាសាហ៊ិរុ 『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤, ឆ្នាំ២០១០, ទំព័រ៨៦
[71]長谷部恭男『憲法』（第５版）２０１１年、３３７頁。
ហាសេបិយ៉ាសឹអុ 『រដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៥ , ឆ្នាំ២០១១, ទំព័រ៣៣៧

របស់តុលាការ។ ចំពោះបណ្ដឹងទាក់ទងទៅនឹងការប្រព្រឹត្តិបទល្មើសណាមួយ ដែលជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពបំពេញភារកិច្ចរបស់សមាជិកសភារូបនោះ ការតម្រូវមានការព្រមព្រៀងឱ្យសមាជិករូបនោះជាប់ពិរុទ្ធពីសំណាក់ប្រធានសភា គឺជារឿងសំខាន់ណាស់។

**ឆ. ព្រំដែននៃអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់**

យោងទៅលើគោលជំហរ ដែលមានការតម្រូវទាមទារឱ្យចាំបាច់ត្រូវតែធ្វើការផ្ដល់នូវអភ័យឯកសិទ្ធិទៅដល់សមាជិកសភាដើម្បីឱ្យសមាជិកសភា អាចបំពេញកិច្ចការរបស់ខ្លួន ដើម្បីផលប្រយោជន៍សាធារណៈនោះ នៅពេលដែលមានការប៉ះទង្គិចជាមួយនឹងសិទ្ធិរបស់ប្រជាពលរដ្ឋទូទៅជាធម្មតា មិនគួរផ្ដល់អទិភាពដល់សមាជិកសភាដែលមានអភ័យឯកសិទ្ធិនោះទេ ជាពិសេសនៅក្នុងករណីដែលប្រសិនបើសមាជិករូបនោះបានបញ្ចេញយោបល់ណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាពជីវិតឯកជនរបស់ពលរដ្ឋទូទៅណាមួយ ឬមួយបានធ្វើការរំលោភបំពានសិទ្ធិជនដទៃដោយធ្វើការបរិហារកេរ្តិ៍ជននោះជាដើម គឺមិនគួរផ្ដល់ការការពារតាមផ្លូវច្បាប់ណាមួយទៅដល់សមាជិកសភារូបនោះឡើយ[72] ។ ការបញ្ចេញយោបល់ក្នុងសភារបស់សមាជិកសភាគឺត្រូវបានចាត់ទុកថាជាការធ្វើសកម្មភាពបំពេញកិច្ចការក្នុងនាមជាមន្ត្រីរាជការសាធារណៈ ហេតុដូចនេះហើយ ការធ្វើឱ្យសម្រេចជាលទ្ធផលនូវច្បាប់ស្ដីពីសំណងជំងឺចិត្តរបស់រដ្ឋ ដែលតម្រូវឱ្យរដ្ឋត្រូវទទួលខុសត្រូវឬយ៉ាងណានោះគឺបានក្លាយទៅជាបញ្ហាចោទ។ នៅត្រង់ចំនុចនេះ ក្នុងករណីដែលសមាជិកសភារូបណាមួយបានបញ្ចេញយោបល់បរិហារប៉ះពាល់ទៅដល់ប្រជាពលរដ្ឋ ឬបានស្ដែងយោបល់ដែលនាំឱ្យមានការថមថយចុះនូវទំនុកចិត្តរបស់ពលរដ្ឋមកលើសភានៅក្នុងសភានោះ យោងទៅតាមមាត្រា១វាក្យខណ្ឌ១នៃច្បាប់នេះបានចែងថា ដើម្បីឱ្យការអនុវត្តច្បាប់ស្ដីពីសំណងជំងឺចិត្តរបស់រដ្ឋមានភាពវិជ្ជមាន ប្រសិនបើមានសមាជិកសភារូបណាម្នាក់បានធ្វើសកម្មភាពផ្ទុយពីច្បាប់ សមាជិកសភាដែលបានធ្វើសកម្មភាពមិនជាប់ពាក់ព័ន្ធទៅនឹងភារកិច្ច ហើយមានគោលបំណងធ្វើមិនត្រឹមត្រូវ និងមិនស្របច្បាប់ រួមទាំងបានដឹងថាអ្វីដែលខ្លួនបានប្រព្រឹត្តិគឺជាការបោកប្រាស់តែនៅតែប្រព្រឹត្តិទៀតនោះ គឺសិទ្ធិអំណាចរបស់សមាជិកសភាដែលអភ័យឯកសិទ្ធិរូបនេះ ។

ពាក់ព័ន្ធទៅនឹងការកំណត់ព្រំដែននៃអភ័យឯកសិទ្ធិនេះដែរ ថាតើទោះបីជាសមាជិកសភាមានអភ័យឯកសិទ្ធិក៏ពិតមែន ប៉ុន្តែសមាជិកសភាអាចប្រើប្រាស់ និងអនុវត្តនូវសិទ្ធិដែលមានអភ័យ

[72]渋谷秀樹・赤坂正浩『憲法２統治』（第４版）（２０１０年）（８７頁。）
ស៊ិបឹតានិហ៊ីដេគិ・អាកៈសាកៈម៉ាសាហ៊ិរុ 『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤, ឆ្នាំ២០១០, ទំព័រ៨៧
長谷部恭男『憲法』（第５版）２０１１年、３３７頁。
ហាសេបិយ៉ាសឹអុ 『រដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៥ , ឆ្នាំ២០១១, ទំព័រ៣៣៧

ឯកសិទ្ធិនោះបានត្រឹមកម្រិតណាមួយ។ ទាក់ទិននឹងបញ្ហានេះ មានទ្រឹស្តីចំនួនពីរដែលបានធ្វើការទាមទារឱ្យមានការកំណត់ដែនអភ័យឯកសិទ្ធិ។

ទ្រឹស្តីទី១បានលើកឡើងដោយឈរលើគោលជំហរថា នៅពេលដែលប្រជាពលរដ្ឋទូទៅយល់ឃើញថាការនិយាយបញ្ចេញយោបល់របស់សមាជិកសភានៅក្នុងសភា បានបំពានទៅដល់ជីវិតឯកជន និង កេរ្តិ៍ឈ្មោះរបស់ខ្លួននោះ ប្រជាពលរដ្ឋអាចធ្វើបណ្តឹងទាមទារឱ្យរដ្ឋសងជំងឺចិត្តដល់ខ្លួនពីការរំលោភបំពាននោះបាន។

ទ្រឹស្តីទី២បានធ្វើការអះអាងបន្ថែមទៅលើទ្រឹស្តីទី១ថា នេះមិនត្រឹមតែជាការទទួលខុសត្រូវរបស់រដ្ឋទេ បើមានករណីបែបនេះកើតឡើង សមាជិកសភាខ្លួនឯងផ្ទាល់ក៏អាចត្រូវឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីនេះផងដែរ។ សមាជិកសភាខ្លួនឯងបានដឹងហើយថា អ្វីដែលខ្លួនបាននិយាយបានធ្វើគឺជាការកុហកបំភ្លៃការពិត ថែមទាំងមិនខ្វល់ថាតើពាក្យសំដីរបស់ខ្លួនឯងផ្ទាល់បានកុហក ឬមិនកុហកទេ ប៉ុន្តែនៅតែនិយាយបញ្ចេញយោបល់របស់ខ្លួនបំពានទៅលើជីវិតឯកជន និងកេរ្តិ៍ឈ្មោះរបស់ពលរដ្ឋទៀត។ នៅក្នុងករណីបែបនេះ ទ្រឹស្តីទី២បានបង្ហាញគោលជំហររបស់ខ្លួនក្នុងនាមជាពលរដ្ឋដើមបណ្តឹង ហើយទាមទារឱ្យមានការកំណត់ព្រំដែននៃអភ័យឯកសិទ្ធិរបស់សមាជិកសភា ដោយមិនគួរត្រូវបានផ្តល់នូវសិទ្ធិបែបនេះខ្លាំងក្លាពេកឡើយ។

ប៉ុន្តែ ទាក់ទិនទៅនឹងការបញ្ចេញមតិយោបល់នៅក្នុងសភានេះដែរ ប្រសិនបើឱ្យសមាជិកសភាខ្លួនឯងផ្ទាល់ក្លាយជាភាគីនៃបណ្តឹងរដ្ឋប្បវេណី សមាជិកសភារូបនោះនឹងត្រូវក្លាយទៅជាចុងចម្លើយ។ វាជារឿងចាំបាច់មួយដែលតម្រូវឱ្យចុងចម្លើយចូលខ្លួនទៅតតាំងក្តីនៅសវនាការដោយផ្ទាល់។ នេះការទទួលខុសត្រូវរបស់សមាជិកសភាដែលបានបង្កឱ្យកើតមានរឿងក្តីបែបនេះដោយសារតែការថ្លែងមតិយោបល់របស់ខ្លួន។ ប៉ុន្តែប្រសិនបើធ្វើការពិចារណាឱ្យបានល្អិតល្អន់ទៅលើករណីនេះ ប្រសិនបើឱ្យសមាជិកសភាទទួលខុសត្រូវដោយសារតែការបញ្ចេញមតិយោបល់របស់ខ្លួនបែបនេះ ហាក់ដូចជាធ្វើឱ្យប៉ះពាល់ដល់អនុភាពនៃពាក្យសម្តី និងគំនិតយោបល់របស់សមាជិកសភា ហើយធ្វើឱ្យចុះអន់ថយនូវការញេញមតិយោបល់ក្នុងនាមជាសមាជិកសភា។

ហេតុនេះ បើធ្វើការប្រៀបធៀបរវាងទ្រឹស្តីទាំងពីរ ទ្រឹស្តីទី១ហាក់ដូចជាមានភាពសមរម្យជាងទ្រឹស្តីទី២។

**៩. ភាពចាំបាច់ឬមិនចាំបាច់នៃការចេញដីការបណ្តោះអាសន្នឱ្យសមាជិកសភាជាប់ពិរុទ្ធ**

នៅពេលដែលមានការផ្ទុះឡើងនូវជំលោះក្នុងសភា រហូតមានការប្តឹងដាក់បណ្តឹងព្រហ្មទណ្ឌទៅលើសមាជិកសភាដែលបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌនោះ តើការចេញដីការបណ្តោះ

អាសន្នដាក់ឱ្យជាប់ពិរុទ្ធដល់សមាជិកសភារូបនោះ តើចាំបាច់ឬមួយយ៉ាងណានោះបានក្លាយទៅជាបញ្ហា។ ទាក់ទិននឹងបញ្ហានេះ មានអនុសាសន៍ជាច្រើនបានលើកឡើងដោយមានមតិផ្ទុយគ្នា។

**នៅក្នុងករណីចាំបាច់:**

អនុសាសន៍ដែលគាំទ្រឱ្យមានការចេញដីការបណ្តោះអាសន្នបានលើកឡើងថា សមាជិកសភាត្រូវតែធ្វើសកម្មភាពក្នុងនាមជាតំណាងរាស្ត្រដែលត្រូវបំពេញក្នុងតួនាទីភារកិច្ច។ ហេតុនេះគួរតែពិចារណាទៅមើលថា សមាជិកសភារូបនោះបានបញ្ចេញសកម្មភាពតាមតួនាទីភារកិច្ច ឬមិនមែននោះជារឿងមួយដែលត្រូវធ្វើការកត់សម្គាល់មុនគេ មានន័យថាត្រូវគិតទៅលើសកម្មភាពដែលសមាជិកសភារូបនោះបានធ្វើ។ ប៉ុន្តែ ដោយសារការអនុវត្តសិទ្ធិក្នុងតួនាទីរបស់ខ្លួនដែលសមាជិកសភាយល់ថាខ្លួនមានសិទ្ធិចាំបាច់ និង មិនអាចខ្វះបាននោះបាននាំឱ្យសមាជិកសភាចេះតែធ្វើសកម្មភាពមួយចំនួនដែលរំលោភបំពានលើសិទ្ធិស្វ័យភាពរបស់ខ្លួន ។ បញ្ហាដែលកើតចេញពីការរំលោភបំពានលើសិទ្ធិស្វ័យភាពនោះមានច្រើនករណីរួចមកហើយ ដែលនេះជាហេតុផលសំខាន់ចាំបាច់បំផុតក្នុងការលើកយកមកធ្វើជាមូលហេតុនៃភាពចាំបាច់ ក្នុងការចេញដីការបណ្តោះអាសន្នដាក់ឱ្យជាប់ពិរុទ្ធក្នុងករណីមានការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌណាមួយ។

**នៅក្នុងករណីមិនចាំបាច់:**

ទន្ទឹមនឹងមានអនុសាសន៍លើកឡើងពីភាពចាំបាច់ ក៏មានអនុសាសន៍លើកផ្ទុយពីនេះដែរថាបើសិនពិចារណាទៅមើលថា សមាជិកសភារូបនោះបានបញ្ចេញសកម្មភាពតាមតួនាទីភារកិច្ច ឬមិនមែននោះជារឿងមួយដែលត្រូវធ្វើការកត់សម្គាល់ក៏ពិតមែន តែអាចធ្វើការបែងចែកដោយរបៀបណាថាសកម្មភាពណាស្ថិតក្នុងគោលដៅការពារដោយអភ័យឯកសិទ្ធិ ហើយសកម្មភាពណាមិនមែននោះ គឺជារឿងមួយដ៏ពិបាក។ ក្នុងករណីនេះ មានការទាមទារឱ្យគួរតែផ្តល់សិទ្ធិអទិភាពដល់សមាជិកសភានូវសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចនៅក្នុងសភាវិញជាការល្អជាង និង ចាំបាច់ជាង។ យ៉ាងណាមិញ ពាក់ព័ន្ធនឹងការផ្តល់អភ័យឯកសិទ្ធិនេះ បើឱ្យលើកយកបញ្ហារវាងការផ្តល់សិទ្ធិ ក្នុងការសម្រេចសេចក្តី និងសិទ្ធិស្វ័យភាពរបស់សមាជិកសភាមកធ្វើការចងភ្ជាប់គ្នា ហើយធ្វើការពិចារណាទៅលើចំនុចនេះ យើងឃើញមានភាពមន្ទិលសង្ស័យច្រើន។ ក្នុងករណីនេះ បញ្ហាដែលថា បើផ្តល់សិទ្ធិក្នុងការធ្វើសេចក្តីសម្រេចដល់សមាជិកសភារូបនោះ គឺគួរតែមិនគួរផ្តល់សិទ្ធិស្វ័យភាពឱ្យដល់សមាជិកសភារូបនោះទៀតទេ។

ជាសរុបទៅ ការដែលចាំបាច់ក្នុងការដាក់ឱ្យជាប់ពិរុទ្ធដោយចេញដីការបណ្តោះអាសន្ននោះគឺមិនមានចែងនៅក្នុងរដ្ឋធម្មនុញ្ញទេ។ បើពិចារណាទៅលើចំនុចនេះ ការចេញដីការបណ្តោះអាសន្នគឺមិនមានភាពចាំបាច់ទេ។

## ផ្នែកទី៣ ការសិក្សាប្រៀបធៀបអភ័យឯកសិទ្ធិសមាជិករដ្ឋសភានៅប្រទេសកម្ពុជា និង ប្រទេសជប៉ុន

ដោយឈរលើគោលជំហរនៃការបែងចែកអំណាចដាច់ពីគ្នារវាងស្ថាប័ននីតិបញ្ញត្តិ ប្រតិបត្តិ និងតុលាការតាមបែបលទ្ធិប្រជាធិបតេយ្យ ដោយឡែកបើក្រលេកមើលទៅលើស្ថាប័ននីតិបញ្ញត្តិវិញប្រទេសកម្ពុជា និងប្រទេសជប៉ុនសុទ្ធតែបានជ្រើសរើសយកប្រព័ន្ធនៃការផ្តល់អំណាច តាមបែបសភានិយមដោយអនុវត្តទ្វិកសភានិយម មានស្ថាប័ននីតិបញ្ញត្តិជាស្ថាប័នដែលមានអំណាចកំពូលដែលមានរដ្ឋសភាជាសភាជាន់ទាប និងព្រឹទ្ធសភាជាសភាជាន់ខ្ពស់។ យ៉ាងណាមិញ ប្រទេសទាំងពីរសុទ្ធតែបានផ្តល់តួនាទី និងសិទ្ធិក្នុងការសម្រេចសេចក្តីសំខាន់ៗមួយចំនួន ទៅដល់រដ្ឋសភាលើសព្រឹទ្ធសភា។ ហេតុនេះ សរបញ្ជាក់ឱ្យឃើញថាសមាជិករដ្ឋសភានៃប្រទេសទាំងពីរគឺដើរតួនាទីសំខាន់ណាស់ក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ដែលតំណាងឱ្យប្រជាពលរដ្ឋទូទាំងប្រទេសតាមរយៈការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដូចគ្នា។ យ៉ាងណាមិញ ដើម្បីឱ្យសមាជិករដ្ឋសភាដែលជាតំណាងរាស្ត្រអនុវត្តការងារប្រកបដោយប្រសិទ្ធភាព ការផ្តល់អភ័យឯកសិទ្ធិសភាទៅឱ្យអ្នកតំណាងរាស្ត្រ គឺជារឿងដែលត្រូវតែធ្វើនៅក្នុងរបបសភានិយម។ បើក្រលេកទៅមើលពីប្រវត្តិនៃការផ្តល់អភ័យឯកសិទ្ធិ នៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ក៏ដូចជាប្រទេសជប៉ុនផងដែរដែរ គឺសុទ្ធតែបានទទួលឥទ្ធិពលពីការអនុវត្តសភានិយមដូចគ្នា ដោយបានចែងបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញដោយយោងទៅតាមរបត់នៃប្រវត្តិសាស្ត្ររៀងខ្លួន។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ដោយយោងទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់របស់ប្រទេសនីមួយៗគឺមិនមានលក្ខណៈដូចគ្នាទាំងស្រុងនោះឡើយ គឺពិតជាមានចំនុចខុសគ្នានៅក្នុងការអនុវត្តទាំងនោះទៅតាមប្រទេសនីមួយៗ។

បន្ទាប់ពីបានស្វែងយល់រួចមកហើយ អំពីការផ្តល់អភ័យឯកសិទ្ធិរបស់ប្រទេសកម្ពុជា និងប្រទេសជប៉ុនរួចមក ដើម្បីឱ្យកាន់តែច្បាស់លាស់ទៅទៀត នៅក្នុងផ្នែកនេះយើងនឹងធ្វើការសិក្សាប្រៀបធៀបរកចំនុចស្របគ្នា(កថាខណ្ឌទី១) និង ចំនុចខុសគ្នា(កថាខណ្ឌទី២)រវាងការផ្តល់អភ័យឯកសិទ្ធិរវាងប្រទេសទាំងពីរ។

### កថាខណ្ឌទី១ ចំនុចស្របគ្នានៃការផ្តល់អភ័យឯកសិទ្ធិ

តាមរយៈការផ្តល់អភ័យឯកសិទ្ធិសភាទៅដល់សមាជិករដ្ឋសភានៅក្នុងរដ្ឋធម្មនុញ្ញ រួមទាំងការអនុវត្តជាក់ស្តែង យើងក្រលេកឃើញថា នៅក្នុងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាមានចែងត្រឹមតែ មួយមាត្រាប៉ុណ្ណោះ និងមានចែងបន្ថែមទៀតនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ រីឯនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសជប៉ុនមានចែងតែពីរមាត្រា និងមានបញ្ញត្តិបន្ថែមទៀតនៅក្នុងច្បាប់ស្តីពីសភា ប៉ុន្តែបើពិនិត្យទៅលើអត្ថន័យខ្លឹមសារនៃមាត្រានីមួយៗរវាងប្រទេសទាំងពីរ ក៏ដូចជាតាមការបក

ស្រាយពន្យល់ ក្នុងបណ្ដាសៀវភៅផ្នែកនីតិរដ្ឋធម្មនុញ្ញទាក់ទិននឹងអភ័យឯកសិទ្ធិរដ្ឋសភានេះ យើងអាចមើលឃើញពីចំនុចស្របគ្នាមួយចំនួនគឺទៅលើផ្នែក គោលបំណងនៃការផ្ដល់អភ័យឯកសិទ្ធិ(១) លក្ខណៈនៃ អភ័យឯកសិទ្ធិ(២)។

**១. គោលបំណងនៃការផ្ដល់អភ័យឯកសិទ្ធិ**

យោងទៅតាមវាក្យខណ្ឌ២នៃមាត្រា៨០នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា បានចែងថា តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។

រីឯនៅក្នុងកថាខណ្ឌ២នៃមាត្រា៥០នៃរដ្ឋធម្មនុញ្ញជប៉ុន បានចែងថា លើកលែងតែមានច្បាប់ដទៃទៀតបានចែង សមាជិកសភាមិនអាចត្រូវបានចាប់ខ្លួននៅក្នុងអាណត្តិរបស់ខ្លួនឡើយ និងមាត្រា៥១បានចែងអំពីសិទ្ធក្នុងការបញ្ចេញយោបល់ និងការបោះឆ្នោតបញ្ចេញមតិរបស់សមាជិកសភា។ មាត្រានេះបានចែងបញ្ជាក់ថាការថ្លែងសុន្ទរកថា ការជជែកវែកញែកពិភាក្សា និងការបោះឆ្នោតបញ្ចេញមតិរបស់សមាជិកសភាទាំងពីរនៅក្នុងសភា គឺមិនទទួលខុសត្រូវនៅខាងក្រៅសភាឡើយ។

យើងអាចនិយាយបានថា ន័យរបស់វាក្យខណ្ឌ២នៃមាត្រា៨០នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាគឺគ្រោបរួមទាំងការបញ្ចេញមតិ និងការមិនត្រូវបានចាប់ខ្លួន ឃុំខ្លួន ឃាត់ខ្លួន។ រីឯ រដ្ឋធម្មនុញ្ញរបស់ប្រទេសជប៉ុនគឺបែងចែកជា២មាត្រា ដោយមួយមាត្រាចែងអំពីការមិនត្រូវបានចាប់ខ្លួន និងមួយមាត្រាទៀតចែងអំពីការបញ្ចេញមតិយោបល់។ ទោះបីជាយ៉ាងនេះក្ដី គោលបំណងនៃការផ្ដល់អភ័យឯកសិទ្ធិនេះគឺដូចគ្នា។

គោលបំណងទី១ គឺការពារសមាជិករដ្ឋសភាដើម្បីកុំឱ្យមានការបារម្ភ និងភិតភ័យពីការចាប់ខ្លួនដោយមិនត្រឹមត្រូវ និងការពារការគាបសង្កត់ ការគម្រាមកំហែងពីសំណាក់ស្ថាប័ននីតិប្រតិបត្តិ ឬរាជរដ្ឋាភិបាល ក្នុងអំឡុងពេលនៃការបំពេញតួនាទីភារកិច្ចរបស់ខ្លួនក្នុងនាមជាតំណាងរាស្ត្រនៅក្នុងអាណត្តិរបស់ខ្លួន ។

គោលបំណងទី២ គឺផ្ដល់ការការពារ និងផ្ដល់សិទ្ធិសេរីភាពដល់សមាជិករដ្ឋសភានូវការនិយាយស្ដីបញ្ចេញមតិយោបល់ នៅក្នុងការបំពេញមុខងារភារកិច្ចរបស់ខ្លួនក្នុងនាមជាតំណាងរាស្ត្រដែលនិយាយ បញ្ចេញមតិតំណាងឱ្យប្រជាពលរដ្ឋទូទាំងប្រទេស ដើម្បីចៀសវាងពីការជ្រៀតជ្រែក ឬ បំបិទសិទ្ធិក្នុងការបញ្ចេញមតិយោបល់ និងបកស្រាយពីការពិតណាមួយ ឬការរិះគន់ក្នុងន័យស្ថាបនាទៅដល់ការដឹកនាំ និងការអនុវត្តរបស់រាជរដ្ឋាភិបាល។

**២. លក្ខណៈនៃអភ័យឯកសិទ្ធិ**

ទាំងការផ្តល់អភ័យឯកសិទ្ធិក្នុងប្រទេសកម្ពុជា និង ប្រទេសជប៉ុន យើងសង្កេតឃើញថា លក្ខណៈនៃអភ័យឯកសិទ្ធិនេះ គ្របដណ្តប់លើធាតុផ្សំពីរគឺៈ

**ធាតុផ្សំទី១ គឺភាពមិនទទួលខុសត្រូវៈ** អភ័យឯកសិទ្ធិក្នុងករណីនេះមានលក្ខណៈដាច់ខាត ដោយ តំណាងរាស្ត្រ មិនអាចត្រូវបាន ចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុ ពីបាន សម្តែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខរបស់ខ្លួននៅក្នុងអាណត្តិឡើយ។ ភាពមិនទទួលខុសត្រូវ មិនមែនការពារតំណាងរាស្ត្រក្នុងនាមបុគ្គលទេ ប៉ុន្តែការពារមុខងារតំណាងរាស្ត្រ ។ ភាពមិនទទួលខុសត្រូវ គ្របដណ្តប់លើការបោះឆ្នោត ការបញ្ចេញមតិ សំណើ និងរបាយការណ៍របស់តំណាងរាស្ត្រក្នុងក្របខ័ណ្ឌការប្រជុំពេញអង្គ ឬក្នុងគណៈកម្មការ។

**ធាតុផ្សំទី២ គឺ ភាពមិនអាចរំលោភបំពានបានៈ** ករណីនេះ មិនមានលក្ខណៈដាច់ខាតទេក្នុងន័យថា អភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រអាចនឹងត្រូវដកហូតដោយសមាជិកដទៃទៀត។ ប៉ុន្តែទោះជាយ៉ាងណាក្តី ភាពមិនអាចរំលោភបំពានបាន ការពារបុគ្គលច្រើនជាងមុខងារ ដើម្បីចៀសវាងកុំឱ្យចាត់ទុកតំណាងរាស្ត្រ ដូចជាបុគ្គលឯកជនធម្មតា ដែលអាចជាកម្មវត្ថុនៃការបំភិតបំភ័យ និងការឃាត់ខ្លួនដោយគ្មានហេតុផល។

ជារួម ភាពមិនទទួលខុសត្រូវ គឺការពារទៅដល់ភាពជាមុខងារ មានន័យថា មិនមែនការពារបុគ្គលដោយសារគាត់ជាតំណាងរាស្ត្រទេ ប៉ុន្តែក្នុងនាមគាត់មានមុខងារតួនាទីក្នុងការបំពេញភារកិច្ច និងសកម្មភាពនានាក្នុងនាមជាតំណាងរាស្ត្រ គឺច្បាប់ផ្តល់ការការពារទៅលើមុខងារជាតំណាងរាស្ត្រទៅវិញទេ។ បើគាត់ជាតំណាងរាស្ត្រមែន តែប្រព្រឹត្តិអំពើផ្ទុយពីគោលបំណងនៃការផ្តល់អភ័យឯកសិទ្ធិក្នុងនាមជាតំណាងរាស្ត្រដែលត្រូវបំពេញភារកិច្ចស្របតាមច្បាប់កំណត់ តែបែរជាអាងខ្លួនជាតំណាងរាស្ត្រធ្វើស្រេចតែចិត្ត តាមលក្ខណៈផ្ទាល់ខ្លួន ប្រយោជន៍ផ្ទាល់ខ្លួន បង្កហេតុ និង ផលវិបាកនានាជាលក្ខណៈឯកជនមិនទាក់ទងនឹងផលប្រយោជន៍ជាតិនោះគាត់ត្រូវតែទទួលខុសត្រូវ ប៉ុន្តែភាពមិនទទួលខុសត្រូវនៅទីនេះ គឺមិនទទួលខុសត្រូវរាល់ការបំពេញសកម្មភាពទៅតាមច្បាប់ផ្តល់ជូនក្នុងនាមជាតំណាងរាស្ត្រ និងបំរើផលប្រយោជន៍ជាតិ និងផលប្រយោជន៍សាធារណៈ ។

ចំណែកឯភាពមិនអាចរំលោភបំពានបានគឺសំដៅទៅលើការផ្តល់សិទ្ធិពិសេស និងការលើកតម្កើងឋានៈមួយទៅដល់សមាជិករដ្ឋសភាផ្ទាល់ជាលក្ខណៈបុគ្គល មិនផ្តោតលើការពារមុខងារ ពីព្រោះគាត់មាននាមជាតំណាងរាស្ត្រតំណាងឱ្យពលរដ្ឋទូទាំងប្រទេស និងបំពេញភារកិច្ចដ៏សំខាន់ក្នុងស្ថាប័នមានអំណាចកំពូល ដើម្បីសម្រេចកំណត់ជោគវាសនារបស់ប្រទេសជាតិទៀត ហេតុ

នេះហើយ គួរគប្បីផ្ដល់ការការពារ និងសិទ្ធិពិសេសមួយលើសពីប្រជាពលរដ្ឋធម្មតា ដើម្បីប្រសិទ្ធិភាពនៅក្នុងការអនុវត្តតួនាទីរបស់ខ្លួនប្រកបដោយ ទំនុកចិត្ត និងដោយគ្មានភាពភ័យខ្លាច។

ប៉ុន្តែ នៅក្នុងលក្ខណៈទាំងពីរនេះ នៅក្នុងករណីមានការប្រព្រឹត្តិខុសច្បាប់ និងអនុវត្តន៍ផ្ទុយពីគោលបំណងនៃការផ្ដល់អភ័យឯកសិទ្ធិ ឬ ធ្វើសកម្មភាពមិនទាក់ទងនឹងការបំពេញមុខងារជាតំណាងរាស្ត្រ សមាជិកសភារូបនោះ ត្រូវតែទទួលខុសត្រូវនូវរាល់ផលប៉ះពាល់ ដែលកើតចេញពីទង្វើរបស់ខ្លួន និងមិនការពារភាពជាបុគ្គលទៀតនោះឡើយ បើធ្ងន់ធ្ងរអាចនឹងត្រូវដកហូតអភ័យឯកសិទ្ធិ និង ត្រូវចាប់ខ្លួនបានផងដែរ។

## កថាខណ្ឌទី២ ចំនុចខុសគ្នានៃការផ្ដល់អភ័យឯកសិទ្ធិ

ទន្ទឹមនឹងចំនុចស្របគ្នានេះផងដែរ យើងក៏សង្កេតឃើញថាមានចំនុចខុសគ្នាជាច្រើនទាំងផ្នែកទ្រឹស្តីមួយចំនួន និង និតិវិធីក្នុងការប្រព្រឹត្តិទៅនានាទាក់ទងនឹងអភ័យឯកសិទ្ធិនេះ រវាងប្រទេសទាំងពីរ។ ប្រទេសជប៉ុន មានការបែងចែកដាច់ស្រលះពីគ្នារវាងអភ័យឯកសិទ្ធិក្នុងការមិនត្រូវបានចាប់ខ្លួន និង អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់។ ដោយឡែក នៅក្នុងមាត្រា៨០ វាក្យខណ្ឌ២នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា គឺចែងក្ដោបរួមទៅលើសិទ្ធិក្នុងការបញ្ចេញមតិ ដោយ សំដែងថា តំណាងរាស្ត្រមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួន ដោយហេតុថាបានសំដែងមតិយោបល់នៅក្នុងអណត្តិរបស់ខ្លួនឡើយ។ ការចែងបែបនេះ ថាតើមានន័យថា ចង់ផ្ដោតសំខាន់ទៅលើសិទ្ធិ ក្នុងការសំដែងមតិយោបល់ ឬក៏យ៉ាងណានោះ ធ្វើឱ្យពិបាកនៅក្នុងការវែកញែកទាំងនិយមន័យ ទ្រឹស្តី វិសាលភាព និងខ្លឹមសារទូទៅក្នុងការផ្ដល់អភ័យឯកសិទ្ធិនេះ។ ប៉ុន្តែ ប្រទេសជប៉ុនហាក់ដូចជាបានញែកដាច់ពីគ្នា និង មានភាពច្បាស់លាស់ទៅលើការផ្ដល់ទាំងនិយមន័យទ្រឹស្តី វិសាលភាព និង ខ្លឹមសារទូទៅក្នុងការផ្ដល់អភ័យឯកសិទ្ធិនេះ ដោយយើងអាចវែកញែកឃើញនូវចំនុចខុសគ្នាជាច្រើនរវាងប្រទេសទាំងពីរ។ ហេតុនេះយើងបានធ្វើការបែងចែកជាពីរផ្នែករវាងអភ័យឯកសិទ្ធិក្នុងការមិនត្រូវបានចាប់ខ្លួន និង អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់មកពន្លេចឱ្យឃើញពីលក្ខណៈខុសប្លែកគ្នា និង ការខ្វះចន្លោះនៃច្បាប់។

### ១. ទាក់ទិននៅនឹងអភ័យឯកសិទ្ធិក្នុងការមិនត្រូវបានចាប់ខ្លួន

ទាក់ទិននៅនឹងផ្នែកនេះ ដោយយោងទៅតាមរដ្ឋធម្មនុញ្ញ និង ការចែងបន្ថែមទៀតនៅក្នុងច្បាប់ បើពិនិត្យទៅលើអត្ថន័យខ្លឹមសារនៃមាត្រានីមួយៗ ក៏ដូចជាតាមការបកស្រាយពន្យល់ នៅក្នុងបណ្ដាសៀវភៅផ្នែកនីតិរដ្ឋធម្មនុញ្ញ ទាក់ទិននឹងអភ័យឯកសិទ្ធិរដ្ឋសភានេះរវាងប្រទេសទាំងពីរ យើងអាចពន្លេចឃើញនូវលក្ខណៈខុសគ្នាមួយចំនួនដូចជា ករណីក្នុងការមានការចាប់ខ្លួនសមាជិករដ្ឋសភាមុនអាណត្តិ(ក), លក្ខខណ្ឌក្នុងការចាប់ខ្លួនដោយបទល្មើសព្រហ្មទណ្ឌជាក់ស្ដែង(ខ), នីតិវិធី

នៃកាស្នើរសុំលើកអភ័យឯកសិទ្ធិដើម្បីចាប់ខ្លួនសមាជិករដ្ឋសភា(គ), និងការស្នើរសុំទាមទារឱ្យមានការដោះលែងសមាជិករដ្ឋសភា(ឃ)។

**ក. ករណីក្នុងការមានការចាប់ខ្លួនសមាជិករដ្ឋសភាមុនអណត្តិ**

យោងទៅតាមមាត្រា៥០វាក្យខណ្ឌ២នៃរដ្ឋធម្មនុញ្ញជប៉ុននាពេលបច្ចុប្បន្នបានចែងថា បើទោះបីជាមានសមាជិកណាមួយត្រូវបានចាប់ខ្លួនមុនអាណត្តិក៏ដោយ ប្រសិនបើសភាមានតម្រូវការចាំបាច់ណាមួយកើតឡើងចំពោះសមាជិករូបនោះត្រូវតែធ្វើការដោះលែងភ្លាម។ មានន័យថា ជួនកាលអាចមានសមាជិករដ្ឋសភាណាម្នាក់បានប្រព្រឹត្តិបទល្មើស ឬមិនប្រព្រឹត្តិបទល្មើសក៏ដោយចុះ ប៉ុន្តែសមាជិករូបនោះជាប់ការសង្ស័យថាបានប្រព្រឹត្តិបទល្មើស និងត្រូវបានចាប់ខ្លួន ឃុំខ្លួននៅមុន ពេលការបើកពិធីជួបជុំដំបូងដើម្បីប្រកាសនីតិកាលថ្មី។ ទោះបីជាសមាជិករូបនោះបានជាប់ឃុំខ្លួន រួចទៅហើយក៏ដោយ ប៉ុន្តែប្រសិនបើមានភាពចាំបាច់ណាមួយ ដែលតម្រូវការសមាជិករូបនោះ ចូលបង្ហាញខ្លួននៅក្នុងសភាដើម្បីបំពេញកូរ៉ុម ឬ ដើម្បីបំពេញកិច្ចការសំខាន់ណាមួយនៅក្នុងរដ្ឋសភានោះសមាជិករូបនោះត្រូវតែទទួលបានការដោះលែង។ នេះសរបញ្ជាក់ឱ្យឃើញថា ប្រទេសជប៉ុនមានការគិតគូរខ្លាំងទៅដល់ដំណើរការដោយរលូនគ្មានភាពរាំងស្ទះនៅក្នុងការបំពេញកិច្ចការ របស់ខ្លួនដើម្បីផលប្រយោជន៍ជាតិជាធំ គឺគេមិនគិតគូរទៅដល់កំហុសបុគ្គល ហើយច្រានចោលនូវសមត្ថភាព និងផលប្រយោជន៍ពីបុគ្គលក្នុងការដំណើរការអភិវឌ្ឍជាតិរបស់គេទេ។

ផ្ទុយទៅវិញ ចំពោះប្រទេសកម្ពុជាវិញទាំងក្នុងរដ្ឋធម្មនុញ្ញ ក៏ដូចជាគ្មានច្បាប់ណាមួយចែងទាក់ទងទៅនឹងករណី ដោះលែងសមាជិករដ្ឋសភាដែលត្រូវចាប់ខ្លួនមុនអាណត្តិឡើយ។

**ខ. លក្ខខណ្ឌក្នុងការចាប់ខ្លួនដោយបទល្មើសព្រហ្មទណ្ឌជាក់ស្តែង**

ចំពោះប្រទេសកម្ពុជា នៅក្នុងករណីនេះ យោងទៅតាមមាត្រា ៧ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ បានចែងថា"តំណាងរាស្ត្រណាបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ នឹងអាចអនុញ្ញាតបើកឱ្យធ្វើការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន" ។

ក្នុងករណីនេះ មានន័យថា ប្រសិនបើសមាជិករដ្ឋសភាមិនបានប្រព្រឹត្តិបទល្មើសជាក់ស្តែងទេនោះ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនអាចប្រព្រឹត្តិទៅបានលុះត្រាមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាជាមុនសិនដោយការលើកអភ័យឯកសិទ្ធិរបស់សមាជិករូបនោះមុននឹងអនុវត្តទៅតាមនីតិវិធីរបស់តុលាការ ។ ប៉ុន្តែ ប្រសិនបើជាបទល្មើសជាក់ស្តែង នោះមិនចាំបាច់សុំការយល់ព្រមជាមុនពីសំណាក់រដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាដើម្បីធ្វើការប្រជុំសម្រេចដកអភ័យឯកសិទ្ធិនោះទេ គឺអាចចាប់ខ្លួនហើយចាំ

រាយការណ៍ជូនជាបន្ទាន់ជាក្រោយ បើយោងទៅតាមវាក្យខណ្ឌ៣នៃមាត្រា៨០នៃរដ្ឋធម្មនុញ្ញ និង មាត្រា១២នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ។

ប៉ុន្តែផ្ទុយទៅវិញ ចំពោះប្រទេសជប៉ុនវិញ ទោះបីជាសមាជិករដ្ឋសភារូបនោះបានប្រព្រឹត្តិនូវបទល្មើសព្រហ្មទណ្ឌជាក់ស្តែងក៏ដោយ គឺចាំបាច់ទាមទារនូវការយល់ព្រមពីរដ្ឋសភាជាមុនសិនក្នុងការលើកអភ័យឯកសិទ្ធិ ហើយទើបអាចអនុញ្ញាតឱ្យធ្វើការចាប់ខ្លួនបាន ដោយឈរលើគោលជំហរថា បើទោះបីជាសង្ស័យថាបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌជាក់ស្តែងក៏ដោយ ចៀសវាងការចាប់ខ្លួនមិនត្រឹមត្រូវ ដូចជាខ្លាចថាមានការលូកដៃចូលពីសំណាក់ស្ថាប័ននីតិប្រតិបត្តិជាដើម ឬកង្វះចំណាត់ការត្រឹមត្រូវពីសំណាក់តុលាការ ទើបមុននឹងសម្រេចអនុញ្ញាតឱ្យចាប់ខ្លួនត្រូវឆ្លងកាត់ការពិចារណា និង ធ្វើការពិភាក្សាសម្រេចឱ្យបានច្បាស់លាស់ជាមុនសិនទៅលើករណីនេះ។

តែបើក្នុងករណីមានការប្រព្រឹត្តិបទល្មើសជាក់ស្តែងនៅក្នុងសភាវិញ ចំពោះប្រទេសជប៉ុន គឺផ្តល់សិទ្ធិសម្រេចពិសេសទៅឱ្យប្រធានរដ្ឋសភាជាអ្នកសម្រេច ដើម្បីរក្សាសណ្តាប់ធ្នាប់ នៅក្នុងរដ្ឋសភា ប្រសិនបើប្រធានរដ្ឋសភាអនុញ្ញាតឱ្យចាប់ខ្លួននោះអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋសភានឹងធ្វើការចាប់ខ្លួនបាន។

**គ. នីតិវិធីនៃការស្នើរសុំលើកអភ័យឯកសិទ្ធិដើម្បីចាប់ខ្លួនសមាជិករដ្ឋសភា**

ចំពោះប្រទេសកម្ពុជាវិញ ដើម្បីធ្វើការចាប់ខ្លួនសមាជិករដ្ឋសភាណាម្នាក់បាន លុះត្រា មានការដកអភ័យឯកសិទ្ធិជាមុននៅក្នុងករណីមិនមែនបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ នីតិវិធី នៅក្នុងករណីនេះ គឺដំបូងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវដាក់សេចក្តីស្នើរសុំ ដែលមានភ្ជាប់មកជាមួយនូវសេចក្តីថ្លែងហេតុ ដើម្បីផ្ញើមកប្រធានរដ្ឋសភា[73] ។ ការលើកអភ័យឯកសិទ្ធិសភា ត្រូវធ្វើនៅក្នុងសម័យចន្លោះ ប្រជុំរដ្ឋសភាដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវធ្វើការពិនិត្យ និងពិចារណា ដោយផ្អែកទៅលើបទល្មើស និងភស្តុតាងផ្សេងៗ និងសេចក្តីថ្លែងហេតុរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយត្រូវបានធ្វើការប្រជុំ និងអនុម័តសម្រេចឱ្យសមស្របទៅនឹងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដាក់នៅចន្លោះសម័យប្រជុំពេញអង្គរបស់រដ្ឋសភា ដើម្បីដកអភ័យឯកសិទ្ធិសភាសមាជិករដ្ឋសភារូបណាមួយ ត្រូវបានអនុម័តដោយមតិភាគច្រើន ពីរភាគបី ( ២/៣ ) នៃចំនួនសមាជិករដ្ឋសភាទាំងមូល[74] ។

ចំពោះប្រទេសជប៉ុនវិញ នីតិវិធីក្នុងការទាមទារឱ្យមានការចាប់ខ្លួនសមាជិករដ្ឋសភាអាចធ្វើទៅបាន គឺមុននឹងតុលាការមានសមត្ថកិច្ច ឬក៏ចៅក្រមចេញដីការបង្គាប់ឱ្យចាប់ខ្លួនត្រូវធ្វើលិខិត

[73] មាត្រា ៨ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឆ្នាំ២០០៦

[74] មាត្រា ១១ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឆ្នាំ២០០៦

ចាំបាច់ក្នុងការទាមទារការចាប់ខ្លួនដាក់ជូនគណៈរដ្ឋមន្ត្រី បន្ទាប់ពីគណៈរដ្ឋមន្ត្រីទទួលស្គាល់នូវលិខិតចាំបាច់ក្នុងការទាមទារឱ្យមានការចាប់ខ្លួន ដែលតុលាការមានសមត្ថកិច្ចបានដាក់ជូនភ្លាម គឺត្រូវទាមទារឱ្យគណៈរដ្ឋមន្ត្រីធ្វើការរៀបចំនូវលិខិតចំលងពីលិខិតចាំបាច់ក្នុងការទាមទារ ឱ្យមានការចាប់ខ្លួននោះ និងធ្វើការប្រកាសទទួលស្គាល់ពីការចាប់ខ្លួននោះបន្ទាប់ពីដាក់លិខិតស្នើរទៅរដ្ឋសភា ហើយបើរដ្ឋសភាបានយល់ព្រមអនុញ្ញាតឱ្យធ្វើការចាប់ខ្លួន ទើបតុលាការអាចធ្វើចំណាត់ការតាមនីតិវិធីរបស់ខ្លួន។

**ឃ. ការស្នើរសុំទាមទារឱ្យមានការដោះលែងសមាជិករដ្ឋសភា**

ចំពោះប្រទេសជប៉ុន នៅក្នុងការស្នើរទាមទារឱ្យមានការដោះលែងសមាជិកសភាដែលត្រូវបានធ្វើការចាប់ខ្លួនមុនអាណត្តិ គឺលុះត្រាមានការព្រមព្រៀងដោយចុះហត្ថលេខាព្រមព្រៀងពីសមាជិកសភាចំនួន២០រូបឡើងទៅ ដោយភ្ជាប់ជាមួយលិខិតចាំបាច់ក្នុងការទាមទារឱ្យមានការដោះលែងនោះដាក់ស្នើរទៅប្រធានសភា[75]។

ចំពោះនៅក្នុងប្រទេសកម្ពុជាវិញ ក្នុងករណី រាល់ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាកតាមការអនុម័តដោយមតិភាគច្រើនបីភាគបួន ( ៣/៤ ) នៃសមាជិករដ្ឋសភាទាំងមូល[76]។

**២. ទាក់ទិននៅនឹងអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់**

យើងមិនអាចនិយាយបានថា នេះជាការប្រៀបធៀបស្វែងរកនូវចំនុចខុសគ្នាទាក់ទិននឹងករណីនេះឡើយ ដោយហេតុថានេះជានត្ថិភាពនៃច្បាប់របស់ប្រទេសកម្ពុជាយើងដែលមិនបានចែងបញ្ជាក់ និង វែកញែកឱ្យលម្អិតទៅវិញទេ។ ប៉ុន្តែទោះជាយ៉ាងណា យើងអាចនិយាយបានថានេះក៏ជាលក្ខណៈខុសគ្នាមួយក្នុងការអនុវត្តដែរ ដោយរួមមានទៅលើចំនុចមួយចំនួនដូចជា ការកំនត់ទៅលើនិយមន័យនៃការបញ្ចេញមតិយោបល់(ក), ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរបស់រដ្ឋ(ខ), សមាសភាគនៃអភ័យឯកសិទ្ធិ(គ), ទំហំនៃការផ្តល់អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់(ឃ)។

**ក. ការកំនត់ទៅលើនិយមន័យនៃការបញ្ចេញមតិយោបល់**

តាមយោងមាត្រា៥១នៃរដ្ឋធម្មនុញ្ញរបស់ប្រទេសជប៉ុននាពេលបច្ចុប្បន្ននេះ បានចែងអំពីសិទ្ធក្នុងការបញ្ចេញយោបល់ និងការបោះឆ្នោតបញ្ចេញមតិរបស់សមាជិកសភា។ មាត្រានេះបានចែងបញ្ជាក់ថាការថ្លែងសុន្ទរកថា ការជជែកវែកញែកពិភាក្សា និងការបោះឆ្នោតបញ្ចេញមតិរបស់សមាជិកសភាទាំងពីរនៅក្នុងសភាគឺមិនទទួលខុសត្រូវនៅខាងសភាឡើយ។

---

[75] ច្បាប់ស្តីពីសភារបស់ជប៉ុនមាត្រា៣៤កថាខណ្ឌ៣ ឆ្នាំ១៩៤៧

[76] មាត្រា ១៣ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឆ្នាំ២០០៦

ថ្វីត្បិតតែនៅក្នុងរដ្ឋធម្មនុញ្ញមិនបានចែងពីនិយមន័យ ទ្រឹស្តីនៃការថ្លែងសុន្ទរកថា ការជជែកវែកញែកពិភាក្សា និងការបោះឆ្នោតបញ្ចេញមតិ ប៉ុន្តែនៅក្នុងសៀវភៅរបស់សាស្ត្រាចារ្យផ្នែករដ្ឋធម្មនុញ្ញបានសរសេរអំពីការកំណត់និយមនេះយ៉ាងច្បាស់លាស់ថា សមាជិករដ្ឋសភាមានសិទ្ធិក្នុងការទទួលបានអភ័យឯកសិទ្ធិពីការការថ្លែងសុន្ទរកថា ការជជែកវែកញែកពិភាក្សា និងការបោះឆ្នោតបញ្ចេញមតិរបស់ខ្លួន។ ការពិភាក្សាគឺជាការសំដែងឡើងដោយផ្ទាល់មាត់នូវមតិប្រឆាំង ឬស្របទៅលើកម្មវត្ថុនៃការប្រជុំ ចំណែកឯសុន្ទរកថាវិញ គឺជាការសំដែងចេញនូវយោបល់ដោយផ្ទាល់មាត់ដូចគ្នាតែមិនមែនជាការពិភាក្សាមានមតិស្របមតិផ្ទុយអ្វីនោះទេ ការថ្លែងបែបនេះ ជាពិសេសគឺធ្វើឡើងនៅពេលដែលចង់ចង្អុលបង្ហាញទៅលើចំងល់ណាមួយទៅលើសេចក្តីព្រាង របស់អ្នកដាក់ពាក្យស្នើរសុំ។ ចំពោះការបញ្ចេញមតិយោបល់ គឺសំដៅដល់ការសំដែងបង្ហាញនូវមតិស្របឬមតិប្រឆាំងទៅលើកម្មវត្ថុនៃប្រធានបទដែលលើកឡើង នៅពេលឈរឈ្មោះ ឬនៅពេលមានធ្វើការបោះឆ្នោតបញ្ចេញមតិណាមួយ។

ផ្ទុយទៅវិញ ចំពោះប្រទេសកម្ពុជាវិញទាំងក្នុងរដ្ឋធម្មនុញ្ញ ក៏ដូចជាគ្មានច្បាប់ណាមួយចែងទាក់ទងទៅនឹងការកំណត់សិទ្ធិក្នុងការទទួលបានអភ័យឯកសិទ្ធិពីការការថ្លែងសុន្ទរកថា ការជជែកវែកញែកពិភាក្សា និងការបោះឆ្នោតបញ្ចេញមតិរបស់សមាជិករដ្ឋសភាតាមនិយមន័យនេះឡើយ។

**ខ. ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរបស់រដ្ឋ**

ចំពោះប្រទេសជប៉ុនវិញ ក្នុងករណីសមាជិករដ្ឋសភាណាម្នាក់ ក្នុងនាមជាតំណាងរបស់ប្រជាពលរដ្ឋ មិនទទួលខុសត្រូវដោយផ្ទាល់ទៅលើការសងសំណាងរដ្ឋប្បវេណីក្នុងករណីមានការលើកសំណួរដេញដោល ពិភាក្សាយោបល់នៅក្នុងសកម្មភាពតាក់តែងច្បាប់ ឬការទទួលស្គាល់នូវការចងភ្ជាប់ខ្លួនទៅនឹងសន្ធិសញ្ញានានា ការថ្លែងសុន្ទរកថា ការបញ្ចេញមតិយោបល់ ដែលការលើកឡើងមួយចំនួន បានបង្កនូវផលប៉ះពាល់ទៅដល់ សិទ្ធិរបស់បុគ្គលឯកជន ឬសិទ្ធិរបស់ប្រជាពលរដ្ឋ ប៉ុន្តែរដ្ឋមាន ច្បាប់ស្តីពីសំណាងជំងឺចិត្តរបស់រដ្ឋទទួលសងជំងឺចិត្តតែចំពោះរាល់ការបំពេញសកម្មភាពទាំងនេះ គឺដើម្បីគិតគូរពីផលប្រយោជន៍ជាតិ និងផលប្រយោជន៍រួម និងស្ថិតក្នុងតួនាទីភារកិច្ច ដែលសមាជិកសភាគួរបំពេញ។ ផ្ទុយទៅវិញ បើស្ថិតក្នុងករណីសមាជិករដ្ឋសភារូបនោះបានបំពានលើ តួនាទីភារកិច្ច និងយកសិទ្ធិអំណាចរបស់ខ្លួនយកមកប្រើប្រាស់ខុសគោលបំណងច្បាប់ ដូចជាបាន ប្រើប្រាស់ពាក្យសម្តី និងបញ្ចេញមតិយោបល់នានាដោយមានគោលបំណងមិនល្អ និងមិនត្រឹមត្រូវស្របច្បាប់ មានលក្ខណៈ បោកប្រាស់ ញុះញង់ កុហក មូលបង្កាច់ ឬបរិហារកេរ្តិ៍នាំឱ្យខូចកិត្តិយសបុគ្គលឯកជន និងជាលក្ខណៈផ្ទាល់ខ្លួនមិនទាក់ទងនឹងរដ្ឋ នោះរដ្ឋ នឹងមិនទទួលសងសំណាងជំងឺចិត្តទេ។ រដ្ឋត្រូវតែត្រួតពិនិត្យមើលឱ្យច្បាស់លាស់ ថាតើស្ថានភាពនោះជាស្ថាន

ភាពដែលបង្កឡើងដោយការអនុវត្តផ្ទុយពីការផ្តល់អំណាចតាមច្បាប់ពីសំណាក់សមាជិកសភា ឬក៏យ៉ាងណានោះគឺជារឿងសំខាន់ណាស់ ដើម្បីធ្វើការកំណត់លក្ខខណ្ឌដែលអាចឱ្យរដ្ឋសងសំណងជំងឺចិត្តបាន។

ផ្ទុយទៅវិញ ចំពោះប្រទេសកម្ពុជា គឺមិនមានច្បាប់ណាមួយកំណត់ពីការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីជំនួសតំណាងរាស្ត្រនៅឡើយទេ ។ ចំពោះប្រទេសជប៉ុនគឺមានច្បាប់ស្តីពីសំណងជំងឺចិត្តរបស់រដ្ឋ។

**គ. សមាសភាគនៃអភ័យឯកសិទ្ធិ**

នៅប្រទេសជប៉ុន គឺដូចគ្នាទៅនឹងប្រទេសបារាំង និង អាឡឺម៉ង់ដែរ គឺការជ្រើសរើសយកប្រព័ន្ធនៃការផ្តល់អភ័យឯកសិទ្ធិនេះគឺក្នុងគោលបំណង ដើម្បីផ្តល់ការការពារឯករាជ្យមួយទៅដល់សមាជិកសភា។ នៅប្រទេសជប៉ុន រដ្ឋមន្ត្រីក្រសួងការពារជាតិ ដែលបានធ្វើការបញ្ចេញមតិយោបល់ក្នុងនាមជារដ្ឋមន្ត្រី គឺមិនទទួលបានអភ័យឯកសិទ្ធិទេ។ នៅក្នុងរដ្ឋធម្មនុញ្ញបានចែងបញ្ជាក់យ៉ាងច្បាស់ហើយថា អ្នកដែលអាចទទួលបាននូវអភ័យឯកសិទ្ធិនេះគឺសមាជិកសភា។ សមាជិកសភាដែលបានក្លាយទៅជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័ននីតិប្រតិបត្តិ បើទោះបីជាធ្វើការសំដែងមតិយោបល់នៅក្នុងសភាក៏ដោយក៏មិនត្រូវបានការពារដោយអភ័យឯកសិទ្ធិនេះដែរ។ មានន័យថា អភ័យឯកសិទ្ធិមួយនេះ គឺមានអនុភាពអនុវត្តន៍បានតែចំពោះសមាជិកសភាតែប៉ុណ្ណោះ ចំពោះប្រជាពលរដ្ឋ ប្រជាជនធម្មតា ឬនរណាក៏ដោយក៏គ្មានការការពារដោយអភ័យឯកសិទ្ធិនេះដែរ។

ទាក់ទិននឹងករណីនេះ នៅប្រទេសកម្ពុជាវិញ សមាជិកសភាដែលបានក្លាយទៅជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័ននីតិប្រតិបត្តិក៏នៅតែមានអភ័យឯកសិទ្ធិសភាដែរឲ្យតែមាននាមចេញពីតំណាងរាស្ត្រ។

**ឃ. ទំហំនៃការផ្តល់អភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់**

ចំនុចនេះទាក់ទិនទៅនឹង ភាពមិនទទួលខុស ត្រូវក្រៅសភា និងក្នុងសភារាល់ការបញ្ចេញមតិយោបល់នានារបស់សមាជិករដ្ឋសភា។

ចំពោះប្រទេសជប៉ុន សកម្មភាពដែលត្រូវបានការពារដោយអភ័យឯកសិទ្ធិ គឺជាសកម្មភាពដែលបានប្រព្រឹត្តិនៅក្នុងសភា មានន័យថា គឺជាសកម្មភាពដែលសមាជិកសភាបានប្រព្រឹត្តិក្នុងការបំពេញភារកិច្ចរបស់ខ្លួន នៅក្នុងការប្រជុំពេញអង្គ និងសកម្មភាពនៅក្នុងគណៈកម្មាធិការ ។

មិនត្រឹមតែជាសកម្មភាពនៅក្នុងសភាទេ ទោះបីជាសកម្មភាពដែលបានប្រព្រឹត្តិឡើងនៅក្រៅសភាដូចជានៅក្នុងវេទិកាសាកសួរផ្លាស់ប្តូរយោបល់ជាសាធារណៈដែលប្រព្រឹត្តិឡើង នៅក្រៅ

សភាក៏ដោយក៏រាប់បញ្ចូលជាសកម្មភាព ដែលត្រូវទទួលបានការការពារដោយអភ័យឯកសិទ្ធិផង ដែរ។ ប្រសិនបើជាការបញ្ចេញសកម្មភាពនៅក្នុងការបំពេញតួនាទីរបស់សមាជិកសភា តាមន័យចង្អៀត ទោះបីជាមិនមែនស្ថិតនៅក្នុងពេលថ្លែងសុន្ទរកថា ពិភាក្សា និងបញ្ចេញមតិយោបល់ ក៏ដោយក៏ការបញ្ចេញសកម្មភាពនោះ គឺស្ថិតក្នុងទស្សនៈវិស័យនៃការផ្តល់អភ័យឯកសិទ្ធិផងដែរ លើកលែងតែធ្វើសកម្មភាពហិង្សាគឺមិនផ្តល់ការការពារឱ្យឡើយ។

ចំពោះប្រទេសកម្ពុជាវិញ ទាក់ទិននឹងទំហំវិសាលភាពនៃអភ័យឯកសិទ្ធិនេះគឺកំពុងតែប្រឈមនឹងបញ្ហានៅឡើយ ដោយមិនមានបញ្ញត្តិច្បាប់ណាចែងទាក់ទិននឹងបញ្ហានេះទេ។

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយទាក់ទងបញ្ហាក្នុងការអនុវត្តសិទ្ធិនៃអភ័យឯកសិទ្ធិនៃប្រទេសកម្ពុជា និងប្រទេសជប៉ុន

នៅក្នុងជំពូកទី៣នេះ យើងធ្វើការបែងចែកជា២ផ្នែក គឺយើងធ្វើការសិក្សាទៅលើបញ្ហាប្រឈមទាក់ទិននឹងអភ័យឯកសិទ្ធិ(ផ្នែកទី១) និងធ្វើការបកស្រាយអំពីដំណោះស្រាយ(ផ្នែកទី២)។

## ផ្នែកទី១ បញ្ហាប្រឈម

បញ្ហាប្រឈមទាំងទៅលើបញ្ហាច្បាប់ ក៏ដូចជាបញ្ហាក្នុងការអនុវត្តគឺជៀសមិនផុតឡើយ ឬអាចថាកម្រនឹងជៀសផុតណាស់ មិនថាប្រទេសនោះមានប្រព័ន្ធច្បាប់រឹងមាំយ៉ាងណា និងអនុវត្តច្បាប់បានល្អយ៉ាងណាក៏ដោយ។ នៅក្នុងផ្នែកនេះ យើងនឹងធ្វើការសិក្សាអំពីបញ្ហាប្រឈមទាក់ទិននឹងបញ្ហាអភ័យឯកសិទ្ធិនៅក្នុងប្រទេសកម្ពុជា(កថាខណ្ឌទី១) និងបញ្ហាប្រឈមដែលកើតមាននៅក្នុងប្រទេសជប៉ុន(កថាខណ្ឌទី២)។

### កថាខណ្ឌទី១ បញ្ហាប្រឈមនៅកម្ពុជា

បន្ទាប់ពីការបោះឆ្នោតនីតិកាលទី៥ បានបញ្ចប់ទៅ ក៏កើតមានបញ្ហាចម្រូងចម្រាសមិនចេះចប់ មិនចេះហើយ រវាងគណបក្សដែលមានអាសនៈក្នុងសភា ។ បញ្ហានេះ បានក្លាយទៅជាបញ្ហាក្តៅគគុកក្នុងសង្គមនយោបាយប្រទេសខ្មែរ និង មានការចាប់អារម្មណ៍ពីសំណាក់ប្រជាពលរដ្ឋទូទៅ ទាំងបណ្តាប្រទេសអន្តរជាតិមួយចំនួន ក៏បានលូកដៃចូលមកក្នុងបញ្ហានេះរួមទាំងទទួលបានការយកចិត្តទុកដាក់ និងវិភាគ រិះគន់ ស្តាបនា ពីសំណាក់អង្គការសង្គមស៊ីវិលនានាផងដែរ។ បន្ទាប់ពីបញ្ហាចម្រូងចម្រាសរឿងមិនទទួលស្គាល់លទ្ធផលបោះឆ្នោត ការមិនចូលខ្លួនតាមការកោះហៅរបស់អង្គព្រះមហាក្សត្រ និងមិនចូលរួមក្នុងសភា ការបន្តការធ្វើបាតុកម្មបណ្តាលឱ្យមានសោកនាដកម្មជាច្រើនបានកើតឡើងពេលតតាំងចំពោះគ្មាននាទីតិកាលទី៥នេះ។ ទោះបីជាក្រោយមកទៀតដោយមានការសម្របសម្រួលខាងនយោបាយ ដោយបង្កើតឱ្យមានវប្បធម៌ សន្ទនារវាងគណបក្សមានអាសនៈក្នុងសភាទាំងពីរ និងការព្រមចូលក្នុងសភារបស់គណបក្សប្រឆាំងវិញក៏ដោយ ក៏បញ្ហានយោបាយនៅតែបន្តយ៉ាងក្តៅគគុក ហាក់គ្មានបន្ថយកំដៅបន្តិចណាឡើយរហូតមកទល់សព្វថ្ងៃនេះ។ យ៉ាងណាមិញ បញ្ហាដែលកំពុងតែក្លាយជាប្រធានបទ និង ត្រូវបានកំពុងនឹងវិភាគវែកញែកពីសំណាក់មជ្ឈដ្ឋានអ្នកច្បាប់ អន្តរជាតិ និងអង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងមហាជនទូទៅនោះ គឺបញ្ហាអភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រ ដោយមានការជជែកវែកញែក និងត្រូវបានបកស្រាយដោយមតិផ្ទុយគ្នាជាច្រើនទាក់ទិននឹងការមានអភ័យឯកសិទ្ធិ និងការអនុវត្ត

នូវអភ័យឯកសិទ្ធិនេះតាមរយៈមាត្រា៨០នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន ជាពិសេសពាក់ព័ន្ធនឹងការចាប់ខ្លួនឃុំខ្លួនអ្នកតំណាងរាស្ត្រទាំងមានអភ័យឯកសិទ្ធិ។

**១. ការបកស្រាយផ្សេងគ្នាទៅលើអត្ថិភាពនៃការមានអភ័យឯកសិទ្ធិ**

អ្នកតំណាងរាស្ត្រគ្រប់រូប គឺជាតំណាងរាស្ត្រដែលកើតចេញពីការបោះឆ្នោតជ្រើសរើសពីម្ចាស់ឆ្នោតដែលបានផ្តល់សេចក្តីទុកចិត្ត គាំទ្រឱ្យពួកគាត់ធ្វើជាអ្នកតំណាងរបស់ខ្លួននៅក្នុងស្ថាប័ននីតិបញ្ញត្តិ។ នៅពេលដែលពួកគាត់មានលក្ខណៈសម្បត្តិពេញលេញ ទៅតាមច្បាប់នៃភាពជាតំណាងរបស់ខ្លួននោះ គឺពួកគាត់ត្រូវបានការពារ និងធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទៅលើសកម្មភាពនៃការបំពេញមុខងាររបស់ខ្លួន ។ មាត្រា ៨០ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងថា "តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា" ត្រង់ចំណុចនេះ គឺចង់ធ្វើការបញ្ជាក់ថា អ្នកតំណាងរាស្ត្រគ្រប់រូបត្រូវបានការពារ ក៏ដូចជាធានាដោយអភ័យឯកសិទ្ធិសភា ។ មានន័យថា រាល់សមាជិករដ្ឋសភាគ្រប់រូប គឺមិនត្រូវបានទទួលទោសមកពីការសម្តែងមតិយោបល់របស់ខ្លួននៅក្នុងពេលបញ្ចេញមតិ ក្នុងពេលសកម្មភាពនៃការបំពេញមុខងាររបស់ខ្លួននោះឡើយ ។ ការចែងបញ្ជាក់យ៉ាងដូចនេះ គឺក្នុងគោលបំណងឱ្យអ្នកតំណាងរាស្ត្រគ្រប់រូប មានភាពរឹងមាំទៅលើការបំពេញមុខងាររបស់ខ្លួនដោយពុំមានការភ័យខ្លាចចំពោះបញ្ហាប្រឈមទៅលើផ្លូវច្បាប់ ។ ដូចនេះអភ័យឯកសិទ្ធិសមាជិករដ្ឋសភា គឺសំខាន់ណាស់សម្រាប់អ្នកតំណាងរាស្ត្រគ្រប់ៗរូប ។ ទោះបីជាអភ័យឯកសិទ្ធិសភាមានភាពសំខាន់យ៉ាងនេះក៏ដោយ ក៏វាមិនមែនចេះតែកើតឡើងនោះដែរ លុះត្រាតែអ្នកតំណាងរាស្ត្រទាំងនោះ បានបំពេញទៅតាមលក្ខខណ្ឌដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ ឬ បទដ្ឋានគតិយុត្តផ្សេងៗទៀតដែលបានចែងបញ្ជាក់ ។ ទាក់ទងទៅនឹងបញ្ហានេះ យើងសង្កេតឃើញថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាពុំបានចែងឱ្យបានច្បាស់លាស់ឡើយ អំពីការចាប់ផ្តើមទទួលបាននូវអភ័យឯកសិទ្ធិសមាជិករដ្ឋសភានៅពេលណាឱ្យប្រាកដនោះទេ ។ ដោយសារតែភាពមិនច្បាស់លាស់នេះហើយបានធ្វើឱ្យមានការយល់ឃើញ និងបកស្រាយខុសៗគ្នាពីសំណាក់អ្នកនយោបាយ អ្នកច្បាប់មួយចំនួន ក្នុងនោះ ក្រុមខ្លះយល់ឃើញថា អភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រកើតឡើងនៅពេលដែលពួកគាត់ដឹងថា លទ្ធផលនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្របានបង្ហាញឱ្យឃើញថា បក្សណាខ្លះឈ្នះ ហើយអ្នកតំណាងរាស្ត្រណាខ្លះ មានឈ្មោះជាប់ជាតំណាងរាស្ត្រទៅតាមការកំណត់របស់បក្សនយោបាយនីមួយៗ ។ នៅពេលដែលអ្នកតំណាងរាស្ត្រណាម្នាក់ដឹងថា ខ្លួនត្រូវបានជាប់ឆ្នោតជាសភាតំណាងរាស្ត្រហើយនោះ គឺអភ័យឯកសិទ្ធិសភាត្រូវបានកើតឡើងដោយស្វ័យប្រវត្តិ ។ ជាក់ស្តែងសំដីដកស្រង់មួយរបស់លោកស្រី មូរ សុខហួរ បាននិយាយនៅពេលដែល

លោកស្រី និង អ្នកតំណាងរាស្ត្រផ្សេងទៀតនៃគណបក្សសង្គ្រោះជាតិត្រូវបានតុលាការនៃសាលារាជធានីភ្នំពេញ ធ្វើការកោះហៅដើម្បីសាកសួរទាក់ទងនឹងបណ្តឹងចោទប្រកាន់អំពីការប៉ះទង្គិចហិង្សានៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៤ថា«...ការចោទប្រកាន់មកលើរូបលោកស្រី និងអ្នកតំណាងរាស្ត្រដទៃទៀត ក៏មិនគួរកើតមានតាំងតែពីដើមមក ដោយសារតែលោកស្រីបានជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រ ហើយដែលលោកយល់ឃើញថា អភ័យឯកសិទ្ធិសភាត្រូវតែកើតមានសម្រាប់លោកស្រីជាស្វ័យប្រវត្តិ។ រីឯមតិខ្លះទៀតយល់ឃើញថា អភ័យឯកសិទ្ធិសមាជិករដ្ឋសភា កើតមានបន្ទាប់ពីសមាជិកដែលបានជាប់ឆ្នោតទាំងនោះចូលទៅស្បថកាន់តំណែងក្នុងសភា នៅពេលនោះហើយជាពេលដែលអ្នកតំណាងរាស្ត្រគ្រប់រូបមានអភ័យឯកសិទ្ធិ ។ ដូចយ៉ាង ថ្លែងក្នុងសន្និសីទកាសែតមួយនៅសណ្ឋាគារសាន់វ៉េ នាព្រឹកថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៣ ប្រធានផ្នែកសិទ្ធិមនុស្ស និងច្បាប់នៃអង្គការអាដហុក លោក នី ចរិយា បានមានប្រសាសន៍ថា ប្រសិនតំណាងរាស្ត្រទាំងអស់មានអភ័យឯកសិទ្ធិ បន្ទាប់ពីការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ដោយប្រជាពលរដ្ឋកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ និងបន្ទាប់មកមានសេចក្តីប្រកាសព័ត៌មានមួយ របស់រដ្ឋសភាកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ទទួលស្គាល់លើថារដ្ឋសភាបង្កើតឡើង ដោយមានតំណាងរាស្ត្រទាំង១២៣រូប ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់បោះឆ្នោត ។ ដូច្នេះរាល់ការចាប់ខ្លួន ការឃុំខ្លួន ឬការកោះហៅតំណាងរាស្ត្រ ដោយស្ថាប័នតុលាការ បើគ្មានការ«ព្យួរ»នូវអភ័យឯកសិទ្ធិនៃអ្នកតំណាងរាស្ត្រជាមុននោះទេ ជាករណី«ខុសច្បាប់»[77] ។ ក្នុងករណីនេះ មាត្រា២នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ បានចែងបញ្ជាក់ហើយថា តំណាងរាស្ត្រដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ហើយក្រោយពីបានប្រកាសសុពលភាព និងស្បថចូលកាន់តំណែងរួចហើយ គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងរបស់ប្រជាពលរដ្ឋនៅក្នុងមណ្ឌលរបស់ខ្លួននោះទេ ហេតុនេះយើងអាចនិយាយបានថា អភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រនីមួយៗ ក៏ត្រូវបានកើតឡើងផងដែរបន្ទាប់ពីការប្រកាសសុពល.ភាពនៃអ្នកតំណាងរាស្ត្រហើយនោះ ព្រមទាំងត្រូវបានស្បថចូលកាន់តំណែងរួចហើយ ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តីក៏ចំនុចនេះបានបង្កជាបញ្ហាចោទរួចទៅហើយដោយសារតែមិនមានបទ ច្បាប់ណាមួយធ្វើការចែងឱ្យត្រូវចំចំនុចជាក់ច្បាស់តែម្តងឡើយ ទើបបង្កទៅជាមានមតិបកស្រាយ ទៅលើចំនុចនេះផ្សេងៗគ្នាយ៉ាងដូច្នេះដែរ។

**២. ការកំណត់មិនច្បាស់លាស់អំពីវិសាលភាពនៃការផ្តល់អភ័យឯកសិទ្ធិ**

[77] ដកស្រង់ចេញពីគេហទំព័រhttp://www.monoroom.info/news> 「តំណាងរាស្ត្រគណបក្សប្រឆាំងគ្មានអភ័យឯកសិទ្ធិ?」 ចេញផ្សាយថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៤ ដោយអ៊ុម វ៉ារី

ថ្វីត្បិតតែ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជាច្បាប់កំពូលនៃប្រទេសជាតិ ដែលបានចែងអំពីអភ័យឯកសិទ្ធិសភានៅត្រង់មាត្រា ៨០ នៃរដ្ឋធម្មនុញ្ញក៏ពិតមែន ក៏ការចែងនេះ នៅពុំទាន់មានភាពច្បាស់លាស់នៅឡើយនោះទេ ។ ពោលគឺ ពុំបានបញ្ជាក់អំពី វិសាលភាពរបស់អភ័យឯកសិទ្ធិនេះ ថាមានត្រឹមណា ឬកំណត់បែបណានោះឡើយ ។ ភាគច្រើនគេតែងតែសង្កេតឃើញថា រដ្ឋធម្មនុញ្ញមិនចែងលម្អិតទៅលើផ្នែកណាមួយបានច្បាស់លាស់ ពោលគឺចែងតែគោលសំខាន់ៗតែប៉ុណ្ណោះ រីឯការបកស្រាយលម្អិតទៅលើផ្នែកណាមួយនោះ គឺមានច្បាប់ដោយឡែកមួយទៀតជាអ្នកចង្អុលបង្ហាញទៅលើផ្នែកទាំងនោះបានយ៉ាងពិស្តារ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ តាមការសិក្សាស្រាវជ្រាវកន្លងមក គឺយើងពុំដែលឃើញមានមាត្រាណាមួយ ឬក៏បទដ្ឋានគតិយុត្តណាមួយបានធ្វើការចែងលម្អិតទៅលើបញ្ហា ទាក់ទងទៅនឹងអភ័យឯកសិទ្ធិសភារបស់សមាជិករដ្ឋសភានេះដែរ ពិសេសចំណុចវិសាលភាពនៃអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភាតែម្តង គឺពុំដែលធ្លាប់មាននោះទេ ។ ភាពពុំមានការកំណត់ ឬកំណត់ន័យមិនច្បាស់លាស់យ៉ាងដូច្នេះ ទើបអ្នកសិក្សា ឬអ្នកអនុវត្តច្បាប់មួយចំនួនមានការយល់ឃើញក៏មិនច្បាស់លាស់នោះដែរ ដោយមិនដឹងថា តើអភ័យឯកសិទ្ធិនៃសមាជិករដ្ឋសភានេះមានវិសាលភាពប៉ុណ្ណា ? កម្រិតណា ? ទៅលើអ្វីខ្លះនោះទេ ? ដែលការកំណត់មិនច្បាស់លាស់នេះហើយ ជាហេតុនាំឱ្យកើតមាននូវភាពមិនច្បាស់លាស់ បង្កើតជាបច្ច័យធ្វើឱ្យមានការយល់ឃើញផ្សេងៗគ្នា ។ ជាក់ស្តែងនៅក្នុងសង្គមកម្ពុជា យើងនៅពេលបច្ចុប្បន្ននេះ អ្នកនយោបាយខ្លះយល់ឃើញថា "អភ័យឯកសិទ្ធិសមាជិករដ្ឋសភា" មានតែទៅលើខ្លួនបុគ្គលដែលជាសមាជិករដ្ឋសភាតែប៉ុណ្ណោះ ដោយអភ័យឯកសិទ្ធិសភានេះ វាពុំមានទៅលើរថយន្ត ឬទីកន្លែងរស់នៅរបស់គាត់នោះទេ ។ ទាក់ទងទៅនឹងការយល់ឃើញបែបនេះ ក៏យើងមិនអាចនិយាយថាខុសបានដែរ ពីព្រោះវាពុំមានការកំណត់ណាមួយឱ្យបានច្បាស់លាស់ទៅលើចំណុចនេះ ជាក់ស្តែងគឺមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ពុំបានចែងពីវិសាលភាពនៃអភ័យឯកសិទ្ធិនេះបានច្បាស់លាស់ ហើយបន្ថែមពីនេះ ក៏គ្មានចម្លើយណាមួយត្រូវបានលើកយកមកបកស្រាយបំភ្លឺឱ្យបានជាក់ច្បាស់នោះដែរ ។

ជាក់ស្តែង នៅក្នុងការចេញផ្សាយជាបន្តបន្ទាប់[78] ព្រឹត្តិបត្រ The Cambodia Daily បានរាយការណ៍នូវព្រឹត្តិការក្នុងលេខចេញផ្សាយជាបន្តបន្ទាប់របស់ខ្លួន ស្តីពីអភ័យឯកសិទ្ធិសភារបស់មេដឹកនាំបក្សប្រឆាំង លោក សម រង្ស៊ី និង សហការីរបស់លោកពីរនាក់ទៀត គឺលោក ជា ប៉ូច និង លោកជាម ចន្នី ។

[78] ច្បាប់ចេញផ្សាយថ្ងៃទី ៣១ ខែ មករា, ថ្ងៃទី០១ ខែកុម្ភៈ និងច្បាប់ចេញផ្សាយថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ ២០០៥

នៅក្នុងព្រឹត្តការណ៍ដំបូងបំផុត គឺខាងប៉ូលីសបានឆែកឆេរក្នុងរថយន្តរបស់ លោក សម រង្ស៊ី ហើយដែលក្រោយមកបានបណ្តាលឱ្យមានប្រតិកម្មពីលោកស្នងការប៉ូលីសក្រុងភ្នំពេញ និង លោក ខៀវ កាញ្ញារិទ្ធ អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ។

នៅក្នុងព្រឹត្តការណ៍ការបន្ទាប់មកទៀត គឺជាការដកអភ័យឯកសិទ្ធិសភាពីអ្នកទាំងបីនេះ ហើយដែលក្រោយមកបានបណ្តាលឱ្យមានការប្រឆាំងជំទាស់ពីសម្តេច ហេង សំរិន ដែលជាប្រធានទីមួយនៃរដ្ឋសភា ។

វាគួរតែមានការស្វែងយល់ឱ្យបានច្រើនជាងនេះទៀត នូវទស្សនៈទានស្តីពី"អភ័យឯកសិទ្ធិសភា" ក្នុងនោះក៏រួមមានផងដែរនូវ ការសម្រេចចិត្តឱ្យមានភាពច្បាស់លាស់ថែមទៀតនូវវិសាលភាព និង រយៈពេលជាដើម។

យោងតាមមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ អភ័យឯកសិទ្ធិសភាការពារដល់សមាជិករដ្ឋសភាពីការចោទប្រកាន់ទាំងឡាយ ការឃាត់ខ្លួន ឬការចាប់ខ្លួន ដែលបណ្តាលមកពីការសម្តែងមតិក្នុងការបំពេញភារកិច្ចរបស់ខ្លួន លើកលែងតែក្នុងករណីដែលសភាខ្លួនឯង បានដកអភ័យឯកសិទ្ធិទាំងនេះចេញ ឬមានករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។

ជាការពិតណាស់ថា អភ័យឯកសិទ្ធិទាំងអស់នេះ វាមិនអាចការពារដល់សមាជិករដ្ឋសភាពីការឆែកឆេរពីខាងប៉ូលីសបានទេ ហើយដូចដែលលោក ហេង ៧ បាននិយាយថា "លោកនឹងធ្វើការស៊ើបអង្កេត ហើយនឹងដាក់ពិន័យលើមន្ត្រីទាំងនោះ បើសិនជាមានការចាំបាច់" ។ ម្យ៉ាងទៀតនៅក្នុងពេលនោះដែរ លោក ខៀវ កាញ្ញារិទ្ធ ក៏បាននិយាយដែរថា " ទោះបីជាលោក សម រង្ស៊ី បានការពារដោយអភ័យឯកសិទ្ធិសភា ក៏ប៉ុន្តែរថយន្តរបស់លោកគ្មានអភ័យឯកសិទ្ធិសភាទេ" ។

ការឆែកឆេររបស់ប៉ូលីស គឺមានលក្ខណៈខាងនយោបាយ ឬក៏ថាជាការបំភិតបំភ័យខាងនយោបាយ បើសិនជាពួកគេព្យាបាទទៅលើជនណាម្នាក់ដោយគ្មានដីកា ។ ការស៊ើបអង្កេតត្រូវធ្វើឡើង បើទោះបីថាមាន ឬក៏គ្មានអភ័យឯកសិទ្ធិសភា ។ វិសាលភាពនៃអភ័យឯកសិទ្ធិនេះ រួមមានលើរូបកាយ ទីកន្លែងដែលសមាជិករដ្ឋសភារស់នៅ ការសម្តែងមតិរបស់ពួកគេ ។ ប៉ុន្តែ សួរថា តើទាំងអស់នេះ វាស្ថិតនៅនឹងកន្លែងនៃអាគាររបស់រដ្ឋសភា ឬថានៅក្នុងបរិវេណ ឬក៏នៅទីកន្លែងណាមួយនោះ[79]។

រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មិនមានការចែងបញ្ជាក់ពីបញ្ហាដូចជានៅទីកន្លែង ការសម្តែងមតិ ដែលត្រូវធ្វើឡើងនៅទីកន្លែងណាមួយថា តើនៅខាងក្រៅ ឬនៅខាង

[79] កៅ មុយថង, សៀវភៅនីតិរដ្ឋធម្មនុញ្ញកម្ពុជា, បោះលើកទី១ ដោយបណ្ណាគារអង្គរ, ឆ្នាំ២០០៦ ទំព័រ១៩៦

ក្នុងនៃអាគាររដ្ឋសភា ហើយវាគ្មានការកំណត់រយៈពេលនៃការមានអភ័យឯកសិទ្ធិនោះ ដូចជា ថាតើគេមានអភ័យឯកសិទ្ធិជារៀងរហូតដែរឬទេ បើសិនជាគេនៅតែជាសមាជិករដ្ឋសភា ? ឬក៏នៅក្នុងអាណត្តិរបស់រដ្ឋាភិបាល ? ឬក៏នៅក្នុងនីតិកាលរបស់សភា ? ហើយប្រសិនបើអភ័យឯកសិទ្ធិនោះត្រូវបានដកហូតដោយសមាជិករូបនោះត្រូវទទួលទណ្ឌកម្មជាប់ពន្ធនាគារ តែបន្ទាប់ពីអនុវត្តទោសនោះរួច មានន័យថាពេលចេញពីពន្ធនាគារ តើគាត់នៅតែអាចបន្តងារជាតំណាងរាស្រ្តដែលមានអភ័យឯកសិទ្ធិសភាទៀតឬយ៉ាងណា ពីព្រោះគាត់បានអនុវត្តទោសរួចរាល់ទៅហើយ ហើយអាណត្តិរបស់រដ្ឋសភាមិនទាន់បញ្ចប់នៅឡើយនោះ។

### ៣. វប្បធម៌និទណ្ឌភាពចំពោះការចំពានទៅលើតំណាងរាស្រ្ត

តំណាងរាស្រ្តម្នាក់ៗបន្ទាប់ពីការជាប់ឆ្នោតពេញសិទ្ធិជាតំណាងរាស្រ្តរួចមក គឺមិនមែនត្រឹមតែជាតំណាងឱ្យប្រជាពលរដ្ឋតែក្នុងមណ្ឌលដែលខ្លួនឈរឈ្មោះនោះទេ គឺជាតំណាងឱ្យប្រជាពលរដ្ឋទាំងមូលនៅទូទាំងប្រទេសកម្ពុជា ។ តាមរយៈការជាប់ឆ្នោតជាតំណាងរាស្រ្តពេញលេញហើយនោះ គឺសមាជិករដ្ឋសភាទាំង១២៣ នាក់ ត្រូវតែខិតខំបំពេញនូវកិច្ចការបំរើឱ្យប្រជាពលរដ្ឋនៅទូទាំងប្រទេសដោយយកប្រយោជន៍សមូហភាពជាធំ មិនគិតប្រយោជន៍បុគ្គល ឬប្រយោជន៍មួយក្រុមណាមួយ ទោះបីជាមណ្ឌលដែលប្រជាពលរដ្ឋនោះបានបោះឆ្នោតឱ្យខ្លួនក៏ដោយ ។ ដូចនេះហើយទើបរដ្ឋធម្មនុញ្ញមាត្រា៧៧ កថាខណ្ឌទី២ ចែងថា "អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ"។ ការចែងយ៉ាងដូច្នេះ គឺចង់ធ្វើការការពារសមាជិករដ្ឋសភាគ្រប់រូបមិនឱ្យភ័យខ្លាចចំពោះការទម្លាក់ពីតំណែងនៅពេលដែលពួកគាត់មិនបានធ្វើតាមប្រជាពលរដ្ឋនៅក្នុងមណ្ឌលដែលបោះឆ្នោតឱ្យខ្លួន។ ភាពជាតំណាងរបស់អ្នកតំណាងរាស្រ្ត គឺមានវិសាលភាព និងភារកិច្ចធំធេងណាស់សម្រាប់ប្រទេសជាតិទាំងមូល ពីព្រោះកិច្ចការសំខាន់ៗរបស់ជាតិ គឺត្រូវបានផ្ញើវាសនាទៅលើតំណាងទាំង១២៣នាក់នេះហើយ ។ តំណាងរាស្រ្តទាំង១២៣នាក់នៅក្នុងអាណត្តិទី៥នេះ គឺជាក្បាលម៉ាស៊ីនដឹកនាំដ៏សំខាន់នៅក្នុងស្ថាប័ននីតិបញ្ញត្តិសម្រាប់ធ្វើការគ្រប់គ្រង រៀបចំ ដឹកនាំប្រទេសជាតិឱ្យមានការរីកចម្រើន ។ បើយើងគិតទៅលើបញ្ហានេះទៅ គឺស្ថាប័ននីតិបញ្ញត្តិមួយនេះមានសារៈសំខាន់ណាស់ តែបើយើងធ្វើការពិនិត្យទៅលើច្បាប់ដែលចែងសម្រាប់ការពារអ្នកតំណាងរាស្រ្តវិញ គឺមានលក្ខណៈដូចជាប្រជាពលរដ្ឋធម្មតាទៅវិញ ។ ការនិយាយយ៉ាងនេះ គឺចង់សំដៅទៅលើបទល្មើសដែលជនដៃដល់បានប្រព្រឹត្តិមកលើអ្នកតំណាងរាស្រ្ត ដូចជាអំពើហិង្សាដែលប្រព្រឹត្តិទៅលើអ្នកតំណាងរាស្រ្តមកពីគណបក្សសង្គ្រោះជាតិ គឺលោក ញ៉យ ចំរើន និងលោក គង់ សភា ដែលត្រូវជនមួយក្រុមព្រួតគ្នាវាយ នៅពេលបើករថយន្តចេញពីប្រជុំនៅ មន្ទីររដ្ឋសភា កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ ជាដើម ។ ទាក់ទងទៅនឹងបញ្ហានេះ គឺយើងពុំទាន់មានការកំណត់ណាមួយផ្សេងពីពលរដ្ឋធម្មតា

នោះទេ ។ បើយើងក្រឡេកមកមើលរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ គឺពុំបានចែងកំណត់អំពីទោសទណ្ឌសម្រាប់ជនល្មើសដែលប្រព្រឹត្តិទៅលើអ្នកតំណាងរាស្ត្រនោះទេ ។ បើបែរមកពិនិត្យនៅក្នុងក្រមព្រហ្មទណ្ឌវិញ ក៏មិនមានចែងឱ្យដាច់ដោយឡែកនោះដែរ ពោលគឺបញ្ញត្តិតែទោសដែលជនល្មើសប្រព្រឹត្តិបទហិង្សា ទៅលើអ្នករាជការសាធារណៈ (មាត្រា ២២១ នៃក្រមព្រហ្មទណ្ឌ) តែប៉ុណ្ណោះ រីឯច្បាប់ផ្សេងៗក៏មិនបានបញ្ជាក់នោះដែរ ។

ប៉ុន្តែតាមការអនុវត្តកន្លងមក យើងឃើញថាជនដែលប្រព្រឹត្តិហិង្សា និងបំពានទៅលើអ្នកតំណាងរាស្ត្រគឺត្រូវបានតុលាការសម្រេចកាត់ទោស ដោយយោងទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដូចជាការអនុវត្តទៅលើប្រជាពលរដ្ឋទូទៅដែរ។ ប៉ុន្តែ បើយើងធ្វើការពិចារណាឱ្យបានល្អិតល្អន់ទៅ តំណាងរាស្ត្រក្នុងនាមជាអ្នកតំណាងឱ្យប្រជាពលរដ្ឋទូទាំងប្រទេស គួរតែត្រូវបានការពារពីសំណាក់ការបំពានទាំងនេះ ដោយបញ្ញត្តិច្បាប់ដ៏តឹងរឹងមួយទៅលើវប្បធម៌និទណ្ឌភាពនៃការបំពានទៅលើអ្នកតំណាងរាស្ត្រដែលមានអភ័យឯកសិទ្ធិនេះ បើមិនពុំនោះទេ តើមានអ្វីខុសគ្នារវាងពលរដ្ឋទូទៅ និងតំណាងរាស្ត្រនោះ។

**៤. ការបកស្រាយផ្ទុយគ្នាចំពោះការលើកអភ័យឯកសិទ្ធិរដ្ឋសភាដោយបទល្មើសព្រហ្មទណ្ឌ**

មាត្រា ៨០ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ចែងថា៖

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសម្តែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភា និងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោមនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃរបស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាកប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាក តាមមតិភាគច្រើនបីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការចែងយ៉ាងដូចនេះ នៅក្នុងមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ សួរថា តើវាគ្រាប់គ្រាន់ ឬនៅសម្រាប់ការប្រើប្រាស់នូវមាត្រានេះ យកមកអនុវត្តន៍នៅពេលបច្ចុប្បន្ន ? នៅពេលដែលអ្នកតំណាងរាស្ត្រណាម្នាក់ត្រូវបានចាប់ខ្លួន នៅក្នុងពេលប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ក្រសួងមានសមត្ថកិច្ចត្រូវរាយការណ៍ជូនរដ្ឋសភា ឬគណៈកម្មាការអចិន្ត្រៃយ៍ ដើម្បីធ្វើការសម្រេចលើកអភ័យឯកសិទ្ធិសភា ដោយអនុម័តយកមតិពីរភាគបី(២/៣) ។ ក្រសួងមានសមត្ថកិច្ចនៅក្នុងន័យនេះ គឺក្រសួងយុត្តិធម៌[80] ដែលមានសមត្ថកិច្ចក្នុងការស្នើរលើកអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រណាម្នាក់ ។ ប៉ុន្តែនីតិវិធីបន្តទៀតដែលត្រូវអនុវត្តមុននឹងមានការចាប់ខ្លួនអ្នកតំណាងរាស្ត្រ គឺពុំមានការចែងលម្អិតនោះទេ ។ ដូចដែលរដ្ឋធម្មនុញ្ញបានចែងហើយថា ការប្រជុំរបស់រដ្ឋសភាសម្រាប់រកសម្លេងពីរភាគបី(២/៣) នៃចំនួនសមាជិករដ្ឋសភាទាំងមូល ដើម្បីលើកអភ័យឯកសិទ្ធិសមាជិករដ្ឋសភា។ យោងតាមស្មារតីនៃមាត្រា៧ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រដែលឡាយព្រះហស្តលេខាប្រកាសឱ្យប្រើដោយព្រះបាទ នរោត្តម សីហមុនី នៅថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០០៦ បានចែងថា“តំណាងរាស្ត្រណាបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ នឹងអាចអនុញ្ញាតបើកឱ្យធ្វើការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន” ។

ក្នុងករណីនេះ មានន័យថា ប្រសិនបើសមាជិករដ្ឋសភាមិនបានប្រព្រឹត្តិបទល្មើសជាក់ស្តែងទេនោះ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនអាចប្រព្រឹត្តិទៅបានលុះត្រាមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាជាមុនសិនដោយការលើកអភ័យឯកសិទ្ធិរបស់សមាជិករូបនោះមុននឹងអនុវត្តទៅតាមនីតិវិធីរបស់តុលាការ។ ប៉ុន្តែ ប្រសិនបើជា បទល្មើសជាក់ស្តែង នោះមិនចាំបាច់សុំការយល់ព្រមជាមុនពីសំណាក់រដ្ឋសភាឬពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាដើម្បីធ្វើការប្រជុំសម្រេចដកអភ័យឯកសិទ្ធិនោះទេ គឺអាចចាប់ខ្លួនហើយចាំរាយការណ៍ជូនជាបន្ទាន់ជាក្រោយ បើយោងទៅតាមវាក្យខណ្ឌ៣នៃមាត្រា៨០នៃរដ្ឋធម្មនុញ្ញ និងមាត្រា១២នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ។

ទោះជាយ៉ាងនេះក្តី ខាងគណបក្សប្រឆាំងយល់ឃើញថា ការចោទប្រកាន់ ការឃាត់ខ្លួន ការចាប់ខ្លួន ឬក៏ការឃុំខ្លួន អ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិទាំងមិនទាន់លើកអភ័យឯកសិទ្ធិសភាខាងលើ គឺជាការផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ ខុសទៅនឹងនីតិវិធីដែលកំណត់នៅក្នុងច្បាប់ស្តីពី

[80] មាត្រា ៨ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឆ្នាំ២០០៦

លក្ខន្តិកៈតំណាងរាស្ត្រ ។ បើអភ័យឯកសិទ្ធិសមាជិករដ្ឋសភាមិនទាន់ត្រូវបានលើក គឺតុលាការមិនអាចធ្វើចំណាត់ការនីតិវិធីអ្វីបានឡើយទៅលើសមាជិករដ្ឋសភានោះ។

### ៥. ការចោទប្រកាន់តាមមាត្រា៥៣៨នៃក្រមព្រហ្មទណ្ឌ

តំណាងអយ្យការនៃសាលាដំបូងរាជធានីភ្នំពេញបានចោទប្រកាន់លោក កឹម សុខា ប្រធានស្តីទីគណបក្សសង្គ្រោះជាតិថាបានប្រព្រឹត្តិបទល្មើសជាក់ស្តែង ករណីមិនចូលបំភ្លឺតាមការកោះហៅរបស់តុលាការ ដោយលោកអាចប្រឈមជាប់ពន្ធនាគារពី១ខែ ទៅ ៦ខែ[81]។ នៅក្នុងសេចក្តីថ្លែងការណ៍មួយចុះថ្ងៃទី២៦ ខែឧសភា អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ[82] បានឱ្យដឹងថា បន្ទាប់ពីស្តាប់ចម្លើយរបស់នាងខុម ចាន់តារ៉ាទី ហៅស្រីមុំ ដែលត្រូវបានគេទម្លាយថាជាស្រីកំណាន់លោក កឹម សុខា អយ្យការបានកោះហៅជនសង្ស័យ២រូបដែលជាតំណាងរាស្ត្របក្សប្រឆាំង គឺលោក ពិន រតនា និងលោក គុ វ៉ាន់ចាន់ មកឆ្លើយបំភ្លឺហើយ លោក កឹម សុខា ក៏ត្រូវបានកោះហៅ ក្នុងឋានៈជាសាក្សីផងដែរ។ អយ្យការបញ្ជាក់ថាក្នុងដំណាក់កាលស៊ើបអង្កេត លោក កឹម សុខា ជា"សាក្សីដែលមានសារៈសំខាន់បំផុត"សម្រាប់ឆ្លើយបំភ្លឺនូវរឿងរ៉ាវមួយចំនួនដែលបានកើតឡើង។ សេចក្តីថ្លែងការណ៍បន្តថាលោក កឹម សុខា មិនចូលបំភ្លឺដោយមិនមានមូលហេតុសមស្របដោយគ្រាន់តែឱ្យមេធាវីបញ្ជូនលិខិតមកអយ្យការ។

បើតាមសេចក្តីថ្លែងការណ៍ អយ្យការពិនិត្យឃើញថា"ការមិនប្រព្រឹត្តិរបស់ឯកឧត្តម កឹម សុខា ដែលមិនបានចូលខ្លួនមកឆ្លើយបំភ្លឺតាមការកោះហៅរបស់តំណាងអយ្យការទាំងពីរលើកនេះ គឺជាបទល្មើសតាមមាត្រា៥៣៨"។ មាត្រា៥៣៨ចែងថារាល់បុគ្គលណាដែលត្រូវបានកោះហៅមកឱ្យឆ្លើយបំភ្លឺជាសាក្សីនៅមុខអយ្យការឬចៅក្រមស៊ើបសួរឬមុខតុលាការព្រហ្មទណ្ឌ ហើយមិនព្រមចូលខ្លួនមកតាមដីកាកោះហៅនោះ ដោយគ្មានមូលហេតុសមស្រប ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ៦ខែ និងពិន័យជាប្រាក់ពី ១០ម៉ឺន ទៅ ១លានរៀល។ តុលាការចាត់ទុកថាការមិនចូលបំភ្លឺជាការប្រព្រឹត្តិបទល្មើសជាក់ស្តែង ស្របតាមខ្លឹមសារមាត្រា៨៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយសម្រេចចោទប្រកាន់លោក កឹម សុខា និងបានបញ្ជូនសំណុំរឿងនេះទៅចៅក្រមស៊ើបសួរ។

សេចក្តីថ្លែងការណ៍ឱ្យដឹងទៀតថាតុលាការបានសុំឱ្យនគរបាលយុត្តិធម៌ចាប់ខ្លួន លោក កឹម សុខា ប៉ុន្តែមិនទាន់រកឃើញលោក កឹម សុខា។ ព្រះរាជអាជ្ញារងនៃសាលាដំបូងរាជធានីភ្នំពេញ លោក សៀង សុខ បានកោះហៅលោក កឹម សុខា ឱ្យចូលមកតុលាការបំភ្លឺក្នុងនាមជាសាក្សីចំនួន

---

[81] ដោយលោក ស៊ុន ណារិន, បក្សប្រឆាំងប្រកាសបើកកិច្ចប្រជុំបន្ទាន់ ក្រោមអធិបតីលោកកឹម សុខា ចេញថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ ម៉ោង7:43AM http://vodhotnews.com

[82] សូមមើលឧបសម្ព័ន្ធ៦

២លើក គឺនៅថ្ងៃទី១៧ខែឧសភា និងនៅថ្ងៃទី២៦ ខែឧសភា លើសំណុំរឿងសញ្ជារកម្ម ប៉ុន្តែលោក កឹម សុខា សម្រេចមិនចូលបំភ្លឺ ដោយថាលោកមានអភ័យឯកសិទ្ធិ។ ដោយសារការមិនចូលបំភ្លឺនេះ នៅម៉ោងប្រមាណ១២នឹង២០នាទីកាលពីថ្ងៃព្រហស្បតិ៍ សមត្ថកិច្ចបានឡោមព័ទ្ធទីស្នាក់បក្សសង្គ្រោះជាតិមួយភ្លែតដើម្បីរកចាប់ខ្លួនលោក កឹម សុខា តែមិនទាន់អាចចាប់បានភ្លាមៗ។ មុនការឡោមព័ទ្ធទីស្នាក់ការបក្សនៅសង្កាត់ចាក់អង្រែលើ សមត្ថកិច្ចរាប់សិបនាក់ក៏បានឃាត់រថយន្តរបស់លោក កឹម សុខា នៅព្រឹកម៉ោងប្រមាណ១១និង៣៥នាទី នៅលើផ្លូវនរោត្តម ក្បែរសាលាពញាហុក តែរថយន្តនោះមិនមានវត្តមានរបស់លោក កឹម សុខានោះទេ គឺមានតែភរិយារបស់លោក កឹម សុខា និងអ្នកបើករថយន្តតែប៉ុណ្ណោះ។

ការសង្ស័យថាលោក កឹម សុខា អាចនឹងត្រូវចាប់ខ្លួន ក្រោយពេលប្រធានអង្គភាពប្រឆាំងអំពើពុករលួយ លោក ឱម យ៉ិនទៀង បានលើកឡើងកាលពីកន្លងទៅថាអ្នកមានអភ័យឯកសិទ្ធិទាំងអស់មិនអាចប្រឆាំងវិធានការរបស់រដ្ឋាភិបាលឬនគរបាលយុត្តិធម៌នោះទេ។ លោកពន្យល់ថាប្រសិនបើតុលាការចោទប្រកាន់អ្នកមានអភ័យឯកសិទ្ធិ ទាល់តែមានការព្យួរអភ័យឯកសិទ្ធិ។ លោកបញ្ជាក់បន្ថែមថាប្រសិនបើករណីមិនចូលតាមការកោះហៅរបស់តុលាការ លោក កឹម សុខា នឹងត្រូវចាប់ខ្លួន ដោយថានេះជាបទល្មើសជាក់ស្តែង។

ប៉ុន្តែ មេធាវីចំនួន៥រូបរបស់លោក កឹម សុខា បានបកស្រាយផ្លូវច្បាប់ទៅកាន់ព្រះរាជអាជ្ញាក្នុងលិខិតមួយចុះថ្ងៃទី២៤ ខែឧសភាថា តុលាការគ្មានសិទ្ធិនាំខ្លួនលោក កឹម សុខា ទេ ដរាបណាដំណើការនីតិវិធីច្បាប់ស្ថិតក្នុងការស៊ើបអង្កេតបឋមនោះ [83] ។ លិខិតនោះបញ្ជាក់ថាដំណាក់កាលស៊ើបអង្កេតបឋមដូចសំណុំរឿងលោក កឹម សុខា ដែលតុលាការកំពុងដំណើការនីតិវិធីនេះ ក្រុមមេធាវីអះអាងថាតំណាងអយ្យការមិនមានសិទ្ធិអំណាចណាមួយ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឱ្យប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំកូនក្តីពួកគេឱ្យចូលបង្ហាញខ្លួន ឬនាំខ្លួនបានទេ។ មេធាវីរបស់លោក កឹម សុខា គឺលោក សំ សុគង់ មានប្រសាសន៍ថាការចាប់ខ្លួនលោក កឹម សុខា ជាការប្រព្រឹត្តិខុសច្បាប់ និងរដ្ឋធម្មនុញ្ញ។

### ៦. ការបកស្រាយផ្សេងគ្នាទាក់ទិននឹងការកោះហៅសមាជិករដ្ឋសភាចូលខ្លួនក្នុងតុលាការ

[83] ដោយ លោក ញឹម សុខន ।មេធាវីពន្យល់ថាតុលាការគ្មានសិទ្ធិនាំខ្លួន លោក កឹម សុខា ពេលនីតិវិធីស្ថិតក្នុងការស៊ើបអង្កេតបឋម ថ្ងៃព្រហស្បតិ៍ ទី២៦ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 2:06 PMhttp://vodhotnews.com/2016/05/lawyers-explain-that-the-court-had-no-right-to-bring-kem-sokha-in/

ក្រៅពីបញ្ហាខាងលើ យើងក៏សង្កេតឃើញបន្ថែមទៀតផងដែរថា នៅក្នុងពេលបច្ចុប្បន្នថ្មីៗនេះ គឺមានការយល់ឃើញផ្ទុយគ្នាជាច្រើនទាក់ទងទៅនឹងអភ័យឯកសិទ្ធិសមាជិករដ្ឋសភា ។ អ្នកខ្លះ គាត់យល់ឃើញថា អភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រ អាចការពារអ្នកតំណាងរាស្ត្របានតែក្នុង៤ករណីទេ គឺការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន ដោយឡែកមិនអាចការពារតំណាងរាស្ត្រពី ការកោះហៅ របស់តំណាងអយ្យការ ឬការកោះហៅដោយតុលាការបានទេ ។ ជាក់ស្តែង នៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦អ្នកនាំពាក្យក្រសួងយុត្តិធម៌ ចេញសេចក្តីថ្លែងការណ៍លេខពិសេសមួយ[84] ថា "[. . . អភ័យឯកសិទ្ធិសភា ការពារតំណាងរាស្ត្រ ចំពោះកិច្ចនីតិវិធីចំនួន៤ តែប៉ុណ្ណោះ គឺ ការចាទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួន ប៉ុន្តែពុំមានចំណុចណាមួយនៃមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់ដទៃទៀត នៃព្រះរាជាណាចក្រកម្ពុជាដែលការពារតំណាងរាស្ត្រពីការកោះហៅរបស់អង្គការអយ្យការ ឬ ការកោះហៅដោយតុលាការនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ រដ្ឋប្បវេណី និងសំណុំរឿងផ្សេងៗទៀតឡើយ. . .]" ប៉ុន្តែទាក់ទងទៅនឹងបញ្ហានេះ អ្នកខ្លះទៀតគាត់យល់ថា ប្រសិនបើពុំមានការលើកអភ័យឯកសិទ្ធិសភាជាមុនទេ គឺមិនអាចកោះហៅអ្នកតំណាងរាស្ត្រណាម្នាក់បាននោះឡើយ ដូចយ៉ាង លោក ស៊ីន ស៊ូប៊ែរ្តិ៍ ជាអតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមួយរូបបាននិយាយថា ការឃាត់ខ្លួន ឬឃុំខ្លួនអ្នកតំណាងរាស្ត្របាន លុះណាតែតំណាងរាស្ត្ររូបនោះត្រូវដកអភ័យឯកសិទ្ធិសភាជាមុនដោយសំឡេង២ភាគ៣ បើមិនបានប្រព្រឹត្តិបទល្មើសជាក់ស្តែង។ ចំណែកការកោះហៅតំណាងរាស្ត្រណាមួយ ចូលបំភ្លឺនៅតុលាការ យ៉ាងហោចណាស់ក៏ត្រូវធ្វើលិខិតសុំការអនុញ្ញាតិពីប្រធានរដ្ឋសភាជាមុនសិន "វាអត់ស្របនឹងរដ្ឋធម្មនុញ្ញពីព្រោះតំណាងរាស្ត្រមានអភ័យឯកសិទ្ធិ កាលណាគេកោះហៅ ឬគេឃុំហ្នឹងត្រូវតែគណៈកម្មាធិការអចិន្ត្រៃយ៍សភានឹងលើកអភ័យឯកសិទ្ធិហ្នឹង បើអត់ទាន់លើកទេវា អត់ត្រូវ អត់ស្របតាមរដ្ឋធម្មនុញ្ញ មានន័យថារំលោភរដ្ឋធម្មនុញ្ញហើយ យ៉ាងម៉េចក៏ដោយត្រូវសុំច្បាប់ពីប្រធានរដ្ឋសភាសិន"។ ប៉ុន្តែអ្នកនាំពាក្យរដ្ឋសភាលោក ឡេង ម៉េងឡុង ឯណោះវិញ បានលើកឡើងថា ការកោះហៅតំណាងរាស្ត្រណាម្នាក់ចូលបំភ្លឺ គឺមិនចាំបាច់ឆ្លងរដ្ឋសភាទេ តាមមាត្រា៨០នៃរដ្ឋធម្មនុញ្ញ តំណាងរាស្ត្រអាចប្រើសិទ្ធិចូលឬមិនចូលតាមដីកានោះ " ទេៗអត់ទេ អាហ្នឹង គឺថាអំណាចដាច់ពីគ្នា ការកោះហៅគេកោះហៅអញ្ចឹងហើយ ប៉ុន្តែអ្នកចូលក៏ចូលទៅ ។ ប៉ុន្តែក្នុងឋានៈគាត់ជាសមាជិកសភា មានមាត្រា៨០នៃរដ្ឋធម្មនុញ្ញបានធានាពីអភ័យឯកសិទ្ធិសភា " [85] ។

---

[84] សូមមើលឧបសម្ព័ន្ធ៤

[85] ដកស្រង់ចេញពី VOD ដែលបានចុះផ្សាយថា "អតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញថាវិធានការច្បាប់ពេលនេះ"ដូចបាយឡុក បាយឡ"ដោយ លោក ញឹម សុខន ថ្ងៃពុធ ទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 5:39 PM ។

### ៧. ការបកស្រាយផ្សេងគ្នាទៅលើមាត្រា៨០នៃរដ្ឋធម្មនុញ្ញ

មាត្រា ៨០ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ចែងថាៈ

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសម្តែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភា និង អាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ ពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោមនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។ ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាក តាមមតិភាគច្រើនបីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ថ្ងៃបន្ទាប់ពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ចេញសេចក្តីថ្លែងការណ៍[86]មិនចូលទៅកាន់តុលាការតាមដីការកោះរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក្រសួងយុត្តិធម៌នៅថ្ងៃទី៥ ឧសភា ក៏បានចេញសេចក្តីថ្លែងការណ៍តប[87] ហើយបញ្ជាក់ថា គឺជាទង្វើដែលមានចរិកដាក់សម្ពាធទៅលើអំណាចតុលាការ ដែលជាអំណាចឯករាជ្យធានាការពារដោយច្បាប់ និង រដ្ឋធម្មនុញ្ញ។

មាត្រា៨០ នៃរដ្ឋធម្មនុញ្ញត្រូវបានអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងនឹងក្រសួងយុត្តិធម៌ធ្វើការបកស្រាយផ្សេងគ្នា ទាក់ទងទៅនឹងការកោះហៅអ្នកតំណាងរាស្ត្រ ដែលមានអភ័យឯកសិទ្ធិទៅបំភ្លឺនៅតុលាការជុំវិញរឿងស្នេហារបស់លោក កឹម សុខា-ស្រីមុំ និងរឿងបរិហារកេរ្តិ៍លោកកឹម សុខា-ធី សុវណ្ណថា[88]។

លោកសុម ឆ័យ ប្រធានក្រុមអ្នកតំណាងរាស្ត្រ ឬ អភិបាលក្រុមអ្នកតំណាងរាស្ត្រ គណបក្សសង្គ្រោះជាតិលើកឡើងថា សេចក្តីថ្លែងការណ៍របស់សមាជិកសភាគណបក្សសង្គ្រោះជាតិគ្រាន់តែ

---

[86] សូមមើលឧបសម្ព័ន្ធ៣

[87] សូមមើលឧបសម្ព័ន្ធ៤

[88] ដោយ ញឹម សុផល, ចំណុចខ្លះនៃរដ្ឋធម្មនុញ្ញទាមទារឲ្យមានការធ្វើច្បាប់បន្ថែមចៀសវាងការបកស្រាយខុសគ្នា, ចុះផ្សាយនៅថ្ងៃ06/05/2016 ខ្សែរអាត់សំលេង http://www.rfa.org/khmer/

ជាការជំរុញស្ថាប័នកំពូលៗ សំដៅឱ្យមានភាពឯករាជ្យពីគ្នា[89]។ "អ្វីដែលជាសេចក្តីថ្លែងការណ៍របស់អ្នកតំណាងរាស្ត្រ យើងពុំមានគោលបំណងគាបសង្កត់ទៅលើស្ថាប័នណាទេ យើងជំរុញឱ្យស្ថាប័នដែលត្រូវតែមានភាពឯករាជ្យដាច់ពីគ្នា ដូចជា ស្ថាប័នរដ្ឋសភាដែលជាស្ថាប័ននីតិបញ្ញត្តិ ស្ថាប័នរដ្ឋាភិបាល ដែលជាស្ថាប័ននីតិប្រតិបត្តិ គឺថាធ្វើយ៉ាងណាកុំឱ្យលូកលាន់ទៅនឹងស្ថាប័នតុលាការ ដែលជាស្ថាប័នមួយបញ្ជាក់នៅក្នុងរដ្ឋធម្មនុញ្ញថាជាស្ថាប័នឯករាជ្យ» លោកសុមឆ័យបានលើកឡើង ។ ជាមួយគ្នានេះលោកជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌បានលើកថា សកម្មភាពរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិជាការមើលងាយ និងមិនសហការ។ "គាត់ហាក់ដូចជាមើលងាយទៅលើ ចំណាត់ការរបស់តុលាការ ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចនៅពេលដែលតុលាការចេញដីការកោះទៅ គាត់បដិសេធមិនចូលតាមដីការកោះហ្នឹង ហេតុនេះមានន័យថា គាត់មើលងាយទៅលើចំណាត់ការរបស់ក្រសួងមានសមត្ថកិច្ច មួយទៀតគឺរំលោភបំពានទៅលើបទបញ្ញត្តិនៃច្បាប់កំណត់ថា ពលរដ្ឋគ្រប់រូប ត្រូវតែមានកាតព្វកិច្ចក្នុងការចូលមកសហការជាមួយអាជ្ញាធរ មានសមត្ថកិច្ចរាល់ការអនុវត្តច្បាប់។ ហេតុនេះហើយពលរដ្ឋគ្រប់រូប មិនថាជានរណាទេ មិនថាមិនមែនជាសមាជិក ឬក៏សង្គមស៊ីវិល ឬមួយអង្គការអ្វីនោះទេមាន កាតព្វកិច្ចត្រូវតែចូលសហការជាមួយអាជ្ញាធរក្នុងការអនុវត្តច្បាប់តាមបញ្ញត្តិច្បាប់។ ដូចនេះ ការចេញដីការបដិសេធមិនចូលរួម មិនសហការជាមួយ មិនចូលខ្លួនតាមការកោះ នេះគឺបានន័យថា ជាការមើលងាយ ទៅលើចំណាត់ការនៃអាជ្ញាធរមានសមត្ថកិច្ច" លោកជិន ម៉ាលីនបានលើកឡើងយ៉ាងដូច្នេះ។

លោកជិន ម៉ាលីនយល់ថា មាត្រា៨០នៃរដ្ឋធម្មនុញ្ញ ក៏ដូចជាច្បាប់ផ្សេងៗទៀតមិនបានចែងពាក់ព័ន្ធនឹងការកោះអញ្ជើញរបស់តុលាការ ហៅទៅសួរនាំដែលការសួរនាំនោះក្រោមរូបភាពជាកិច្ចសហការ។ "អ្នកជំនាញច្បាប់ ក៏ដូច ជាក្រសួងយុត្តិធម៌នោះឃើញថាមានការសោកស្តាយទៅលើសេចក្តីថ្លែងការណ៍របស់ គណបក្សសង្គ្រោះជាតិ ដែលសេចក្តីថ្លែងការណ៍នោះគឺយោងទៅលើមាត្រា៨០ ដែលនេះ ជាការបំភាន់មតិសាធារណៈជនទៅលើខ្លឹមសារ អត្ថន័យនៃមាត្រា៨០ បើពិនិត្យឱ្យបានល្អិតល្អន់មាត្រា៨០នោះគឺគេកំណត់តែពីការឃុំខ្លួន ឃាត់ខ្លួន ចាប់ខ្លួនឬក៏ចោទប្រកាន់ប៉ុណ្ណោះដែលអភ័យឯកសិទ្ធិត្រូវបានការពារ តែបើចំពោះបទល្មើសជាក់ស្តែងគឺអភ័យឯកសិទ្ធិមិនអាចត្រូវការពារបានទេ ប៉ុន្តែការកោះហៅនោះមិនមែនជានីតិវិធីនៃការឃុំខ្លួន ឃាត់ខ្លួន ចាប់ខ្លួន ឬក៏ចោទប្រកាន់ទេ គឺជាការកោះហៅដើម្បីចូលមកបំភ្លឺដើម្បីផ្តល់ពត៌មាន ស្វែងរកការពិត និងជាការចូលរួមសហការជាមួយអជ្ញាធរមានសមត្ថកិច្ច ក្នុងការអនុវត្តច្បាប់ដែលពលរដ្ឋទាំងអស់ត្រូវតែមានកាតព្វកិច្ចចូលរួម" លោកជិន ម៉ាលីនបញ្ជាក់បន្ថែម។

ជាមួយនឹងគ្នានេះ លោកមេធាវី សុក សំអឿន ប្រធានក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាលើកឡើងពីអភ័យឯកសិទ្ធិសភា និងការកោះអញ្ជើញ។ "នៅក្នុងរដ្ឋធម្មនុញ្ញបានចែងចំពោះតែរឿងឃាត់ខ្លួន

[89] ដោយ ញឹម សុផល, ចំណុចខ្លះនៃរដ្ឋធម្មនុញ្ញទាមទារឲ្យមានការធ្វើច្បាប់បន្ថែមចៀសវាងការបកស្រាយខុសគ្នា, ចុះផ្សាយនៅថ្ងៃ06/05/2016 ខ្សែរអាត់សំលេង http://www.rfa.org/khmer/

ឃុំខ្លួននិងចាប់ខ្លួន មិនមានចែងអំពីការអញ្ជើញទេ។ ចំពោះការអញ្ជើញនេះដែរ មិនមានបញ្ហាអ្វីទេគ្រាន់តែសាមីខ្លួនអាចមានសិទ្ធិទៅ ឬមិនទៅអត់មានទោសពៃអ្វីទេ តែបើជាប្រជាពលរដ្ឋធម្មតាបើតុលាការកោះហៅហើយមិនទៅចូលខ្លួនតាមការកោះហៅរបស់តុលាការ គឺតុលាការនឹងចេញដីការបន្តទៀតគឺហៅថាដីការឃាត់ខ្លួន។ តែចំពោះតំណាងរាស្ត្រដែលមានអភ័យឯកសិទ្ធិ ទោះបីមិនចូលខ្លួនតាមការកោះហៅរបស់តុលាការក៏ដោយក៏គ្មានសិទ្ធិទៅឃាត់ខ្លួនតំណាងរាស្ត្ររូបនោះដែរ។ បើទៅឃាត់ខ្លួនមានន័យថាជាការទៅចាប់ខ្លួនហើយ ដែលនេះជាការយល់ឃើញរបស់ខ្ញុំ តែបើចំពោះរដ្ឋាភិបាលយល់ឃើញយ៉ាងម៉េចខ្ញុំក៏មិនដឹងដែរ។ ខ្ញុំយល់ថា អ្វីទៅជាអភ័យឯកសិទ្ធិ ព្រោះអភ័យឯកសិទ្ធិ គឺមិនអាចត្រូវបានចាប់ខ្លួន ឃុំខ្លួន ឃាត់ខ្លួន" លោកអុក សំអឿនបានលើកឡើង[90]។

### ៨. បញ្ហាចោទនៅលើអត្ថន័យនៃការញុះញង់ និង ការបញ្ឆេញមតិ

ទាក់ទិននឹងករណីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមណ្ឌលសៀមរាប លោក អ៊ុំ សំអាន វិញ លោកត្រូវបានគេថាការលើកឡើងរបស់លោក អ៊ុំ សំអាន តាមបណ្តាញសង្គម Facebook ដោយចោទប្រកាន់ផែនទីផ្លូវការរបស់រាជរដ្ឋាភិបាលប្រើប្រាស់សព្វថ្ងៃ ក្នុងការបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម គឺជាផែនទីក្លែងក្លាយនិងការបង្ហោះសារផ្សេងៗទៀតនោះ គឺមានចរិតញុះញង់បង្កឱ្យរឹករវដល់សន្តិសុខនិង ការញុះញង់ឱ្យមានការរើសអើង[91]។ ការលើកឡើងដោយប្រើប្រាស់ពាក្យថាមានចរិតនេះគឺជាការបកស្រាយ ដោយមិនស្របតាមគោលការណ៍នៃការបកស្រាយនៅក្នុងព្រហ្មទណ្ឌនោះទេ។ មាត្រា៥នៃក្រមចែងថាក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយ"យ៉ាងតឹងរ៉ឹង"។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬ ប្រព្រឹត្តិតាមទិសភាពបានឡើយ។ ក្នុងករណីរបស់លោក អ៊ុំ សំអាន លោកបានសរសេរបកស្រាយ ផ្តល់បទសម្ភាសន៍និងបង្ហោះឯកសារពាក់ព័ន្ធកិច្ចការព្រំដែន ដោយលោក អ៊ុំ សំអាន ផ្ទាល់ក៏បានបញ្ជាក់ដែរថាទង្វើរបស់លោកគ្រាន់តែចង់តាមដាន ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការប្រើប្រាស់ផែនទីនិងការបោះបង្គោលព្រំដែន ក្នុងន័យការពារមិនឱ្យបាត់បង់ទឹកដីខ្មែរ ជាទង្វើគិតដល់ជាតិ ដែលកិច្ចការនេះក្នុងនាមជាតំណាងរាស្ត្រគួរណាស់តែធ្វើសម្រាប់ជាតិ។

ក្នុងករណីលោកតំណាងរាស្ត្រអ៊ុំ សំអាននេះផងដែរ ថាតើការដែលលោកចង់តាមដានផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការប្រើប្រាស់ផែនទី និងការបោះបង្គោលព្រំដែនក្នុងន័យការពារមិនឱ្យបាត់បង់ទឹកដីខ្មែរ ជាទង្វើគិតដល់ជាតិ ដែលកិច្ចការនេះក្នុងនាមជាតំណាងរាស្ត្រគួរណាស់តែធ្វើ

[90] ដោយ ញឹម សុផល, ចំណុចខ្លះនៃរដ្ឋធម្មនុញ្ញទាមទារឲ្យមានការធ្វើច្បាប់បន្ថែមចៀសវាងការបកស្រាយខុសគ្នា, ចុះផ្សាយនៅថ្ងៃ06/05/2016 ខ្សែរអាត់សំលេង http://www.rfa.org/khmer/

[91] ដោយvodadminថ្ងៃព្រហស្បត៍ទី១៤ខែមេសាឆ្នាំ២០១៦ម៉ោង 7:30AM http://vodhotnews.com/2016/04/letter-to-editor-immunity-can-be-protected/

សម្រាប់ជាតិនេះតើជាការញុះញង់ ឬយ៉ាងណា។ តាមធម្មតា ក្នុងនាមជាតំណាងរាស្ត្រ តំណាងឱ្យប្រជាពលរដ្ឋទូទាំងប្រទេសត្រួតពិនិត្យការអនុវត្ត និង ការដឹកនាំរបស់រាជរដ្ឋាភិបាល ឱ្យមានភាពត្រឹមត្រូវ និងមានតួនាទីមើលថែសុខទុក្ខការពារប្រជារាស្ត្រ និង ផលប្រយោជន៍ជាតិ។ ប៉ុន្តែប្រសិនបើការដែលតំណាងរាស្ត្រ បានធ្វើបែបនេះ ដើម្បីបញ្ជាក់ពីការពិតការពារជាតិ ជាការញុះញង់ តើភាពជាអ្នកតំណាងរាស្ត្រមានន័យយ៉ាងណា? ហើយតើនេះជាការញុះញង់ ឬ ជាការបញ្ចេញមតិក្នុងនាមជាតំណាងរាស្ត្រ? នៅត្រង់ចំនុចនេះ មិនមានបញ្ញត្តិច្បាប់ណាមួយ ចែងបញ្ជាក់អំពីអត្ថន័យទាំងនេះ សម្រាប់ជាគោលការណ៍អនុវត្តន៍របស់តំណាងរាស្ត្រឡើយ។ ហេតុនេះហើយតើពេលណាបញ្ចេញមតិទៅជាការត្រឹមត្រូវស្របតាមរដ្ឋធម្មនុញ្ញ ហើយពេលណាបញ្ចេញមតិទៅក្លាយជាការញុះញង់នាំឱ្យមានទោស នោះជាបញ្ហា។

### កថាខណ្ឌទី២ បញ្ហាប្រឈមនៅជប៉ុន

#### ១. លក្ខខណ្ឌ និងរយៈពេលនៃការចាប់ខ្លួន

នៅពេលដែលសភាបានធ្វើការអនុញ្ញាតឱ្យចាប់ខ្លួនសមាជិកសភារូប ណាមួយហើយ ថាតើគួរកំណត់លក្ខខណ្ឌបែបណា ឬថាតើអាចកំណត់រយៈពេលនៃការចាប់ខ្លួនបានឬយ៉ាងណានោះគឺក្លាយជាចំនុចបញ្ហានៅជប៉ុន ពីព្រោះថាក្នុងករណីបើមាន ការកំណត់រយៈពេលជាទុកមុន នឹងត្រូវបានតុលាការពិចារណាពីការមោឃភាពនៃការកំណត់រយៈពេលនោះ។

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៥៤ សភាបានយល់ព្រមឱ្យធ្វើការចាប់ខ្លួនសមាជិក ហើយមានការកំណត់រយៈពេលក្នុងការឃុំខ្លួនត្រឹមថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៤ ប៉ុន្តែត្រូវបានតុលាការធ្វើការពិចារណាមោឃភាពចោលនូវការកំណត់រយៈពេលនោះ ហើយមកដល់ថ្ងៃទី៧ ខែមីនា ទើបសមាជិក រូបនោះត្រូវបានធ្វើការចាប់ឃុំខ្លួន[92]។ ចំពោះបញ្ហានេះ ដោយសារតែជួនកាលសភាអាចមិនបានធ្វើការព្រមព្រៀងទាំងស្រុងឱ្យធ្វើការចាប់ខ្លួនសមាជិកសភារូបនោះទេ ហេតុនេះហើយទើបមានគំនិតដែលមិនគាំទ្រវាល់ការកំណត់នូវរយៈពេល ឬ កំណត់លក្ខខណ្ឌនោះទេ។

ករណីមួយទៀត នៅសម័យស្សូវ៉ាឆ្នាំ២៩ ថ្ងៃ១៦ ខែកុម្ភៈ សមាជិករដ្ឋសភាម្នាក់ត្រូវបានសង្ស័យថាបានប្រព្រឹត្តិអំពើពុករលួយ ក៏មានទាមទារឱ្យធ្វើការចាប់ខ្លួនសមាជិករដ្ឋសភារូបនោះ។ ក្នុងថ្ងៃនោះដែរ បន្ទាប់ពី មានការទាមទារឱ្យចាប់ខ្លួន ព្រះរាជអាជ្ញាតុលាការតូក្យូម្នាក់បានធ្វើលិខិតស្នើរសុំឱ្យចាប់ខ្លួនទៅគណៈរដ្ឋមន្ត្រី។ បន្ទាប់មកគណៈរដ្ឋមន្ត្រី បានប្រជុំពិភាក្សាពីបញ្ហារបស់សមាជិករដ្ឋសភារូបនេះរួចមក ថ្ងៃទី២៣ ខែកុម្ភៈនៅឆ្នាំដដែលនោះ នៅក្នុងអំឡុងពេលប្រជុំពេញ

[92]長谷部恭男『憲法』（第５版）２０１１年、３３６頁。
ហាសេបិយ៉ាសឹអុ 『រដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៥ , ឆ្នាំ២០១១, ទំព័រ៣៣៦

អង្គរបស់សភា សភាបានកំណត់ កំណត់រយៈពេល និងសម្រេចអនុញ្ញាតឱ្យចាប់ខ្លួនសមាជិករដ្ឋសភារូបនោះពីថ្ងៃកំណត់រហូតដល់ ថ្ងៃទី៣ ខែមីនា ឆ្នាំដដែល។ គណៈរដ្ឋមន្ត្រីក៏បានទទួលស្គាល់ពីការកំណត់កាលបរិច្ឆេទ និងរយៈពេល នៃការចាប់ខ្លួននេះដែរ ព្រមទាំងបានប្រកាសជាដំណឹងអំពីការចាប់ខ្លួនសមាជិករដ្ឋសភានោះទៅកាន់តុលាការក្រុងតូក្យូថែមទៀត។ ដោយសារហេតុនេះហើយ នៅថ្ងៃបន្ទាប់ពីមានប្រកាសពីការព្រមព្រៀងឱ្យចាប់ខ្លួន ទើបនៅថ្ងៃទី២៤ខែកុម្ភៈឆ្នាំដដែលចៅក្រម បានបង្គាប់ឱ្យអនុវត្តតាមការចាប់ខ្លួនសមាជិករដ្ឋសភារូបនោះ ហើយបន្ទាប់មកនៅខែដដែលថ្ងៃទី២៦ ដោយមានការទាមទារពីព្រះរាជអាជ្ញា ចៅក្រមសាលាដំបូងក្រុងតូក្យូបានសម្រេចធ្វើការឃុំខ្លួនសមាជិករដ្ឋសភារូបនោះនៅក្នុងពន្ធនាគារក្រុងតូក្យូ។

ក៏ប៉ុន្តែ រដ្ឋធម្មនុញ្ញមាត្រា៥០ និង ច្បាប់ស្តីពីសភាមាត្រា៣៣បានចែងបញ្ជាក់ច្បាស់ហើយថា ចំពោះសមាជិកសភាទាំងពីរ អាចប្រើប្រាស់សិទ្ធិដើម្បីធ្វើការអនុញ្ញាតឱ្យចាប់ខ្លួនដោយគ្មានលក្ខខណ្ឌ ម្យ៉ាងទៀតក៏អាចប្រើប្រាស់សិទ្ធិក្នុងការបដិសេធមិនឱ្យចាប់ខ្លួនបាន ដោយយោងទៅតាមការវិនិច្ឆ័យវាស់វែងរបស់ខ្លួន ហេតុនេះហើយនៅពេលដែលមានការអនុញ្ញាតឱ្យចាប់ខ្លួនទៅតាមការស្នើរសុំទាមទារឱ្យចាប់ខ្លួននៅពេលជាមួយគ្នានោះអាចកំណត់កាលបរិច្ឆេទ និងរយៈពេលឱ្យធ្វើការចាប់ខ្លួនបាន។

លក្ខខណ្ឌចំបងនោះគឺស្របពេលនឹងការអនុញ្ញាតឱ្យកំណត់រយៈពេលក្នុងការចាប់ខ្លួន បើយោងតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេស គឺមានឋានានុក្រមខ្ពស់ជាងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ហេតុនេះហើយក្នុងករណីខាងលើ ការដែលសភាបានកំណត់រយៈពេលត្រឹមថ្ងៃទី ៣ ខែមីនាក្នុងការចាប់ខ្លួនសមាជិករដ្ឋសភានោះ ព្រះរាជអជ្ញាមិនគួរទាមទារឱ្យមានការឃុំខ្លួន ហើយចៅក្រមផងដែរ មិនគួរចេញសេចក្តីសម្រេចឱ្យធ្វើការឃុំខ្លួនតាមកាលបរិច្ឆេទ និងរយៈពេលកំណត់នោះទេហើយក៏មិនគួរកំណត់លក្ខខណ្ឌណាមួយដើម្បីធ្វើការឃុំខ្លួនទេ ព្រោះសេចក្តីសម្រេច ឱ្យធ្វើការកំណត់លក្ខខណ្ឌក្នុងការឃុំខ្លួននេះ គឺផ្ទុយទៅនឹងច្បាប់ ទើបមានការទាមទារឱ្យលុបចោលសេចក្តីសម្រេចដែលបានកំណត់រយៈពេលនោះវិញ។

ចំនុចបញ្ហាត្រង់ថា ការព្រមព្រៀងឱ្យមានការចាប់ខ្លួនសមាជិករដ្ឋសភា ដោយមានកំណត់រយៈពេល និង លក្ខខណ្ឌចំបងនៃការចាប់ខ្លួននេះ មានសុពលភាពតាមច្បាប់ ឬក៏យ៉ាងណាបានក្លាយទៅជាបញ្ហាដែលកំពុងតែពិភាក្សាវែកញែកក្នុងបណ្តាចំនោមអ្នកច្បាប់។

ស្របតាមការយល់ព្រមឱ្យចាប់ខ្លួនបាន ប្រសិនបើពិចារណាទៅឃើញថាចាំបាច់ សភាអាចមានសិទ្ធិកំណត់រយៈពេល និងលក្ខខណ្ឌដើម្បីធ្វើការចាប់ខ្លួនបាន។ ប៉ុន្តែបើទោះបីជាយ៉ាងនេះក្តី ក៏មានមតិប្រឆាំងលើកឡើងថា មិនគួរធ្វើការកំណត់រយៈពេល និងលក្ខខណ្ឌក្នុងការចាប់ខ្លួនទេ ប៉ុន្តែ

បើយោងលើភាពចាំបាច់ និង មានហេតុផលត្រឹមត្រូវច្បាស់លាស់តែប៉ុណ្ណោះចាំធ្វើការកំនត់រយៈពេល មានន័យថានេះជាការទាមទារឱ្យមានការយល់ព្រមឱ្យធ្វើការចាប់ខ្លួនដោយភាពត្រឹមត្រូវ។ បើទោះបីជាមានមតិយល់ឃើញមិនស្របគ្នា ទាក់ទិននឹងបញ្ហានេះ ប៉ុន្តែបើយោងទៅតាមការអះអាងរបស់សមាជិកសភាភាគច្រើនគឺមិនគាំទ្រឱ្យមានការកំណត់រយៈពេល និងលក្ខខណ្ឌទេ ប្រសិនបើគិតថាវត្តមានរបស់សមាជិកសភាដែលនឹងត្រូវធ្វើការចាប់ខ្លួននោះគឺចាំបាច់ត្រូវតែមាន ដើម្បីធ្វើការធ្វើការសេចក្តីសម្រេចក្នុងសភា។

បញ្ហាថា តើមានករណីណាខ្លះទើបអាចយល់ព្រមឱ្យចាប់ខ្លួន ឬមិនយល់ព្រមឱ្យចាប់ខ្លួន? គោលបំណងនៃការមិនត្រូវបានចាប់ខ្លួននេះសំដៅលើចំនុចណាមួយ លក្ខខណ្ឌពិសេសអ្វីទើបមិនអាចត្រូវចាប់ខ្លួន? មានសិទ្ធិនោះហើយហេតុអ្វីមានអញ្ញត្រកម្ម? ហេតុអ្វីអាចលើកលែងបាន និងមិនអនុញ្ញាតឱ្យចាប់ក៏បាន ឬចាប់ក៏បាន?

បើគោលបំណងនៃការមិនចាប់ខ្លួន គឺការពារសេរីភាពក្នុងការបំពេញភារកិច្ចរបស់សមាជិកសភា និង ការពារពីការឆ្លៀតឱកាសចំនេញខាងនយោបាយហើយធ្វើការចាប់ខ្លួនមិនត្រឹមត្រូវហេតុនេះ មុននឹងចាប់ខ្លួនបានគួរតែត្រូវឆ្លងកាត់ការអនុញ្ញាតពីសភាជាមុនសិន ទើបការចាប់ខ្លួននោះត្រឹមត្រូវ ប្រកបដោយហេតុផលជាក់លាក់។

តែបើក្នុងករណីមានគោលដៅការពារទៅដល់សេរីភាព ក្នុងការធ្វើសេចក្តីសម្រេចរបស់សភាដោយមិនឱ្យមានការជ្រៀតជ្រែកអ្វីមួយនោះ គឺមិនអាចចាប់ខ្លួនដោយសំអាងហេតុផលមិនស្របច្បាប់នោះទេ ប៉ុន្តែត្រូវពិចារណាលើភាពសំខាន់ចាំបាច់នូវវត្តមានរបស់សមាជិកសភារូបនោះថាគួរតែចាប់ខ្លួន ឬ មិនគួរចាប់ខ្លួនព្រោះសភាចាំបាច់ត្រូវការវត្តមានរបស់សមាជិកសភារូបនោះដើម្បីធ្វើសេចក្តីសម្រេចក្នុងសភា។ ករណីនេះសភាអាចមិនអនុញ្ញាតឱ្យចាប់ខ្លួនបានប្រសិនបើពិចារណាទៅយល់ឃើញថា វត្តមានសមាជិករូបនោះនៅក្នុងសភាពិតជាសំខាន់ចាំបាច់ពិតមែន។

ប៉ុន្តែ ថាតើស្ថិតក្នុងករណីបែបណាទើបអាចអនុញ្ញាតឱ្យធ្វើការចាប់ខ្លួនសមាជិកសភាបាន? តើហេតុផលក្នុងការចាប់ខ្លួននោះត្រឹមត្រូវឬយ៉ាងណា គួរតែធ្វើការពិចារណាឱ្យបានល្អិតល្អន់ទៅលើបញ្ហានេះ។ ម្យ៉ាងវិញទៀត តើការចាប់ខ្លួនសមាជិកសភាណាម្នាក់ អាចធ្វើឱ្យប៉ះពាល់ទៅដល់ការប្រព្រឹត្តិទៅរបស់សភាដែរឬយ៉ាងណានោះក៏គួរតែរិះគិតពិចារណាទៅលើចំនុចនេះដូចគ្នា។

ការចាប់ខ្លួននេះអាចអនុញ្ញាតបានប៉ុន្តែមានការកំណត់នូវរយៈពេលដ៏ជាក់លាក់មួយ ដើម្បីធ្វើការសម្រេចថាឱ្យចាប់ខ្លួន ឬមិនឱ្យចាប់នៅក្នុងអំឡុងពេលដែលបានកំនត់នោះ។ ប៉ុន្តែចំនុចដែលជាបញ្ហានោះគឺថា តើអាចមានលទ្ធភាពក្នុងការយល់ព្រមឱ្យមានការកំណត់រយៈពេលជាកំណត់មួយក្នុងការធ្វើការឃុំខ្លួននោះឬយ៉ាងណានោះ ពាក់ព័ន្ធនឹងបញ្ហានេះមានគំនិតខ្លះ លើក

ឡើងថាពិតជាអាចធ្វើការកំណត់បាន ប៉ុន្តែមានមតិមួយចំនួនទៀតលើកឡើងថា មិនអាចទៅរួចនោះឡើយ។ ក៏ប៉ុន្តែ សភាមានការលំបាកណាស់ក្នុងការញែកហេតុផលឱ្យបានដាច់ស្រលះ និងច្បាស់លាស់មួយ ដើម្បីយកហេតុផលនោះជាហេតុផលដ៏ត្រឹមត្រូវក្នុងការអនុញ្ញាតឱ្យធ្វើការចាប់ខ្លួនសមាជិកណាម្នាក់។ បើយោងទៅតាមយុត្តិសាស្ត្រវិញ ទាក់ទងនឹងការព្រមព្រៀងឱ្យមានការកំណត់រយៈពេលក្នុងការចាប់ខ្លួននេះដែរ មានការប្រកាសឱ្យធ្វើការលុបចោល ប្រសិនបើមានការកំណត់រយៈពេលឃាត់ខ្លួនទុកជាមុនរួចស្រេចនោះ[93]។

### ២. ករណីមានការបរិហារកេរ្តិ៍ពីសំណាក់សមាជិកសភា

សកម្មភាពដែលទាក់ទងទៅនឹង "ការថ្លែងសុន្ទរកថា" ក៏ឃើញមានបញ្ហាចោទឡើងផងដែរ ជាពិសេសបញ្ហាសំខាន់ដែលបានចោទឡើងនោះគឺ ការរំលោភបំពានលើតួនាទីភារកិច្ចខ្លួន ក្នុងនាមជាតំណាងរាស្ត្រ ប៉ុន្តែការសម្រេចសេចក្តីទៅលើសេចក្តីព្រាងច្បាប់ ឬការបោះឆ្នោតបញ្ចេញមតិជាដើមនោះ ទាក់ទិននឹងករណីនេះ បើមានគំនិតបំណងប្រឆាំងទៅនឹងសេចក្តីព្រាងច្បាប់នោះ ក៏រាប់បញ្ចូលជាសកម្មភាពក្នុងការបំពេញភារកិច្ចបានដែរ។ ប៉ុន្តែអ្វីដែលជាការពិបាកត្រង់ថា តើគួរបែងចែកឱ្យបានដាច់ស្រឡះ ថាតើសកម្មភាពណាដែលធ្វើទៅចាត់ទុកជាសកម្មភាពក្នុងការបំពេញភារកិច្ច ហើយសកម្មភាពណាដែលមិនចាត់ទុកជាសកម្មភាពដែលមិនទាក់ទងទៅនឹងការបំពេញភារកិច្ច។ ជាឧទាហរណ៍ មានអនុសាសន៍ជាច្រើនបានលើកឡើងថា ការនិយាយដើម មូលបង្កាច់ អ្នកដទៃនៅក្នុងសភា ស្ថិតក្រៅវិសាលភាពនៃការផ្តល់អភ័យឯកសិទ្ធហើយ ប៉ុន្តែ បើតាមការអនុវត្តសព្វថ្ងៃតាមសភាពពិត គឺមិនមែនបែបនោះឡើយ មានន័យថា ការអនុវត្ត និង ទ្រឹស្តីគឺមិនដូចគ្នា។

នៅក្នុងកិច្ចប្រជុំមួយ ស្តីពីបញ្ហាធ្វើវិសោធនកម្មច្បាប់ស្តីពីឱសថរបស់គណៈកម្មាធិការកិច្ចការសង្គម សមាជិកសភាមួយរូប បានលើកបញ្ចេញឈ្មោះពិតរបស់ប្រធានមន្ទីរពេទ្យមួយកន្លែងលើកយកមកបង្ហាញក្នុងអង្គប្រជុំ ដោយបាននិយាយថា ប្រធានមន្ទីរពេទ្យនោះបានប្រព្រឹត្តអំពើមិនគប្បីនាំឱ្យប៉ះពាល់ទៅដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អ្នកជំងឺស្ត្រី៥នាក់ដែលរងទុក្ខដោយសារតែការញៀនថ្នាំ[94]។ នៅថ្ងៃបន្ទាប់ក្រោយពីការលើកឡើងរបស់សមាជិកសភារូបនេះ ប្រធានមន្ទីរពេទ្យ នោះបានធ្វើអត្តឃាតដោយសារពាក្យបរិហាកេរ្តិ៍នោះ។ ក្រុមគ្រួសាររបស់សព បានអះអាងថា

[93] (東京地囮決昭和２９・３・６判期時２２号３頁)。
សេចក្តីសម្រេចរបស់តុលាការក្រុងតូក្យូ លេខ២២ទំព័រ៣ ថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៥៤

[94] 長谷部恭男・中島　徹・赤坂正浩・阪口正二郎・本　執秀紀　『ケースブック憲法』第３版、２０１０年、８８３頁。
ហាសេបិយ៉ាសឹអុ・ណាកាជីម៉ាតុអុរឹ・អាកៈសាកៈម៉ាសាហ៊ិរុ・សាកាហ្គឹឆិសូជិរុ・ម៉ូតុហ៊ិជិណុរី 『សៀវភៅករណីសិក្សារដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៣, ឆ្នាំ២០១០, ទំព័រ៨៨៣

ដោយសារតែពាក្យសម្តីវាយប្រហារបរិហារកេរ្តិ៍របស់សមាជិកសភារូបនោះហើយ ទើបបណ្តាលឱ្យប្រធានមន្ទីពេទ្យធ្វើអត្តឃាត ហេតុនេះហើយទើបក្រុមគ្រួសារសពបានដាក់បណ្តឹងប្តឹងទាមទារឱ្យសមាជិកសភារូបនោះសងជាប្រាក់សំណងជំងឺចិត្តដោយផ្ទាល់តាមមាត្រា៧០៩ និង ៧១០នៃក្រមរដ្ឋប្បវេណីជប៉ុន ហើយក៏បានធ្វើបណ្តឹងមួយទៀត ប្តឹងទៅរដ្ឋឱ្យរដ្ឋសងសំណងជំងឺចិត្តដូចគ្នាដោយយោងទៅតាមមាត្រា១នៃច្បាប់ស្តីពីសំណងជំងឺចិត្តរបស់រដ្ឋ។ នៅក្នុងករណីនេះ តុលាការកំពូលបានចេញសេចក្តីសម្រេចបដិសេធមិនតម្រូវឱ្យសមាជិកសភារូបនោះ ទទួលខុសត្រូវនៅក្នុងការសងជំងឺចិត្តទៅដល់ក្រុមគ្រួសារសពឡើយ។ មិនតែប៉ុណ្ណោះ ថែមទាំងមិនទទួលយកនូវបណ្តឹងដែលប្តឹងឱ្យរដ្ឋត្រូវសងជំងឺចិត្តដែរ។

ប៉ុន្តែ នៅក្នុងករណីដែលសមាជិកសភាណាម្នាក់បានធ្វើការបរិហារកេរ្តិ៍ពលរដ្ឋទូទៅ ហើយសកម្មភាពនោះបានបញ្ជាក់យ៉ាងច្បាស់លាស់ថា សមាជិកសភារូបនោះបានប្រព្រឹត្តិនូវសកម្មភាពក្នុងគោលបំណងមិនត្រឹមត្រូវ មិនស្មោះត្រង់ ផ្ទុយពីច្បាប់ដោយទោះបីជាបានដឹងថាស្ថានភាពដែលខ្លួនបានបង្ហាញឡើងជាអំពើបោកប្រាស់ ផ្ទុយពីអំណាចពិតប្រាកដក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះរដ្ឋមានតួនាទីត្រូវទទួលខុសត្រូវក្នុងការសងសំណងជំងឺចិត្ត។

## ផ្នែកទី២ ដំណោះស្រាយ

### កថាខណ្ឌទី១ ដំណោះស្រាយនៅកម្ពុជា

#### ១. បណ្តាទស្សនៈទូទៅទាក់ទិននឹងមាត្រា៨០នៃរដ្ឋធម្មនុញ្ញ និង ការបញ្ចេញមតិរបស់តំណាងរាស្ត្រ

មាត្រា៨០ត្រូវបានចែកជា៥វាក្យខណ្ឌ ដែលវាក្យខណ្ឌ១ និង២ ចែងថា តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ តំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំបែកមុខងាររបស់ខ្លួនសោះឡើយ។ កថាខណ្ឌទាំងពីរនេះងាយយល់ទេ គឺក្នុងការបំពេញមុខងាររបស់ខ្លួនក្នុងជីវភាពជាអ្នកតំណាងរាស្ត្រនៅក្នុងអាណត្តិរបស់ខ្លួន ជាពិសេសគ្រប់រូបភាពនៃការបញ្ចេញមតិមិនត្រូវបានចាត់ទុកថាមានទោសឡើយ ពោលគឺស្ថិតក្នុងក្របខ័ណ្ឌនៃតួនាទី និងមុខងាររបស់ខ្លួន[95]។ ចំណុចនេះបានបញ្ជាក់យ៉ាងច្បាស់ថាក្នុងមុខងាររបស់ខ្លួន មុខងារជាអ្នកតំណាងរាស្ត្រ ដែលផ្ទុយពីមតិខ្លះលើក

---

[95] ដោយ VOD Admin | ថ្ងៃចន្ទ ទី៣០ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 4:07 PM | លិខិតមិត្តអ្នកអាន
http://vodhotnews.com/2016/05/letter-to-editor-article-80-of-constitution

ឡើងថាមានអភ័យឯកសិទ្ធិសភាមានតែនៅក្នុងសភាប៉ុណ្ណោះ ពេលចេញពីសភា ពេលទៅហូប គុយទាវ ឬទៅដល់ផ្ទះលែងមានហើយ។

បន្ទាប់មកទៀត វាក្យខណ្ឌទី៣ សំខាន់ណាស់សម្រាប់ពេលដូចបច្ចុប្បន្ន។ វាក្យខណ្ឌនេះមានខ្លឹមសារ "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច" បានន័យថា ប្រសិនបើតំណាងរាស្ត្រណាមួយបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ក្រសួងមានសមត្ថកិច្ច ត្រូវប្រាប់ទៅរដ្ឋសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាជាបន្ទាន់។ អញ្ចឹងតើរាយការណ៍ដើម្បីអ្វី? រាយការណ៍ដើម្បីឱ្យរដ្ឋសភាកោះប្រជុំក្នុងការសម្រេចលើករណីរបស់តំណាងរាស្ត្រណាម្នាក់ហើយតើសម្រេចលើអ្វី? សម្រេចទៅលើអភ័យឯកសិទ្ធិសភាថាត្រូវដកឬមិនដកអភ័យឯកសិទ្ធិ ដើម្បីឱ្យតុលាការបន្តនីតិវិធីរបស់ខ្លួនដោយត្រូវការសំឡេងពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ដែលមាននៅក្នុងវាក្យខណ្ឌទី៤ "សេចក្តីសម្រេចរបស់គណៈកម្មធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល" មានន័យថា នៅពេលរដ្ឋសភាសម្រេចដកអភ័យឯកសិទ្ធិតំណាងរាស្ត្ររួចហើយ តុលាការអាចបន្តនីតិវិធីលើតំណាងរាស្ត្ររូបនោះបានហើយ។ ចុះបើរដ្ឋសភារកសំឡេងមិនបានពីរភាគបីដើម្បីដកអភ័យឯកសិទ្ធិ តើត្រូវដោះស្រាយយ៉ាងណា? យើងត្រូវបកទៅរកវាក្យខណ្ឌទី២ដដែល ដូចនេះតុលាការត្រូវផ្អាកនីតិវិធីសិនហើយដោះលែងតំណាងរាស្ត្រវិញឱ្យចូលធ្វើការចម្មតារង់ចាំដល់ចប់អាណត្តិ អស់អភ័យឯកសិទ្ធិដោយស្វ័យប្រវត្តិទើបអាចចាត់ការតាមនីតិវិធី ទើបមិនមាននិទណ្ឌភាពដោយសារអភ័យឯកសិទ្ធិ។

ដោយឡែកប្រសិនបើរដ្ឋសភាយល់ឃើញថាការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយមិនមានភាពចាំបាច់នៅក្នុងកាលៈទេសៈនោះ ឬ ចង់ផ្អាកនីតិវិធីតុលាការមិនឱ្យបន្តទៅមុខហើយទុកឱ្យតំណាងរាស្ត្រណាមួយនៅបន្តធ្វើការទៀតសិន ត្រូវបានបញ្ជាក់នៅក្នុងវាក្យខណ្ឌចុងក្រោយ"ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាកប្រសិនបើរដ្ឋសភា បានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល"។ មានន័យថាតុលាការបានបន្តនីតិវិធីរបស់ខ្លួនលើតំណាងរាស្ត្រដែលបានដកអភ័យឯកសិទ្ធិរួចហើយ រដ្ឋសភាបានអនុម័តតាមមតិភាគច្រើនបីភាគបួនដើម្បីស្នើរដល់តុលាការដើម្បីផ្អាកនីតិវិធីសិន រង់ចាំដល់ចប់អាណត្តិទើបអាចបន្តនីតិវិធីទៀត។

សរុបមក មាត្រា៨០ មានខ្លឹមសារគ្រប់គ្រាន់ក្នុងការការពារតំណាងរាស្ត្រពីការឃុំខ្លួន ចោទប្រកាន់នានានិងបានផ្តល់បុព្វសិទ្ធិដល់សភាក្នុងការផ្អាកនីតិវិធីតុលាការបាន ព្រោះការផ្អាកនីតិវិធីតុលាការមិនមែនបានន័យថា តំណាងរាស្ត្រណាម្នាក់អាចរួចខ្លួនពីអំណាចយុត្តាធិការនោះទេ។ និយាយរួម ប្រសិនបើមិនមានការដកអភ័យឯកសិទ្ធិសភារបស់សមាជិកសភាណាម្នាក់នោះទេ តុលាការមិនអាចបន្តនីតិវិធីរបស់ខ្លួនបានឡើយ ហើយក៏គ្មានចំណុចណានៅក្នុងមាត្រា៨០ចែងថា សំឡេងភាគច្រើនដាច់ខាតរបស់រដ្ឋសភាអាចឱ្យតុលាការបន្តនីតិវិធីរបស់ខ្លួន លើតំណាងរាស្ត្រណាម្នាក់បានដែរ។

កាលឆ្នាំ២០០៨-២០០៩ អំឡុងពេលក្រមព្រហ្មទណ្ឌកំពុងស្ថិតនៅជាសេចក្តីព្រាងរហូតដល់សភា បក្សប្រឆាំងនិងអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានសំណូមពរឱ្យមានការផ្តល់និយមន័យនៃបទល្មើសមួយចំនួនដែលមានលក្ខណៈស្រពិចស្រពិលឱ្យមានភាពច្បាស់លាស់ ជាក់លាក់ជាងនេះ ដូចជាបទបរិហារកេរ្តិ៍ បទញុះញង់ជាដើម ដើម្បីចៀសវាងការបកស្រាយមិនត្រឹមត្រូវនាំឱ្យមានអ្នករងគ្រោះដោយអយុត្តិធម៌[96]។

- **ជាការបញ្ចេញមតិ ឬជាការញុះញង់?**

ងាកមកមើលករណីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមណ្ឌលសៀមរាប លោក អ៊ុំ សំអានវិញ លោកត្រូវបានគេថា"ការលើកឡើងរបស់លោក អ៊ុំ សំអាន តាមបណ្តាញសង្គមFacebook ដោយចោទប្រកាន់ផែនទីផ្លូវការរបស់រាជរដ្ឋាភិបាលប្រើប្រាស់សព្វថ្ងៃក្នុងការបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម គឺជាផែនទីក្លែងក្លាយនិងការបង្ហោះសារផ្សេងៗទៀតនោះ គឺមានចរិតញុះញង់បង្កឱ្យវឹកវរដល់សន្តិសុខនិង ការញុះញង់ឱ្យមានការរើសអើង"។ ការលើកឡើងដោយប្រើប្រាស់ពាក្យថា"មានចរិត"នេះ គឺជាការបកស្រាយដោយមិនស្របតាមគោលការណ៍នៃការបកស្រាយនៅក្នុងព្រហ្មទណ្ឌនោះទេ។ មាត្រា៥នៃក្រមចែងថាក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយ"យ៉ាងតឹងរ៉ឹង"។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តិតាមទិសភាពបានឡើយ។ ក្នុងករណីរបស់លោក អ៊ុំ សំអាន លោកបានសរសេរបកស្រាយ ផ្តល់បទសម្ភាសន៍និងបង្ហោះឯកសារពាក់ព័ន្ធកិច្ចការព្រំដែន ដោយលោក អ៊ុំ សំអាន ផ្ទាល់ក៏បានបញ្ជាក់ដែរថាទង្វើរបស់លោកគ្រាន់តែចង់តាមដាន ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការប្រើប្រាស់ផែនទីនិងការបោះបង្គោលព្រំដែនក្នុងន័យការពារមិនឱ្យបាត់បង់ទឹកដីខ្មែរ ជាទង្វើគិតដល់ជាតិ ដែលកិច្ចការនេះក្នុងនាមជាតំណាងរាស្ត្រគួរណាស់តែធ្វើសម្រាប់ជាតិ។ ទង្វើបែប អ៊ុំ សំអាន បើលោកមិនមែនជាតំណាងរាស្ត្របក្សប្រឆាំង ហើយមិនលើក

[96] ដោយvodadminថ្ងៃព្រហស្បត៍ទី១៤ខែមេសាឆ្នាំ២០១៦ម៉ោង 7:30AM http://vodhotnews.com/2016/04/letter-to-editor-immunity-can-be-protected/

រឿងប្រធានបទរសើបទេ ក៏គ្មានអ្នកណាយកមកបកស្រាយដែរ ហើយករណីនេះត្រូវបានគេមើលឃើញថាគ្រាន់តែជាបញ្ចេញមតិធម្មតារបស់តំណាងរាស្ត្រម្នាក់ប៉ុណ្ណោះ។ តើមានអ្វីខុសឆ្គង? ម៉្យាងវិញទៀត ក្រមព្រហ្មទណ្ឌ ចែងតែពីអត្ថិភាពនៃអំពើញុះញង់ដោយមិនបានចែងពីផលនៃអំពើញុះញង់ដែលមានទំនាក់ទំនងនឹងគ្នាទេ រីឯទង្វើ អ៊ុំ សំអាន វិញមិនបានធ្វើឱ្យមានភាពវឹកវរដល់សង្គម និងមានការរើសអើងនោះទេ មិនដូចអ្នកបណ្តោយឱ្យមាននិទណ្ឌភាព ភាពអយុត្តិធម៌ ប្លន់ដីរាស្ត្រ និងទាញយកធនធានរ៉ែ ព្រៃឈើនិងផលពីរដ្ឋដទៃទៀតមកជាផលប្រយោជន៍តែគ្រួសារ និងបក្សពួកខ្លួនទេ ។

- **អ្វីជាអភ័យឯកសិទ្ធិ មានន័យយ៉ាងណា?**

ក្នុងឋានៈជាតំណាងរាស្ត្រត្រូវមានបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិដើម្បីបំពេញមុខងាររបស់ខ្លួនដោយរលូនដោយគ្មានការភ័យខ្លាច។ អភ័យឯកសិទ្ធិមានន័យថាជាសិទ្ធិដែលមិនរងនូវការភ័យខ្លាច មិនរងនូវការគំរាម អភ័យឯកសិទ្ធិប្រៀបដូចអាវក្រោះការពារខ្លួនអ៊ីចឹងដែរ ដែលសិទ្ធិនេះអាចការពារបានតែក្នុងការបំពេញមុខនាទីរបស់ខ្លួនប៉ុណ្ណោះ។ មាត្រា៧ ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រចែងថា តំណាងរាស្ត្រណាបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌនឹងអាចអនុញ្ញាតឱ្យធ្វើការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនតាមច្បាប់ និងនីតិវិធីបានលុះត្រាតែមានការលើកអភ័យឯកសិទ្ធិជាមុនសិន។ ឧបមាថា លោក អ៊ុំ សំអាន បានទៅសម្លាប់អ្នកណា ឬស្រវឹងស្រាបើករថយន្តបុកគេស្លាប់ឬអាងខ្លួនជាតំណាងរាស្ត្រទៅបាញ់គេ អភ័យឯកសិទ្ធិមិនអាចការពារលោកពីការចាប់ខ្លួនបានឡើយ ហើយបើចង់ដំណើរការនីតិវិធីទៀតត្រូវជូនដំណឹងទៅសភា ដើម្បីលើកអភ័យឯកសិទ្ធិជាមុនសិន(ដោះអាវក្រោះសិន) ទើបអាចជំនុំជម្រះបាន តាមមាត្រា១២(ក្នុងករណីតំណាងរាស្ត្រណាបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនបាន ហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈអចិន្ត្រៃយ៍រដ្ឋសភា នៅចន្លោះសម័យប្រជុំរដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច)។ ការសម្រេចរបស់រដ្ឋសភាគឺសម្រេចថាត្រូវលើកអភ័យឯកសិទ្ធិ ឬផ្អាកនីតិវិធីតាមមាត្រា១៣(ការផ្អាកនីតិវិធីចោទប្រកាន់)វិញ មិនមែនភ្លាមប្រជុំសម្រេចឱ្យតុលាការបន្តនីតិវិធីឬមិនបន្ត នោះទេគួរតែគិតពិចារណាពីភាពចាំបាច់របស់តំណាងរាស្ត្រក្នុងការបំពេញតួនាទីរបស់ខ្លួន។

### ២.មតិយោបល់របស់អ្នកវិភាគឯករាជ្យនិងបណ្តាអង្គការសង្គមស៊ីវិល និងក្រៅរដ្ឋាភិបាលនានា

#### ក. ទាក់ទិននឹងករណីការបកស្រាយផ្សេងគ្នាលើរដ្ឋធម្មនុញ្ញមាត្រា៨០

លោកកែម ឡី អ្នកវិភាគសង្គម និង នយោបាយកម្ពុជាថាមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញចាំបាច់ត្រូវមានការពន្យល់ន័យទូលំទូលាយតាមរយៈការបង្កើតជាច្បាប់ បើពុំដូចនោះទេនៅតែមាន

ការភាន់ច្រលំក្នុងការបកស្រាយ។ "វាត្រូវតែមាននិយមន័យនៃមាត្រា៨០នោះ ថាតើនិយមន័យទូលាយជាងនេះទៅ លើន័យនីមួយៗ ពាក្យនីមួយៗនោះគឺត្រូវមានការរៀបចំ ទីពីរយើងត្រូវមានគោលការណ៍ ណែនាំក្នុងការអនុវត្ត ឬមួយក៏មានច្បាប់តែម្ដងជាឧទាហរណ៍ មិនមែនមានតែត្រឹមអភ័យឯកសិទ្ធិក្នុងរដ្ឋធម្មនុញ្ញប៉ុណ្ណឹងទេ តែចង់មានច្បាប់មកអនុវត្តតែម្ដងឱ្យវាទូលំទូលាយជាងនេះ។ យើងឃើញថាមាត្រាខ្លះនៅក្នុងរដ្ឋធម្មនុញ្ញ គឺមិនមានរៀបចំជាច្បាប់ដើម្បីអនុវត្តទេ ដូចនេះ មួយម៉ាត់ មួយឃ្លា ពីរឃ្លា មួយមាត្រា នៅក្នុងរដ្ឋធម្មនុញ្ញអត់បានតាមចិត្តអញ្ចឹងហើយ ព្រោះអត់មានចែងហើយអត់មានច្បាប់ ឬ គោលការណ៍ណែនាំក្នុងការអនុវត្តបន្តទៀត។ មួយទៀតបង្កើតគោលការណ៍អនុវត្តហើយត្រូវធ្វើការបង្រៀនទៅដល់ភ្នាក់ងារអនុវត្តច្បាប់ដូចជាចៅក្រម ព្រះរាជអជ្ញា មេធាវីក៏ដូចជាមន្ត្រីរាជការ។ ដោយសារមិនមានការធ្វើបែបនេះហើយនាំឱ្យវាកើតមានបញ្ហានៅក្នុងស្រុកខ្មែរ ហើយបើកាលណានរណាមានអំណាច អ្នកហ្នឹងឈ្នះហើយ" លោកកែមឡីបានលើកឡើងដូចនេះ[97]។

លោក កែម ឡី បញ្ជាក់ផងដែរពីការតាក់តែងច្បាប់ដោយគ្មានភាគីឯករាជ្យចូលរួមពិនិត្យ "សង្គមយើងនៅ ក្នុងការតាក់តែងច្បាប់ បកស្រាយច្បាប់ និយមន័យច្បាប់ ឬមួយក៏ធ្វើកំនត់ហេតុច្បាប់មានបញ្ហា ត្រង់ថានៅក្នុងរដ្ឋធម្មនុញ្ញចែងបែបទូលាយ តែពេលយកទៅធ្វើជាច្បាប់យើងធ្វើលំអិត តែយើងអត់មានភាគីឯករាជ្យ ក្រុមប្រឹក្សាអ្នកច្បាប់ឯករាជ្យណាមកពិនិត្យថាស្របតាមរដ្ឋធម្មនុញ្ញឬក៏អត់"។ បន្ថែមពីនេះ លោកកែម ឡី ទទូចឱ្យមានគោលការណ៍ណែនាំ និង និយមន័យច្បាស់លាស់នៅក្នុងការធ្វើច្បាប់នីមួយៗ ។ "យើងសង្កេតឃើញច្បាប់ច្រើនអត់មានគោលការណ៍ណែនាំក្នុងការអនុវត្ត ច្បាប់មួយចំនួនមានគោលការណ៍ណែនាំក្នុងការអនុវត្តល្អ ឧទាហរណ៍ដូចជាច្បាប់ស្ដីពីក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ច្បាប់ស្ដីពីការគ្រប់គ្រងឃុំសង្កាត់ គឺល្អ ឃើញមានគោលការណ៍ណែនាំ មាននិយមន័យ ការអនុវត្តច្រើន តែច្បាប់ខ្លះអត់មានគោលការណ៍ណែនាំច្បាស់លាស់ទេហើយក៏អត់មាននិយមន័យច្បាស់លាស់"។

**ខ. ទាក់ទងករណីតំណាងរាស្ត្រមិនចូលខ្លួនតាមការកោះហៅរបស់តុលាការ**

អ្នកច្បាប់អះអាងថា ការបដិសេធចូលទៅបំភ្លឺរបស់លោក កឹម សុខា ប្រធានស្ដីទីគណបក្សសង្គ្រោះជាតិ ពាក់ព័ន្ធនឹងបណ្ដឹងរបស់កញ្ញា ធី សុវណ្ណថា ពីបទបរិហារកេរ្ដិ៍នៅថ្ងៃ១១ ឧសភា នេះជារឿងត្រឹមត្រូវ[98]។

---

[97] ដោយ ញឹម សុផល, ចំណុចខ្លះនៃរដ្ឋធម្មនុញ្ញទាមទារឲ្យមានការធ្វើច្បាប់បន្ថែមចៀសវាងការបកស្រាយខុសគ្នា, ចុះផ្សាយនៅថ្ងៃ06/05/2016 ខ្សែអាត់សំលេង http://www.rfa.org/khmer/

[98] ដោយយន់ សាមៀន, អ្នកច្បាប់ថាលោក កឹមសុខាមិនចូលបំភ្លឺនៅតុលាការជារឿងត្រឹមត្រូវ, ចេញថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៦, http://www.rfa.org/khmer/

ប្រធានការិយាល័យមេធាវីក្រុមអ្នកច្បាប់អមរិន្ទ្រ លោកមេធាវី សុក សំអឿន បញ្ជាក់ថា លោក កឹម សុខា អាចបដិសេធពាក្យបណ្តឹងរបស់កញ្ញា ធី សុវណ្ណថា ហើយមិនចាំបាច់ចូលខ្លួនទៅកាន់តុលាការឡើយ។ លោកបន្តថា បើទោះបីជាខ្សែអាត់សំឡេងក្នុងទូរស័ព្ទជាសំឡេងរបស់ឯកឧត្តម កឹម សុខា ក៏ដោយ ក៏មិនមែនជាការ "បរិហារកេរ្តិ៍" ដែរ ព្រោះការឆ្លើយឆ្លងគ្នាក្នុងទូរស័ព្ទនោះមានតែបុគ្គល២នាក់ប៉ុណ្ណោះ។ ចំណែកការផ្សព្វផ្សាយសំឡេងខ្សែអាត់ដែលត្រូវបានអ្នកដទៃលួចថត និងយកទៅផ្សព្វផ្សាយជាសាធារណៈក៏មិនអាចចាត់ថា ជាអំពើ "បរិហារកេរ្តិ៍" ដែរ។ លោកបន្តថា ការបរិហារកេរ្តិ៍ ទាល់តែនិយាយឱ្យប៉ះពាល់គេក្នុងទីសាធារណៈ ទើបអាចចាត់ទុកជាបទបរិហារកេរ្តិ៍។

**គ. ទាក់ទិនចំពោះការបកស្រាយផ្ទុយគ្នាចំពោះនីតិវិធីដកហូតអភ័យឯកសិទ្ធិសភាដោយបទល្មើសព្រហ្មទណ្ឌ**

ទាក់ទិននឹងករណីនេះ ដើម្បីជម្រះមន្ទិលសង្ស័យ ក្រសួងយុត្តិធម៌ក៏បានចេញសេចក្តីថ្លែងការណ៍មួយទាក់ទងនឹងករណីសំណុំរឿងព្រហ្មទណ្ឌរបស់ឯកឧត្តមកឹម សុខា ក្នុងបទចោទប្រកាន់តាមមាត្រា៥៣៨នៃក្រមព្រហ្មទណ្ឌ ថាទោះបីជាគ្មានការអនុញ្ញាតពីសភាក៏អាជ្ញាធរមានសមត្ថកិច្ចអាចចាប់ខ្លួនបានដែរដោយយោងទៅតាមករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ នៅកម្ពុជា កន្លងមក ច្បាប់ត្រូវបានបកស្រាយផ្សេងៗគ្នា ទៅតាមការយល់ឃើញ ឬនិន្នាការរៀងៗខ្លួន។ សំណុំរឿងលោក កឹម សុខា គឺជាឧទាហរណ៍ស្រាប់។ អ្នកនាំពាក្យក្រសួងយុត្តិធម៌ បានហៅការខកខានមិនបានចូលទៅបំភ្លឺនៅតុលាការ ថាជាបទល្មើសជាក់ស្តែង ខណៈគណបក្សសង្គ្រោះជាតិយល់ឃើញផ្សេង។

ការបកស្រាយច្បាប់ផ្សេងៗពីគ្នា មិនមែនជារឿងប្លែកអ្វីទេនៅកម្ពុជា ។ បញ្ហានេះធ្លាប់កើតមានឡើងតាំងពីយូរមកហើយ។ ប៉ុន្តែថ្មីៗនេះ មានករណីចំនួនពីរ ដែលទទួលបានការចាប់អារម្មណ៍ ជជែកពិភាក្សា យ៉ាងផុលផុសពីសំណាក់អ្នកច្បាប់។ ជាការកត់សម្គាល់ ករណីទាំងពីរនោះ សុទ្ធតែកើតឡើងចំពោះមន្ត្រីជាន់ខ្ពស់នៃគណបក្សសង្គ្រោះជាតិ។

ករណីទី១ គឺការមិនចូលខ្លួនទៅបំភ្លឺនៅតុលាការរបស់លោក កឹម សុខា ក្នុងនាមជាសាក្សីដោយមិនមានមូលហេតុសមស្រប។ ក្រសួងយុត្តិធម៌លើកឡើងថា ករណីលោកកឹម សុខា ជាបទល្មើសជាក់ស្តែង។ វាជាស្ថានភាពបទល្មើស ដែលទើបប្រព្រឹត្តិរួចភ្លាម។ ហើយសមត្ថកិច្ចអាចស្វែងរកចាប់ខ្លួននិងចោទប្រកាន់លោក កឹម សុខា បាន ដោយអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ មិនចាំបាច់មានការលើកលែងអភ័យឯកសិទ្ធិសភាឡើយ។ ប៉ុន្តែគណបក្សសង្គ្រោះជាតិ បានអះអាងថា ករណីនេះ មិនមែនជាបទល្មើសជាក់ស្តែងឡើយ។ មេធាវីរបស់លោក កឹម សុខា បានធ្វើលិខិតមួយជូនតំណាងអយ្យការ បញ្ជាក់ពីមូលហេតុសមស្របនៃការមិនចូលទៅបំភ្លឺរបស់លោក កឹម សុខា។ ការស្វែងរកចាប់ខ្លួនលោក កឹម សុខា ពីសំណាក់កងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាល គឺជាការ

រំលោភយ៉ាងធ្ងន់ធ្ងរ លើអភ័យឯកសិទ្ធិសភារបស់លោកកឹមសុខា។ នេះបើតាមគណបក្សសង្គ្រោះជាតិ។

ការចាប់ខ្លួនលោក អ៊ុំ សំអាន កាលពីពាក់កណ្ដាលខែមេសាកន្លងទៅនេះ ក៏ជាករណីមួយទៀត ដែលបង្កើតជាសង្គ្រាមសម្ដីនៃការបកស្រាយខ្លឹមសារច្បាប់ផងដែរ។ សំណុំរឿងរបស់លោក អ៊ុំ សំអាន ពាក់ព័ន្ធនឹងការផ្សព្វផ្សាយខ្លឹមសារ វីដេអូ និងផែនទីក្លែងក្លាយ ត្រូវបានតុលាការក្រុងភ្នំពេញចាត់ទុកថា ជាបទល្មើសជាក់ស្ដែង។ បទល្មើសជាក់ស្ដែងនេះ អនុញ្ញាតឱ្យសមត្ថកិច្ចចាប់ខ្លួនតំណាងរាស្ត្ររូបនេះបាន ស្របតាមច្បាប់ជាធរមាន ដោយមិនចាំបាច់មានការយល់ព្រមពីរដ្ឋសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាឡើយ។ ប៉ុន្តែសង្គមស៊ីវិល និងបក្សប្រឆាំងបានហៅការចាប់ខ្លួននោះថា ធ្វើឡើងដោយខុសច្បាប់ ខុសនីតិវិធី។ បើតាមសង្គមស៊ីវិលនិងបក្សប្រឆាំង វីដេអូ ឬខ្លឹមសារនៅលើបណ្ដាញសង្គម គឺជាការបញ្ចេញមតិ មិនមែនជាបទល្មើសជាក់ស្ដែង ដែលអាចឱ្យអាជ្ញាធរចាប់ខ្លួនដោយមិនចាំបាច់ដកអភ័យឯកសិទ្ធិជាមុននោះទេ។ ទាំងនេះ គេនៅមិនទាន់និយាយដល់ការបោះឆ្នោតរបស់សមាជិកសភាមកពីបក្សកាន់អំណាច ឱ្យបន្តនីតិវិធីលើសំណុំរឿងរបស់លោក អ៊ុំ សំអាន ផង។ បក្សប្រឆាំងពន្យល់ដោយផ្អែកលើមាត្រា៨០នៃរដ្ឋធម្មនុញ្ញថា រដ្ឋសភាត្រូវការសំឡេងយ៉ាងហោចណាស់២ភាគ៣ ឬសមាជិកសភាចំនួន៨៣រូបឡើងទៅ ដើម្បីប្រជុំដកអភ័យឯកសិទ្ធិសមាជិកសភាណាម្នាក់ និងសំឡេង៣ភាគ៤ ឬសមាជិកសភាចំនួនចាប់ពី៩២រូបឡើងទៅ ដើម្បីប្រជុំបញ្ឈប់ការបន្តនីតិវិធីរបស់តុលាការ ក្នុងការឃាត់ខ្លួន ឬឃុំខ្លួនសមាជិកសភាណាម្នាក់។ ប៉ុន្តែតំណាងរាស្ត្រមកពីបក្សកាន់អំណាចលើកឡើងថា តំណាងរាស្ត្រពីគណបក្សខ្លួនដែលមានសមាជិកសរុបជាង៦០នាក់ អាចបោះឆ្នោតឱ្យបន្តនីតិវិធីតុលាការលើសមាជិកសភាបាន ។ ធ្វើទៅបាន ព្រោះរដ្ឋធម្មនុញ្ញចែងតែពីការបញ្ឈប់នីតិវិធីដោយសំឡេង៣ភាគ៤ មិនបានកំណត់ពីកូរ៉ុមសំឡេងដែលត្រូវការដើម្បីបន្តនីតិវិធីឡើយ។ នៅកម្ពុជា មាត្រានីមួយៗនៃច្បាប់ត្រូវបានបង្កើតឡើងដោយមាននិយមន័យណាមួយរបស់ខ្លួន។ ការបកស្រាយច្បាប់ទៀតសោត អាចធ្វើទៅបានក្នុងករណីចាំបាច់។ ហើយមានតែក្រុមប្រឹក្សាធម្មនុញ្ញប៉ុណ្ណោះ ដែលអាចបកស្រាយច្បាប់បាន។ យ៉ាងណាក៏ដោយ នៅកម្ពុជាពេលខ្លះ ច្បាប់ត្រូវបានអ្នកមានឥទ្ធិពល បកស្រាយទៅតាមការចង់បានរបស់ខ្លួន ដើម្បីដាក់ទោសទៅលើគូបដិបក្ខ។ ប៉ុន្តែគេពិបាកនឹងបន្ទោសទាំងស្រុងទៅលើការបកស្រាយច្បាប់ដូច្នេះណាស់ ខណៈពេលដែលច្បាប់ខ្លះនៅមានវិសាលភាពទូលំទូលាយ និងមានចន្លោះប្រហោងនៅឡើយ។ ច្បាប់មួយចំនួន រួមទាំងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃប្រទេសផង ត្រូវការធ្វើវិសោធនកម្ម ឬធ្វើច្បាប់បន្ថែម ដើម្បីចៀសវាងការបកស្រាយខុសគ្នា។ ហើយក្នុងករណីដែលមានការបកស្រាយខុសគ្នា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវដើរតួជាអាជ្ញាកណ្ដាល ដើម្បីកាត់សេចក្ដី។ ព្រោះមានតែ ក្រុមប្រឹក្សាធម្មនុញ្ញប៉ុណ្ណោះ ដែលអាចបកស្រាយច្បាប់បាន។ ត្រង់ថា ក្រុមប្រឹក្សាធម្ម

នុញ្ញមានឆន្ទៈកម្រិតណា ក្នុងការបកស្រាយខ្លឹមសារច្បាប់ដោយផ្អែកទៅលើច្បាប់ មិនផ្អែកទៅលើនិន្នាការនយោបាយហើយ មានតែក្រុមប្រឹក្សាធម្មនុញ្ញខ្លួនឯងប៉ុណ្ណោះ ទើបអាចឆ្លើយសំណួរនេះបាន។

ក្រុមអ្នកច្បាប់បានពន្យល់ថា បណ្ដឹងអាជ្ញាមិនរលត់ទេ បើសិនមិនទាន់មានការស៊ើបអង្កេតថាគ្មានទោសឬមានការដកពាក្យចោទប្រកាន់នោះវិញទេ។ ប៉ុន្តែបើអ្នកជាប់បណ្ដឹងនោះជាអ្នកតំណាងរាស្ត្រមានអភ័យឯកសិទ្ធិ កំពុងធ្វើការក្នុងរដ្ឋសភា ហើយតុលាការចង់ចោទប្រកាន់ ឬដំណើរការបណ្ដឹងចាស់នោះ ត្រូវឆ្លងកាត់សភាប្រជុំដកអភ័យឯកសិទ្ធិ ដែលត្រូវការសំឡេង២ភាគ៣ អនុម័តជាមុនសិន ដោយយោងមាត្រា៨០នៃរដ្ឋធម្មនុញ្ញ[99]។

ទាក់ទងខ្លឹមសារច្បាប់នេះ បណ្ឌិតច្បាប់ លោក ហាង ឫទ្ធី ជាប្រធានអង្គការ ស៊ីអិនរ៉ូ (CNRO) ពន្យល់បន្ថែមទៅលើទិដ្ឋភាពច្បាប់ និងអភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រទាក់ទងបណ្ដឹងនេះ៖ "នៅក្នុងសមាជិកនៃរដ្ឋសភាលើកិច្ចការបទល្មើសមានពីរបែប[100]។ ទីមួយបើតំណាងរាស្ត្រណាមួយបានប្រព្រឹត្តិបទល្មើសឧក្រិដ្ឋ (សម្លាប់មនុស្ស) ករណីនេះសមត្ថកិច្ចមានសិទ្ធិចាប់ខ្លួនដោយមិនចាំបាច់សភាប្រជុំដកអភ័យឯកសិទ្ធិទេ។ ចំណុចទីពីរ បើតំណាងរាស្ត្រណាមួយមានបណ្ដឹងអាជ្ញានៅក្នុងនោះ ហើយបានចូលស្បថស្បែជាសមាជិកសភាពេញសិទ្ធិដូច្នេះ វាអាស្រ័យទៅលើតុលាការ បើតុលាការដាក់ដីកាទៅរដ្ឋសភាដោយអ្នកនោះជាប់ពាក់ព័ន្ធបទល្មើស ដូចជាបទមជ្ឈិម ឬបទឧក្រិដ្ឋណាដែលត្រូវបានចោទប្រកាន់ ប៉ុន្តែមិនមែនជាបទល្មើសជាក់ស្ដែង នោះត្រូវមានកិច្ចប្រជុំធ្វើសេចក្ដីសម្រេចពីរដ្ឋសភាសិនថា ឱ្យចោទ ឬមិនឱ្យចោទប្រកាន់នោះ គឺជាតួនាទីរបស់សភាទេ។

### ឃ. ទាក់ទិននឹងការចេញដីការកោះហៅតំណាងរាស្ត្រ

អ្នកនាំពាក្យក្រសួងយុត្តិធម៌បានចេញសេចក្ដីថ្លែងការណ៍មួយចុះថ្ងៃទី ២៧ ខែ ឧសភា ស្ដីពីករណីសំណុំរឿងព្រហ្មទណ្ឌរបស់លោក កឹម សុខា ក្នុងបទចោទប្រកាន់តាមមាត្រា ៥៣៨ នៃក្រមព្រហ្មទណ្ឌ[101] ។ អ្នកនាំពាក្យក្រសួងយុត្តិធម៌ បានលើកឡើងថា សំណុំរឿងចោទប្រកាន់ លើលោក កឹម សុខា គឺជាបទល្មើសដែលទើបប្រព្រឹត្តិរួចភ្លាម គឺជាបទល្មើសជាក់ស្ដែងតាមមាត្រា ៨៦ នៃក្រមព្រហ្មទណ្ឌ ដោយលោក កឹម សុខា មិនចូលខ្លួននៅចំពោះមុខអយ្យការអមសាលាដំបូងតាមដីកាកោះ។ ក្រសួងយុត្តិធម៌ក៏បានលើកឡើងនូវទិដ្ឋភាពច្បាប់ស្ដីអំពី "បទបដិសេធក្នុងការចូលខ្លួន"

[99] ដោយ ទេព សុវ៉ាវី និង សេក បណ្ឌិត, លោក ហ៊ុន សែន បង្ហាញជំហរមិនព្រមលុបបណ្ដឹងអាជ្ញារបស់បក្សប្រឆាំងរឿងហិង្សានៅទីលានប្រជាធិបតេយ្យ ចេញផ្សាយថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១៥ http://www.rfa.org/khmer/

[100] ដោយ ទេព សុវ៉ាវី និង សេក បណ្ឌិត, លោក ហ៊ុន សែន បង្ហាញជំហរមិនព្រមលុបបណ្ដឹងអាជ្ញារបស់បក្សប្រឆាំងរឿងហិង្សានៅទីលានប្រជាធិបតេយ្យ ចេញផ្សាយថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១៥ http://www.rfa.org/khmer/

[101] ដោយលោក លី បេឡា, ក្រសួងយុត្តិធម៌ស្នើឲ្យតុលាការអនុវត្តច្បាប់លើករណីលោកកឹម សុខា ចេញថ្ងៃសៅរ៍ ទី២៨ ខែ ឧសភា ឆ្នាំ២០១៦

ដែលមាត្រា៥៣៨ [102] ចែងថា រាល់បុគ្គលណាដែលត្រូវបានកោះហៅឱ្យមកឆ្លើយជាសាក្សីនៅមុខអយ្យការ ឬចៅក្រមស៊ើបសួរ ឬមុខតុលាការព្រហ្មទណ្ឌ ហើយមិនព្រមចូលខ្លួនតាមដីកាកោះដោយគ្មានមូលហេតុសមស្រប ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ៦ខែ និងពិន័យជាប្រាក់ពី ១០ម៉ឺន ទៅ ១លានរៀល។

តាមសេចក្តីថ្លែងការណ៍ដដែល លើកឡើងពីអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រតាមមាត្រា ១២ នៃច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រចែងថា "ក្នុងករណីតំណាងរាស្ត្រណាបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនបាន ហើយធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណ:កម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នៅចន្លោះសម័យប្រជុំរដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច។"

គួរបញ្ជាក់ថាកាលពីថ្ងៃទី ២៦ ខែ ឧសភាតំណាងអយ្យការនៃសាលាដំបូងរាជធានីភ្នំពេញបានចោទប្រកាន់លោក កឹម សុខា ពីបទ"បដិសេធក្នុងការចូលខ្លួន" និងសុំឱ្យនគរបាលយុត្តិធម៌ចាប់ខ្លួន លោក កឹម សុខាផងដែរ។

ក្នុងករណីប្រព្រឹត្តិបទល្មើសជាក់ស្តែង ករណីលោក កឹម សុខា ដូចគ្នាទៅនឹងករណីចាប់ខ្លួនតំណាងរាស្ត្របក្សប្រឆាំង លោក អ៊ុំ សំអាន រឿងចោទប្រកាន់ ការអត្ថាធិប្បាយប្រើប្រាស់ផែនទីក្លែងក្លាយ ។ ករណីនេះ មិនត្រូវការដកអភ័យឯកសិទ្ធិដែលត្រូវការសំឡេងពីរភាគបីនៃសមាជិកសភាទាំង១២៣រូបនោះទេ គឺសភានឹងបោះឆ្នោតថាតើឱ្យតុលាការបន្តនីតិវិធីឬយ៉ាងណា ដោយត្រូវការសំឡេងបីភាគបួនក្នុងការបដិសេធថាមិនឱ្យតុលាការបន្តនីតិវិធី[103]។ ក្រោយមក នៅថ្ងៃច័ន្ទ ទី ៣០ខែឧសភា ឆ្នាំ២០១៦រដ្ឋសភាខ្មែរបានបើកកិច្ចប្រជុំពេញអង្គលើកទី៦របស់ខ្លួន ក្នុងនោះករណីលោកកឹម សុខា ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ ត្រូវបានលើកមកពិភាក្សាជាពិសេស និងបន្ទាន់ជាងគេ។ បន្ទាន់រហូតដល់រដ្ឋសភា ប្រើពេលមិនដល់កន្លះម៉ោងផងដោយបានសម្រេចឱ្យតុលាការបន្តនីតិវិធី របស់ខ្លួនលើករណីមេដឹកនាំបក្សប្រឆាំងនេះ។

### **កថាខណ្ឌទី២ ដំណោះស្រាយនៅជប៉ុន**

#### **១. ដំណោះស្រាយទៅលើបញ្ហាការកំណត់លក្ខខណ្ឌ និងរយៈពេល**

ចំពោះបញ្ហាដែលមានការកំណត់លក្ខខណ្ឌ និងរយ:ពេលជាមុនទៅលើការចាប់ខ្លួននេះ គឺត្រូវបានតុលាការកំពូលមោឃភាពចោល។

---

[102] សូមមើលឧបសម្ព័ន្ធ៤

[103] ដោយលោក ស៊ុន ណារិន, បក្សប្រឆាំងប្រកាសបើកកិច្ចប្រជុំបន្ទាន់ ក្រោមអធិបតីលោកកឹម សុខា ចេញថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ២០១៦ ម៉ោង7:43AM http://vodhotnews.com

រដ្ឋធម្មនុញ្ញមាត្រា៥០ លើកលែងតែមានច្បាប់កំណត់ដោយឡែក សមាជិកសភាមិនអាចធ្វើការចាប់ខ្លួនក្នុងអាណត្តិរបស់ខ្លួនឡើយ ហើយច្បាប់ស្តីពីសភាមាត្រា៣៣ក៏បានចែងបញ្ជាក់ផងដែរថាក្រៅពីករណីមានការប្រព្រឹត្តិបទល្មើសជាក់ស្តែង មិនអាចធ្វើការអនុញ្ញាតឱ្យចាប់ខ្លួនសមាជិកសភាបានទេ និងចាំបាច់មានការយល់ព្រមពីសភា។ បើធ្វើការពិចារណាទៅលើរដ្ឋសភាដែលជាស្ថាប័នមានអំណាចកំពូលក្នុងការសម្រេច ជោគវាសនារបស់ប្រទេសជាតិ ហើយសមាជិករដ្ឋសភាគឺជាអ្នកដែលគោរពនូវតួនាទីភារកិច្ច ក្នុងការធ្វើសេចក្តីសម្រេចធំៗមួយចំនួនពាក់ព័ន្ធនឹងកិច្ចការប្រទេសជាតិ។ បើទោះបីជាមានការសង្ស័យថា សមាជិករដ្ឋសភារូបណាម្នាក់បានប្រព្រឹត្តិបទល្មើសក៏ដោយក៏អំណាចក្នុងការស៊ើបអង្កេតពីបទល្មើសមួយនោះ ជាសមត្ថកិច្ចអនុវត្តន៍របស់អំណាចតុលាការ ដើម្បីកុំឱ្យមានការរំលោភអំណាចជ្រៀតជ្រែក ចូលទៅក្នុងសមត្ថកិច្ចរបស់តុលាការពីសំណាក់សមាជិករដ្ឋសភា ទើបលើកលែងករណីដែលថាបានបង្ហាញយ៉ាងច្បាស់លាស់អំពីភាពចាំបាច់ និងភាពត្រឹមត្រូវស្របច្បាប់ក្នុងការចាប់ខ្លួនសមាជិករដ្ឋសភា ដែលបានប្រព្រឹត្តិបទល្មើសនៅក្រៅសភាគឺសមាជិករដ្ឋសភាម្នាក់ៗមានតួនាទីធ្វើការពិភាក្សា សម្រេចស្វែងរកភាពចាំបាច់ និងភាពត្រឹមត្រូវក្នុងការចាប់ខ្លួន។ ប្រសិនការចាប់ខ្លួនត្រឹមត្រូវ និង ស្របតាមភាពចាំបាច់បានបង្ហាញឱ្យឃើញជាក់ច្បាស់ហើយក៏ដោយ បើទោះបីជាអតីតសមាជិករដ្ឋសភាបានប្រព្រឹត្តិបទល្មើសនោះក៏ដោយ ក៏អំណាចក្នុងការស៊ើបអង្កេតលើករណីបទល្មើសនោះ ក៏ជាអំណាចរបស់តុលាការដែរ។

ប្រសិនបើមានការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌជាក់ស្តែងក្នុងសភា គឺប្រធានសភាជាអ្នកសម្រេចសេចក្តីយល់ព្រមឱ្យធ្វើការចាប់ខ្លួនទើបអាចចាប់ខ្លួនបាន។ ទន្ទឹមនឹងការមានសិទ្ធិក្នុងការយល់ព្រមឱ្យធ្វើការចាប់ខ្លួនរបស់សភា គឺត្រូវធ្វើការសម្រេចសេចក្តីអំពីភាពចាំបាច់ និងភាពត្រឹមត្រូវស្របច្បាប់ក្នុងការចាប់ខ្លួន និងមានសិទ្ធិក្នុងការបដិសេធរាល់ការចាប់ខ្លួនដោយមិនត្រឹមត្រូវ និងមិនចាំបាច់ ហេតុនេះហើយ សមាជិករដ្ឋសភាដែលបានសង្ស័យថាប្រព្រឹត្តិបទល្មើសហើយ មិនគួរធ្វើការ ចាប់ខ្លួនទៅតាមនីតិវិធីដូចជាប្រជាពលរដ្ឋធម្មតាទូទៅនោះទេ ប៉ុន្តែគួរតែពិចារណាទៅលើកម្រិតភាពចាំបាច់របស់សមាជិករដ្ឋសភារូបនោះ ដែលត្រូវធ្វើការសម្រេចសេចក្តីពាក់ព័ន្ធនឹងស្ថានភាព នយោបាយរបស់ប្រទេសជាតិ។

បើសិនជាស្ថិតក្នុងករណីបែបនេះ បើទោះបីជារដ្ឋសភាអាចធ្វើការបដិសេធរាល់ការចាប់ខ្លួនដោយមិនមានភាពចាំបាច់ស្របតាមច្បាប់នោះក៏ដោយ ប៉ុន្តែប្រសិនបើរដ្ឋសភារកឃើញពីចំនុចសំខាន់ចាំបាច់ ដែលត្រូវតែធ្វើការចាប់ខ្លួនសមាជិករដ្ឋសភារូបនោះ ហើយជាការចាប់ដោយស្របច្បាប់នោះគ្មានលក្ខខណ្ឌរារាំងអ្វីនោះទេ រដ្ឋសភាត្រូវធ្វើការយល់ ព្រមអនុញ្ញាតឱ្យចាប់ខ្លួន។

ទោះបីជាស្ថិតក្នុងករណីចាប់ខ្លួនដោយមានភាពត្រឹមត្រូវក៏ដោយ បើសិនជាធ្វើការពិចារណាពីភាពចាំបាច់ ដើម្បីឱ្យសមាជិកសភាដែលត្រូវធ្វើការចាប់ខ្លួននោះអាចសម្រេចសេចក្តីនានាក្នុងសភា នោះមិនគួរឱ្យមានការកំណត់រយៈពេលក្នុងការចាប់ខ្លួននោះឡើយ។ បើទោះបីជាសមាជិករដ្ឋសភានោះបានប្រព្រឹត្តិបទល្មើសក្រៅសភាក៏ដោយ ដោយយោងទៅតាមហេតុផលដូចគ្នាខាងលើពីភាពចាំបាច់របស់គាត់ក្នុងការធ្វើសេចក្តីសម្រេចក្នុងសភា ដោយមិនឱ្យមានច្បាប់ណាមួយចែងទាក់ទងពីការកំណត់រយៈពេលក្នុងការចាប់ខ្លួននោះឡើយ។

ដោយយោងតាមហេតុផលខាងលើនេះ ទើបទន្ទឹមនឹងការអនុញ្ញាតឱ្យចាប់ខ្លួនហើយមានការកំណត់រយៈពេលនេះគឺផ្ទុយទៅនឹងច្បាប់។

អ្នកដែលប្តឹងជំទាស់ទៅនឹងករណីនេះបានអះអាងថា យោងតាមសិទ្ធិក្នុងការអនុញ្ញាតឱ្យចាប់ខ្លួន ឬមិនចាប់ខ្លួននេះ គឺប្រសិនបើយល់ព្រមឱ្យចាប់ខ្លួន រដ្ឋសភាអាចមានសិទ្ធិក្នុងការកំណត់នូវរយៈពេលឱ្យចាប់ខ្លួនបានព្រោះនេះ ជាផ្នែកមួយនៃការអនុវត្តការចាប់ខ្លួនឱ្យមានប្រសិទ្ធិភាព ប៉ុន្តែទោះបីជាយ៉ាងនេះក្តី អភ័យឯកសិទ្ធិក្នុងការមិនត្រូវបានចាប់ខ្លួន គឺមិនអនុញ្ញាតឱ្យមានការកំណត់សម្រេចនូវរយៈពេលឱ្យចាប់ខ្លួននោះទេ។ ការលើកឡើងរបស់អ្នកដែលដាក់ពាក្យសុំប្តឹងជំទាស់ទៅលើបញ្ហានេះ មិនមែនដោយសារតែរដ្ឋធម្មនុញ្ញជាច្បាប់កំពូលមានអំណាចអនុវត្តលើសច្បាប់ដទៃៗទៀត ដូចជាច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនោះទេដែលថាការចែងពាក់ពន្ធ័នឹងសិទ្ធិក្នុងការយល់ព្រមឱ្យចាប់ខ្លួនសមាជិកសភានៅក្នុងរដ្ឋធម្មនុញ្ញ គឺមិនទទួលស្គាល់នូវបញ្ញត្តិកំណត់នៅក្នុងច្បាប់ ស្តីពីនីតិវិធីព្រហ្មទណ្ឌនោះឡើយ តែការអនុញ្ញាតឱ្យចាប់ខ្លួនសមាជិករដ្ឋសភាក៏អាចមានលទ្ធភាពអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌដែរ ហេតុដូចនេះហើយ ទើបនាំឱ្យមានមន្ទិលសង្ស័យថា សិទ្ធិអំណាចក្នុងការអនុញ្ញាតឱ្យធ្វើការចាប់ខ្លួន គឺគួរតែប្រគល់អំណាចចាត់ចែងតាម ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ជាជាងរដ្ឋធម្មនុញ្ញ។

សិទ្ធិរបស់រដ្ឋសភា ក្នុងការសម្រេចអនុញ្ញាតឱ្យធ្វើការចាប់ខ្លួននោះថាត្រូវអនុវត្តដោយយោងទៅតាម ទាំងរដ្ឋធម្មនុញ្ញ និងរាល់នីតិវិធីដែលមានចែងក្នុងច្បាប់បាន ឬក៏មិនបាននោះថែមទាំងមិនអាច ធ្វើការទាមទារឱ្យមានការចាប់ខ្លួនខុសពីការកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នោះទេ។

ចំពោះរឿងក្តីលើកនេះ ការដែលអនុញ្ញាតឱ្យចាប់ខ្លួនសមាជិករដ្ឋសភារូបនោះដោយមានការកំណត់រយៈពេលនឹងនាំឱ្យមានមន្ទិលសង្ស័យទៅលើចំនុចសំខាន់ៗ ដែលជាគ្រឹះក្នុងការចាប់ខ្លួន ទើបនាំឱ្យមានការមោឃៈភាពចោលនូវការចេញសេចក្តីសម្រេចដែលមិនទទួលស្គាល់តាមនីតិវិធីព្រហ្មទណ្ឌ។

## ២. ដំណោះស្រាយនៅលើករណីបរិហារកេរ្តិ៍របស់សមាជិករដ្ឋសភា

ករណីមានការទាមទារឱ្យសមាជិករដ្ឋសភាទទួលខុសត្រូវក្នុងការសងជំងឺចិត្តនេះ យោងទៅតាមច្បាប់ស្តីពីសំណងជំងឺចិត្តរបស់រដ្ឋ ដោយសារ តែសមាជិករដ្ឋសភា ត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងនាមជាមន្ត្រីរាជការសាធារណៈ ហេតុនេះហើយ មិនតម្រូវឱ្យសមាជិកម្នាក់ៗទទួលខុសត្រូវដោយផ្ទាល់ខ្លួនទៅលើសកម្មភាពដែលបានបំពេញក្នុងភារកិច្ចនោះទេ[104]។

ចំពោះករណីមានការទាមទារឱ្យរដ្ឋសងសំណងជំងឺចិត្តនេះផងដែរ យោងទៅតាមមាត្រា ១ នៃច្បាប់ស្តីពីសំណងជំងឺចិត្តរបស់រដ្ឋ មន្ត្រីរាជការសាធារណៈដែលបានប្រព្រឹត្តិខុសច្បាប់ ផ្ទុយពីករណីដែលត្រូវទទួលខុសត្រូវនូវកាតព្វកិច្ចតាមច្បាប់ ក្រោមការបំពេញតួនាទីភារកិច្ចចំពោះប្រជាពលរដ្ឋម្នាក់ៗនោះផ្ទុយពីគោលបំណងការពារដោយច្បាប់ យោងទៅតាមបណ្ណាយុត្តិសាស្ត្រពីមុននៅក្នុងករណីអង្គហេតុខាងលើនេះ រដ្ឋនឹងបដិសេធនូវការសងសំណងជំងឺចិត្ត។

សមាជិករដ្ឋសភាទាក់ទងទៅនឹងការតាក់តែងច្បាប់ បើយោងទៅតាមបញ្ញត្តិច្បាប់ ទំនាក់ទំនងដោយចំពោះទៅនឹងប្រជាពលរដ្ឋ ក្នុងការទទួលខុសត្រូវមានភាពជាលក្ខណៈនយោបាយនេះ នៅក្នុងទំនាក់ទំនងដែលមានលក្ខណៈរវាងសមាជិករូបនោះទៅនឹងការទាមទារ សិទ្ធិរបស់ពលរដ្ឋមានលក្ខណៈជារឿងផ្ទាល់ខ្លួនបែបនេះគឺមិនត្រូវទទួលខុសត្រូវនូវកាតព្វកិច្ច តាមច្បាប់នេះទេ ប៉ុន្តែសកម្មភាពក្នុងការតាក់តែងច្បាប់របស់សមាជិកសភា រាល់ការតាក់តែងច្បាប់ ចាំបាច់ត្រូវតែស្របទៅនឹងរដ្ឋធម្មនុញ្ញ។ ផ្ទុយទៅវិញ នៅពេលដែលរដ្ឋសភាហ៊ានធ្វើសកម្មភាពបង្កើតច្បាប់ណាមួយដោយឆន្ទៈខ្លួនឯង ក្នុងករណីដែលបញ្ហាកើតឡើងនោះមិនមែនជាអញ្ញត្រកម្មដែលមិនអាចឱ្យយើងធ្វើការប៉ាន់ស្មានដឹងបានពីបញ្ហាដែលនឹងកើតឡើងនោះ មិនគួរឱ្យរដ្ឋជាអ្នកទទួលខុសត្រូវក្នុងការសងសំណងជំងឺចិត្តនោះឡើយ។ ហេតុផលនោះគឺ សមាជិករដ្ឋសភាមិនត្រឹមតែសម្រេចសេចក្តីក្នុងសកម្មភាពតាក់តែងច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែទាំងក្នុងការទទួលស្គាល់នូវការចងភ្ជាប់ខ្លួនទៅនឹងសន្ធិសញ្ញានានា ក៏ដូចជាការគ្រប់គ្រង ហិរញ្ញវត្ថុជាដើមនោះដែលរាល់ការសម្រេចចិត្តដ៏ច្រើននេះជាការបំពេញសកម្មភាពដ៏មានភាពត្រឹមត្រូវសមរម្យក្នុងគោលដៅបង្រួបបង្រួម ឬធ្វើការផ្លាស់ប្តូរកែប្រែរាល់ឯកភាពជាតិ និងឆន្ទៈជាតិទាំងមូល។ មួយវិញទៀតនោះសមាជិករដ្ឋសភាដែលត្រូវសម្រេចសេចក្តីក្នុងសកម្មភាពតាក់តែងច្បាប់ ទាំងក្នុងការទទួលស្គាល់នូវការចងភ្ជាប់ខ្លួនទៅនឹងសន្ធិសញ្ញានានា ក៏ដូចជាការគ្រប់គ្រងហិរញ្ញវត្ថុជាដើមនោះរួមទាំងមានការថ្លែងសុន្ទរកថា ការសាកសួរដេញ

[104]長谷部恭男・中島 徹・赤坂正浩 阪口正二郎・本 執秀紀 『ケースブック憲法』第３版、２０１０年、８８３－８８４頁。
ហាសេបិយ៉ាសឹអុ · ណាកាជីម៉ាតុអុរឺ · អាកៈសាកៈម៉ាសាហ៊ីរ៉ុ · សាកាហ្គីឆិស្វជិរុ · ម៉ូតុហ៊ិជិណុរី 『សៀវភៅករណីសិក្សារដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៣, ឆ្នាំ២០១០, ទំព័រ៨៨៣ ដល់៨៨៤

ដោល និងការបញ្ចេញមតិយោបល់ក្នុងគោលបំណងត្រួតពិនិត្យទៅលើសកម្មភាព ស្ថានភាពនយោបាយរបស់ប្រទេសថែមទៀត គឺដោយយោងទៅតាមការត្រូវធ្វើសេចក្តីសម្រេចចិត្តដ៏ច្រើននេះមិនមែន ជាសកម្មភាពក្នុងការបង្កើតមតិឯកភាពជាតិទេ ប៉ុន្តែនេះជាសកម្មភាពក្នុងគោលដៅកែតម្រូវរាល់ឆន្ទៈរបស់រដ្ឋ។

យោងទៅលើហេតុផល ដែលសមាជិកសភាត្រូវធ្វើការសម្រេចសេចក្តីធំៗជាច្រើនដែលសុទ្ធតែពាក់ព័ន្ធទៅនឹងជោគវាសនារបស់ប្រទេសជាតិ ជាពិសេសដើម្បីរក្សាឱ្យបាននូវស្ថេរភាពនយោបាយរបស់ប្រទេស។ នៅពេលដែលមានការលើកសំណួរដេញដោល ពិភាក្សាយោបល់នៅក្នុងសកម្មភាពតាក់តែងច្បាប់ ឬ ការទទួលស្គាល់នូវការចងភ្ជាប់ខ្លួនទៅនឹងសន្ធិសញ្ញានានានោះរាល់ការលើកឡើងទាំងអស់ គឺអាចមានលទ្ធភាពបង្កនូវផលប៉ះពាល់ទៅដល់សិទ្ធិរបស់បុគ្គលឯកជន ឬសិទ្ធិរបស់ប្រជាពលរដ្ឋក៏ពិតមែន ប៉ុន្តែការលើកសំណួរដេញដោល ពិភាក្សាយោបល់ ការបញ្ចេញមតិទាំងនេះជាសកម្មភាពដែលសមាជិករដ្ឋសភាត្រូវបំពេញក្នុងតួនាទី ភារកិច្ចរបស់ខ្លួនជាតំណាងឆន្ទៈរបស់ប្រជាពលរដ្ឋ ហេតុនេះហើយរាល់ការបំពេញសកម្មភាពទាំងនេះមិនគួរត្រូវបានចាត់ទុកជាស្ថានភាពមួយរំលោភបំពានច្បាប់មិនត្រឹមត្រូវ ឬនេះជាការរំលោភសិទ្ធិឯកជនឡើយ ដោយសារតែរាល់ការបំពេញសកម្មភាពទាំងនេះ គឺដើម្បីគិតគូរពីផលប្រយោជន៍ជាតិ និង ផលប្រយោជន៍រួមជាចំបង មានន័យថានេះជាការថ្លឹងថ្លែងរវាងផលប៉ះពាល់មួយភាគតូច និង ផលប៉ះពាល់ធំមួយណាបង្កជាគ្រោះធ្ងន់ធ្ងរជាង។

ប៉ុន្តែប្រសិនបើមិនទាក់ទងជាមួយនឹងជោគវាសនាជាតិ មិនមែនដើម្បីផលប្រយោជន៍រួមរបស់ប្រជាជាតិ តែត្រឹមជាការបញ្ចេញសកម្មភាព និងមតិយោបល់មានលក្ខណៈជារឿងផ្ទាល់ខ្លួនរវាងសមាជិកសភាមានអភ័យឯកសិទ្ធិជាមួយនឹងប្រជាពលរដ្ឋជាបុគ្គលឯកជន ដែលមិនទាក់ទងទៅនឹងការបំពេញតួនាទីភារកិច្ចតែបង្កជាផលប៉ះពាល់ដល់សិទ្ធិឯកជនរបស់ពលរដ្ឋនោះ មិនត្រូវបានការពារដោយអភ័យឯកសិទ្ធិនោះទេ។

ជារួមមក សមាជិករដ្ឋសភាក្នុងនាមជាតំណាងរបស់ប្រជាពលរដ្ឋ មិនទទួលខុសត្រូវដោយផ្ទាល់ទៅលើការសងសំណងរដ្ឋប្បវេណី ក្នុងករណីមានការលើកសំណួរដេញដោល ពិភាក្សាយោបល់នៅក្នុងសកម្មភាពតាក់តែងច្បាប់ ឬការទទួលស្គាល់នូវការចងភ្ជាប់ខ្លួនទៅនឹងសន្ធិសញ្ញានានា ការថ្លែងសុន្ទរកថា ការបញ្ចេញមតិយោបល់ ដែលការលើកឡើងមួយចំនួន បានបង្កនូវផលប៉ះពាល់ទៅដល់ សិទ្ធិរបស់បុគ្គលឯកជន ឬសិទ្ធិរបស់ប្រជាពលរដ្ឋ ប៉ុន្តែរដ្ឋមានច្បាប់ស្តីពីសំណងជំងឺចិត្តរបស់រដ្ឋ ប៉ុន្តែទទួលសងជំងឺចិត្តតែចំពោះរាល់ការបំពេញសកម្មភាពទាំងនេះ គឺដើម្បីគិតគូរពីផលប្រយោជន៍ជាតិ និងផលប្រយោជន៍រួម និង ស្ថិតក្នុងតួនាទីភារកិច្ច ដែលសមាជិកសភាគួរ

បំពេញ។ ផ្ទុយទៅវិញ បើស្ថិតក្នុងករណីសមាជិករដ្ឋសភារូបនោះបានបំពានលើតួនាទីភារកិច្ច និង យកសិទ្ធិអំណាចរបស់ខ្លួនយកមកប្រើប្រាស់ខុសគោលបំណងច្បាប់ ដូចជាបានប្រើប្រាស់ពាក្យសម្តី និងបញ្ចេញមតិយោបល់នានាដោយមានគោលបំណងមិនល្អ និង មិនត្រឹមត្រូវស្របច្បាប់ មានលក្ខណៈ បោកប្រាស់ ញុះញង់ កុហក មួលបង្កាច់ ឬបរិហារកេរ្តិ៍នាំឱ្យខូចកិត្តិយសបុគ្គលឯកជន និងជាលក្ខណៈផ្ទាល់ខ្លួនមិនទាក់ទងនឹងរដ្ឋ នោះរដ្ឋ នឹងមិនទទួលសងសំណងជំងឺចិត្តទេ។ ដូចនេះរដ្ឋត្រូវតែត្រួតពិនិត្យមើលឱ្យច្បាស់លាស់ ថាតើស្ថានភាពនោះជាស្ថានភាពដែលបង្កឡើងដោយការអនុវត្តផ្ទុយពីការផ្តល់អំណាចតាមច្បាប់ពីសំណាក់សមាជិកសភា ឬក៏យ៉ាងណានោះគឺជារឿងសំខាន់ណាស់ ដើម្បីធ្វើការកំណត់លក្ខខណ្ឌដែលអាចឱ្យរដ្ឋសងសំណងជំងឺចិត្តបាន។

# សេចក្តីសន្និដ្ឋាន

ជារួមមក ឆ្លងកាត់តាមការពន្យល់បកស្រាយ និងសិក្សាស្រាវជ្រាវទៅលើប្រធានបទរួចមក យើងអាចធ្វើការសន្និដ្ឋាន និងវាយតម្លៃបានថា ប្រធានបទនេះពិតជាប្រធានបទថ្មីស្រឡាងមួយ ដែលពន្លេចឱ្យឃើញពីសារៈសំខាន់នៃការយល់ដឹង និងសិក្សាទៅលើចំនុចបញ្ហានៃប្រធានបទនេះ ព្រមទាំងបានពញ្ញាក់ស្មារតីភ្ញាក់រលឹកថា បញ្ហាទាក់ទិននឹងអភ័យឯកសិទ្ធិសភានេះមិនមែនជារឿងតូចតាចដែលអាចមើលរំលងនោះបានឡើយ។ ពិតប្រាកដណាស់ថា តាមរយៈការបកស្រាយទៅលើប្រធានបទ បានស្តែងឱ្យឃើញយ៉ាងច្បាស់អំពីចំនុចបញ្ហាដ៏ក្តៅគគុកនៅក្នុងសង្គមកម្ពុជា ដែលជាហេតុមួយនាំឱ្យស្ថានភាពនយោបាយមិនមានលក្ខណៈល្អប្រសើរប៉ុន្មានឡើយ។ មិនតែប៉ុណ្ណោះក៏បានធ្វើឱ្យយើងអាចមើលឃើញពីចំនុចខ្វះខាត ចំនុចអសកម្ម និងចំនុចល្អប្រសើរនៃការផ្តល់អភ័យឯកសិទ្ធិ ទាំងក្នុងការអនុវត្តទាំងនៅប្រទេសកម្ពុជា និងប្រទេសជប៉ុន។ សមាជិករដ្ឋសភាក្នុងនាមជាតំណាងរាស្ត្រគឺជាអ្នកតំណាងឱ្យប្រជាពលរដ្ឋទូទាំងប្រទេស កើតចេញពីការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋ ជាអ្នកតំណាងឱ្យឆន្ទៈប្រជាពលរដ្ឋ បំពេញតួនាទីក្នុងនាមជាប្រជាពលរដ្ឋ និងដើម្បីបំរើផលប្រយោជន៍ជូនប្រជាពលរដ្ឋ ព្រមទាំងប្រទេសជាតិទាំងមូល។ យើងឃើញថា ក្នុងនាមជាតំណាងរាស្ត្រមួយរូបត្រូវទទួលភារៈ និងត្រូវបំពេញកិច្ចការដ៏សំខាន់ ។ តែអ្វីដែលគួរតែកត់សម្គាល់នោះ គឺតំណាងរាស្ត្រមិនត្រឹមតែបម្រើសុខទុក្ខជូនប្រជាពលរដ្ឋតែប៉ុណ្ណោះទេ ប៉ុន្តែតំណាងរាស្ត្រត្រូវបំពេញ តួនាទីជាភ្នែក ជាច្រមុះជំនួសប្រជាពលរដ្ឋក្នុងការតាមដានមើលសកម្មភាពដឹកនាំប្រទេសរបស់រាជរដ្ឋាភិបាល និងជាអ្នកជួយកាច់តម្រង់ទិស រិះគន់កែលម្អក្នុងន័យស្ថាបនាប្រសិនបើរាជរដ្ឋាភិបាលបំពេញតួនាទីមិនទាន់ បានត្រឹមត្រូវ ដើម្បីធ្វើឱ្យការដឹកនាំប្រទេសជាតិប្រកបដោយចីរភាព ព្រមទាំងទទួលបាននូវប្រសិទ្ធភាពខ្ពស់។ យ៉ាងណាមិញ មិនចំពោះតែតំណាងរាស្ត្រទេ សូម្បីតែប្រជាជនសាមញ្ញក៏ដោយដើម្បីអាចធ្វើអ្វីមួយបានដោយ គ្មានការរារាំងដោយស្របច្បាប់ និងដោយគ្មានការភ័យខ្លាច ចាំបាច់ណាស់ត្រូវតែមានសិទ្ធិក្នុងការធ្វើអ្វីមួយនោះដោយមានការទទួលស្គាល់ និងការការពារពីច្បាប់ ចំណែកឯតំណាងរាស្ត្រគឺជាអ្នកតំណាងឱ្យប្រជាពលរដ្ឋទាំងមូលទូទាំងប្រទេស ដើម្បីអាចបំពេញតួនាទី ភារកិច្ចរបស់ខ្លួនដោយគ្មានការភ័យខ្លាច និងប្រកបដោយប្រសិទ្ធភាពនោះគឺ តំណាងរាស្ត្រត្រូវតែមានសិទ្ធិលើសពីសិទ្ធិធម្មតារបស់ប្រជាជនសាមញ្ញទៅទៀត នោះគឺសិទ្ធិមានអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រដែលកំពុងតែត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញផងដែរ។ ប៉ុន្តែចំនុចត្រង់នេះ បាននឹងកំពុងក្លាយទៅជាបញ្ហាចោទ។ ជាការពិត កាលណាមានបញ្ហាកើតឡើង ចាំបាច់ត្រូវតែព្យាយាមរកដំណោះស្រាយ។ ដូចគ្នានេះដែរ នៅក្នុងប្រទេសប្រជាធិបតេយ្យ ការបញ្ចេញសកម្មភាពក្នុងការបំពេញភារកិច្ច ជាពិសេសការសំដែងមតិ

យោបល់ដោយសេរីដោយគ្មានការភ័យខ្លាចរបស់សមាជិករដ្ឋសភា គឺជាចំនុចគ្រឹះសំខាន់ ក្នុងការធានាការដឹកនាំ និងការប្រព្រឹត្តិទៅនៃសភាជាតិទាំងមូល ក៏ដូចជាការពង្រឹង និងការដាក់កំហិតមួយទៅដល់រាជរដ្ឋាភិបាល ក្នុងការដឹកនាំប្រទេសជាតិប្រកបដោយភាពទទួលខុសត្រូវ និងមានការអភិវឌ្ឍរីកចម្រើនស្របតាមគោលនយោបាយអភិវឌ្ឍជាតិ និង ធានាឱ្យបាននូវឯករាជ្យភាពនៃអំណាចទាំងបី ដែលរួមមានអំណាចនីតិបញ្ញត្តិរបស់សភា អំណាចនីតិប្រតិបត្តិរបស់រាជរដ្ឋាភិបាល និងអំណាចតុលាការ។ ជាងនេះទៅទៀត មុននឹងធ្វើចំណាត់ការទៅលើអ្វីមួយចាំបាច់ត្រូវសំអាងទៅលើនីតវិធីច្បាស់លាស់ពិតប្រាកដ ក្នុងការយកទៅអនុវត្តប្រកបដោយភាពត្រឹមត្រូវ។ ជាមួយគ្នានេះផងដែរ នត្ថិភាពនៃច្បាប់ ឬ ការចែងមិនបានច្បាស់លាស់ ដែលជាបច្ច័យនាំឱ្យមានការបកស្រាយដោយមតិ និងការយល់ឃើញផ្សេងៗពីគ្នាដោយពេលខ្លះរកអ្នកខុស អ្នកត្រូវមិនឃើញ ហើយនាំយកទៅអនុវត្តផ្ទុយគ្នា ក៏ជាចំនុចបញ្ហាដែលមិនគួរមើលរំលង ពីព្រោះចំនុចទាំងនេះហើយ ដែលបង្កទៅជាជំលោះ ដែលពិបាកនឹងធ្វើការដោះស្រាយ។ ហេតុនេះហើយ យើងមិនអាចទុកចោលបញ្ហា ហើយយល់ថានេះមិនមែនជាបញ្ហាធំដុំ ឬមួយនេះគឺមិនទាក់ទងនឹងយើងជាប្រជាពលរដ្ឋធម្មតាឡើយ ពីព្រោះថា បញ្ហានេះទាក់ទងទៅដល់សមាជិករដ្ឋសភាដែលជាតំណាងរបស់ប្រជាពលរដ្ឋ ហើយទាក់ទងនឹងនយោបាយដែលជាចរន្តឈាមនៃអាយុជីវិតជាតិ។ បើកាលណាមិនរួមគ្នារកដំណោះស្រាយទេ នឹងធ្វើឱ្យបញ្ហាកាន់តែរីករាលដាលធ្ងន់ធ្ងរទៅៗ និងចេះតែបន្តកើតឡើងនូវបញ្ហានោះដដែលជាដដែល ដោយហេតុថាគ្មានចំណាត់ការ និងវិថីនៃការដោះស្រាយមួយឱ្យបានច្បាស់លាស់។ ដោយយោងទៅលើបញ្ហាទាំងនេះ ថាតើរដ្ឋធម្មនុញ្ញនៃមាត្រា៨០ ដែលចែងអំពីអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភាគួរតែធ្វើវិសោធនកម្ម ឬមួយគួរតែបង្កើតច្បាប់មួយ ដោយឡែកក្រៅពីច្បាប់ស្ដីពីលក្ខន្តិកៈតំណាងរាស្ត្រ ដោយធ្វើការចែងឱ្យលម្អិតទាក់ទងនឹងការផ្ដល់អភ័យឯកសិទ្ធិរដ្ឋសភា ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្តតួនាទីរបស់ខ្លួនឱ្យបានកាន់តែល្អប្រសើរ ក្នុងគោលបំណងការពារប្រជាជាតិ និងផលប្រយោជន៍ជាតិទាំងមូល។

# អនុសាសន៍

ឆ្លងកាត់តាមការបកស្រាយពន្យល់ទៅលើប្រធានបទ ដោយមានការសិក្សាប្រៀបធៀបរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុនរួចមក យើងសង្កេតឃើញថា បើទោះបីជាទាក់ទងទៅនឹងបញ្ហាអភ័យឯកសិទ្ធិរដ្ឋសភានេះ នៅមានចំនុចខ្លះបានប្រឈម និងកំពុងប្រឈមទៅនឹងបញ្ហា និងមានចំនុចខ្លះទៀតហាក់ដូចជាមានភាពខ្វះចន្លោះ ប៉ុន្តែយើងក៏សង្កេតឃើញមានលក្ខណៈល្អប្រសើរច្រើននៅក្នុងប្រព័ន្ធច្បាប់ និងការអនុវត្តនៅត្រង់ចំនុចជាច្រើនផងដែរ។ ប៉ុន្តែ យ៉ាងណាមិញ បើធ្វើការថ្លឹងថ្លែងអំពីចំនុចល្អប្រសើរ និងចំនុចខ្វះខាតទាំងនោះរវាងប្រទេសទាំងពីរ យើងអាចនិយាយបានថា ចំនុចខ្លះដែលបានប្រឈម និងកំពុងប្រឈមទៅនឹងបញ្ហា និង ភាពខ្វះចន្លោះចំពោះប្រទេសជប៉ុនហាក់ដូចជាមានលក្ខណៈទ្រង់ទ្រាយតូច។ ជាពិសេស គឺទាក់ទិននឹង បទបញ្ញត្តិច្បាប់យុត្តិសាស្ត្រ និងបណ្តាគោលការណ៍ទ្រឹស្តីនានាទាក់ទិននឹងអភ័យឯកសិទ្ធិរដ្ឋសភា នេះចំពោះប្រទេសជប៉ុនហាក់ដូចជាមានភាពច្បាស់លាស់ច្រើន និងមានភាពទូលំទូលាយ ដូចជាធ្វើការញែកដាច់ពីគ្នានៅទ្រឹស្តី និងនីតិវិធីទាក់ទិននឹងការចាប់ខ្លួន និងការបញ្ចេញមតិយោបល់របស់សមាជិករដ្ឋសភាអាចនាំយកមកធ្វើការវិភាគថ្លឹងថ្លែង ក្នុងការរកដំណោះស្រាយបានច្រើនទន្ទឹមនឹងប្រទេសកម្ពុជានៅមានបញ្ហាខ្វះចន្លោះច្រើនទៅលើនត្តិភាពនៃច្បាប់ គោលការណ៍អនុវត្តច្បាប់ និងភាពស្រពិចស្រពិលនៃច្បាប់ទាក់ទិននឹងការផ្តល់អភ័យឯកសិទ្ធិនេះ ដែលនាំឱ្យមានបញ្ហាច្រើនក្នុងការអនុវត្តជាក់ស្តែង។ ទាក់ទិននឹងបញ្ហាទាំងនេះ យើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួន ទុកជាទុនរួមគំនិតក្នុងការចូលរួមចំណែកជាជំនួយក្នុងការដោះស្រាយ។

- ចំពោះប្រទេសជប៉ុន ថ្វីត្បិតថាមានលក្ខណៈល្អប្រសើរច្រើន តែក៏គេចមិនផុតពីចំនុចខ្វះខាតដែលគួរតែធ្វើការកែតម្រូវ។

ចំពោះទាក់ទិននឹងបញ្ហាអភ័យឯកសិទ្ធិមិនត្រូវបានចាប់ខ្លួនៈ

ច្បាប់គួរតែកំណត់ឱ្យបានច្បាស់ថា តើករណីណាទើបអាចអនុញ្ញាតឱ្យធ្វើការចាប់ខ្លួនបាន ហើយករណីណាដែលមិនគួរធ្វើការចាប់ខ្លួនទេទោះបីជាបានប្រព្រឹត្តិ ឬសង្ស័យថាបានប្រព្រឹត្តិបទល្មើសក៏ដោយ ដោយសំអាងលើភាពចាំបាច់ ដូចនេះគួរធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់អំពី ភាពចាំបាច់ទាំងនោះ ថាករណីបែបណាទើបចាំបាច់ ហើយបែបណាមិនចាំបាច់ដើម្បីយកមកធ្វើជាសំអាងហេតុមុននឹងអនុញ្ញាតឱ្យចាប់ខ្លួន ឬមិនឱ្យចាប់ខ្លួននោះដោយសារមិនមានកំណត់នៅក្នុងមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ ឬបទបញ្ញត្តិ ណាមួយនោះឡើយ ហេតុនោះទើបតម្រូវឱ្យមានការបញ្ជាក់ឱ្យច្បាស់លាស់ពីវិសាលភាពដោយចែងក្នុងច្បាប់មួយជាក់លាក់។

មួយវិញទៀត គួរតែធ្វើការព្រមព្រៀងគ្នាឱ្យបាន និងរកដំណោះស្រាយទៅលើបញ្ហានៃ ការកំណត់រយៈពេល និងលក្ខខណ្ឌក្នុងការចាប់ខ្លួន ថាតើគួរឱ្យកំណត់ ឬ មិនកំណត់ ដោយសំអាង ទៅលើភាពចាំបាច់ស្របច្បាប់ត្រឹមត្រូវមួយ។

ចំពោះទាក់ទិននឹងករណីអភ័យឯកសិទ្ធិក្នុងការបញ្ចេញមតិយោបល់៖

គួរតែធ្វើការបែងចែកឱ្យដាច់ថាសកម្មភាពក្នុងការបំពេញតួនាទីណាមួយ ដែលមានទំនាក់ទំនងទៅនឹងការថ្លែងសុន្ទរកថា ឬជាការពិភាក្សា ឬជាការបញ្ចេញមតិយោបល់ ។ ត្រង់ចំនុចនេះ គួរតែធ្វើការកំណត់ទៅលើថា តើសកម្មភាពណាមួយដែលសមាជិករដ្ឋសភាអាចធ្វើបានដើម្បីបំពេញតួនាទីឱ្យស្របតាមច្បាប់ ហើយសកម្មភាពណាដែលមិនអាចអនុញ្ញាតឱ្យធ្វើក្នុងពេលបំពេញតួនាទី ដើម្បីអាចកំណត់អំពីព្រំដែន ក៏ដូចជាវិសាលភាពនៃការការពារបានតាមអភ័យឯកសិទ្ធិស្របច្បាប់ ចៀសវាងការអនុវត្តទៅហើយមានបញ្ហា មិនអាចវែកញែកបានថានោះជាបញ្ហាដោយសារភាព មិនច្បាស់លាស់នៃច្បាប់។

- ចំពោះប្រទេសកម្ពុជា៖

ដោយសារតែមានការបកស្រាយផ្សេងគ្នានៅឡើយ ទើបច្បាប់គួរតែកំណត់ឱ្យបានច្បាស់លាស់ ថាតើអភ័យឯកសិទ្ធិរដ្ឋសភាកើតមានពេលណាឱ្យពិតប្រាកដ ពេលប្រកាសលទ្ធផលឆ្នោតជាស្ថាពរ អ្នកជាប់ឆ្នោតមានអាសនៈទាំងនោះ ក្លាយទៅជាសមាជិករដ្ឋសភាមានអភ័យឯកសិទ្ធិដោយស្វ័យប្រវត្តិ ឬទាល់តែនៅពេលចូលស្បថកាន់តំណែង និងទទួលស្គាល់ដោយសភា។

គួរតែចែងអំពីវិសាលភាពនៃការផ្ដល់អភ័យឯកសិទ្ធិនេះឱ្យបានច្បាស់ថា មានវិសាលភាពកម្រិតណា ទៅលើអ្វីខ្លះដូចជាមានតែទៅលើរូបកាយបុគ្គល ឬទ្រព្យសម្បត្តិ ឬទីកន្លែងរស់នៅរបស់សមាជិករដ្ឋសភាក៏មានអភ័យឯកសិទ្ធិដែរឬយ៉ាងណា ឬមានតែនៅក្នុងពេលបំពេញភារកិច្ចក្នុងរដ្ឋសភា ពេលចេញក្រៅ រដ្ឋសភា មិនមានអភ័យឯកសិទ្ធិ។

មួយវិញទៀត ទាក់ទងនឹងរយៈពេលនៃអភ័យឯកសិទ្ធិ មានរហូតឱ្យតែគាត់នៅតែជាសមាជិករដ្ឋសភា ឬមានក្នុងនីតិកាលរបស់រដ្ឋសភា។ ត្រង់ចំនុចនេះរដ្ឋសភា មាននីតិកាល៥ឆ្នាំ សមាជិកសភាក៏មានអណត្តិ ៥ឆ្នាំ តែប្រសិនបើក្នុងពេលបំពេញអណត្តិបាន១ឆ្នាំ សមាជិករដ្ឋសភារូបណាមួយបានប្រព្រឹត្តិបទល្មើសនាំឱ្យត្រូវអនុវត្តទោស៣ឆ្នាំក្នុងពន្ធនាគារ បន្ទាប់ពីអនុវត្តទោសរួច នៅសល់១ឆ្នាំទៀតទើបនីតិកាលរដ្ឋសភាបញ្ចប់ទៅ ហេតុនេះ តើគាត់នៅតែអាចបន្តតំណែងក្នុងការធ្វើជាសមាជិករដ្ឋសភាមានអភ័យឯកសិទ្ធិឬយ៉ាងណា ឬតំណាងរាស្ត្រផ្សេងដែលមានជំនួសតំណែងគាត់នឹងត្រូវចាកចេញ ហើយប្រគល់តំណែងឱ្យសមាជិកសភាដែលអនុវត្តន៍ទោសរួចរាល់នោះ។ ត្រង់នេះ ច្បាប់គួរតែធ្វើការចែងបញ្ជាក់ឱ្យច្បាស់លាស់។

គួរតែចែងអំពីវប្បធម៌និទណ្ឌភាពទៅលើការរំលោភបំពាន ឬការប្រព្រឹត្តិបទល្មើសណាមួយមកលើសមាជិករដ្ឋសភា ពីព្រោះ បើអនុវត្តទោសទៅលើអ្នកប្រព្រឹត្តិទាំងនោះដូចមកលើពលរដ្ឋសាមញ្ញដែរ តើមានអ្វីខុសប្លែករវាងពលរដ្ឋធម្មតា និងសមាជិករដ្ឋសភាដែលជាតំណាងរាស្ត្រ។

អត្ថន័យ ខ្លឹមសារ នៃមាត្រា៨០ ហាក់ដូចជាមិនទាន់ពេញលេញអាចអនុវត្តបានដោយរលូនទេ បើមិនអាចធ្វើវិសោធនកម្មគួរតែចែងច្បាប់មួយដោយឡែកទាក់ទងនឹងអភ័យឯកសិទ្ធិរដ្ឋសភានេះ ដោយបន្ថែម និងពន្យល់ទៅលើខ្លឹមសារ និយមន័យ វិសាលភាព គោលការណ៍អនុវត្តទូទៅនីតិវិធីជាក់លាក់បំផុតមួយដើម្បីអាចអនុវត្តបានដោយមិនមានការបកស្រាយផ្សេងគ្នា។

មាត្រា៨០នៃរដ្ឋធម្មនុញ្ញនេះផងដែរ មិនមានចែងអំពីការកោះហៅសមាជិករដ្ឋសភាដែលជាតំណាងរាស្ត្រនោះទេ ហេតុនេះហើយ តើការមិនចូលខ្លួនតាមការកោះហៅរបស់តុលាការរបស់តំណាងរាស្ត្រជារឿងត្រឹមត្រូវ ឬមួយនេះជាការរំលោភបំពានទៅលើចំណាត់ការតុលាការដែល មិនថាពលរដ្ឋទូទៅ ឬតំណាងរាស្ត្រទេ ត្រូវតែចូលខ្លួនតាមការកោះហៅរបស់តុលាការ។ បើមិនចូលខ្លួនចាត់ទុកជាបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ដោយមិនចាំបាច់លើកអភ័យឯកសិទ្ធិទេត្រូវតែចាប់ខ្លួន ឬ ទាល់តែលើកអភ័យឯកសិទ្ធិទើបអាចចាប់ខ្លួនបានឬយ៉ាងណានោះ ច្បាប់គួរតែចែងឱ្យបានជាក់ច្បាស់បន្ថែមទៅលើបញ្ហានេះ។

គួរតែចែងឱ្យបានតឹងរឹង និងជាក់លាក់អំពីនិយមន័យនៃការបញ្ចេញមតិយោបល់ និងកម្រឹតវិសាលភាពច្បាស់លាស់មួយទៅលើចំនុចនេះ ថាតើការធ្វើសកម្មភាពក្នុងការបញ្ចេញមតិណាមួយជាការបញ្ចេញមតិត្រឹមត្រូវស្របតាមច្បាប់ក្នុងការបំពេញមុខងារក្នុងអណត្តិ ហើយការធ្វើសកម្មភាពក្នុងការបញ្ចេញមតិណាមួយ ជាការបញ្ចេញមតិមិនត្រឹមត្រូវស្របតាមច្បាប់ ដែលអាចហៅថាជាការញុះញង់ នាំឱ្យមានទោសតាមក្រមព្រហ្មទណ្ឌឬយ៉ាងណានោះ ដោយសារតែច្បាប់គឺច្បាប់ មិនអាចធ្វើការបកស្រាយទាំងទទឹងទិស ឬមិនមែនតែអនុវត្តទាំងទទឹងទិសតាមតែបញ្ហាកើតមានហើយទើបបកស្រាយច្បាប់ទៅតាមតែចិត្តនឹកឃើញ រកតែត្រូវ រកតែល្អដើម្បីការពារផលប្រយោជន៍ ជនណាមួយតាមក្រោយនោះឡើយ ហេតុនេះហើយគួរតែមានការចែងក្នុងច្បាប់ជាជំហារច្បាស់លាស់មួយក្នុងការអនុវត្ត ដើម្បីភាពត្រឹមត្រូវ យុត្តិធម៌ជាទីបំផុត។

# ឯកសារយោង

## ក. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាភាសាខ្មែរ ៖

1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាលើកទី១ ប្រទានដោយសម្តេច នរោត្តមសីហនុ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៤៧ ។
2. រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋកម្ពុជា ឆ្នាំ១៩៧២ ដាក់ជូនប្រជាពលរដ្ឋធ្វើប្រជាមាតិ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២ ។
3. រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ ប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ ។
4. រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រកាសឱ្យប្រើដោយប្រធានក្រុមប្រឹក្សារដ្ឋនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ ។
5. រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជាប្រកាសឱ្យប្រើប្រធានក្រុមរដ្ឋ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ ។
6. រដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។
7. ធម្មនុញ្ញបន្ថែមប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤។
8. ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦ ។
9. បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ឆ្នាំ២០០៦ ។
10. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១១។
11. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី១៥ថ្មី ដល់ជំពូកទី១៦ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ។
12. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ។

## ខ. សៀវភៅស្រាវជ្រាវជាភាសាខ្មែរ៖

1. សៀវភៅ សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ រៀបរៀង និង ចងក្រងដោយសាស្ត្រាចារ្យ បណ្ឌិត ឈុន ណារ៉េត បោះពុម្ពឆ្នាំ ២០១០ ។
2. សៀវភៅ នីតិរដ្ឋធម្មនុញ្ញ រៀបរៀងដោយសាស្ត្រាចារ្យ ម៉ុក ដារ៉ា បោះពុម្ពឆ្នាំ ២០១០។

3. សៀវភៅ រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជា រៀបរៀង និងចងក្រង ដោយ បណ្ឌិត សេង ប៊ុនធឿន បោះពុម្ពឆ្នាំ ២០១៥ ។
4. សៀវភៅ រដ្ឋធម្មនុញ្ញកម្ពុជា រៀបរៀងដោយ កៅ មុយថង កែសម្រួលដោយ ម៉ី វិចិត្រ បោះពុម្ពផ្សាយដោយបណ្ណាគារ អង្គរ ។
5. សៀវភៅ នីតិរដ្ឋធម្មនុញ្ញកម្ពុជា អ្នកនិពន្ធ លោក ឈន សុភាព,លោក អ៊ូច ចាន់ណូរ៉ា,លោក ស៊ូ សុជាតិ,លោក យ៉ាន់ វ៉ាន់ជីលុច និងលោក អេចេន ករនុយ, បោះពុម្ពលើកទី២ ដោយបន្ថែម និងកែសម្រួលចេញពីសៀវភៅដែលបោះពុម្ពលើកទី១ របស់លោកសាស្ត្រាចារ្យ Maurice GAILLARD,"ប្រជាធិបតេយ្យកម្ពុជា, រដ្ឋធម្មនុញ្ញ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣", រោងពុម្ពL'Harmattan, ឆ្នាំ១៩៩៤ ។
6. សៀវភៅ នីតិរដ្ឋធម្មនុញ្ញ, រៀបរៀងដោយសាស្ត្រាចារ្យ សាត់ សាម៉ីឌី បោះពុម្ព ឆ្នាំ ២០១៣-២០១៤ ។
7. សៀវភៅ រដ្ឋធម្មនុញ្ញ និងរដ្ឋាភិបាលនៃប្រទេសកម្ពុជា រៀបរៀងដោយមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ បោះពុម្ពឆ្នាំ ២០០០ ។
8. សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ រៀបរៀងដោយសាស្ត្រាចារ្យ ខាត់ ធី បោះពុម្ពឆ្នាំ ២០០៩។
9. សៀវភៅ ស្ថាប័ននយោបាយព្រះរាជាណាចក្រកម្ពុជា រៀបរៀងដោយសាស្ត្រាចារ្យ ដុំ អ៊ីម បោះពុម្ពលើកទី១ ឆ្នាំ ២០១២ ។
10. សៀវភៅ ប្រជុំរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៤៧-២០១៤ រៀបរៀងដោយ ហួត វុទ្ធី ឆ្នាំ ១៩៩៨ ។
11. សៀវភៅ មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ និពន្ធដោយ ឯកឧត្តម ឥន យឿន បោះពុម្ពលើកទី៣ ឆ្នាំ២០១០ ។
12. សៀវភៅ រដ្ឋាភិបាលកម្ពុជាពីឆ្នាំ១៩៤៥ដល់ឆ្នាំ ២០១០ រៀបរៀងដោយ ពុយ គា បោះពុម្ពលើកទី២ឆ្នាំ២០១០។
13. សៀវភៅ កម្រងឯកសារសំណួរ-ចម្លើយ ទាក់ទងនឹងរដ្ឋធម្មនុញ្ញ រៀបចំចងក្រងដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ ២០១១ ។
14. សៀវភៅ ប្រវត្តិសង្ខេបតំណាងរាស្ត្រនីតិកាលទី៥ ២០១៣-២០១៨ ផលិតដោយ ខុមប្រ៉េល បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១៥ ។
15. សៀវភៅ នីតិរដ្ឋធម្មនុញ្ញ រៀបរៀងដោយសាស្ត្រាចារ្យ សុខ យ៉ាន, សុខ ចិន្តា ឆ្នាំ២០១៤-២០១៥ ។

16. មុខនាទី និង ការប្រព្រឹត្តិទៅនៃសភាកម្ពុជា រៀបចំចងក្រងដោយ បណ្ឌិត កៅ គឹមហួន, វ៉ាន់ ប៊ុនថេត, លុយ ច័ន្ទផល, បោះពុម្ពផ្សាយដោយវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និង សន្តិភាព, ឆ្នាំ២០០១ ។
17. សៀវភៅ អត្ថាធិប្បាយវចនានុក្រមច្បាប់ រៀបរៀងដោយ ហ៊ីង ធីឫទ្ធិ បោះពុម្ពលើកទី១ ឆ្នាំ ១៩៩៦ ។
18. សៀវភៅ សទ្ទានុក្រមពាក្យច្បាប់ រៀបរៀងដោយៈ ឆយ អូន,ឥន យឿន,ងួន យ៉ាណា,អ៊ិត មល្លិកា,សៀន វិសាល ឆ្នាំ២០១២ ។
19. សារណាបញ្ចប់ការសិក្សាៈ ដំណើរការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅព្រះរាជាណាចក្រកម្ពុជានីតិកាលទី៥ ស្រាវជ្រាវដោយនិស្សិតឈ្មោះ លី ចាន់មករា,ប៉ិច សីលា ឆ្នាំ២០១៤-២០១៥ ។
20. សារណាបញ្ចប់ការសិក្សាៈ ការរៀបចំ និង ការប្រព្រឹត្តទៅនៃរដ្ឋសភានីតិកាលទី៥ នៅព្រះរាជាណាចក្រកម្ពុជានីតិកាលទី៥ ស្រាវជ្រាវដោយនិស្សិតឈ្មោះ ភឹម បូរិ, សានលីណា,ឆ្នាំ ២០១៤-២០១៥។

## គ. ឯកសារជាភាសាជប៉ុន

1. 日本国憲法 រដ្ឋធម្មនុញ្ញប្រទេសជប៉ុន
2. 日本の国会法　ច្បាប់ស្តីពីសភាប្រទេសជប៉ុន
3. 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（2011 年 2 月）

   មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា『ប្រវត្តិសាស្ត្រ និង ពលរដ្ឋវិទ្យា ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ) (ខែកុម្ភៈ ឆ្នាំ ២០១១)
4. 名古屋大学日本法教育研究センター『日本法を学ぶための日本法システム』（カンボジア版）（2013 年 9 月）

   មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា『ប្រព័ន្ធច្បាប់ប្រទេសជប៉ុន ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ) (ខែកញ្ញា ឆ្នាំ ២០១៣)
5. 田中嘉彦『シリーズ憲法の論点⑥』「二院制」国立国会図書館調査及び立法考査局、２００５年。

   តាណាកាយ៉ូស៊ីហ៊ីកុ『បញ្ហានៅក្នុងសេរីរដ្ឋធម្មនុញ្ញ⑥』「សភាពីរជាន់」ស្ថាប័នត្រួតពិនិត្យអង្គការនីតិបញ្ញត្តិ និងស្រាវ ជ្រាវបណ្ណាល័យសភាជាតិ, ឆ្នាំ២០០៥

6. 高橋和之『立憲主義と日本国憲法』第２版（有斐閣、2010 年）。

តាកាហាស៊ីកាស៊ឹយឹគី『គោលការណ៍អាស្រ័យរដ្ឋធម្មនុញ្ញ និង រដ្ឋធម្មនុញ្ញប្រទេសជប៉ុន』បោះពុម្ពលើកទី២, រោងពុម្ពយឹហិកាកុ, ឆ្នាំ២០១០

7. 渋谷秀樹・赤坂正浩『憲法２統治』、（第４版、２０１０年）。

ស៊ិប៊ឹតានិហ៊ីដេគិ・អាក:សាក:ម៉ាសាហ៊ិរុ『រដ្ឋធម្មនុញ្ញ២ នយោបាយ』, បោះពុម្ពលើកទី៤ , ឆ្នាំ២០១០

8. 小林孝輔・芹沢『憲法』第５版、２００６年。

កុប៉ាយ៉ាស៊ី・សេរីសាវ៉ា『រដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៥, ឆ្នាំ២០០៦

9. 長谷部恭男『憲法』（第５版）２０１１年。

ហាសេបិយ៉ាសឹអុ 『រដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៥ , ឆ្នាំ២០១១

10. 長谷部恭男・中島　徹・赤坂正浩・阪口正二郎・本　執秀紀『ケースブック憲　法』第３版、２０１０年。

ហាសេបិយ៉ាសឹអុ・ណាកាជីម៉ាតុអ៊ុរី・អាក:សាក:ម៉ាសាហ៊ិរុ・សាកាហ្គឹឆិស្វជិរុ・ម៉ូតុហ៊ិដិណុរី 『សៀវភៅករណីសិក្សារដ្ឋធម្មនុញ្ញ』, បោះពុម្ពលើកទី៣, ឆ្នាំ២០១០

## ឃ.គេហទំព័រនានា

1. http://www.national-assembly.org.kh
2. http://www.nec.org.kh
3. http://www.vod.com.kh
4. http://vodhotnews.com
5. http://km.rfi.fr/cambodia/
6. http://km.rfi.fr/analysis/
7. http://www.rfa.org/khmer/
8. http://www.freshnewsasia.com/index.php/en/
9. http://www.monoroom.info/news
10. http://www.japaneselawtranslation.go.jp/law/detail_main?id=174
11. http://www.sangiin.go.jp/japanese/kids
12. http://law.e-gov.go.jp/htmldata/S22/S22HO079.html
13. http://www.shugiin.go.jp/internet/itdb_annai.nsf/html/statics/shiryo/dl-dietlaw.htm